# ព្រះរាជបុត្រារបស់ព្រះជាម្ចាស់
# អ្នកសង្គ្រោះរបស់យើង

ដែកឃី អ៊ូស

## លាតត្រដាងផែនការណ៍របស់ព្រះជាម្ចាស់សម្រាប់ការសង្គ្រោះរបស់យើងតាមរយៈដំណើរជីវិតព្រះយេស៊ូវគ្រីស្ទ

### ដកស្រង់ចេញពីព្រះគម្ពីរដំណឹងល្អ ម៉ាថាយ ម៉ាកុស លូកា និង យ៉ូហាន

“ពួកអ្នកដែលកោតខ្លាចដល់ទ្រង់ គេនឹងឃើញទូលបង្គំ ហើយមានសេចក្តីអំណរ
ដោយព្រោះទូលបង្គំបាន សង្ឃឹមដល់ព្រះបន្ទូលនៃទ្រង់”
ទំនុកដំកើង ១១៩:៧៤

គ្រប់បទគម្ពីរ ត្រូវបានដកស្រង់ពីព្រះគម្ពីរបរិសុទ្ធ រក្សាសិទ្ធិ© ឆ្នាំ១៩៥៤ និង © ឆ្នាំ១៩៦២
ដោយសមាគមព្រះគម្ពីរកម្ពុជា ប្រើប្រាស់ដោយមានការអនុញ្ញាតិ និង រក្សាសិទ្ធគ្រប់យ៉ាង

# មាតិកា

**មេរៀនទី ១: ហេតុផលនៃដំណឹងល្អ**

1. ដំណើររឿងរបស់យ៉ូសែប និង ម៉ារី
2. ដំណើររបស់លោក យ៉ូហាន
3. កំណើតរបស់ព្រះយេស៊ូវគ្រីស្ទ
4. ការប្រកាសអំពីកំណើតរបស់ព្រះយេស៊ូវគ្រីស្ទ

**មេរៀនទី ២**

1. ការស្រាវជ្រាវរកម៉ាគី (Magi)
2. ការភៀសខ្លួនទៅកាន់ប្រទេសអេស៊ីព្ទ
3. ការនាំកុមារព្រះយេស៊ូវចូលក្នុងព្រះវិហារ
4. ព្រះយេស៊ូវ និង លោក ស៊ីម្មាន
5. ព្រះយេស៊ូវ និង លោកស្រី អាណា

**មេរៀនទី ៣**

1. ការស្រាវជ្រាវរកព្រះយេស៊ូវ
2. ព្រះយេស៊ូវត្រូវរកឃើញនៅក្នុងដំណាក់ព្រះបិតាទ្រង់
3. ព្រះយេស៊ូវត្រាស់ហៅ លោក ពេត្រុស អន់ទ្រេ យ៉ាកុប និង យ៉ូហាន
4. ព្រះត្រាស់ហៅលោក ម៉ាថាយ
5. ការដើរតាមព្រះយេស៊ូវមានន័យដូចម្ដេច

## មេរៀនទី ៤

1. ការអស្ចារ្យមុនគេបង្អស់របស់ព្រះយេស៊ូវ
2. ក្រិត្យវិន័យរបស់ពួកលេវីអំពីជម្ងឺឃ្លង់
3. ជម្ងឺឃ្លង់នៃអំពើបាប
4. បុរសកើតឃ្លង់ម្នាក់ត្រូវបានជាស្អាត
5. ជីវិតដែលមិនអាចប៉ះពាល់បាន

## មេរៀនទី ៥

1. ប្រៀបដូចជាចៀមដែលគ្មានអ្នកគង្វាល
2. ការស្រេកឃ្លានរបស់ហ្វូងមនុស្ស
3. ព្រះយេស៊ូវប្រទានអាហារដល់មនុស្ស ប្រាំពាន់នាក់
4. ការឆ្លុះបញ្ចាំង: តើមានអ្វីទើបនឹងកើតឡើង?
5. ព្រះយេស៊ូវគឺជានំប៉័ងនៃជីវិត

## មេរៀនទី ៦

1. ព្រះយេស៊ូវបានសម្លុតព្យុះសមុទ្រឱ្យស្ងប់
2. ព្រះយេស៊ូវបានសម្លុតព្យុះសមុទ្រដែលយារយីដល់ទូករបស់ខ្ញុំឱ្យបាត់
3. ព្រះយេស៊ូវបានរៀនអំពីឡាសាដែលមានជម្ងឺ
4. ព្រះយេស៊ូវទ្រង់ប្រាប់ថាឡាសាបានស្លាប់ហើយ
5. ព្រះយេស៊ូវបានប្រោសឡាសាឱ្យរស់ពីស្លាប់ឡើងវិញ

## ការរំលឹកសារឡើងវិញ:

សិក្សា #១២ - ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ សេចក្ដីសង្គ្រោះរបស់យើង

# ការចាប់ផ្ដើម

ក្នុងខណៈពេលដែលលោកអ្នកកំពុងបន្តការសិក្សាព្រះគម្ពីររបស់លោកអ្នក ក្នុងមេរៀន "ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ អ្នកសង្គ្រោះរបស់យើង" អ្នកនឹងបន្តដំណើរផ្សងព្រេងមួយដែលត្រូវបានតាក់តែងឲ្យជីវិតរបស់អ្នកបានកាន់តែមុតស្រួចថែមទៀត។ ការធ្វើដំណើររបស់អ្នកនឹងមានតែមួយគត់ ហើយនឹងត្រូវបានកំណត់នៅក្នុងផ្នែកមួយ ដោយការស្រេកឃ្លានក្នុងភាពរីកលូតលាស់នៅក្នុងចំណេះដឹងផ្នែកខាងព្រះគម្ពីរ និងការពេញចិត្តចំពោះតួអង្គថ្មីៗជាច្រើនដែលមាននៅក្នុងសេចក្ដីពិតនៃព្រះគម្ពីរ។ ការប្ដេជ្ញាចិត្តក្នុងការសិក្សាព្រះគម្ពីររបស់អ្នក បានសន្យាថានឹងបង្កើនជីវិតរបស់អ្នកដូចដែលព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់លោកអ្នកតាមរយៈព្រះបន្ទូលរបស់ទ្រង់ដែរ។

យើងខ្ញុំសូមលោកទឹកចិត្តលោកអ្នកឲ្យមានសម្ភារៈ ៥ យ៉ាងនៅក្នុងដៃសម្រាប់សិក្សាមេរៀននេះ។ សម្ភារៈទាំងនោះនឹងត្រូវយកមកប្រើប្រាស់ក្នុងពេលកំពុងសិក្សាមេរៀននិមួយៗ ព្រោះវានឹងអាចជួយសម្រួលដល់ការសិក្សារបស់លោកអ្នក។

1. ព្រះគម្ពីរសម្រាប់សិក្សាៈ ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ សេចក្ដីសង្គ្រោះរបស់យើង។
2. ព្រះគម្ពីរខ្មែរបរិសុទ្ធ ចំណាំៈ បើសិនជាលោកអ្នកចង់ទិញព្រះគម្ពីរថ្មី លោកអ្នកគប្បីរើសយកព្រះគម្ពីរណាដែលមានៈ

   ក. មានរាយចំណងជើងធំៗនៃកំណ្ឌគម្ពីរនិមួយៗ

   ខ. សម្គាល់ខយោងនៅតាមទំព័រនិមួយៗនៃព្រះគម្ពីរ

   គ. មាលិសំព្ទនៅផ្នែកខាងក្រោយនៃព្រះគម្ពីរ

   ឃ. ភ្ជាប់ជាមួយនូវផែនទីសម្គាល់ពីទីតាំងនានាទាក់ទិននឹងរឿងនៅក្នុងព្រះគម្ពីរ
3. ប៊ិច ខ្មៅដៃ និង ហាយឡាយ
4. សៀវភៅសម្រាប់កត់ត្រា
5. ក្រដាស់សម្រាប់សរសេរចំណាំ (តាមទំហំដែលលោកអ្នកពេញចិត្ត)

ជាមួយនឹងលក្ខណ្ឌសំខាន់ៗទាំងបីដូចបានរៀបរាប់ខាងលើ ត្រង់ចំណុចទី ២ លោកអ្នកនឹងត្រូវតែរៀបចំឲ្យគ្រប់មុខ និង ត្រៀមខ្លួនជាស្រេចក្នុងការរុករកតាមរយៈមេរៀនទាំងនេះ។ បើសិនជាលោកអ្នកនឹងរកទិញព្រះគម្ពីរថ្មី សូមលោកអ្នកកុំស្ទាក់ស្ទើរក្នុងការសួរ ឬ សុំការណែនាំពីអ្នកលក់ ដើម្បីឲ្យគេបានជួយផ្ដល់យោបល់សម្រាប់លោកអ្នក ធ្វើដូច្នេះ លោកអ្នកនឹងមានការងាយស្រួលក្នុងការស្វែងរកខគម្ពីរពេលរៀន។

មានរឿងខ្លះដែលលោកអ្នកត្រូវតែដឹងដឹង: ព្រះគម្ពីរជាទូទៅមានជាច្រើនជំនាន់ និង ការសម្រាយខុសៗគ្នា! យើងខ្ញុំសូមផ្តល់យោបល់សម្រាប់លោកអ្នក គួរគប្បីជ្រើសរើសយកព្រះគម្ពីរខ្មែរបរិសុទ្ធជំនាន់ណាក៏បាន ឲ្យតែមានខយោង ហើយត្រូវបានទទួលស្គាល់ដោយសមាគមព្រះគម្ពីរកម្ពុជា ឬ ព្រះគម្ពីរខ្មែរសម្រាប់អ្នកសិក្សាទូទៅជាការងាយស្រួលដល់លោកអ្នក។

សូមលោកអ្នកកុំមានចិត្តស្ទាក់ស្ទើរក្នុងការកត់ចំណាំ ឬ គូសហាយឡាយនៅលើព្រះគម្ពីររបស់លោកអ្នក! ព្រោះព្រះគម្ពីរគឺជារបស់លោកអ្នកផ្ទាល់! ដូច្នេះ ទើបបានជាយើងខ្ញុំតម្រូវឲ្យលោកអ្នកមានប៊ិច ខ្មៅដៃ ឬ ហាយឡាយដូចបានជម្រាបមកខាងដើមស្រាប់។ លោកអ្នកត្រូវដឹងថាព្រះគម្ពីរនេះគឺសម្រាប់សិក្សា ហេតុដូចនេះ ទោះបីជាលោកអ្នក គូសបន្ទាត់ពីក្រោម គូសជារង្វង់ ឬក៏ហាយឡាយ ឬបែបណាតាមដែលលោកអ្នកគិតថាវាធ្វើឲ្យងាយស្រួលចំណាំ។ ទន្ទឹមនឹងនេះដែរ យើងខ្ញុំក៏សូមលើកទឹកចិត្តលោកអ្នកឲ្យមានសៀវភៅសរសេរមួយផ្សេងទៀតសម្រាប់កត់ត្រាចំណុចសំខាន់ៗ ឬ សំនួរ ចម្លើយដែលពាក់ព័ន្ធក្នុងមេរៀន។

នៅក្នុងចំណោមមេរៀនទាំង៦ ដែលលោកអ្នកនឹងត្រូវសិក្សានេះត្រូវបានបែងចែកជា ៥ ផ្នែក។ នៅក្នុងផ្នែកទាំងនេះគឺមានលំនាំតែមួយប៉ុណ្ណោះ យ៉ាងនេះនឹងអាចជួយសម្រួលដល់លោកអ្នកមានការងាយស្រួលក្នុងការសិក្សា។ សម្រាប់ទីកន្លែងសម្រាប់សិក្សាគឺអាស្រ័យការជ្រើសរើសរបស់លោកអ្នក! មានមេរៀនខ្លះវែង ដែលទាមទារឲ្យលោកអ្នកផ្លាស់ប្តូរបរិយាកាសខ្លះ! ជួនកាលមានមេរៀនខ្លះខ្លី ដូច្នេះលោកអ្នកអាចបញ្ចប់ការសិក្សាក្នុងពេលតែម្តង។

ប្រសិនបើនេះគឺជាលើកដំបូងក្នុងការស្គាល់ព្រះគម្ពីរ លោកអ្នកអាចនឹងគិតថាគួរតែចាប់ផ្តើម ជាមួយនឹង "ការរុករកនៅក្នុងព្រះគម្ពីរ" វិញ។ ការសិក្សានេះ ត្រូវបានរចនាឡើងនូវឧបករណ៍ជំនួយសម្រាប់ជួយអភិវឌ្ឍន៍ជំនាញលោកអ្នកបន្ថែម នឹងធ្វើទៅជាអ្នកសិក្សាព្រះគម្ពីរដ៏មានទំនុកចិត្តម្នាក់។ "ការរុករក នៅក្នុងព្រះគម្ពីរ" លោកអ្នកអាចទាញយកពីក្នុងគេហទំព័រ www.FullValue.org បាន។ ទោះបីជាយ៉ាង ណាក៏ដោយការសិក្សានេះមិនទាមទារឲ្យសិក្សា "ភាពស្មោះត្រង់របស់ព្រះជាម្ចាស់ សេចក្តីសង្ឃឹមរបស់យើង" នោះឡើយ។

- **ផែនការរបស់ព្រះជាម្ចាស់ ជម្រើសរបស់យើង:** គឺត្រូវបានសិក្សាលើ ១១ ជំពូកដំបូងនៃព្រះគម្ពីរលោកុប្បត្តិ
- **សេចក្តីសន្យារបស់ព្រះជាម្ចាស់ ព្រះពររបស់យើង:** គឺត្រូវបានសិក្សាអំពីសាច់រឿងរបស់លោកអ័ប្រាហាំដែលមាននៅក្នុងព្រះគម្ពីរ លោកុប្បត្តិ ជំពូក ១២ ដល់ជំពូក ២៥

- **សេចក្តីស្មោះត្រង់របស់ព្រះម្ចាស់ សេចក្តីសង្ឃឹមរបស់យើង:** គឺត្រូវបានសិក្សាអំពីដំណើររឿងរបស់អ៊ីសាក់ និង យ៉ាកុប ដែលមាននៅក្នុងព្រះគម្ពីរ លោកុប្បត្តិ ជំពូក ២៥ ដល់ជំពូក ៣៦
- **ការអត់ទោសបាបរបស់ព្រះម្ចាស់ សេរីភាពរបស់យើង:** មាននៅក្នុងព្រះគម្ពីរ លោកុប្បត្តិ ជំពូក ៣៧-៥០ គឺជាដំណើររឿងរបស់យ៉ូសែប និង បងប្អូនប្រុសៗរបស់គាត់។
- **ការត្រាស់ហៅរបស់ព្រះម្ចាស់ ការរំដោះរបស់យើង:** ផ្នែកទី១ និង ទី ២ គឺមានបញ្ចូលទាំងព្រះគម្ពីរនិក្ខមនំផងដែរ។
- **វត្តមានរបស់ព្រះម្ចាស់ ជ័យជំនះរបស់យើង:** គឺត្រូវបានសិក្សាសាច់រឿងមួយចំនួនដែលត្រូវបានដកស្រង់ចេញមកពីព្រះគម្ពីរ យ៉ូស្វេ និង ព្រះគម្ពីរពួកចៅហ្វាយ។
- **បំណងព្រះហឫទ័យរបស់ព្រះម្ចាស់ ផ្លូវរបស់យើង:** គឺជាការសិក្សាអំពីដំណើររឿងរបស់នាងរស់ សាំយ៉ូអែល និង ស្តេចសូល។
- **សេចក្តីមេត្តាករុណារបស់ព្រះម្ចាស់ សេចក្តីសង្គ្រោះរបស់យើង:** គឺត្រូវបានសិក្សាអំពីដំណើររឿងរបស់ ព្រះបាទដាវីឌ ព្រះបាទសាឡូម៉ូន ហោរា អេលីយ៉ា និង លោកអេលី។
- **សេចក្តីប្រោសលោះរបស់ព្រះម្ចាស់ សេចក្តីសុចរិតរបស់យើង:** គឺត្រូវបានសិក្សាអំពីដំណើររឿងរបស់ ដានីញ៉ែល យ៉ូណាស អែសរ៉ា និង នេហេមា។

ទោះបីជាការសិក្សាទាំងនេះត្រូវបានទទួលការណែនាំក៏ដោយ វាហាក់ដូចជាមិនសូវចាំបាច់ដូចជាការសិក្សាមេរៀនទី ១២ ដែលមានចំណងជើងថា "ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ អ្នកសង្គ្រោះរបស់យើង" នេះដែរ។

ជាចុងក្រោយនេះ លោកអ្នកត្រូវតែយល់ថាការសិក្សាតាមេរៀនទាំងអស់នេះ គឺត្រូវបានរៀបរៀងឡើងសម្រាប់ឲ្យលោកអ្នកអាចយកទៅដោយខ្លួនឯងផ្ទាល់។ ម្យ៉ាងវិញទៀត វាត្រូវបានរចនាឡើងមានលក្ខណៈងាយស្រួលដល់អ្នកប្រើ ទៅតាមកម្រិតនៃការលត់ដំខ្លួនឯងចំពោះការលំបាកបន្តិចបន្តួចក្នុងការប្រើប្រាស់សៀវភៅមេរៀនទាំងនេះ។ ក្នុងពេលជាមួយគ្នាកនេះដែរ ការសិក្សានឹងនាំអារម្មណ៍របស់លោកអ្នកឲ្យការរំភើបរីករាយផងដែរ ហើយលោកអ្នកនឹងទទួលបាននូវពត៌មាន និង ចំណេះដឹងថ្មីៗ ដែលនឹងធ្វើឲ្យលោកអ្នកមានបំណងចង់ចែករំលែកចំណេះដឹងថ្មីៗពីការសិក្សានេះទៅអ្នកដទៃទៀតផង។ ជាងនេះទៅទៀតនោះលោកអ្នកនឹងមានសំណួរ ដែលជាបញ្ហាប្រឈមមួយចំនួនតម្រូវឲ្យទទួលបានចម្លើយដែរ។

ការសន្ទត់ទុកជាមុនអំពីការឆ្លើយតបរបស់អ្នកត្រូវបានលើកទឹកចិត្តយ៉ាងទទូច ដើម្បីឲ្យធ្វើការពិចារណាក្នុងអញ្ជើញមិត្តភក្តិពីរ ឬបីនាក់ឲ្យចូលរួមសិក្សាជាមួយនឹងលោកអ្នកផងដែរ។ វិន័យនៃការធ្វើលំហាត់ប្រាណនៅកន្លែងណាមួយ! ជាឧទាហរណ៍ថា បើសិនជាយើងមានដៃគូម្នាក់ទៀតចូលរួមជាមួយ នោះវានឹងកាន់តែធ្វើមានភាពងាយស្រួលជាងមុន ដោយម្នាក់ៗត្រូវការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក។ ប្រហែលជាប្តី/ប្រពន្ធរបស់អ្នកមានបំណងចង់អញ្ជើញប្តីប្រពន្ធពីរ ឬ បីគូរផ្សេងទៀតឲ្យមកចូលរួមជាមួយលោកអ្នកដែរមិនខាន។ ឬប្រហែលជាលោកអ្នកកំពុងរស់នៅក្នុងផ្ទះជួល ហើយមានបំណងចង់បបួលអ្នកដែលជួលបន្ទប់នៅក្បែរ ឲ្យចូលរួមសិក្សាជាមួយនឹងលោកអ្នកដែរក៏ថាបាន។ ហើយប្រហែលជាមាននរណាម្នាក់នៅកន្លែងធ្វើការចង់ត្រូវបានអញ្ជើញឲ្យទៅចូលរួមរៀនពីអ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលតាមរយៈព្រះគម្ពីរ។ ប្រហែលជាលោអ្នកអាចជាសមាជិកនៃពួកជំនុំណាមួយនៅក្បែរកន្លែងលោកអ្នករស់នៅ ឬ លោកអ្នកស្គាល់ពួកជំនុំណាមួយនៅក្បែរៗនោះ ដែលពួកគេមានកម្មវិធីសិក្សាព្រះគម្ពីរប្រហាក់ប្រហែលគ្នា ក្នុងរយៈពេលមួយសប្តាហ៍ម្តង នោះលោកអ្នកក៏អាចទំនាក់ទំនងពួកគេឲ្យមកចូលរួមសិក្សារួមគ្នាបានដែរ។

បើទោះបីជាលោកអ្នកកំពុងស្ថិតនៅក្នុងស្ថានភាព ឬ បរិយាកាសបែបណាក៏ដោយ ចូរលោកអ្នកត្រូវបង្កើតការប្រមូលផ្តុំគ្នាសិក្សាឲ្យប្រកបដោយសុវត្ថិភាពល្អ ជាលក្ខណៈក្រុមតូច ឬ ក្រុមកោសិកា ដើម្បីជួបជុំគ្នាក្នុងមួយសប្តាហ៍ម្តង ដើម្បីចែករំលែក ចំណេះដឹង និង ទទួលការរីកចម្រើនជាមួយលើផ្នែកចំណេះដឹងខាងព្រះគម្ពីរ។ សមាជិកក្នុងក្រុមសិក្សាព្រះគម្ពីរនិមួយ ទោះបីជាមានគ្នាតិច ឬ ច្រើនក្តី ក៏នៅតែអាចទទួលបានការរីកលូតលាស់ ក្នុងចំណេះដឹងផ្នែកខាងព្រះបន្ទូលព្រះដែរ ឲ្យតែម្នាក់មានការប្តេជ្ញាខ្ពស់ និង មានភាពស្មោះត្រង់ក្នុងការចូលរួមសិក្សាជាមួយគ្នាឲ្យបានទៀតទាត់។

ឥឡូវនេះ គឺដល់ពេលវេលាចាប់ផ្តើមហើយ! ចូរយើងបន្តដំណើរផ្សងព្រេងរបស់យើងតទៅមុខទៀត!

# សេចក្ដីណែនាំ

តាមរយៈប្រវត្តិសាស្ត្រទាំងស្រុងរបស់ព្រះជាម្ចាស់គឺត្រូវបានស្ថិតនៅក្នុងបេសកកម្មមួយ គឺជាបេសកកម្មនៃការត្រាស់ហៅយើងម្នាក់ៗឲ្យវិលត្រឡប់ទៅរកទ្រង់ ហើយមានទំនាក់ទំនងជាមួយនឹងទ្រង់ឡើងវិញ។ នៅក្នុងព្រះគម្ពីរ លោកុប្បត្តិជំពូក ៣ យើងដឹងថា ទំនាក់ទំនងដ៏ល្អឥតខ្ចោះរវាងព្រះជាម្ចាស់ ជាមួយលោកអ័ដាម និងអេវ៉ាត្រូវបានបាក់បែកដោយសារការមិនស្ដាប់បង្គាប់របស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ នាខណៈពេលដែលពួកគេរស់នៅក្នុងសួនច្បារនៅឡើយ ព្រះជាម្ចាស់បានចាប់ផ្ដើមដំណើរការស្ដារ និង ផ្សះផ្សាទំនាក់ទំនងដែលបាក់បែកនោះឲ្យបានជានាឡើងវិញរួចទៅហើយ។ នៅក្នុងព្រះគម្ពីរ លោកុប្បត្តិ ៣:១៥ ទ្រង់បានប្រទានសេចក្ដីសន្យាដំបូងបង្អស់ថាទ្រង់នឹងប្រទាននូវព្រះអង្គសង្គ្រោះមកដល់ពួកគេ។ បេសកកម្មរបស់ព្រះអង្គបានចាប់ផ្ដើមរៀបចំអ្វីៗទាំងអស់ ដែលទ្រង់បានបង្កើតមកឲ្យត្រឡប់មកឯចំណងមេត្រីភាពយ៉ាងជិតស្និទ្ធនៃទំនាក់ទំនងជាមួយទ្រង់ឡើងវិញ។

ឥឡូវនេះ ខណៈពេលដែលយើងបានចាប់ផ្ដើមការសិក្សាអំពីដំណឹងល្អទាំងបួន (ម៉ាថាយ ម៉ាកុស លូកា និង យ៉ូហាន) គឺបួនកំណួគម្ពីរដំបូងនៃព្រះគម្ពីរសញ្ញាថ្មី យើងនឹងសិក្សាអំពីផែនការណ៍ អំពីយុទ្ធសាស្ត្ររបស់ទ្រង់ ដើម្បីឲ្យបេសកកម្មបានសម្រេចតាមការគ្រោងទុករបស់ទ្រង់។ ជើងឯករបស់ព្រះជាម្ចាស់ ដែលជាព្រះរាជបុត្រាដ៏វិសុទ្ធតែមួយរបស់ទ្រង់ គឺព្រះយេស៊ូវ ត្រូវបានប្រសូតមកជាទារកម្នាក់រស់នៅលើផែនដីក្នុងសណ្ឋានសាច់ឈាមជាមនុស្ស ហើយបន្ទាប់ទ្រង់ត្រូវទទួលការរងទុក្ខលំបាក រហូតទាល់តែសុគត ក្នុងគោលបំណងដើម្បីបង់ថ្លៃលោះបាបរបស់យើងម្នាក់ៗ ដែលបានប្រព្រឹត្តរំលងជាហេតុធ្វើមានការដាច់ចេញពីព្រះជាម្ចាស់តាំងពីយូរយាមកហើយនោះ។ ព្រះយេស៊ូវបានធ្វើដូច្នេះ គឺក្នុងគោលបំណងឲ្យចេតនាចង់ផ្សះផ្សាទំនាក់ទំនងជាមួយនឹងមនុស្សឡើងវិញរបស់ព្រះជាម្ចាស់ បានតភ្ជាប់គ្នាឡើងសារជាថ្មីម្ដងទៀត។ ព្រះយេស៊ូវដែលជាជើងឯករបស់ព្រះជាម្ចាស់បានធ្វើគ្រប់កិច្ចការទាំងអស់សម្រាប់ពួកយើងរាល់គ្នា គឺជាកិច្ចការដែលយើងម្នាក់ៗមិនអាចធ្វើបានសម្រាប់ខ្លួនឯងបានឡើយ ហើយយើងនឹងបានឃើញថាសេចក្ដីសន្យាអំពីព្រះអង្គសង្គ្រោះ ព្រះយេស៊ូវគ្រីស្ទដែលជាព្រះមេស៊ី និងជាព្រះរាជបុត្រាតែមួយរបស់ព្រះជាម្ចាស់យកជ័យជម្នះលើអំណាចនៃអំពើបាប និងសេចក្ដីស្លាប់ដោយរបៀបណា។

តាមរយៈមេរៀនទាំងអស់ដែលយើងត្រូវសិក្សានេះ យើងនឹងអានអំពីដំណើររឿងមួយចំនួនដែលនឹងលាតត្រដាងឲ្យបានដឹងថា ព្រះយេស៊ូវគឺជាអ្នកណា។ យើងនឹងត្រូវត្រឡប់ទៅត្រឡប់សារចុះសារឡើងក្នុងរវាងព្រះគម្ពីរដំណឹងល្អទាំងបួន គឺក្នុងគោលបំណងដើម្បីលើកកំពស់ការយល់ដឹងរបស់យើង អំពីរឿងដែលថាទ្រង់គឺជាព្រះបុត្រារបស់ព្រះជាម្ចាស់ និងជាព្រះអង្គសង្គ្រោះនៃពិភពលោកទាំងមូលនេះ។ មានរឿងរ៉ាវមួយចំនួនយើងអាចត្រូវបានតាមរយៈ អ្នកសរសេរព្រះគម្ពីរដំណឹងល្អតែម្នាក់ ឬ ពីរនាក់ ហើយមានរឿងរ៉ាវមួយ

ចំនួនទៀត យើងក៏អាចដឹងតាមរយៈអ្នកសរសេរព្រះគម្ពីរដំណឹងល្អទាំងបួននាក់ព្រមគ្នាដែរ។ តទៅមុខទៀត វានឹងលេចចេញនូវភាពខុសគ្នាខ្លះៗ រវាងអ្នកនិពន្ធទាំងនេះ ប៉ុន្តែវានឹងមិនធ្វើឲ្យមានការរាំងស្ទះ ឬ បង្អាក់ដល់ការសិក្សារបស់យើងឡើយ។ ចូរចាំថាអ្នកនិពន្ធនិមួយៗ គោលដៅ និង ព្យាយាមដើម្បីឲ្យបានឈានទៅដល់ ហើយមិនមែនអ្នកនិពន្ធទាំងអស់សុទ្ធត្រូវបានធ្វើជាសក្ខីភាពដោយភ្នែកគេបានមើលឃើញនោះទេ។

រំលឹកសារជាថ្មីម្តងទៀត គឺវាមិនអាចធ្វើទៅបានទេ ក្នុងការបញ្ចូលដំណើររឿងឲ្យបានលំអិត សម្រាប់គ្រប់កំណត់ត្រាទាំងអស់អំពីព្រះយេស៊ូវនោះ ហេតុនេះគឺមានតែធ្វើការសន្និដ្ឋានសង្ខេបតែប៉ុណ្ណោះ ហើយចំពោះសាច់រឿងទាំងប៉ុន្មាន ដែលត្រូវបានជ្រើសរើសមកសិក្សា គឺនឹងតម្រូវឲ្យលោកអ្នកចាប់ផ្តើមក្នុងពេលបន្តិចទៀតខាងមុខនេះហើយ។ ចូរនឹកចាំថាព្រះវរបិតាជាម្ចាស់ទ្រង់សព្វព្រះហឫទ័យចង់ឱ្យលោកអ្នកដឹង និង ស្គាល់ពីសេចក្តីស្រឡាញ់យ៉ាងអស្ចារ្យដែលទ្រង់មានសម្រាប់លោកអ្នក ព្រមទាំងទំនាក់ទំនងរបស់ទ្រង់ក្នុងការចែករំលែកជាមួយលោកអ្នក។ សូមឲ្យលោកអ្នកទទួលបានភាពសប្បាយរីករាយ ដើម្បីឲ្យបានដឹងថាព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះនិងជាព្រះដ៏ប្រោសលោះរបស់លោកអ្នក!

# មេរៀនទី ១

## មេរៀនទី ១ - ផ្នែកទី ១

### សេចក្ដីណែនាំ:

អស់រយៈពេលរាប់រយឆ្នាំបានកន្លងផុតទៅ ចាប់តាំងពីរាស្ត្រអ៊ីស្រាអែលដែលនៅសេសសល់ទាំងប៉ុន្មានក៏បានត្រឡប់មកពីស្រុកបាប៊ីឡូនដោយបានចូលទៅតាំងទីលំនៅក្នុងទឹកដីសន្យាជាថ្មីម្ដងទៀត។ នៅក្នុងអំឡុងពេលនោះគឺជាគម្លាតពេលវេលាមួយរវាងព្រះគម្ពីរ ម៉ាឡាគី (គម្ពីរសញ្ញាចាស់) និងកំណើតនៃព្រះយេស៊ូវ (គម្ពីរសញ្ញាថ្មី) នៅអំឡុងពេលនោះដែរពួកសាសន៍យូដាបានទទួលការជិះជាន់យ៉ាងធ្ងន់ធ្ងរពីសំណាក់សាសន៍ ក្រិក និង រ៉ូម៉ាំងដែលពួកគេគឺជាអ្នកដឹកនាំ និងត្រួតត្រានៅលើទឹកដីនោះ។ លុះមកដល់ការបើកទំព័រថ្មីនៃព្រះគម្ពីរសញ្ញាថ្មី គឺមានស្ដេចហេរ៉ូដ ធ្វើជាអ្នកត្រួតត្រាយ៉ាងព្រៃផ្សៃ ដោយគ្មានមេត្តារបស់ ប៉ាឡេស្ទីន វាគឺជាពេលវេលាដែលសាសន៍អ៊ីស្រាអែលត្រូវប្រគល់ទឹកដីដែលព្រះជាម្ចាស់ប្រទានឲ្យទៅអ្នកផ្សេងគ្រប់គ្រង។

ព្រះគម្ពីរបួនកំណួដំបូងនៃព្រះគម្ពីរសញ្ញាថ្មី វាគឺជាដំណឹងល្អទាំងបួនដែលបានសរសេរឡើងដោយម៉ាថាយ ម៉ាកុស លូកា និងយ៉ូហាន។ ពួកគេម្នាក់ៗបានសរសេរឡើងទៅតាមទស្សនៈ គំនិតអ្នកអាន អ្នកស្ដាប់ផ្សេងៗគ្នាដែរ។ ឧទាហរណ៍ដូចជា ម៉ាថាយចង់ឱ្យអ្នកអានសាសន៍យូដាបានដឹងថាព្រះយេស៊ូវគឺជាព្រះមេស៊ីដែលបានសម្រេចតាមសេចក្ដីសន្យាតាមបទទំនាយរបស់ព្យាការីអេសាយ និង យេរេមាកាលពីយូរលង់ណាស់មកហើយនោះ។ ចំណែកឯ លូកា វិញបានសរសេរតម្រូវចំពោះគំនិតរបស់ ថេវភីល (Theophilus) (លូកា ១:៣) និង សាសន៍រ៉ូម៉ាំងដទៃទៀត ដែលកំពុងត្រូវបានសិក្សាអំពី ព្រះមេស៊ីត្រូវបានចាក់ប្រេងតាំងដែលហៅថាព្រះគ្រីស្ទ។

ក្នុងខណៈពេលដែលយើងបន្តការសិក្សាព្រះគម្ពីររបស់យើង យើងនឹងធ្វើការផ្ដោតសំខាន់ទៅលើតួអង្គព្រះយេស៊ូវ។ យើងនឹងបានស្វែងយល់ជាមួយនឹងទ្រង់ដោយធ្វើការដកស្រង់សាច់រឿងមួយចំនួននៅក្នុងព្រះគម្ពីរដំណឹងល្អមកសិក្សា តួយ៉ាងដូចជាមនុស្សពីរនាក់គឺ លូកា និង យ៉ូហាន *ហេតុអ្វី* បានជាពួកគេទាំងពីរមានសរសេរអំពីគណនេយ្យភាពនៃជីវិតរបស់ព្រះយេស៊ូវ។

ក. តើនៅក្នុងព្រះគម្ពីរ លូកា ១:៣-៤ បានប្រាប់អ្វីខ្លះដល់យើង? ______________________________

______________________________________________

______________________________________________

______________________________________________

**២. តើនៅក្នុងព្រះគម្ពីរ យ៉ូហាន ២០:៣១ បានប្រាប់អ្វីខ្លះដល់យើង?** ____________________

____________________

____________________

**លោក លូកា មានបំណងចង់ឲ្យ ថេវភីឡូ (Theophilus) បានជ្រាបអំពីសេចក្ដីពិតមួយចំនួនដែលគាត់បានបង្រៀន។ លោកយ៉ូហានមានបំណងចង់ឲ្យអ្នកដែលបានអានអ្វីៗដែលគាត់សរសេរនោះបានជឿថាព្រះយេស៊ូវជាព្រះគ្រីស្ទ ហើយជឿថាពួកគេនឹងមានជីវិតអស់កល្បជានិច្ច។ មានមនុស្សជាច្រើនបានកំណត់គោលដៅសម្រាប់ជីវិតរបស់ខ្លួនរួចជាស្រេច ហើយពួកគេ បានប្ដេជ្ញាចិត្តគំនិតធ្វើយ៉ាងណាឲ្យបានទៅដល់គោលដៅដែលបានកំណត់ទុកនោះ។ នៅក្នុងព្រះគម្ពីរ ភីលីព ៣:១០ លោក ប៉ូលបាន ប្រាប់អំពីគោលដៅនៃជីវិតរបស់គាត់ដោយបាននិយាយថា** "ដើម្បីឲ្យខ្ញុំបានស្គាល់ទ្រង់ និងព្រះចេស្ដានៃដំណើរដែលទ្រង់រស់ឡើងវិញ ហើយនិងសេចក្ដីប្រកបក្នុងការរងទុក្ខរបស់ទ្រង់ ព្រមទាំងត្រឡប់ទៅដូចជាទ្រង់ក្នុងសេចក្ដីស្លាប់ផង"**។ នេះវាក៏អាចជាការកំណត់គោលដៅសម្រាប់ជីវិតរបស់យើងដើម្បីឲ្យបាន ដឹងថាព្រះយេស៊ូវគ្រីស្ទគឺជាព្រះជាម្ចាស់ និង ជាព្រះសង្គ្រោះ ក៏ដូចជាសម្រាប់មិត្តភ័ក្រ ដោយការស្គាល់ទ្រង់នោះយើងនឹងបានជឿលើទ្រង់ ហើយទទួលយកព្រះអម្ចាស់មកដាក់ក្នុងជីវិតដោយនូវក្នុងព្រះនាមរបស់ទ្រង់ផងដែរ។**

## សេចក្ដីអធិស្ឋានៈ

**ឱ ព្រះវរបិតា ដ៏មានព្រះគុណអើយ! ទូលបង្គំប្រៀបដូចជានាវាមួយដែលទើបនឹងចាប់ផ្ដើមធ្វើដំណើរចូលទៅក្នុងដំណឹងល្អ ដែលប្រាប់អំពីដំណឹងល្អរបស់ព្រះអង្គសម្រាប់ពិភពលោកទាំងមូលនេះ ដ្បិតព្រះយេស៊ូវគឺជាដំណឹងល្អ។ សូមជួយឲ្យទូលបង្គំបានស្គាល់ទ្រង់ ក្នុងខណៈពេលដែលទូលបង្គំបានស្វែងរក និងសិក្សាស្វែងយល់ឲ្យបានដឹងថាទ្រង់គឺជានរណា ហើយថាហេតុអ្វីបានជាទ្រង់យាងមកលើផែនដី ហើយពីរបៀបដែលជីវិតរបស់ទ្រង់មានភាពទាក់ទាញដល់ជីវិតរបស់ទូលបង្គំ។ សូមឲ្យចិត្តគំនិតនៃទូលបង្គំនៅតែខ្នះខ្នែងក្នុងការស្ដាប់របស់តាមទ្រង់ផង! ហើយសូមបើកចិត្តគំនិតទូលបង្គំតាមរយៈសាច់រឿងនៃការអស្ចារ្យ និងពាក្យប្រស្នាទាំងនោះផង ដ្បិតវាគឺជាព្រះបន្ទូលរបស់ទ្រង់ ដែលព្រះអង្គយកមកប្រើដើម្បីបើកសម្ដែងអង្គទ្រង់ដល់ទូលបង្គំ ដើម្បីឱ្យបានស្គាត់ទ្រង់តតាមរយៈព្រះបុត្រាព្រះយេស៊ូវគ្រីស្ដដែលជាព្រះអម្ចាស់ និង ជាព្រះសង្គ្រោះរបស់ទូលបង្គំ។** ____________________

____________________

____________________

____________________

## សេចក្តីបង្រៀន:

ព្រះគម្ពីរ ម៉ាថាយបានចាប់ផ្តើមឡើងដោយរៀបរាប់អំពីពង្សាវតាររបស់ព្រះយេស៊ូវ មានសំណួរខ្លះៗត្រូវបានឆ្លើយដោយលោក ម៉ាថាយ ដូចជាអំពី: ទីកន្លែងដែលព្រះយេស៊ូវបានយាងមកពីណា? តើពូជពង្សរបស់ព្រះអង្គគឺជានរណា? បើសិនជាលោកអ្នកក្រឡេកតែមួយភ្លែតនៅត្រង់ខគម្ពីរ ២-១៧ មានឈ្មោះមនុស្សខ្លះៗលោកអ្នកប្រហែលជាធ្លាប់បានឮពីមុនមក។ ចូរគូសបន្ទាត់ពីក្រោមឈ្មោះណាដែលលោកអ្នកធ្លាប់ស្គាល់!

- ខ ១-៦ ចាប់ពីជំនាន់លោក អប្រាហាំ រហូតដល់ជំនាន់ព្រះបាទដាវីឌ (១ សាំយ៉ូអែល ១៦)
- ខ ៦-១១ រជ្ជកាលនិមួយៗនៃព្រះមហាក្សត្រនៃអ៊ីស្រាអែល (១ សាំយ៉ូអែល និង ១ សាំយ៉ូអែល)
- ខ ១២-១៦ ចាប់ពីដែលជាប់ជាទាសរនៅក្រុងបាប៊ីឡូន រហូតដល់ជំនាន់កំណើតរបស់ព្រះយេស៊ូវ។

**សំគាល់**: ម៉ាថាយនិយាយពីពព្ធយុកោពីរធំៗនៅក្នុងដំណរពូជពង្សនៃសាសន៍យូដា គឺលោក អប្រាហាំ និងព្រះបាទដាវីឌ។ គាត់មិនបានរៀបរាប់នូវបញ្ជីឈ្មោះនៃបុព្វបុរសទាំងអស់របស់ព្រះយេស៊ូវនោះទេ ពីព្រោះថាម៉ាថាយមានបំណងចង់សរសេរទៅកាន់ពួកសាសន៍យូដា វាគឺជាការសំខាន់ណាស់ដែលថាពូជពង្សរបស់លោក អប្រាហាំ បានចាប់ផ្តើមជាប់ជាមួយនឹងបុព្វបុរស និង ពួកព្ធយុកោរបស់ពួកគេដែរនោះ។ លើសពីនេះទៀត លោក អប្រាហាំ និង ព្រះបាទ ដាវីឌ ក៏ត្រូវបានរៀបរាប់នៅក្នុងខ ៦ ដែលជាដំណរពូជពង្សនៃបុព្វបុរសសំខាន់មួយផ្សេងទៀតរបស់ពួលសាសន៍ យូដា ដូចមានមុខងារព្រះបុត្រានៃព្រះបាទ ដាវីឌដែលបានរៀបរាប់នៅក្នុងដំណឹងល្អតាមរយៈលោក ម៉ាថាយ (៩:២៧, ២០:៣០) ទុកជាឧទាហរណ៍ស្រាប់ វាគឺជាការបញ្ជាប់បន្ថែមមួយទៀតថា ព្រះយេស៊ូវគឺពិតជាព្រះមេស៊ីដែលត្រូវបានរើសតាំងឡើង ដែលសាសន៍អ៊ីស្រាអែលបានរង់ចាំនៅក្នុងប្រវត្តិសាស្ត្ររបស់ពួកគេនោះតាំងពីយូរយាណាស់មកហើយ។

លោក លូកា ក៏បានកត់ត្រាទុកនូវពង្សាវតាររបស់ព្រះយស៊ូវនៅក្នុងព្រះគម្ពីរ លូកា ៣:២៣-៣៨ ផងដែរ។ តើការរៀបរាប់អំពីពង្សាវតាររបស់គាត់មានលក្ខណ:ខុសគ្នាយ៉ាងដូចម្តេចខ្លះ? ____________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

- តើលោក លូកា បានចាប់ផ្តើមរៀបរាប់ពីត្រឹមណាមក? ______________________________

  ______________________________________________________________________

- តើ លោក លូកា បានរៀបរាប់ពង្សាវតាររបស់ព្រះយេស៊ូវពីត្រឹមណាមក? ________________

  ______________________________________________________________________

ព្រះយេស៊ូវ គួតែជាកូនប្រុសរបស់យ៉ូសែប ប៉ុន្តែ លោក លូកា បានប្រាប់យើងថា ទ្រង់បានមានតាំងពីមុនលោក អប្រាហាំទៅទៀតផង! គឺជាកូន ______________ ជាកូន _________________ (នៅក្នុងខ ៣៨)

# មេរៀនទី ១ - ផ្នែកទី ២

## កិច្ចការៈ

ចូរអានដំណើររឿងរបស់នាងម៉ារី នៅក្នុងព្រះគម្ពីរ លូកា ១:២៦-៣៨

1. តើអ្វីទៅជាអង្គហេតុសំខាន់នៅក្នុងខ ២៦-២៧? ______________________________

   ______________________________________________________________

2. តើនាងម៉ារី មានប្រតិកម្មយ៉ាងដូចម្ដេចចំពោះការជំរាបសួររបស់ទេវតា? ________________

   ______________________________________________________________

3. តើនាងម៉ារីបានឆ្លើយតបចំពោះវត្តមានរបស់ទេវតាយ៉ាងដូចម្ដេច? ____________________

   ______________________________________________________________

## លំហាត់ៈ

1. នៅក្នុងខ ២៦-២៧ ម៉ារីគឺជាសាច់ញ្ញាតិរបស់អេលីសាបែត ដែលមានផ្ទៃពោះ ៦ ខែ គឺនៅដែលព្រះជាម្ចាស់ ____________________________ ទេវតា ____________________

   ក. ព្រះជាម្ចាស់បានចាត់ទេវតា កាព្រីយ៉ែលបានទៅឯ ____________________________

   ភូមិ _________________________ ក្នុងស្រុក ________________________

   ដែលត្រូវជា ____________________________________________________

   ខ. បុរសម្នាក់ឈ្មោះថា _________________________ ជាពូជ ________________

   គ. នាងមានឈ្មោះថា ____________________________________________

2. ទេវតាកាព្រីយ៉ែលបានប្រាប់នាងម៉ារីថា ព្រះជាម្ចាស់បានសព្វព្រះហឫទ័យនឹងនាង (ខ៣០) ហើយតើនឹងមានអ្វីកើតឡើងចំពោះនាង (ខ៣១)? ________________________________

   ______________________________________________________________

   ______________________________________________________________

   ______________________________________________________________

   តើបុត្រានោះនឹងបានទៅជាអ្វី (ខ៣២-៣៣)? ______________________________

   ______________________________________________________________

   ______________________________________________________________

   ______________________________________________________________

3. តើនាងម៉ារីបានឆ្លើយតបវិញយ៉ាងដូចម្ដេច?
   ក. ចំពោះពាក្យជំរាបសួររបស់ទេវតា (ខ២៩) ______________________________
   ____________________________________________
   ____________________________________________
   ខ. ចំពោះដំណឹងដែលថានាងនឹងមានផ្ទៃពោះ ហើយប្រសូតបានបុត្រាមួយត្រូវថ្វាយព្រះនាមថា យេស៊ូវ (ខ៣៤) ______________________________
   ____________________________________________
   ____________________________________________
   គ. ចំពោះឃ្លាមួយថា "ដ្បិតការអ្វីដែលព្រះទ្រង់ធ្វើពុំបាន នោះគ្មានសោះឡើយ" (ខ៣៨) ______
   ____________________________________________
   ____________________________________________
4. តើបុត្រានោះនឹងត្រូវថ្វាយព្រះនាមថាដូចម្ដេច?
   ក. នៅក្នុងខ ៣២ ត្រូវថ្វាយព្រះនាមថា: ______________________________
   ខ. នៅក្នុងខ ៣៥ ត្រូវថ្វាយព្រះនាមថា: ______________________________
5. តើដំណើររឿងរបស់នាងម៉ារីត្រូវបានបញ្ចប់យ៉ាងដូចម្ដេច? ____________________
   ____________________________________________
   ____________________________________________
   ____________________________________________
   ____________________________________________

## កិច្ចការ:

ចូរអានដំណើររឿងរបស់ យ៉ូសែប នៅក្នុងព្រះគម្ពីរ ម៉ាថាយ ១:១៨-២៥

1. តើអ្វីទៅជាអង្គហេតុសំខាន់នៅក្នុងខ ១៨-១៩? ______________________________
   ____________________________________________
   ____________________________________________
   ____________________________________________

2. តើមានការបើកសម្តែងតាមរយៈការយល់សប្តិរបស់គាត់យ៉ាងដូចម្តេចនៅក្នុងខ ២០-២១? ____

______________________________________________

______________________________________________

3. តើនឹងបានស្រេចតាមបទទំនាយរបស់ពួកហោរាយ៉ាងដូចម្តេច នៅក្នុងខ២២-២៣? __________

______________________________________________

______________________________________________

4. តើយ៉ូសែបបានឆ្លើយតបចំពោះការយល់សប្តិនោះវិញយ៉ាងដូចម្តេច នៅក្នុងខ ២៤-២៥? _____

______________________________________________

______________________________________________

5. តើដំណើររឿងរបស់នាងម៉ារី និង យ៉ូសែបវាមានលក្ខណៈស៊ីសង្វាក់គ្នាដូចម្តេច? __________

______________________________________________

______________________________________________

______________________________________________

______________________________________________

## លំហាត់:

1. ចូរសរសេរអំពីព្រះនាម និង អត្ថន័យរបស់ព្រះយេស៊ូវដែលគេថ្វាយដល់ទ្រង់:

   ក. ក្នុងខ ១៦, ១៨ ______________________ មានន័យថា: ________________

   ខ. ក្នុងខ ២១ __________________________ មានន័យថា: ________________

   គ. ក្នុងខ ២៣ __________________________ មានន័យថា: ________________

   **សំគាល់:** នៅក្នុងភាសា ក្រិច និង ភាសា ហេព្រើរ គឺត្រូវបានផ្តល់អត្ថន័យយ៉ាងស៊ីជម្រៅទៅលើឈ្មោះ ដូចជា "យេស៊ូវ" មានន័យថា អ្នកសង្គ្រោះក្នុងភាសា ក្រិច ហើយនៅក្នុងភាសាហេព្រើរវិញមានន័យថា ព្រះអម្ចាស់បានសង្គ្រោះហើយ។ ព្រះគ្រីស្ទ គឺជាភាសា ក្រិច ហើយភាសាហេព្រើរវិញគឺ ព្រះមេស៊ី គឺព្រះដែលត្រូវបានអភិសេកឡើង រីឯពាក្យថា អេម៉ាញ៉ូអែល ក៏ដូចគ្នាដែរ ជាភាសាហេព្រើរ មានន័យថា ព្រះជាម្ចាស់គង់ជាមួយយើង។

2. គួរដណ្តឹងរបស់យ៉ូសែបមានផ្ទៃពោះហើយ! ដើម្បីប្រព្រឹត្តឲ្យបានត្រឹមត្រូវតាមទស្សនៈ និង គំនិតរបស់មនុស្សទូរទៅ តើយ៉ូសែបមានផែនការណ៍ដូចម្តេចក្នុងរឿងនេះ (ខ១៩)? ____________

________________________________________________________________

________________________________________________________________

________________________________________________________________

3. ដ្បិតកូនក្នុងផ្ទៃរបស់នាងមិនមែនមានផ្ទៃពោះដោយ ____________________
ប៉ុន្តែ ប្រសូតមកដើម្បី ____________________________________
ហើយឲ្យបានសម្រេចតាម ____________________________ (ខ ២១-២២)

4. យ៉ូសែបបានភ្ញាក់ដឹងខ្លួន! គាត់បានឆ្លើយតបដោយការស្តាប់បង្គាប់! តើអ្វីជាអង្គហេតុសំខាន់គួរឲ្យដែលគួឲ្យចាប់អារម្មណ៍នៅក្នុង ២៥? ______________________________

________________________________________________________________

________________________________________________________________

________________________________________________________________

## ការឆ្លុះបញ្ចាំង:

តើដំណើររឿងរ៉ាវនេះវានឹងចាប់ផ្តើមមួយដោយរបៀបណាទៅ! គឺព្រះជាម្ចាស់ត្រូវយាងចុះមកលើផែនដីក្នុងបែបជាទារកម្នាក់ គឺជារាជព្រះបុត្រារបស់ព្រះជាម្ចាស់ផង ហើយជាកូនមនុស្សផង។ អស់រយៈពេលរាប់រយឆ្នាំមកហើយដែលរាស្ត្ររបស់ព្រះជាម្ចាស់ បានគេរង់ចាំការយាងមករបស់ព្រះមេស្ស៊ី ក្នុងការរង់ចាំនោះពួកគេត្រូវបានឆ្លងកាត់ទុក្ខវេទនាជាច្រើន ដូចជាឆ្នាំនៃទាសភាពដែលត្រូវបានពួកសាសន៍ដទៃជិះជាន់ ស្ទើរតែបាត់បង់អស់សេចកក្តីសង្ឃឹមទៅហើយ គឺសេចក្តីសង្ឃឹមថានៅថ្ងៃណាមួយនឹងមានអ្នកសង្គ្រោះមកជួយសង្គ្រោះរបស់ពួកគេឲ្យរួចផុតពីទុក្ខវេទនាទាំងនេះ។ ហើយឥឡូវនេះ ព្រះជាម្ចាស់បានបញ្ជូនទេវតាជាមួយឲ្យនាំព្រះរាជសារនៃក្តីសង្ឃឹមដល់ក្មេងស្រីម្នាក់បែបនេះទៅវិញ។ ព្រះមេស្ស៊ីនឹងត្រូវចាប់កំណើតជាមួយនឹងនាងម៉ារីដោយព្រះវិញ្ញាណបរិសុទ្ធ គឺមិនមែនដោយមនុស្សនោះឡើយ។ រីឯយ៉ូសែបក៏មិនខ្លាចនឹងទទួលយកនាងម៉ារីមកធ្វើជាប្រពន្ធរបស់គាត់ដែរ។

គឺវាពិតជាមិនស្មានដល់ថានឹងមានរឿងកើតឡើងជាមួយនឹងនាងម៉ារីបែបនេះឡើយ ដែលមានទេវតាមួយបានជួបនឹងនាងដោយបាននាំមកជាមួយនឹងព្រះរាជសាររមួយមកប្រាប់ដូច្នេះ ហើយយ៉ូសែបក៏មិនខុសគ្នាដែរ គាត់គឺជាមនុស្សសុចរិត ដែលរង់ចាំធ្វើតែអ្វីៗដែលល្អត្រឹមត្រូវតែប៉ុណ្ណោះ។ បើនិយាយជារួម យើងឃើញថា នាងម៉ារី គឺជាស្ត្រីដែលមានការចុះចូលចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ចំណែកឯយ៉ូសែប គឺជាបរុសដែលមានការស្តាប់បង្គាប់តាមព្រះជាម្ចាស់។ នៅទីបំផុតយ៉ូសែបបានទទួលយកនាង ម៉ារីមកធ្វើជាប្រពន្ធពេញច្បាប់ ដោយមិនបានរួមដំណេកជាមួយគ្នាឡើយ រហូតទល់តែព្រះឱរសយេស៊ូវបានប្រសូតមក។

# មេរៀនទី ១ - ផ្នែកទី ៣

## សេចក្តីណែនាំ:

នៅខណៈពេលដែលយើងកំពុង បន្តការសិក្សាមេរៀនអំពីព្រះយេស៊ូវដែលមនុស្សផង និងជាព្រះជាម្ចាស់ផង ដូច្នេះយើងត្រូវតែអានព្រះគម្ពីរយ៉ូហាន។ នៅក្នុងជំពូកដំបូងបង្អស់លោក យ៉ូហាន ចង់ប្រាប់យើងអំពីព្រះយេស៊ូវ គឺអំពីកាលដើមដំបូងបង្អស់របស់ទ្រង់ថាតើទ្រង់មានសណ្ឋានបែបណា? តើទ្រង់គឺជានរណា? តើទ្រង់បានមកពីណា? ហេតុអ្វីបានព្រះអង្គយាងមក? តើទ្រង់ដូចទៅនឹងអ្វី? លោក យ៉ូហាន បានសរសេរដោយតម្រូវសម្រាប់ពួកសាសន៍យូដា (សាសន៍អ៊ីស្រាអែល) ផង និងសម្រាប់ពួកសាសន៍ដទៃផង (មនុស្សមិនមែនជាសាសន៍អ៊ីស្រាអែល)។ សូមចងចាំថាលោក យ៉ូហានគឺជាអ្នកប្រកាសដំណឹងល្អម្នាក់ គាត់មានបំណងចង់ឱ្យមនុស្សទាំងអស់បានទទួលជឿលើព្រះជាម្ចាស់ យើងចង់ឲ្យពួកគេមានជីវិតនៅក្នុងព្រះនាមរបស់ទ្រង់ផងដែរ (យ៉ូហាន ២០:៣០-៣១)។

## កិច្ចការ:

សូមអានព្រះគម្ពីរ យ៉ូហាន ១:១-៥, ៩-១៤, ១៦-១៨ ។ យើងអានអំពីដំណើររឿងរបស់នាងម៉ារី និងរឿងរបស់យ៉ូសែប។ ហើយនេះគឺជារឿងរបស់លោក យ៉ូហាន អំពីព្រះយេស៊ូវដែលគាត់ចង់សំដៅថាទ្រង់គឺជាព្រះបន្ទូល។ តើយ៉ូហានចង់ឱ្យយើងសិក្សាអ្វីខ្លះអំពីព្រះយេស៊ូវ? នៅក្នុងជំពូកនេះអាចនឹងអាចនឹងមានការលំបាកខ្លះៗទាំងក្នុងការអាន និងការស្វែងយល់! ចូរឲ្យយើងទាំងអស់គ្នាមានចិត្តអត់ធ្មត់ចំពោះខ្លួនឯងក្នុងពេលកំពុងអានន្ធូវជំពូកនេះ។ ដូច្នេះ ចូរលោកអ្នកអានយឺតៗដោយយកចិត្តទុកដាក់ ហើយត្រូវមានប៊ិច ឬ ហាឡាយដើម្បីគូសបន្ទាត់ពីក្រោមពាក្យ ឬ ឃ្លា ណាដែលវាបានជួយឱ្យលោកអ្នកអាចយល់ដឹងបានដោយទូលំទូលាយថាតើព្រះយេស៊ូវទ្រង់គឺជានរណា?

## លំហាត់:

1. នៅក្នុងខ ១-៥
   ក. តើសេចក្តីពិតទាំងបីយ៉ាងដែលបានប្រាប់យើងមានអ្វីខ្លះ នៅក្នុងខ ១? ______________
   ______________________________
   ______________________________
   ______________________________

   ខ. តើព្រះយេស៊ូវមានការចូលរួមយ៉ាងដូចម្តេចខ្លះក្នុងការបង្កបង្កើត នៅក្នុងខ៣? __________
   ______________________________
   ______________________________

គ. ទ្រង់គឺជា ______________________________ (ខ៤)។

ឃ. នៅក្នុងទ្រង់មាន ______________ ហើយសម្រាប់មនុស្សលោក (ខ៤)។

ង. ពន្លឺនោះ ________ នៅក្នុង _________ ប៉ុន្តែ __________ មិន ______________________________ទេ (ខ៥)

2. នៅក្នុងខ ៩-១៤

ក. ________ ដ៏ពិតក៏បាន ______________ គ្រប់គ្នាដែលបានចូលមកឯ ____________ (ខ៩)។ ព្រះយេស៊ូវបានយាងមកធ្វើជាពន្លឺដល់លោកីយ៍។

ខ. ព្រះយេស៊ូវគង់ក្នុងលោកីយ៍ ហើយ _________________ ក៏ _____ ដោយសារទ្រង់ តែមិន ______________________ (ខ១០)

គ. ព្រះយេស៊ូវបានគង់នៅក្នុងផែនដីរបស់ទ្រង់ (សាសន៍អ៊ីស្រាអែល) ប៉ុន្តែ _________ ______________________________ ទ្រង់សោះ (ខ១១)។

ឃ. ចំពោះអស់អ្នកដែលទទួលទ្រង់ ហើយអ្នកដែលជឿដល់ព្រះនាមទ្រង់ នោះទ្រង់នឹងប្រទានអ្វីឲ្យពួកគេ (ខ១២)? ______________________________

______________________________

ង. យើងបានត្រឡប់ជាកូនរបស់ព្រះជាម្ចាស់ ដែលបានកើតមកពី _______(ខ១៣)។

ច. ព្រះបន្ទូលទ្រង់បានត្រឡប់ជា _________ ហើយ _________ ជាមួយយើងរាល់គ្នា។ យើង (អស់អ្នកដែលបានទទួលទ្រង់ ខ១២) បាន _________ ទ្រង់ នៃព្រះបុត្រាតែមួយដែលបានមកពីព្រះវរបិតាមានពេញដោយ __________ និង ______________________________(ខ១៤)។

3. នៅក្នុងខ ១៦-១៨

ក. យើងទាំងអស់គ្នា ____________________ មកពីទ្រង់ គឺជា ____ ______________________________ (ខ១៦)។

ខ. ដ្បិតបណ្ដា ______________ បានប្រទានមកដោយ __________ តែឯ _______________ និង _________________ មកពី ______________________________ វិញ (ខ១៧)។

គ. គ្មានអ្នកណាដែលឃើញ ____________ ឡើយ។ តើនរណាជាអ្នកបើកសម្តែងឲ្យយើងបានស្គាល់ព្រះវរបិតា? តើនរណាដែលបានធ្វើឲ្យព្រះអង្គបានស្គាល់យើង? តើនរណាដែលបានបើកសម្តែងឲ្យបានស្គាល់ពីលក្ខណៈរបស់ព្រះវរបិតា? (១១៨)។

**សំគាល់:** ជាមួយនឹងខគម្ពីរខាងលើនេះគឺបានចាប់ផ្តើមឡើងដោយបង្ហាញអំពីព្រះត្រៃឯក គឺមានព្រះវរបិតា ព្រះរាជបុត្រា និង ព្រះវិញ្ញាណបរិសុទ្ធ។ ទាំងបីអង្គនេះគឺជារួមគ្នាមកតែមួយ ហើយក៏ជាព្រះតែមួយដែរ គឺជាព្រះជាម្ចាស់តែមួយដដែលទេ ដែលមានពេញដោយព្រះគុណ និង សេចក្តីពិត!

## ការទន្ទេញចងចាំ:

គិតពីរបៀបដែលអ្នកអាចមានអារម្មណ៍ធុញនៅចំណុចនៅក្នុងការសិក្សារបស់អ្នក ព្រះគម្ពីរ យ៉ូហាន ១:១៤ គឺជាបទគម្ពីរមួយយ៉ាងសំខាន់ និង ជាប្រធានបទស្នូលនៃព្រះគម្ពីរយ៉ូហានទាំងមូលផងដែរ។ "ព្រះបន្ទូល (គឺជាពាក្យណែនាំរបស់លោកយ៉ូហានអំពីព្រះយេស៊ូវ) ក៏ត្រឡប់ជាសាច់ឈាម ហើយបានស្នាក់នៅជាមួយនឹងយើងរាល់គ្នា យើងរាល់គ្នាបានឃើញសិរីល្អទ្រង់ គឺជាសិរីល្អនៃព្រះរាជបុត្រាតែ១ ដែលមកពីព្រះវរបិតា មានពេញជាព្រះគុណ និងសេចក្តីពិត។" នៅក្នុងព្រះគម្ពីរសញ្ញាចាស់មានរឿងជាច្រើនដែលបាននិយាយអំពីព្រះជាម្ចាស់បានគង់នៅក្នុងចំណោមប្រជារាស្ត្ររបស់ទ្រង់ ដូចជាមានដុំភ្លើង និង ដុំពពកបានធ្វើដំណើរជាមួយរាស្ត្រអ៊ីស្រាអែលអស់រយៈពេល ៤០ ឆ្នាំ ក្នុងពេលដែលពួកគេបានរសាត់អណ្តែតនៅក្នុងវាលរហោស្ថាន ទាំងអស់នេះគឺជាការរំលឹកឲ្យពួកគេដឹងថាព្រះជាម្ចាស់បានគង់នៅជាមួយពួកគេ។ ព្រះពន្លាដែលព្រះជាម្ចាស់បានបង្គាប់ឲ្យលោក ម៉ូសេ សាងសង់ឡើងនោះ បានបម្រើដល់កិច្ចការមួយបង្ហាញឲ្យមនុស្សទាំងអស់បានមើលឃើញថា ព្រះជាម្ចាស់បានគង់នៅជាមួយពួកគេ ហើយក៏បានស្នាក់នៅក្នុងចំណោមពួកគេដែរ។ ឥឡូវនេះយើងមានព្រះមួយអង្គដែលត្រូវយាងចុះមក រស់នៅក្នុងសណ្ឋានជាបុត្រមនុស្ស គឺអង្គព្រះយេស៊ូវគ្រីស្ទ ដែលត្រូវបានគេហៅថា អេម៉ាញូអែល មានន័យថា ព្រះជាម្ចាស់គង់ជាមួយយើង។ លើសពីការគង់នៅក្នុងចំណោមពួកយើងទៅទៀតនោះ គឺថាទ្រង់បានយាងមកឯពួកយើងទ្រង់មានពេញទៅដោយព្រះគុណ និងសេចក្តីពិត ដើម្បីឲ្យ យើងបានទទួលនូវសេចក្តីស្រឡាញ់ដ៏ឥតលក្ខខណ្ឌរបស់ទ្រង់ចំពោះពួកយើងរាល់គ្នា ជាពិសេសគឺការទទួលនូវព្រះគុណរបស់ទ្រង់។ យើងអាចស្វែងរកព្រះយេស៊ូវឃើញនៅក្នុងសេចក្តីពិត និង សេចក្តីជំនឿពិតនៅក្នុងចិត្ត ព្រោះព្រះអង្គគឺជាផ្លូវ ជាសេចក្តីពិត ហើយជាជីវិត (យ៉ូហាន ១៤:៦)។ អ្វីដែលព្រះអង្គមានព្រះបន្ទូលគឺសុទ្ធតែជាសេចក្តីពិត! ទ្រង់មានព្រះបន្ទូលថា ទ្រង់នឹងគង់នៅជាមួយយើងរហូតអស់កល្បជានិច្ច (ម៉ាថាយ ១:២៣, ២៨:២០) ថែមទៀតផង។ ទ្រង់មានព្រះបន្ទូលទៀតថាទ្រង់បានយាងមកគឺដើម្បីស្វែងរក និងសង្គ្រោះអ្នកដែលបាត់បង់ (លូកា ១៩:១០)។ ព្រះអង្គមានព្រះបន្ទូលថា កូនអើយ! កូនបានរួចពីជរាពិការហើយ (លូកា ១៣:១២)។

ទ្រង់ក៏មានព្រះបន្ទូលដែរថា ជីវិតអស់កល្បជានិច្ចគឺជារបស់យើង បើយើងមានសេចក្តីជំនឿថាព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះនៃពិភពលោកនេះ (យ៉ូហាន ៣:១៦-១៧)។ ព្រះបន្ទូលរបស់ទ្រង់គឺជា សេចក្តីពិត ហើយសេចក្តីពិតនោះនឹងប្រោសឲ្យអ្នករាល់គ្នាបានរួច។ (យ៉ូហាន ៨:៣២)។ សេចក្តីពិតរបស់ព្រះជាម្ចាស់ បានបើកសម្តែងអំពីព្រះគុណ និង ព្រះអំណោយទាននៃក្តីស្រឡាញ់របស់ទ្រង់សម្រាប់យើងរាល់គ្នា។

ចូរសរសេរខ ១៤ ទុកនៅលើក្រដាសកត់ចំណាំរបស់លោកអ្នកក្នុងខណៈពេលដែល បន្តការសិក្សាព្រះគម្ពីរដំណឹងល្អរបស់អ្នក។ ចូរឲ្យបចម្រើនឡើងក្នុងការយល់ដឹងរបស់អ្នកអំពី សេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់សម្រាប់លោកអ្នកតាមរយៈព្រះយេស៊ូវដែលទ្រង់មានពេញទៅដោយព្រះគុណ និងសេចក្តីពិត។

## ការរំលឹកឡើងវិញ៖

ព្រះយេស៊ូវបានយាងមកក្នុងឋានៈជាកូនច្បងនៃព្រះវរបិតា! ព្រះនាមរបស់ព្រះអង្គបានប្រាប់យើងថាទ្រង់គឺជានរណា ហើយមានបេសកកម្មធ្វើអ្វីខ្លះនៅលើផែនដីនេះ។ ដូច្នេះ ចូរធ្វើការរំលឹកឡើងវិញអំពីព្រះនាមទ្រង់ខ្លះ ហើយនិងអ្វីដែលគេបានប្រាប់យើងអំពីទ្រង់។

| **ព្រះនាម** | **អត្ថន័យ និង បេសកកម្ម** |
| --- | --- |
| ព្រះយេស៊ូវ | |
| ព្រះគ្រីស្ទ | |
| អេម៉ាញូអែល | |
| ព្រះបុត្រានៃព្រះដ៏ខ្ពស់បំផុត | |
| ព្រះបុត្រានៃព្រះ | |

បន្ថែមពីលើព្រះនាមដែលបានរៀបរាប់ខាងលើនេះ អ្នកសរសេរព្រះគម្ពីរដំណឹង យ៉ូហាន បាននិយាយថា ព្រះយេស៊ូវគឺជាព្រះបន្ទូល ហើយព្រះបន្ទូលនោះឯងគឺជាព្រះជាម្ចាស់ដែលគ្មាននរណាបង្កើតទ្រង់ឡើង ប៉ុន្តែ អ្វីៗទាំងអស់ត្រូវបានកើតមកដោយសារទ្រង់វិញ។ (យ៉ូហាន ១:១-៣)

# មេរៀនទី ១ - ផ្នែកទី ៤

## សេចក្តីណែនាំ:

យើងទាំងអស់គ្នាបានត្រៀមខ្លួនរួចរាល់ជាស្រេចក្នុងការចងចាំសាច់រឿងណាមួយឲ្យបានច្បាស់។ ចំពោះគ្រីស្ទបរិស័ទមួយចំនួនធំនៅទូទាំងសកលលោកនោះ ពួកគេចាំច្បាស់ជាងគេគឺរឿងក្នុងថ្ងៃណូអែល ដែលឪពុក ម្តាយតែងតែត្រូវបាននិទានរឿងកំណើតកូនច្បង គឺព្រះយេស៊ូវឲ្យកូនៗរបស់ពួកគេស្តាប់។

## កិច្ចការ:

ចូរអានព្រះគម្ពីរ លូកា ២:១-៧ ក្នុងខណ:ពេលដែលលោកអ្នកកំពុងអានដំណើររឿងនោះ ចូរធ្វើការកត់សំគាល់នូវរឿងរ៉ាវផ្សេងៗពីគ្នាដែលព្រះវរបិតាចង់ប្រាប់ដល់យើង:

- ស្ថានភាព និង កាល:ទេស:នានានៅជុំវិញការចាប់កំណើតរបស់ព្រះរាជបុត្រាទ្រង់
- ការអបអរសាទរនៃពួកស្ថានសួគ៌ និង
- ការឆ្លើយតមចំពោះដំណឹងល្អ

## លំហាត់:

1. ទឹកដីនៃប្រទេសអ៊ីស្រាអែលទាំងមូលត្រូវបានត្រួតត្រាដោយពួករ៉ូម៉ាំង។ តើនរណាជាអ្នកកាន់កាប់អំណាចធំជាងគេនៅក្នុងរជ្ជកាលនោះ (ខ១)? ______________________________

   ______________________________

2. តើសេសារ អូគូស្ទ បានចេញរាជសារឲ្យប្រជារាស្ត្រទាំងអស់ទៅធ្វើអ្វី (ខ១)? ______________

   ______________________________

3. អ្នកសរសេរព្រះគម្ពីរដំណឹងល្អ លូកា បានកំណត់ទុកអំពីពេលវេលាដែលព្រះយេស៊ូវប្រសូតរួចជាស្រេច។ ដោយយោងទៅតាមខ ២ តើមានកត់ត្រាខុសគ្នាអំពីពេលវេលាដែលព្រះយេស៊ូវត្រូវប្រសូតយ៉ាងដូចម្តេច? ______________________________

   ______________________________

   សេសារ អូគូស្ទ (ចក្រភពរ៉ូម៉ាំង) និង គីរេនាស (សេរី) បានកំណត់ឆ្នាំនោះដើម្បីធ្វើជំរឿនប្រជាជនប្រាកដមែន។ ការធ្វើជំរឿនគឺក្នុងគោលបំណងដើម្បីប្រមូលពន្ធ ពីព្រោះប្រជារាស្ត្រអ៊ីស្រាអែល មិនតម្រូវឲ្យចូលបម្រើកងទ័ពស្ថិតនៅក្រោមការត្រួតត្រារបស់រ៉ូម៉ាំងឡើង។

4. តើម្នាក់ៗត្រូវទៅចុះឈ្មោះធ្វើជំរឿននៅឯណា (ខ៣)? ______________________________

   ______________________________

5. តើសេចក្តីប្រកាសនោះមានអត្ថន័យដូចម្តេចចំពោះយ៉ូសែប (២៤)? ចូរតាមដានតាមផែនទីនៃការធ្វើដំណើររបស់គាត់។ ព្ទ

   ក. តើគាត់រស់នៅឯណា? ក្នុងស្រុកណា? ____________________

   ខ. តើពួកប៉ាលេស្ទីនរស់នៅក្នុងតំបន់ណា? ____________________

   គ. តើគាត់ត្រូវទៅចុះឈ្មោះធ្វើជំរឿននៅណា? ____________________

   ឃ. ហេតុអ្វីបានជាគាត់ត្រូវទៅចុះឈ្មោះនៅក្នុងស្រុកមួយជាក់លាក់ដូច្នេះ? ____________________

   ____________________

6. តើសេចក្តីប្រកាសនោះមានអត្ថន័យដូចម្តេចចំពោះនាងម៉ារី (២៥)? ____________________

   ____________________

   ____________________

**សំគាល់:** ការធ្វើដំណើរពីភូមិណាសារ៉ែត ទៅកាន់ភូមិបេថ្លេហិមយ៉ាងហោចណាស់ត្រូវចំណាយពេលបីថ្ងៃ។ មនុស្សស្រីចាប់ពីអាយុ ១២ ឆ្នាំឡើងទៅ និងអ្នកមានអាយុច្រើនជាងនេះគឺតម្រូវឲ្យចុះឈ្មោះដើម្បីធ្វើជំរឿន និង បង់ជាចាំបាច់។

7. ក្នុងអំឡុងពេលដែលយ៉ូសែប និង ម៉ារីទៅដល់ភូមិបេថ្លេហិម តើមានអ្វីកើតឡើង (២៦)? ____________________

   ____________________

   ____________________

   នៅក្នុងខ ៧: ហើយនាង____________________ ជា ____________________ រួច ____________________ ដាក់____________________ ពីព្រោះ____________________ គ្មាន____________________ ទេ។

## ការឆ្លុះបញ្ចាំង:

- ចូរចំណាយពេលមួយសន្ទុះ ហើយចូរពិចារណាដល់ពេលវេលានៃសេចក្តីប្រកាសនោះវាកាន់តែជិតមកហើយ វាហាក់ដូចជាឃោរឃៅចំពោះយ៉ូសែប និង ម៉ារីពេលហើយ។ ____________________

  ____________________

  ____________________

  ____________________

- មិនបាច់សង្ស័យអ្វីឡើយ! ក្រុមគ្រួសារនៅក្នុងភូមិណាសារ៉ែតប្រាកដជាបានដឹងជាមុនរួចទៅហើយ អំពីពេលវេលាដែលនាងម៉ារីសម្រាលនោះ។ នាងម៉ារីកំពុងមានផ្ទៃពោះជិតគ្រប់ខែបែបនេះ គឺមិនមែនជាការងាយស្រួលទេ ហើយនឹងងឿយឆ្ងល់ថាតើការធ្វើដំណើរនេះ វាពិតជាចាំបាច់ឬយ៉ាងណា បើពេលវេលាវាកាន់តែជិតណាស់ទៅហើយ។ វាគឺជាការពិតណាស់ហើយ ដែលនាងម៉ារីទន្ទឹងរង់ចាំថ្ងៃដែលត្រូវសម្រាលរបស់នាង! ចំណែកឯយ៉ូសែបវិញ ប្រហែលជាគាត់បានរៀបចំផែនការណ៍ចំពោះអ្វីគ្រប់យ៉ាងដោយប្រុងប្រយ័ត្នជាក់ជាមិនខានឡើង ជាមួយគ្នានោះដែរ គាត់ប្រហែលជាត្រូវយកស្ត្រីៗដែលមានជំនាញខាងឆ្មបពីរ ឬ បីនាក់ទៅជាមួយគាត់ដែរហើយ។ តើនឹងមានអ្វីកើតឡើងខ្លះនៅក្នុងគំនិត បើសិនជាលោកអ្នកត្រូវបានរួមដំណើរជាមួយនឹងពួកគេនៅពេលនោះដែរ? ____

___________________________________________

___________________________________________

___________________________________________

- ព្រះជាម្ចាស់ប្រព្រឹត្តដូច្នេះ គឺដោយមានគោលបំណង! ចូរពិចារណាអំពីបទទំនាយតាមរយៈហោរាមីកា នៅក្នុងព្រះគម្ពីរ មីកា ៥:២។ ចូរសរសេរខនោះសារវិញ។ ____________________

___________________________________________

___________________________________________

- តើអ្នកដែលត្រូវគ្រងរាជ្យលើសាសន៍អ៊ីស្រាអែល នៅជំនាន់នោះ ដែលមានតាំងពីអស់កល្បរៀងមកបានប្រសូតនៅឯណា? តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យបានសម្រេចតាមបទទំនាយរបស់ពួកហោរាដែលបានទាយទុកនោះ?____________________________________

___________________________________________

___________________________________________

- តើព្រះជាម្ចាស់ប្រើអ្នកគ្រងអំណាចដែលមិនគួរជឿមួយនេះ ដើម្បីសម្រេចបំណងព្រះហឫទ័យដ៏សុចរិតរបស់ទ្រង់បានដោយរបៀបណា? ________________________________

___________________________________________

___________________________________________

- តើនៅក្នុងព្រះគម្ពីរ លូកា ២:៧ ប្រាប់យើងអំពីលក្ខណ្ឌបែបណាដែលព្រះយេស៊ូវបានប្រសូតមក?

___________________________________________

___________________________________________

## ការឆន្ទេញចងចាំ:

ព្រះយេស៊ូវបានយាងមកនៅក្នុងសណ្ឋានធម្មជាតិនៃព្រះ យើងបានសិក្សាឃើញថាទ្រង់មានចេតនាលះបង់អ្វីគ្រប់យ៉ាងដើម្បីឱ្យយើងអាចមានអ្វីៗគ្រប់យ៉ាងទាំងអស់នោះវិញ។ ទ្រង់បានយាងមកលើផែនដីនេះដោយគ្មានអ្វីទាំងអស់ ទ្រង់បានប្រសូតមកនៅក្នុងក្រោលសត្វ ក្នុងសភាពក្រីក្រ ព្រោះថានៅភូមិបេថ្លេហិមគ្មានសល់បន្ទប់ណាមួយនៅសំណាក់ទ្រង់ប្រសូតឡើយ។ លោកសាវ័ក ប៉ូល បានប្រាប់យើងតាមរយៈព្រះគម្ពីរ ២ កូរិនថូសទី ៨:៩ ថា "ដ្បិតអ្នករាល់គ្នាបានស្គាល់ព្រះគុណនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ ថាទោះបើទ្រង់ជាសេដ្ឋីក៏ដោយ គង់តែទ្រង់បានត្រឡប់ជាក្រ ដោយព្រោះអ្នករាល់គ្នា ដើម្បីឲ្យអ្នករាល់គ្នាបានមានឡើង ដោយសារសេចក្តីក្រីក្ររបស់ទ្រង់។"

ចូរសរសេរខនេះទុកក្នុងក្រដាសកត់ចំណាំ ដើម្បីទុកជាផ្នែកមួយនៃការចងចាំនៅក្នុងបណ្ណាល័យរបស់អ្នក។ ចូររកឲ្យឃើញនូវភាពសំបូរហូរហៀរក្នុង ជំនាន់របស់លោកអ្នកមើល៍! វាគឺជាគ្រាដែលសំបូរទៅដោយសេចក្តីស្រឡាញ់ ការប្រណីសន្តោសរបស់ព្រះជាម្ចាស់ចំពោះលោកអ្នក ដូច្នេះ ឆ្លៀតក្នុងឱកាសនេះ ចូរអរព្រះគុណដល់ទ្រង់! ហើយត្រូវទូលសូមដល់ទ្រង់អំពីការដែលព្រះអង្គបាន យាងមកដើម្បីបម្រើនៅក្នុងភាពក្រីក្រ យ៉ាងនោះប្រយោជន៍ឲ្យលោកអ្នក អាចស្ម័គ្រចិត្តបម្រើដល់អ្នកដទៃទៀតឲ្យកាន់តែខ្លាំងជាងនេះទៀតផងដែរ នោះពួកគេនឹងបានស្គាល់ព្រះយេស៊ូវគ្រីស្ទ ហើយអាចទទួលទ្រង់ទុកជាព្រះអម្ចាស់ និងជាព្រះអង្គសង្គ្រោះរបស់ពួកគេដែរ។

# មេរៀនទី ១ - ផ្នែកទី ៥

## សេចក្តីណែនាំ:

សាច់រឿងអំពីថ្ងៃបុណ្យណូអែលនៅតែបន្ត! វាពាក់ព័ន្ធជាមួយនឹងសេចក្តីប្រកាសផង និងការអបអរសាទរផង! ក្នុងខណៈពេលដែលលោកអ្នកបានអានបទគម្ពីរបន្ទាប់ទៅទៀតនេះ ចូរព្យាយាមរកមើលឲ្យឃើញនូវការរំភើបចិត្តមួយចំនួនដែលនឹងត្រូវបន្ត។ ព្រះយេស៊ូវជាអ្នកដែលត្រូវបានគេតាំងឡើងគឺជាព្រះមេស្ស៊ីត្រូវបានប្រសូតមកហើយ។ ប្រសិនបើលោកអ្នកនឹងត្រូវប្រកាសអំពីកំណើតនៃកូនរបស់លោកអ្នកតើនឹងគួត្រូវមានការអបអរសាទរដោយរបៀបណា? ប្រសិនបើជាការចាំបាច់តម្រូវឲ្យពិភពលោកទាំងមូលនេះដឹង តើលោកអ្នកគួតែប្រាប់ដល់អ្នកណា? តើលោកអ្នកនឹងប្រកាសដំណឹងនេះយ៉ាងដូចម្តេច? ឬក៏ត្រូវបង្ហោះនៅលើបណ្តាញសង្គមហ្វេសប៊ុក? ឬក៏ត្រូវបង្ហោះតាម Twitter? តើលោកអ្នកនឹងបង្កើតជាវីដេអូខ្លីមួយដើម្បីប្រកាសអំពីកំណើតរួចបង្ហោះនៅលើ YouTube? ចូរពិចារណាពីអ្វីដែលព្រះវរបិតាជាម្ចាស់បានជ្រើសរើសមធ្យោបាយក្នុងការប្រកាសដំណឹងនេះ។

## កិច្ចការ:

ចូរអានព្រះគម្ពីរ លូកា ២:១០-២០

- តើនរណាគឺជាអ្នកប្រកាសដំណឹង?
- តើដំណឹងនេះត្រូវបានប្រកាសប្រាប់ដល់នរណាមុនគេ?
- តើមានការឆ្លើយតបចំពោះដំណឹងនេះយ៉ាងដូចម្តេច?

## លំហាត់:

1. តើនៅក្នុងខ ៨ បានប្រាប់យើងដូចម្តេច? រីឯនៅ_______________________________
   មាន_________________ ដែលចាំយាមរក្សាហ្វូងចៀមរបស់ខ្លួននៅឯវាល __________
   **សំគាល់:** ទោះបីជាខគម្ពីរមិនបាននិយាយថា គង្វាលទាំងនោះត្រូវមើលឃ្វាលហ្វូងចៀមរបស់ពួកគេឲ្យបានល្អដូចជាអ្នកដែលនៅចាំយាមក្នុងព្រះវិហារដែរ ព្រោះថាចៀមទាំងនេះត្រូវបានគេឃ្វាលបានល្អឥតខ្ចោះ ដោយគ្មានកន្លែងណាបន្ទោសបានឡើយ។ ការនេះបានធ្វើឱ្យមានការចាប់អារម្មណ៍ដើម្បីពិចារណាមើលថា ហេតុអ្វីបានជាព្រះវរបិតាបានជ្រើសរើសពួកអ្នកគង្វាលចៀមដើម្បីប្រកាសអំពីកំណើតនៃព្រះរាជបុត្រាទ្រង់ទៅយ៉ាងដូច្នេះទៅវិញ។
2. តើនរណាបានលេចមកឯពួកអ្នកគង្វាយចៀម (ខ៩)? ___________________________

   ______________________________________________________________

3. តើមានអ្វីហែរហមជាមួយទេវតានោះ (ខ៩)? ________________________________

________________________________________________________________

4. តើពួកអ្នកគង្វាលចៀមមានប្រតិកម្មយ៉ាងដូចម្តេចចំពោះហេតុការណ៍នោះ? ____________

________________________________________________________________

5. តើទេវតាបានថ្លែងឡើងដំបូងថាយ៉ាងដូចម្តេច (ខ១០)? __________________________

________________________________________________________________

6. ហេតុអ្វីបានជាមិនឲ្យពួកគេភ័យខ្លាច? ______________________________________

________________________________________________________________

________________________________________________________________

7. ព្រះរាជសារគឺជាដំណឹងល្អ! ដ្បិតគឺជាព្រះរាជសារនៃសេចក្តីអំណរដ៏អស្ចារ្យសម្រាប់មនុស្សគ្រប់ៗគ្នា តើព្រះរាជសារនោះមានអត្ថន័យដូចម្តេច (ខ១១)? ______________________________

________________________________________________________________

________________________________________________________________

8. សំនួរទីមួយសម្រាប់ឪពុកម្តាយគ្រប់រូបដែលមានកូនជាលើកដំបូរ គឺត្រូវរកឈ្មោះដាក់ឲ្យកូន។ ចូរសំគាល់អំពីឈ្មោះ (ព្រះនាម) ដែលបានផ្តល់ឲ្យនៅក្នុងខ ១១: ______________________

________________________________________________________________

________________________________________________________________

ចូររំលឹកឡើងវិញអំពីព្រះនាម និង អត្ថន័យ! ចូរអាននៅក្នុងព្រះគម្ពីរម៉ាថាយ ១:២១ ហើយរំលឹកនូវលំហាត់ក្នុងផ្នែកទី២ សារឡើងវិញផង។

9. តើមានទេវតាបានផ្តល់នូវទីសំគាល់បែបណា ដើម្បីឲ្យពួកអ្នកគង្វាលចៀមបានដឹងពីទីកន្លែងដែលព្រះឱរសប្រសូតមកនោះ (ខ១២)? ______________________________________

________________________________________________________________

10. តើបន្ទាប់មកទៀតមានអ្វីកើតឡើង (ខ១៣)?

- នោះស្រាប់តែមាន________________________________ ពីស្ថានសួគ៌មក
- នៅជាមួយនឹងទេវតានោះក៏ពោលសរសើរដល់ព្រះថា ______________________ ___ ហើយនិង ______________________________________________
- "____________________________________________________________ ____________________________________________________________"

11. សេចក្តីប្រកាសអំពីការចាប់កំណើតត្រូវបានត្រាស់ឲ្យមានការឆ្លើយតប។ ចូរស្រមៃអំពីការជជែកគ្នារបស់ពួកអ្នកគង្វាលចៀមបន្ទាប់ពីពួកទេវតាបានត្រឡប់ទៅស្ថានសួគ៌វិញអស់ទៅ។ តើពួកគេត្រូវសម្រេចចិត្តធ្វើដូចម្តេច (២១៥)? ______________________________________

______________________________________

______________________________________

12. ការអបអរសាទរត្រូវបានចាប់ផ្តើមឡើងហើយ! ពួកទេវតាជាច្រើនបានច្រៀងសរសើរដម្កើងទ្រង់ ហើយពេលនេះ ពួកអ្នកគង្វាលចៀមបានប្រញាប់ប្រញាល់ ម្នីម្នារត់ទៅមើលអ្វីដែលបានកើតឡើងតាមដែលព្រះជាម្ចាស់បានប្រាប់ដល់ពួកគេ។ តើពួកគេបានឃើញអ្វី (២១៦)? ____________

______________________________________

តើលោកអ្នកអាចរកឃើញដោយខ្លួនឯង នៃការចូលមកខិតជិតស្នូកសត្វមួយដែលមានសភាពស្ងប់ស្ងាត់នៅក្នុងដួងចិត្តរបស់អ្នកដែរឬទេ? តើលោកអ្នកកំពុងស្វែងរកមើលព្រះរាជបុត្រានៃព្រះវរបិតាដែលជាព្រះអង្គសង្គ្រោះ និងជាព្រះមហាក្សត្ររបស់លោកអ្នកមែនទេ? តើលោកអ្នកបានឃើញព្រះវរបិតាកំពុងតែរេរា និង មានមោទនភាពដែរឬទេ? តើលោកអ្នកបានឮទ្រង់មានព្រះបន្ទូលថា: "ចូរមើល! នេះគឺដូចជាអ្វីដែលយើងបានប្រាប់អ្នករាល់គ្នាហើយ។ ព្រះឱរស គឺជាព្រះរាជបុត្រច្បងរបស់យើងត្រូវបានរុំដោយសំពត់ដាក់ផ្តេកឲ្យផ្ទំនៅក្នុងស្នូកសត្វ" ដែរឬទេ?

## សេចក្តីបង្រៀន:

ឥឡូវនេះ លោកអ្នកអាចនឹងមានអ្វីមួយចំនួនដែលបានផុសចេញនៅក្នុងគំនិតរបស់អ្នកហើយ។ ពិភពលោកនេះនឹងមិនត្រូវបាននៅដដែលទៀតទេ ពីព្រោះថា ព្រះឱរសនេះនឹងចម្រើនវ័យធំឡើង ហើយនឹងក្លាយទៅជាមនុស្សធំម្នាក់។ មិនដែលធ្លាប់មានសេចក្តីប្រកាសណាមួយអស្ចារ្យដែលត្រូវបានប្រកាសឡើងទេពីមុនមក។ មិនត្រឹមតែមានពួកទេវតាចុះមកពីស្ថានសួគ៌ជាច្រើនកុះករដើម្បីច្រៀង សរសើរដម្កើងប៉ុណ្ណោះទេ ប៉ុន្តែ សិរីរុងរឿងរបស់ព្រះអម្ចាស់ក៏បានភ្លឺចិញ្ចែងចិញ្ចាចនៅជុំវិញពួកគេផងដែរ។

តើសិរីរុងរឿងរបស់ព្រះអម្ចាស់នេះគឺជាអ្វីទៅ? នេះគឺជាសិរីរុងរឿងនៃព្រះជាម្ចាស់ដែលត្រូវបានបង្ហាញគ្រប់ភ្នែកប្រជារាស្ត្ររបស់ទ្រង់បានឃើញនូវវត្តមានរបស់ទ្រង់នៅក្នុងចំណោមពួកគេ។ ប្រជារាស្ត្រអ៊ីស្រាអែលធ្លាប់បានឃើញសិរីរុងរឿងរបស់ទ្រង់នៅក្នុងសណ្ឋានជាសសរភ្លើង ក្នុងកាលដែលពួកគេត្រូវរសាត់អណ្តែតអស់រយ:ពេល ៤០ ឆ្នាំនៅក្នុងវាលរហោស្ថានមុនពេលដែលពួកគេបានចូលទៅក្នុងទឹកដីសន្យា។ លោកម៉ូសេបានឃើញសិរីរុងរឿងរបស់ព្រះអម្ចាស់នៅពេលដែលពពកចុះនៅលើព្រះពន្លា ដូចបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរ និក្ខមនំ ៣៣ ព្រះជាម្ចាស់បានផ្តល់ព្រះគុណរបស់ទ្រង់ដល់លោក ម៉ូសេតាមការសន្យាថាវត្តមាន

របស់ទ្រង់នឹងគង់នៅជាមួយនឹងគាត់។ សិរីរុងរឿងនៃព្រះអម្ចាស់ក៏បានលេចមកឯពួកអ្នកគង្វាលចៀមគឺជាការប្រកាសប្រាប់ឲ្យពួកគេដឹងថាវត្តមានរបស់ព្រះជាម្ចាស់គឺគង់នៅជាមួយនឹងព្រះឱរស និងជាមួយព្រះកុមារយេស៊ូវនៅភូមិបេថ្លេហិម។ ដំណឹងល្អនៃសេចក្តីអំណរនោះគឺថាព្រះគុណនៃព្រះជាម្ចាស់បានមកនៅក្នុងព្រះបុត្រារបស់ទ្រង់ត្រូវមករស់នៅក្នុងចំណោមពួកយើងរាល់គ្នា គឺព្រះបុត្រានេះហើយដែលមានពេញដោយព្រះគុណ និងសេចក្តីពិត (យ៉ូហាន ១:១៤)។ ដំណឹងល្អនៃសេចក្តីអំណរដ៏អស្ចារ្យគឺ ថាព្រះជាព្រះវរបិតាបានប្រទានន្ធវព្រះរាជបុត្រាទ្រង់តែមួយទុកជាកូនចៀមយ៉ាងបរិសុទ្ធឥតខ្ចោះមកពីព្រះជាម្ចាស់ដែលឥតបាបសោះ ដើម្បីនាំសន្តិភាព និង សេចក្តីសុខសាន្តមកដែលនឹងឆ្លងកាត់ការយល់ដឹងទាំងអស់ គឺជាសេចក្តីសុខសាន្តដែលនឹងតែងតែនៅជាមួយយើងជាដរាបអស់កល្បជានិច្ច (យ៉ូហាន ២០:១៩) ។

## ការឆ្លុះបញ្ចាំង:

មុនពេលចាកចេញពីសាច់រឿងនៃបុណ្យណូអែលនេះ យើងត្រូវតែយកពេលវេលាខ្លះដើម្បីពិចារណាទៅលើប្រតិកម្មរបស់អ្នកដែលត្រូវបានជាប់ពាក់ព័ន្ធនៅក្នុងការអបអរសាទរ រួមមានពួកទេវតា ពួកអ្នកគង្វាលចៀម អស់អ្នកដែលបានឮដំណឹងអំពីព្រះឱរស និងនាងម៉ារីជាមុនសិន។

- ខ្ញុំមិនដឹងថាអាចធ្វើអ្វីបាននោះទេ តែខ្ញុំគ្រាន់តែញញឹមនៅពេលដែលខ្ញុំគិតដល់ពួកទេវតាទាំងនោះ។ ចូរស្រមៃ ដល់ការរំភើបរីករាយនៅឯ ស្ថានបរមសុខដូចដែលពួកគេនៅតែ សួរគ្នាទៅវិញទៅមកថា "វាដល់ពេលវេលាហើយមែនទេ? តើពួកយើងអាចចេញទៅប្រកាសប្រាប់ពួកអ្នកគង្វាលចៀមបានហើយមែនទេ?" មានពួកទេវតា និង តួអង្គវិញ្ញាណរាប់ពាន់នៅស្ថានបរមសុខបានថ្លែងឡើងថា មានមើលឃើញឬទេ! មានថាមពលខ្លាំងម្ល៉េះណ៎! ពិតជាគួឲ្យរំភើបចិត្តមែន! ពួកគេបានរង់ចាំពេលវេលាដែលត្រូវប្រកាសប្រាប់ដំណឹងអំពីការយាងមករបស់ព្រះសង្គ្រោះជាយូរណាស់មកហើយ។ គឺស្ទើរតែគ្រប់មនុស្សទាំងអស់ មានអារម្មណ៍រង់ចាំអំណោយថ្ងៃបុណ្យណូអែលល្អឥតខ្ចោះរបស់ពួកគេពីនរណាម្នាក់ ប៉ុន្តែបានតែអង្គុយរង់ចាំនៅក្រោមដើមឈើណូអែលដោយសារតែពេលវេលានោះមិនទាន់មកដល់នៅឡើយ!
- ចុះចំណែកឯពួកអ្នកគង្វាលចៀមទាំងអស់នោះវិញ? ព្រះអម្ចាស់ធ្វើឱ្យខ្ញុំដូចជាពួកអ្នកគង្វាលចៀមទាំងនោះដែរ គឺស្ម័គ្រចិត្តទុកអ្វីៗទាំងអស់ ហើយព្រមទៅតាមការអញ្ជើញរបស់ទ្រង់ដើម្បីទៅឯស្នូកសត្វឲ្យបានឃើញព្រះអំណោយទាននៃព្រះគុណរបស់ទ្រង់សម្រាប់មនុស្សលោកទាំងអស់។ ពេលខ្លះវាហាក់ដូចជាព្រះឱរសនោះត្រូវបានវង្វេងបាត់ ហើយយើងត្រូវទៅតាមរកវិញដោយត្រូវត្រឡប់ទៅកាន់ភូមិបេថ្លេហិមដើម្បីរកមើលសារជាថ្មីម្តងទៀត។ ប៉ុន្តែពួកអ្នកគង្វាលទាំងនោះមិនគ្រាន់តែបានចូលទៅ ហើយ មើលឲ្យដឹងរឿងរ៉ាវគ្រប់យ៉ាងដោយខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែបន្ទាប់ពីនោះមក

ពួកគេបានវិលត្រឡប់ទៅឯវាលដើម្បីមើលថែរក្សាហ្វូងចៀមរបស់ខ្លួនវិញ។ ព្រះអម្ចាស់ធ្វើឱ្យខ្ញុំដូចជាពួកអ្នកគង្វាលនោះដែរ គឺជាអ្នកផ្សព្វផ្សាយគ្រប់អ្វីៗអំពីព្រះឱរសនេះ (ខ ១៧)។ ដំណឹងល្អរបស់ព្រះជាម្ចាស់ គឺមិនមែនគ្រាន់តែសម្រាប់ខ្ញុំប៉ុណ្ណោះទេ តែសម្រាប់គ្រប់មនុស្សទាំងអស់ដែរ (ខ១៤)។ នៅក្នុងខ ២០ បានប្រាប់យើងឲ្យដឹងថា ពួកអ្នកគង្វាលចៀមបានវិលត្រឡប់ទៅវិញ ________ ____________________________________________________ ហើយ ____________________________________________________។ ព្រះ

ដូចអ្វីដែលពួកគេបានឮ និង ឃើញគឺថាជាម្ចាស់គឺសម្រាប់គ្រប់អ្វីៗទាំងអស់! តើព្រះឱរសនឹងធ្វើឲ្យមានការផ្លាស់ប្រែនៅក្នុងជីវិតរបស់ខ្ញុំយ៉ាងដូចម្ដេច? តើខ្ញុំនឹងវិលត្រឡប់ពីស្នូលសត្វដែលព្រះឱរសផ្ទុំនោះវិញ ដោយការថ្វាយសិរីរុងរឿង និង សរសើរដម្កើងដល់ព្រះជាម្ចាស់អំពីគ្រប់អ្វីៗដែលខ្ញុំបានឮ និង ឃើញដែរឬទេ?

- ចំពោះអស់អ្នកណាដែលពួកអ្នកគង្វាលបានប្រាប់គឺសុទ្ធតែបានឆ្លើយតបវិញទាំងអស់។ នៅក្នុងខ ១៨ បានប្រាប់ថា អស់អ្នកដែលបានឮអ្វីដែលពួកអ្នកគង្វាលបានប្រាប់ពួកគេ _____________ ____________________________________________________

ជួនកាល យើងហាក់ដូចជាត្រូវជាប់កាំងឈឹងដោយសេចក្តីងឿយឆ្ងល់ ហើយត្រូវរស់នៅជាមួយនឹងអាកប្បកិរិយាមួយ ‟វាពិតជាល្អណាស់″។ យើងមិនបានសម្រេចចិត្តថាព្រមជឿ ឬមិនជឿនៅឡើយមែន តែទោះបីជាយ៉ាងណាក៏ដោយ យើងនៅតែឆ្លើយតបចំពោះដំណើររឿងនោះវិញថា ‟ដែលជាការល្អណាស់ យើងនឹងត្រឡប់មកវិញម្តងទៀតនៅឆ្នាំក្រោយដើម្បីស្តាប់រឿងនេះ ហើយនិងច្រៀងបទ ខារ៉ូល (Carol) ជាមួយគ្នាទៀត″។

- ជាចុងបញ្ចប់នេះ យើងនឹងអាចខ ១៩នេះ

តែម៉ារី នាង _________________ ទាំងនោះ ដោយ_________________________

គិតតែ________________________________________________________

ពាក្យទាំងនេះបានធ្វើឱ្យយើងឆ្ងល់ថាតើនាងបានដឹងអ្វីដែលយើងធ្វើមិនបានដឹង។ នាងមិនមានរូបថត ឬសៀវភៅកម្រងណាមួយដើម្បីជួយឱ្យនាងផ្គុំចូលគ្នាខែ និង ថ្ងៃចុងក្រោយទេ។ ជីវិតរបស់នាងគឺក្នុងរយៈពេល ៩ ខែចុងក្រោយនេះបានធ្វើឲ្យនាងមានការភ្ញាក់ផ្អើលអំពីសកម្មភាព និងការអស្ចារ្យមួយនេះជាខ្លាំង។ ហើយឥឡូវនេះទារកក្នុងផ្ទៃរបស់នាងត្រូវបានប្រសូតហើយ! គឺប្រសូតបានកូនប្រុសម្នាក់ពិតប្រាកដមែន! ហើយជាធម្មតាទារក គឺត្រូវការមើលបីបាច់រក្សាថែទាំ ត្រូវការសេចក្តីស្រលាញ់ថ្នាក់ថ្នម ដូចជាទារកដទៃៗទៀតដែរ ប៉ុន្តែចំពោះទារកមួយនេះ គឺជាកូនរបស់មនុស្សផង និង ជាព្រះរាជបុត្រានៃព្រះជាម្ចាស់ផងដែរ។

តើមានន័យដូចម្ដេចដែលថា ទ្រង់នឹងសង្គ្រោះប្រជារាស្ត្ររបស់ព្រះអង្គឲ្យរួចពីអំពើបាបរបស់ពួកគេនោះ? តើតម្រូវឲ្យទ្រង់មានការស្ដាប់បង្គាប់តាមព្រះវរបិតា និង ស្ដាប់បង្គាប់នាង ម៉ារីជាមាតាទ្រង់យ៉ាងដូចម្ដេច?

## សំនួរអនុវត្តន៍:

1. ព្រះវរបិតាបានប្រទានព្រះអំណោយមួយយ៉ាងល្អឥតខ្ចោះ គឺជាព្រះរាជបុត្រារបស់ទ្រង់ផ្ទាល់តែម្ដង។ ទ្រង់បានប្រទានព្រះរាជបុត្រារបស់ទ្រង់មកសម្រាប់យើងម្នាក់ៗ ទទួលយកទ្រង់ដាក់ក្នុងជីវិត ដោយសកម្មភាពនៃព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ ឬ ដើម្បីបដិសេធចោលតាមការជ្រើសរើសផ្ទាល់ខ្លួនរបស់យើងម្នាក់ៗ។ តើអ្នកនឹងមានអារម្មណ៍ដូចម្ដេចនៅពេលដែលទទួលបានអំណោយមួយយ៉ាង "ល្អឥតខ្ចោះ"? ______________________________________________

______________________________________________

______________________________________________

2. អំណោយទានរបស់លោកអ្នក គឺមិនមានតម្លៃថោកនោះទេ ប៉ុន្តែតម្រូវឱ្យលោកអ្នកលក់អ្វីៗទាំងអស់ដើម្បីទិញវាបាន។ ចំណែកឯព្រះអំណោយទានរបស់ព្រះវរបិតាវិញ គឺបានតម្រូវឲ្យទ្រង់ប្រទានព្រះរាជបុត្រាទ្រង់តែមួយគត់ ទោះបីជាត្រូវពលីជីវិតហួតដល់ស្លាប់ក៏ដោយ។ តើលោកអ្នកអាចនឹងយកអ្វីមួយដែលមានតម្លៃទៅជំនួសព្រះអំណោយទានរបស់ទ្រង់បាន? តើទ្រង់បានផ្ដល់តម្លៃប៉ុណ្ណាទៅលើលោកអ្នក និង អស់អ្នកណាដែលបានទទួលព្រះអំណោយទានមួយនេះ? ____________

______________________________________________

______________________________________________

______________________________________________

3. នៅពេលណាដែលបានទទួលដំណឹងល្អនេះហើយ លោកអ្នកប្រាកដជាមានការភ្ញាក់ផ្អើល ហើយត្រូវជាប់កាំងជាមិនខានឡើយ។ ចូរសរសេរខគម្ពីរ យ៉ូហាន ៣:១៦-១៧ ទុកនៅក្នុងសៀវភៅរបស់លោកអ្នក។ ______________________________________________

______________________________________________

______________________________________________

ឬ លោកអ្នកប្រៀបបីដូចជាពួកអ្នកគង្វាលចៀមដែរ ដោយប្រាប់ដល់មនុស្សគ្រប់ៗគ្នា អំពីអ្វីដែលលោកអ្នកបានឃើញ និង បានឮ។ ចូរសរសេរនូវខគម្ពីរ ម៉ាកុស ១៦:១៥-១៦ ____________

______________________________________________

# មេរៀនទី ២

## មេរៀនទី ២ - ផ្នែកទី ១

### សេចក្តីណែនាំ:

ប្រពៃណីបាននាំមនុស្សជឿថាម៉ាហ្គី (Magi) ឬមនុស្សដែលមានប្រាជ្ញាពីខាងកើតមករកព្រះយេស៊ូវនៅភូមិបេថ្លេហិមនៅយប់មួយដែលទ្រង់បានប្រសូតមក។ ទោះជាយ៉ាងណា បើតាមការសន្និដ្ឋាន ហោរាទាំងបីនាក់នេះបានមកពីតំបន់ឈូងសមុទ្រពែក ភាគខាងកើតនៃប្រទេសប៉ាឡេស្ទីន ហើយពួកគេត្រូវបានធ្វើដំណើរអស់ជាច្រើនខែដើម្បីមកតាមរកព្រះឱរសយេស៊ូវដែលត្រូវប្រសូតមក។ វាអាចកត់សម្គាល់បានថាពួកអ្នកប្រាជ្ញទាំងនេះ បានមកដល់នៅបន្ទាប់ពីព្រះយេស៊ូវបានប្រសូតមកអស់រយៈពេលជាច្រើនខែ។ តាមរយៈកំណត់ហេតុរបស់លោក លូកានឹងជយយបំពេញឲ្យយើងចំណុចលំអិតខ្លះៗដែលបានកើតឡើងក្នុងមួយសប្តាហ៍ដំបូងបន្ទាប់ពីព្រះយេស៊ូវបានប្រសូតមក។ តទៅនេះយើងនឹងចាប់ផ្តើមពិនិត្យមើលទៅលើកំណត់ហេតុរបស់លោក ម៉ាថាយដែលបានរៀបរាប់អំពីការមកអំពីពួកម៉ាហ្គីទាំងបីនាក់នេះ។

### កិច្ចការ:

ចូរអានព្រះគម្ពីរ ម៉ាថាយ ២:១-១២

- តើមានអ្វីបង្ហាញផ្លូវដល់ពួកម៉ាហ្គី ឲ្យបានមកដល់ទីក្រុងយេរ៉ូសាឡឹម?
- ហេតុអ្វីបានជាពួកគេធ្វើដំណើរមកកាន់ទីក្រុងយេរ៉ូសាឡឹម?
- តើយើងបានសិក្សាអំពីស្តេចហេរ៉ូដដូចម្តេចខ្លះ?

### លំហាត់:

1. តើនៅក្នុងខ ១ បានប្រាប់យើងអំពីអ្វីខ្លះ?
   ក. តើដំណើររឿងបានកើតឡើងយ៉ាងដូចម្តេច? ____________________

   ____________________

   ខ. តើនរណាគឺជាស្តេច? ____________________

   គ. តើនរណាបានមកដល់ទីក្រុងយេរូសាឡឹមពីទិសខាងកើត? ____________________

   ____________________

2. នៅពេលដែលពួកគេបានមកដល់យេរ៉ូសាឡឹម តើពួកគេត្រូវការអ្វី? ____________________

   ____________________

3. នៅក្នុង២២ ពួកគេ ______________________ របស់ទ្រង់ ____________ ______________________ នៅក្នុង ______________________ ដែលត្រូវ ______________________

ប្រសិនបើពួកហោរាទាំងនេះធ្វើដំណើរនៅលើវាលខ្សាច់នៅពេលយប់ងងឹត នោះពួកគេនឹងបានឃើញពន្លឺផ្កាយមួយយ៉ាងធំដែលភ្លឺយ៉ាងពិសេសជាងផ្កាយដទៃទៀត ដែលពិតជាធ្វើឲ្យពួកគេមានការចាប់អារម្មណ៍។ វាពិតជាគួរឱ្យចាប់អារម្មណ៍ក្នុងការកត់សំគាល់ណាស់ ដែលថាពួកគេកំណត់បានថានោះគឺជា "ផ្កាយរបស់គេ" គឺជាផ្កាយនៃព្រះជាម្ចាស់បាននាំផ្លូវពួកគេឲ្យទៅថ្វាយបង្គំដល់ព្រះមហាក្សត្ររបស់ពួកគេ។

4. តើស្តេចហេរ៉ូដមានប្រតិកម្មយ៉ាងដូចម្តេចនៅពេលដែលបានឮពាក្យសម្តីពួកគេបាននិយាយ (២៣)?

______________________

______________________

**សំគាល់:** ស្តេច ហេរ៉ូដ គឺជាសាសន៍យូដាដែលត្រូវបានតែងតាំងដោយទីចក្រភពរ៉ូមដើម្បីបម្រើជាស្តេចក្នុងស្រុកយូដា។ ស្តេច ហេរ៉ូដ គឺជាអ្នកគ្រប់គ្រងគ្មានចិត្តមេត្តា អាណិតអាសូរឡើយ សូម្បីតែសមាជិកក្រុមគ្រួសាររបស់ខ្លួនឯងក៏ហ៊ានសម្លាប់ដែរ។

5. តើមនុស្សគ្រប់គ្នានៅក្នុងក្រុងយេរ៉ូសាឡឹមមានប្រតិកម្មយ៉ាងដូចម្តេច? ____________

______________________

6. តើស្តេចហេរ៉ូដបានកោះហៅនរណាឲ្យប្រជុំគ្នា (២៤)? ______________________

______________________

ពួកនាយកបូជាចារ្យទាំងនោះគឺជាអ្នកមើលការខុសត្រូវនៅក្នុង ព្រះវិហារនៅក្រុងយេរូសាឡឹមដែលជាកន្លែងដែលពួកសាសន៍យូដាថ្វាយបង្គំព្រះជាម្ចាស់។ គ្រូខាងច្បាប់ ឬពួកសាខូស៊ីត្រូវបានគេចាត់ទុកថាជាអ្នកប្រាជ្ញក្នុងចំណោមពួកសាសន៍យូដា នេះបើតាមព្រះគម្ពីរសញ្ញាចាស់។

7. តើស្តេចហេរ៉ូដបានសួរពួកគេដូចម្តេច (២៤)? ______________________

______________________

8. តើពួកគេបានទូលស្តេចហេរ៉ូដយ៉ាងដូចម្តេច (២៥)? ______________________

______________________

តើពួកគេអាចដឹងបានដោយរបៀបណា (២៦)? ______________________

______________________

ចូរមើលទៅខយោង ថាតើបានសរសេរនៅត្រង់កន្លែងណា? ______________________

៩. ឥឡូវនេះ ស្តេចហេរ៉ូដតែមួយអង្គឯងប៉ុណ្ណោះដែលនៅជាមួយពួកម៉ាហ្គី។ តើស្តេច ហេរ៉ូដ បានសួរពួកគេយ៉ាងដូចម្តេចខ្លះ (៧)? ______________________________

______________________________

______________________________

រួចក្រោយមក ពួកគេក៏ចេញដំណើរសំដៅទៅកាន់ភូមិបេថ្លេហិម (៨) តើពេលនោះ ស្តេចហេរ៉ូដ បានសុំឲ្យពួកគេធ្វើអ្វីសម្រាប់ទ្រង់? ______________________________

______________________________

______________________________

## ការឆ្លុះបញ្ចាំងៈ

មុននឹងយើងបន្តសាច់រឿងតទៅមុខទៀត យើងឆ្លៀតក្នុងឱកាសមួយដ៏ខ្លីមួយនេះដើម្បីធ្វើការការឆ្លុះបញ្ចាំងបន្តិចសិន។ ដំបូងឡើយពួកម៉ាហ្គី បានទទូចចង់ដឹងថាតើព្រះឱរសដែលត្រូវប្រសូតមកដើម្បីគ្រងរាជ្យធ្វើជាស្តេចលើសាសន៍យូដានោះគង់នៅឯណា ព្រោះពួកគេបានឃើញផ្កាយរបស់ទ្រង់នៅទិសខាងកើតមក។ គ្រាន់តែពួកគេបានមកដល់ក្រុងយេរូសាឡឹមភ្លាម នោះពួកគេក៏សួរឡើងថា "តើព្រះឱរសដែលបានប្រសូតមកធ្វើជាស្តេចលើសាសន៍យូដាទ្រង់គង់នៅឯណា? ទ្រង់នៅឯណា? យើងអាចរកទ្រង់ឃើញនៅឯណា? ពួកយើងចង់ឃើញទ្រង់ណាស់ ពួកយើងចង់ទៅក្រាបថ្វាយបង្គំទ្រង់ ហេតុដូច្នេះហើយទើបបានជាពួកយើងបានធ្វើដំណើរមក។ នោះហើយជាមូលហេតុដែលយើងបាន ធ្វើដំណើរមកអស់ជាច្រើនសប្តាហ៍ទើបពួកយើងបានមកដល់ទីនេះ។ ពួកគេមាននៅតែបន្តតាមស្វែងរកព្រះយេស៊ូវ រហូតទាល់តែបានរកឃើញ ហើយក្រាបថ្វាយបង្គំព្រះអង្គទើបពួកគេព្រមសុខចិត្តចាកចេញពីទីក្រុងនោះ។

តើខ្ញុំបានស្វែងរកព្រះឱរសយេស៊ូវយ៉ាងឧស្សាហ៍ខ្នះខ្នែងដូចជាពួកម៉ាហ្គីដែរទេ? តើការចង់ដឹង ចង់ឃើញហើយចង់ជួបរបស់ខ្ញុំត្រឡប់ទៅជាការប្តេជ្ញាចិត្តឬយ៉ាងណា? ពួកគេបានដឹងអំពីទីកន្លែងដែលទ្រង់គង់នៅគឺដោយសារតែពួកព្យាការីបានសរសេរទុកអំពីទ្រង់ និង អំពីការចាប់កំណើតរបស់ទ្រង់តាំងពីយូរលង់ណាស់មកហើយ។ តើខ្ញុំបានដឹងពីទីកន្លែងដែលត្រូវទៅរកទ្រង់ដែរឬទេ? តើខ្ញុំមានចិត្តឧស្សាហ៍ព្យាយាមក្នុងការស្វែងរកទ្រង់ដែរទេ? តើខ្ញុំរំពឹងថានឹងរកឃើញទ្រង់នៅទីកន្លែងណា? ព្រះអង្គបានបើកសម្តែងនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ តើខ្ញុំរំពឹងថានឹងស្វែងរកទ្រង់ឃើញ ឬមួយខ្ញុំកំពុងតែស្វែងរកទ្រង់នៅទីកន្លែងណាមួយមិនច្បាស់លាស់ហើយគ្រាន់តែ សង្ឃឹមថានឹងអាចរកទ្រង់ឃើញ?

ពួកម៉ាហ្គីចង់ស្វែងរកទ្រង់ឲ្យឃើញគឺដើម្បីក្រាបថ្វាយបង្គំដល់ទ្រង់។ ចុះចំណែលយើងវិញ តើនឹងត្រូវធ្វើអ្វីនៅពេលដែលបានរកទ្រង់ឃើញ? តើយើងនឹងថ្វាយបង្គំទ្រង់ទុកជាព្រះអង្គសង្គ្រោះ និងជាព្រះមហាក្សត្ររបស់យើងដែរឬយ៉ាងណា? តើយើងនឹងទទួលស្គាល់ទ្រង់ថាជាព្រះមេស្ស៊ីដែលត្រូវបានរើសតាំងឡើងដែរឬទេ? ដូចដែលព្រះជាម្ចាស់បានបើកសម្តែងព្រះបន្ទូលនៃសេចក្តីពិតរបស់ទ្រង់សម្រាប់យើងដែរ តើយើងព្រមទទួលយកសេចក្តីសង្ឃឹម សេចក្តីមេត្តាករុណា និង ជីវិតអស់កល្បជានិច្ចជាមួយនឹងការបន្ទាបខ្លួននៅចំពោះទ្រង់ ដោយការថ្វាយបង្គំទ្រង់ដែរទេ? តើលោកអ្នកគំនិតដូចម្តេចចំពោះការខ្នះខ្នែង ខិតខំស្វែងរករបស់ពួកម៉ាហ្គីដែលបានមកពីទិសខាងកើតដើម្បីបានក្រាបថ្វាយបង្គំដល់ទ្រង់? ____________________

____________________________________________________________________________

____________________________________________________________________________

____________________________________________________________________________

# មេរៀនទី ២ - ផ្នែកទី ២

## សេចក្ដីណែនាំៈ

យើងមិនចាំបាច់ចំណាយពេលវេលាច្រើន ដើម្បីពិនិត្យមើលអំពីការចេញអនុវត្តតាមគម្រោងការសម្លាប់កុមាររបស់ស្ដេចហេរ៉ូឌនោះទេ ពីព្រោះស្ដេចហេរ៉ូឌបានដឹងថាទារកនោះនឹងត្រូវប្រសូតមកដើម្បីធ្វើស្ដេចលើពួកសាសន៍យូដា ហើយស្ដេចហេរ៉ូដក៏បានដឹងពីទីកន្លែងលាក់ខ្លួនរបស់ពួកគេ រួចហើយបានបញ្ជូនពួកម៉ាហ្គីធ្វើដំណើរទៅកាន់ភូមិបេថ្លេហិម។ ស្ដេចហេរ៉ូដបានទុកឱកាសឲ្យពួកគេស្វែងរកទីកន្លែងដែលព្រះឱរសបានស្នាក់នៅ រួចហើយបានផ្ដាំពួកគេថា បើកាលណាបានរកទារកនោះឃើញហើយចូរប្រញាប់រាយការណ៍ទូលទ្រង់ឲ្យបានជ្រាបផង ដើម្បីបានទៅថ្វាយបង្គំព្រះឱរសនោះដែរ។ ប៉ុន្តែ តាមការពិតស្ដេច ហេរ៉ូដ បានមានគម្រោងការសម្លាត់ដ៏អាក្រក់មួយរួចស្រេចទៅហើយ។

## លំហាត់ៈ

1. បន្ទាប់ពីពួកម៉ាហ្គី បានចូលគាល់ស្ដេចហេរ៉ូដរួចហើយ ពួកគេក៏បន្តដំណើររបស់ពួកគេតទៅទៀត។ តើយើងបានដឹងអំពីផ្កាយធំនោះដូចម្ដេចខ្លះ (៩)? ________________________________________

2. ផ្កាយធំនោះបាននាំពួកគេទៅរកទីកន្លែងដែលព្រះឱរសកំពុងស្នាក់នៅ! នៅពេលនោះ តើផ្កាយមានសភាពដូចម្ដេច? ________________________________________

3. នៅទីបំផុតពួកគេក៏បានមកដល់ក្នុងផ្ទះមួយ! នៅពេលដែលពួកគេបានឃើញព្រះឱរស និង នាងម៉ារីជាមាតាទ្រង់ តើពួកគេបានធ្វើអ្វី (១១)? ________________________________________

4. តើបន្ទាប់មកពួកគេបានធ្វើអ្វីទៀត? ________________________________________

5. តើពួកគេបានយកអំណោយអ្វីខ្លះដើម្បីមកថ្វាយដល់ព្រះឱរស?
   ក. ______________________________________________
   ខ. ______________________________________________
   គ. ______________________________________________
6. ការធ្វើដំណើររបស់ពួកគេត្រូវបានបញ្ចប់ដោយជោគជ័យ គឺពួកគេបានតាមស្វែងរកព្រះឱរសនោះឃើញ ហើយក៏បានថ្វាយបង្គំដល់ទ្រង់រួចរាល់ហើយដែរ ដូច្នេះក៏ដល់ពេលវេលាត្រូវវិលត្រឡប់ទៅវិញដែរ។ តើនៅក្នុងខ ១២ បានប្រាប់យើងអំពីការវិលត្រឡប់ទៅវិញរបស់ពួកគេយ៉ាងដូចម្តេច? _
   ______________________________________________
   ______________________________________________

## កិច្ចការៈ

ចូរអានព្រះគម្ពីរ ម៉ាថាយ ២:១៣-២៣

- ទន្ទឹមនឹងនោះដែរ តើមានអ្វីកើតឡើងចំពោះជីវិតរបស់យ៉ូសែប?
- តើព្រះជាម្ចាស់មានផែនការណ៍ដូចម្តេចចំពោះគ្រួសារមួយនេះ?
- តើស្តេចហេរ៉ូដបានធ្វើដូចម្តេច នៅពេលដែលទ្រង់បានជ្រាប់ថា ពួកម៉ាហ្គីមិនបានវិលត្រឡប់មករកទ្រង់វិញនោះ?
- តើព្រះជាម្ចាស់បានណែនាំដល់យ៉ូសែលយ៉ាងដូចម្តេច?

## លំហាត់ៈ

1. ពួកម៉ាហ្គីចេញដំណើរទៅបាត់ហើយ! ហើយក៏មានទេវតាបានលេចមកឯយ៉ូសែបក្នុងសុបិន្ត។ តើទេវតានោះបានបង្គាប់ដល់យ៉ូសែបដូចម្តេច (ខ១៣)? ______________________
   ______________________________________________
   ______________________________________________
2. យ៉ូសែបក៏បានស្តាប់បង្គាប់តាមភ្លាម! យើងអាចដឹងថាគាត់យ៉ូសែប បានធ្វើតាមពាក្យរបស់ទេវតាយ៉ាងបន្ទាន់ដោយរបៀបណា (ខ១៤)? ______________________
   ______________________________________________
   ______________________________________________
3. តើពួកគេត្រូវស្នាក់នៅក្នុងប្រទេសអេស៊ីបយូរប៉ុណ្ណាដែរ (ខ១៥)? ______________
   ______________________________________________

4. បទទំនាយត្រូវបានសម្រេច “ ______________________ នៃ __________________ ខ្ញុំបាន ____________________________________ របស់ខ្ញុំ ______________ ________________________________________________________” ចូរប្រើខគម្ពីរយោងដែលនិយាយអំពីបទទំនាយនេះ ដែលបានកត់ត្រាទុក? ______________________
____________________________________________________________

**សំគាល់:** នៅក្នុងជំនាន់ដើមព្រះជាម្ចាស់ក៏បានជ្រើសរើសមនុស្ស ឲ្យដឹលនាំរាស្ត្ររបស់ទ្រង់ចេញពីប្រទេសអេស៊ីបមកដែរ ហើយឥឡូវនេះព្រះអង្គក៏នឹងនាំយកព្រះរាជបុត្រាទ្រង់តែមួយនោះព្រះយេស៊ូវគ្រីស្ទនោះចេញពីប្រទេសអេស៊ីបជាថ្មីម្តងទៀត។

5. មានបទទំនាយមួយទៀតក៏នឹងត្រូវបានសម្រេចផងដែរ។ តើស្តេចហេរ៉ូដទទួលស្គាល់យ៉ាងដូចម្តេច (ខ១៦)? ________________________________________________________
____________________________________________________________
____________________________________________________________

6. តាមសេចក្តីខឹងក្រោធរបស់ស្តេចហេរ៉ូដ តើព្រះអង្គបានចេញបញ្ជាយ៉ាងដូចម្តេច? __________
____________________________________________________________
____________________________________________________________

គ្រាន់តាមការប៉ានស្មានប៉ុណ្ណោះ គឺមានក្មេងប្រុសៗជាច្រើនត្រូវបានសម្លាប់ មានឮសម្លេងទួញសោកក្នុងគ្រួសារជាច្រើននៅក្នុងភូមិបេថ្លេហិម និង តំបន់នៅជុំវិញភូមិនោះ។

7. នេះគឺជារឿងអស្ចារ្យចុងក្រោយបង្អស់ដែលយើងដឹងអំពីស្តេចហេរ៉ូដ ហើយជាបន្ទាប់ពីនោះទៀតគឺជាដំណឹងអំពីការសុគត់របស់ព្រះអង្គ។ ទេវតានៃព្រះជាម្ចាស់បានលេចមកឯយ៉ូសែបនៅក្នុងសុបិន្តជាថ្មីម្តងទៀត នៅគ្រានោះ តើយ៉ូសែបបានទទួលការណែនាំយ៉ាងដូចម្តេច (ខ១៩-២០)? _____
____________________________________________________________
____________________________________________________________
____________________________________________________________

8. យ៉ូសែបបានឆ្លើយតបដោយការស្តាប់បង្គាប់ ហើយបានធ្វើដំណើរវិលត្រឡប់មកកាន់អ៊ីស្រាអែលវិញ ប៉ុន្តែ តើមានការផ្លាស់ប្តូរនៅក្នុងគម្រោងការរបស់គាត់យ៉ាងដូចម្តេចខ្លះ? ____________
____________________________________________________________
____________________________________________________________

៩. គាត់បានទទួលការហាមប្រាម មិនអនុញ្ញាតិឲ្យវិលត្រឡប់ទៅកាន់ភូមិបេថ្លេហិមវិញឡើយ។ តើគាត់បាននាំគ្រួសាររបស់គាត់ទៅរស់នៅឯណា? ________________________________

________________________________________________________________

10.នៅក្នុងផែនទី មានការពិពណ៌នាអំពីព័ន្ធកិច្ចរបស់ព្រះយេស៊ូវដូចតទៅ:

ក. ទីក្រុងយេរូសាឡឹមស្ថិតនៅក្នុងតំបន់នៃស្រុកយូដា

ខ. ភូមិបេថ្លេហិម គឺស្ថិតនៅតំបន់មួយក្បែរនោះ

គ. ស្រុកណាសារ៉ែតស្ថិតនៅភាគខាងជើង និង នៅភាគខាងលិចនៃសមុទ្រកាលីឡេ

## ការឆ្លុះបញ្ចាំង:

ពួកម៉ាហ្គីបានធ្វើដំណើរមកពីតំបន់ចំងាយដើម្បីក្រាបថ្វាយបង្គំព្រះយេស៊ូវ ហើយ ស្តេចហេរ៉ូដបានដាក់ផែនការណ៍ដើម្បីសម្លាប់ទ្រង់ ចំណែកឯយ៉ូសែបបានទទួលការណែនាំពីទេវតានៃព្រះជាម្ចាស់ដើម្បីទៅកាន់ទីកន្លែងមួយដែលអាចឲ្យព្រះឱរសយេស៊ូវបានទទួលភាពកក់ក្តៅ និង សុវត្ថិភាពនៅក្នុងដៃមាតារបស់ទ្រង់។ ពួកម៉ាហ្គីបានទទួលស្គាល់ផ្កាយរបស់ព្រះជាម្ចាស់បានផ្តល់សញ្ញាខុសប្លែកពីក្នុងកាលដែលពួកគេបានធ្វើដំណើរមកគឺនៅចំពីលើភូមិបេថ្លេហិម។ រីឯស្តេចហេរ៉ូដបានជ្រាបថានឹងមានទារកមួយត្រូវប្រសូតមកដើម្បីឡើងគ្រងរាជ្យលើសាសន៍យូដា ហើយការនេះវាជាគំរាមកំហែងដល់អំណាច និងតួនាទីរបស់ព្រះអង្គ ដូច្នេះហើយទើបទ្រង់ចេញបញ្ជាឲ្យមានបេសកកម្មមួយដើម្បីសម្លាប់ទារកនោះចោល។ ចំណែកយ៉ូសែបវិញការទទួលខុសត្រូវរបស់គាត់គឺជាការស្តាប់បង្គាប់តាមបំណង ព្រះហឫទ័យនៃព្រះវរបិតារបស់ព្រះឱរសដែលគង់នៅស្ថានសួគ៌ គឺគាត់បាននាំព្រះឱរស និង មាតាទ្រង់ចាកចេញទៅកាន់ប្រទេសអេស៊ីបទាំងយប់អាធ្រាត ហើយពួកគេក៏បានរស់នៅទីនោះ លុះដល់ពេលដែលគាត់ និង ក្រុមគ្រួសារត្រឡប់មកវិញគាត់បានទៅរស់នៅក្នុងភូមតូចមួយក្នុងស្រុក ណាសារ៉ែត។

តាមការសង្កេតមើលទៅយើងឃើញថាមានមានមនុស្សបីនាក់បំពេញបេសកកម្មរៀងៗខ្លួន។ តើលោកអ្នកកំណត់អត្តសញ្ញាណឲ្យខ្លួនឯងទៅនឹងបុគ្គលមួយណា? ឬមួយអាចជាពួកម៉ាហ្គីដែលជាអ្នកគោរពប្រតិបត្តិដល់ព្រះឱរសព្រះយេស៊ូវដោយមានអំណោយ ការគោរពឧិនលំទោន ការក្រាបថ្វាយបង្គំ និងការសរសើរដម្កើង? ប្រហែលជាលោកអ្នកបានស្គាល់ព្រះឱរសនោះរួចទៅហើយ! ______________________

________________________________________________________________

________________________________________________________________

________________________________________________________________

**ឬមួយលោកអ្នកអាចជាហេរ៉ូដ? ជាការពិតណាស់លោកអ្នកនឹងមិនព្យាយាមរកមធ្យោបាយដើម្បីសម្លាប់ព្រះឱរសព្រះយេស៊ូវនោះទេ ប៉ុន្តែតើលោកអ្នកបានមើលឃើញថាទ្រង់គឺជាអ្នកដែលត្រូវគំរាមកំហែងដល់អំណាចបុណ្យសក្តិ តួនាទី និង មហិច្ឆតារបស់លោកអ្នកដែរឬទេ? លោកអ្នកអាចនឹងមិនអើពើក្នុងរឿងនេះ តែយ៉ាងហោចណាស់ ក៏លោកអ្នកអាចជាអ្នកចង់បានព្រះឱរស់ដែលជាអ្នកស្រឡាញ់លោកអ្នក និងអ្នកត្រូវការក្តីស្រឡាញ់ពីលោកអ្នកដែរ។** ______________________________

______________________________

______________________________

______________________________

**តើលោកអ្នកអាចមើលឃើញថា ខ្លួនឯងមានអត្តសញ្ញាណដូចជាយ៉ូសែបដែលជាមនុស្សពេញដោយស្តាប់បង្គាប់ ដែលបានព្យាយាមបញ្ចៀសរាល់ការការគំរាមកំហែងពីសំណាក់មនុស្សអាក្រក់ទាំងអស់ដែលប៉ុនប៉ងដើម្បីបំផ្លាញព្រះឱរសព្រះយេស៊ូវដែរឬទេ? យ៉ូសែបគឺជាមនុស្សម្នាក់ដែលបានមើលថែរក្សាលើកិច្ចការរបស់ព្រះជាម្ចាស់។ លោកអ្នកអាចជាមនុស្សម្នាក់ដែលមានចិត្ត គំនិតខ្នះខ្នែងក្នុងការមើលថែរក្សាលើកិច្ចការរបស់ព្រះជាម្ចាស់ប្រកបដោយប្រាជ្ញា និង ពោរពេញដោយការស្តាប់បង្គាប់តាមបំណងព្រះហឫទ័យរបស់ទ្រង់។** ______________________________

______________________________

______________________________

______________________________

**ទោះបីជាលោកអ្នកបានកំណត់ខ្លួនឯងទុកដូចជានរណាក៏ដោយ តែលោកអ្នកត្រូវចងចាំពាក្យទេវតាដែលបានប្រាប់ថា** "មើល ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្តីអំណរយ៉ាងអស្ចារ្យ ដែលសំរាប់បណ្តាជនទាំងអស់គ្នា ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ១អង្គ ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់!"

# មេរៀនទី ២ - ផ្នែកទី ៣

## សេចក្តីណែនាំ:

ដំណើររឿងអំពីបុណ្យណូអែលតទៅទៀតនេះ លូកាបានបន្តការសរសេរនូវសាច់រឿងពីរអំពីព្រះយេស៊ូវនៅក្នុងព្រះវិហារ។ ដំណើររឿងទីមួយគឺនិយាយអំពីកាលដែលព្រះរាជកុមារយេស៊ូវមានព្រះជន្មប្រមាណជា ៦ សប្តាហ៍ ហើយដំណើររឿងមួយទៀតគឺនិយាយអំពីកាលដែលព្រះរាជកុមារយេស៊ូវមានព្រះជន្ម ១២ ឆ្នាំ។ ដំណើររឿងទាំងនេះគឺជាផ្តោតសំខាន់ទៅលើការចម្រើនវ័យឡើងរបស់ព្រះយេស៊ូវ។

## កិច្ចការ:

ចូរអានព្រះគម្ពីរ លូកា ២:២១-២៤

- តើតម្រូវឲ្យធ្វើអ្វីចំពោះទារកនៃសាសន៍យូដានៅក្រោយពីបានអាយុ ៨ ថ្ងៃ?
- ហេតុអ្វីបានជា យ៉ូសែប និង នាងម៉ារីទៅព្រះវិហារ?
- តើការថ្វាយទារកមានន័យដូចម្តេចចំពោះសាសន៍អ៊ីស្រាអែល?

## លំហាត់:

1. តើព្រះយេស៊ូវមានព្រះជន្មប៉ុន្មានឆ្នាំ (ខ២១)? ____________________
2. តើកិច្ចការសំខាន់ជាពិសេសពីរយ៉ាងអ្វីខ្លះដែលតម្រូវឲ្យក្មេងប្រុសសាសន៍យូដាត្រូវធ្វើ?

   ក. ____________________

   ខ. ____________________

   **សំគាល់:** ពិធីកាត់ស្បែកបានសំដៅទៅដល់ជំនាន់លោក អាប់រ៉ាម (លោកុប្បត្តិជំពូក ១៧) គឺនៅពេលដែលព្រះជាម្ចាស់បានជ្រើសរើសចងសម្ពន្ធមេត្រីជាមួយនឹង លោក អាប់រ៉ាម និង ក្រុមគ្រួសាររបស់គាត់ ហើយពិធីកាត់ស្បែកគឺជាទីសំគាល់មួយនៃចងសម្ពន្ធមេត្រី ឬ ការតាំងសេចក្តីសញ្ញា។ ទ្រង់នឹងធ្វើជាព្រះជាម្ចាស់របស់ពួកគេ និង ជាព្រះជាម្ចាស់នៃគ្រប់ជំណាវកូនចៅក្រោយៗរបស់ពួកគេ ចំណែលឯពួកគេវិញនឹងត្រូវធ្វើជាប្រជារាស្ត្ររបស់ទ្រង់។ នៅពេលនោះពួកគេទាំងពីរនាក់ គឺលោក អាប់រ៉ាម និងលោកស្រី សារ៉ាយត្រូវបានប្តូរឈ្មោះទៅជា លោក អ័ប្រាហាំ និងលោកស្រី សារ៉ា វិញ។
3. នៅថ្ងៃទី ៨ ព្រះយេស៊ូវត្រូវបានចុះបញ្ជីឈ្មោះជាផ្លូវការ (លូកា ២:២១)។ តើព្រះអង្គត្រូវបានថ្វាយព្រះនាមនៅពេលណា? ____________________

   ____________________

4. នៅក្នុងព្រះគម្ពីរ លេវីវិន័យជំពូក ១២ តាមក្រឹត្យវិន័យរបស់លោក ម៉ូសេបានប្រាប់យើងអំពីច្បាប់ដែលទាក់ទងជាមួយនឹងការសម្អាតខ្លួន (ការជម្រះកាយ) ខ្លួនក្រោយពេលសម្រាលកូនរួច។ ឥឡូវនេះបានរយៈពេលចំនួន ៤០ ថ្ងៃបន្ទាប់ពីប្រសូតព្រះឱរសយេស៊ូវ ការជម្រះកាយរបស់នាងម៉ារីត្រូវបានធ្វើរួចរាល់ជាស្រេច ហើយយើងបានឃើញនាង ម៉ារី និងយ៉ូសែបប្ដីរបស់នាងនៅក្នុងព្រះវិហារ (លូកា ២:២២)។ នៅក្រោយពីនាងម៉ារីបានធ្វើការជម្រះកាយរួចរាល់ហើយ នោះក៏អាចអនុញ្ញាតឲ្យនាងចូលទៅក្នុងព្រះវិហារដែរ។ តើហេតុអ្វីបានជានាងម៉ារី និងយ៉ូសែបចូលមកក្នុងព្រះវិហារ (ខ២២-២៣)? ____________________________________________

____________________________________________________________

5. នេះគឺជាបញ្ញត្តិដែលព្រះជាម្ចាស់បានបង្គាប់នៅក្នុងព្រះគម្ពីរ និក្ខមនំ ១៣:២ នៅពេលនោះព្រះអង្គមានព្រះបន្ទូលថា "ត្រូវញែកអស់ទាំងកូនច្បងចេញទុកសំរាប់អញ គឺជាកូនណាដែលកើតពីពោះម្ដាយមកមុនបង្អស់ ទោះមនុស្សឬសត្វក្ដី នោះជារបស់ផងអញ។" **តើការនេះត្រូវយ៉ាងណាចំពោះព្រះរាជកុមារយេស៊ូវ?**________________________________

____________________________________________________________

ព្រះយេស៊ូវគឺជាកម្មសិទ្ធិរបស់ព្រះអម្ចាស់! ព្រះអង្គបានយាងមកយកកំណើតជាមនុស្សគឺមិនមែនដើម្បីបម្រើគោលបំណងផ្ទាល់ខ្លួនរបស់ទ្រង់នោះទេ ប៉ុន្តែបម្រើឲ្យបំណងព្រះហឫទ័យនៃព្រះបិតាទ្រង់វិញ។ ក្នុងអត្ថន័យនេះហើយទើបព្រះយេស៊ូវដែលជាកូនច្បងក្នុងគ្រួសារតម្រូវឲ្យថ្វាយទៅដល់ព្រះអម្ចាស់។

6. ការថ្វាយយញ្ញបូជាមួយត្រូវបានធ្វើឡើងផងដែរ។ នេះបើយោងតាមលេវីវិន័យ 12: 6-8 អ្វីដែលជាតម្រូវការសម្រាប់ការលះបង់នោះ?
7. នៅក្នុងព្រះគម្ពីរ លូកា ២:២៤ តើបានប្រាប់យើងថា នាងម៉ារី និង យ៉ូសែបបានយកអ្វីទៅព្រះវិហារដើម្បីទុកជាយញ្ញថ្វាយដល់ព្រះជាម្ចាស់? ______________________________

____________________________________________________________

សំគាល់: មានរឿងខ្លះអាចត្រូវលើកយកមកនិយាយទាក់ទងនឹងការថ្វាយយញ្ញបូជានេះ ១) បើអ្នកណាគ្មានលទ្ធភាពទិញមួយកូនចៀមអាយុមួយខួបបានទេ ដូច្នេះត្រូវឲ្យយកលលកមួយគូ ឬ ព្រាបជំទើរពីរមកជំនួសវិញ។ ២) បើអ្នកណាមានកូនចៀមឈ្មោលហើយ តែមិនដឹងអំពីពេលវេលានោះត្រូវយកលលកមួយគូ ឬ ព្រាបជំទើរពីរមកក៏បាន។ ព្រះយេស៊ូវត្រូវបានសំដៅទៅលើព្រះគម្ពីរយ៉ូហាន ១:៣៦។

នៅពេលដែលលោក យ៉ូហានបាទីស្ដបានឃើញព្រះយេស៊ូវយាងឆ្លងកាត់តាមនោះ តើគាត់បានសំដៅទ្រង់ទៅនឹងអ្វី (ឆរណា)? ________________________________________

________________________________________

នាងម៉ារី និង យ៉ូសែប បានបំពេញតាមក្រឹត្យវិន័យរបស់លោក ម៉ូសេគ្រប់យ៉ាង ដូចជា ធ្វើពិធីកាត់ស្បែកថ្វាយព្រះរាជកុមារយេស៊ូវ ការចុះបញ្ជីកំណើតឲ្យកូន និង ពិធីសម្អាតខ្លួន (ការជម្រះខ្លួនក្រោយពេលសម្រាលកូន) ជាដើម។

## សេចក្ដីបង្រៀនៈ

ព្រះយេស៊ូវត្រូវបានធ្វើពិធីកាត់ស្បែក និង បានថ្វាយដល់ព្រះជាម្ចាស់ក្នុងនាមជាកូនច្បងក្នុងគ្រួសារ ដូច្នេះទ្រង់បានបំពេញតាមច្បាប់ ដែលព្រះជាម្ចាស់បានប្រទានដល់រាស្ត្ររបស់ទ្រង់កាលពីទ្រង់បានចងសម្ព័ន្ធមេត្រីជាមួយនឹងលោក អប្រាហាំ (លោកុប្បត្តិជំពូ ១៧)មកនោះយ៉ាងត្រឹមត្រូវ។ វាគឺជាការសំខាន់ណាស់សម្រាប់ពួកយើងដើម្បីឲ្យបានយល់ច្បាស់អំពីការទាំងនេះ ដោយមិនត្រូវធ្វើតាមបំណងចិត្ត ឬ ការសម្រេចចិត្តរបស់កូននោះទេ។ ផ្ទុយទៅវិញ ឪពុកម្ដាយគ្រប់រូបគប្បីត្រូវបានស្ដាប់បង្គាប់តាមអ្វីដែលព្រះជាម្ចាស់បានបង្គាប់មកសម្រាប់រាស្ត្ររបស់ទ្រង់តាមរយៈការដែលមានទំនាក់ទំនងជាមួយនឹងទ្រង់។

ប្រជារាស្ត្រអ៊ីស្រាអែលទាំងអស់បានរស់នៅក្រោមការតាំងសេចក្ដីសញ្ញា ឬ ការចងសម្ព័ន្ធមេត្រីរបស់ព្រះជាម្ចាស់។ តាមការព្រមព្រៀងដែលបានផ្ដួចផ្ដើមឡើងដោយព្រះជាម្ចាស់ និង ឲ្យចង់សម្រាប់កុមារគ្រប់រូបត្រូវបានចុះឈ្មោះក្នុងបញ្ជីកំណើត ជាការតម្រូវឲ្យឪពុកម្ដាយជាអ្នកផ្ដល់ឈ្មោះសម្រាប់កូនរបស់ខ្លួន ដើម្បីកូននោះបានជាកម្មសិទ្ធិពេញច្បាប់ក្នុងនាមជាសមាជិកនៃគ្រួសារ និង ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ផងដែរ យ៉ាងនោះកូនៗនឹងត្រូវបានរស់នៅជាសមាជិកយ៉ាងពេញសិទ្ធិក្នុងក្រុមគ្រួសាររបស់ព្រះជាម្ចាស់ដោយសេរីភាព និង ការលើកលែងទោស។

មានបញ្ហាមួយបានចោទសួរឡើងថាៈ តើត្រូវធ្វើដូចម្ដេចទើបខ្ញុំអាចផ្សាភ្ជាប់ ទំនាក់ទំនងឲ្យបានក្លាយទៅជាកូនពេញសិទ្ធិរបស់ព្រះជាម្ចាស់ ដែលអាចរស់នៅប្រកបដោយសេរីភាព និង ការអត់ទោសបាន? នៅក្នុងព្រះគម្ពីរ ទុតិយកថា ៣០:៦ បានប្រាប់យើងថា ព្រះជាម្ចាស់នឹង ________________________

________________________ នៃឯង ហើយ ________________________

ឲ្យបាន ____________________ ជា ____________ អស់ពី ____________________

អស់ពី ______________________________ ដើម្បី ________________________

________________________________________

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងបានសិក្សាដឹងថាព្រះជាម្ចាស់បានយកពិធីជ្រមុជទឹក ជំនួសឲ្យពិធីកាត់ស្បែកវិញដើម្បីទុកជាសញ្ញានៃការព្រមព្រៀងថ្មីរបស់ទ្រង់។ ឆ្លងតាមរយៈពិធីបុណ្យជ្រមុជទឹកយើងបានក្លាយជាចំណែកមួយនៃគ្រួសាររបស់ព្រះជាម្ចាស់ដោយឥតគិតថ្លៃ និង ការអត់ទោស។ ទឹក និង ពាក្យសម្ដីដែលបានប្រើក្នុងពេលទទួលពិធីជ្រមុជទឹកគឺជាការប្រកាសប្រាប់ឲ្យដឹងថា យើងបាននៅក្នុងព្រះនាមព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ អំពើបាបទាំងប៉ុន្មានរបស់យើងគឺត្រូវបានទ្រង់អត់ទោសឲ្យរួចហើយ។ ដោយសារតែព្រះយេស៊ូវទើបយើងអាចរស់នៅក្រោមអំណាចថ្មីមួយសម្រាប់ជីវិតរបស់យើង! ការទទួលពិធីជ្រមុជទឹកគឺជាកិច្ចការមួយដ៏តូចរបស់យើងតែប៉ុណ្ណោះដែលយើងត្រូវធ្វើ ប៉ុន្តែកិច្ចការគ្រប់យ៉ាងផ្សេងទៀតព្រះជាម្ចាស់គឺជាអ្នកទទួលខុសត្រូវ នោះគឺជាកិច្ចការដែលព្រះជាម្ចាស់ត្រូវធ្វើនៅក្នុងជីវិតរបស់យើង។ កិច្ចការទាំងអស់នោះរួមមានដូចជា ការប្រណីសន្ដោសក្នុងការអត់ទោសបាបដល់យើង ការប្រកាសជាសាធារណៈឲ្យដឹងថាយើងគឺជាកូនស្ងួនភ្ងាររបស់ទ្រង់ ការធានាអះអាងថាយើងគឺជាកម្មសិទ្ធិរបស់ទ្រង់ផ្ទាល់ ការប្រទានព្រះវិញ្ញាណបរិសុទ្ធរបស់ទ្រង់ដល់យើងដើម្បីឱ្យទទួលបានផ្លាស់ប្រែថ្មីក្នុងជីវិត ការឆ្លុះបញ្ចាំងអំពីព្រះភ័ក្រទ្រង់ដល់មនុស្សទាំងអស់នៅក្នុងលោកីយ៍នេះ។

## ការទន្ទេញចងចាំ:

នៅក្នុងព្រះគម្ពីរ កូឡុស ២:១១-១២ បាននិយាយអំពីការផ្សារភ្ជាប់គ្នានៃទំនាក់ទំនងគ្នារវាងពិធីកាត់ស្បែក និងពិធីបុណ្យជ្រមុជទឹក ការទទួលពិធីនេះគឺធ្វើអំពើបាបដែលជាប់តាំងពីកំណើតមកត្រូវបានកាត់ផ្ដាច់ទាំងអស់។ នៅក្នុងព្រះគ្រីស្ទ ចិត្តរបស់យើងត្រូវបានទទួលពិធីកាត់ស្បែករួចជាស្រេច ហើយតាមរយៈការទទួលពិធីបុណ្យជ្រមុជទឹកគឺយើងបានត្រូវស្លាប់រួមជាមួយទ្រង់ រួចក៏ត្រូវបានរស់ឡើងវិញជាថ្មីម្ដងទៀតរួមជាមួយព្រះគ្រីស្ទដោយមានសេចក្ដីជំនឿលើឫទ្ធានុភាពរបស់ព្រះជាម្ចាស់ គឺជាឫទ្ធានុភាពតែមួយដែលបានប្រោសព្រះយេស៊ូវមានព្រះជន្មរស់ពីសុគតឲ្យឡើងវិញ។ នៅក្នុងបទគម្ពីរនោះបានចែងថា: អ្នករាល់គ្នា ________

______________________ ក្នុងទ្រង់ ដែល ______________________ គឺជាការ __________

________________ ដោយទទួល _________________ វិញហើយអ្នករាល់គ្នា ___________

______ ក៏បាន _____________________ ដោយសារ __________________ ដល់ _______

________________ នៃព្រះដែលទ្រង់បាន ____________________________ឲ្យ ________

____________________________________________________________ ឡើងវិញ។ ___

______________________________________________________________________

______________________________________________________________________

ចូរសរសេរបទគម្ពីរនេះទុកនៅលើសៀវភៅកត់ត្រារបស់លោកអ្នកម្តងទៀត ហើយចូរទន្ទេញឲ្យបានចងចាំរួចទូលសូមដល់ព្រះអម្ចាស់ដើម្បីឱ្យលោកអ្នកមានសេចក្តីជំនឿក្នុងការទទួលជឿដូចដែលលោកអ្នកបានចង់ក្លាយទៅជាកូនសួនភ្ជាររបស់ទ្រង់។ បើសិនជាលោកអ្នកនៅមិនទាន់បានទទួលពិធីបុណ្យជ្រមុជទឹកទេ តែបានជឿថាព្រះជាម្ចាស់កំពុងតែលើកទឹកចិត្ត ហើយត្រាស់ហៅលោកអ្នកនៅក្នុងសេចក្តីជំនឿដើម្បីជឿលើព្រះបន្ទូលរបស់ទ្រង់នោះ ដូច្នេះចូរលោកអ្នកសុំឲ្យដឹកនាំនៃពួកជំនុំណាមួយ ឬមិត្តភ័ក្រដែលជឿលើព្រះយេស៊ូវគ្រីស្ទបានធ្វើពិធីបុណ្យជ្រមុជទឹកសម្រាប់លោកអ្នក ដើម្បីឲ្យបានឮពាក្យថា "ខ្ញុំសូមធ្វើពិធីជ្រមុជទឹកឲ្យអ្នក ដោយនៅក្នុងព្រះនាមព្រះវរបិតា ព្រះរាជព្រះបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ!"

## សេចក្តីអធិស្ឋានៈ

ឱ ព្រះអម្ចាស់អើយ! ព្រះអង្គប្រកាសដោយបានធានាដល់រាស្ត្ររបស់ទ្រង់ថាពួកគេគឺកម្មសិទ្ធិរបស់ទ្រង់ផ្ទាល់ ហើយព្រះអង្គបានចងសម្ព័ន្ធមេត្រី និង ប្រទានសេចក្តីសន្យាដល់ពួកគេថា ព្រះអង្គនឹងធ្វើជាព្រះជាម្ចាស់របស់ពួកគេ ចំណែកពួកគេនឹងធ្វើជាប្រជារាស្ត្ររបស់ព្រះអង្គ។ គ្រប់កិច្ចការទាំងអស់គឺស្ថិតនៅលើព្រះអង្គគឺដោយសារព្រះអង្គបានប្តេជ្ញាប្រទានសេចក្តីសន្យាដូច្នេះសម្រាប់ពួកគេ។ ទូលបង្គំបានចូលមកនៅចំពោះព្រះអង្គដោយទូលបង្គំបានដឹងថា ព្រះអង្គបានធ្វើកិច្ចការគ្រប់យ៉ាងសម្រាប់រាស្ត្របស់ព្រះអង្គគ្រប់ៗគ្នា ព្រមទាំងសម្រាប់ទូលបង្គំផងដែរ។ គឺព្រះអង្គហើយដែលជាអ្នកធានាអះអាងសម្រាប់ទូលបង្គំ ហើយបានដាក់ទូលបង្គំឲ្យរស់នៅក្រោមម្ចាស់ជីវិតថ្មីក្នុងកាលដែលទូលបង្គំរស់ដោយសេចក្តីជំនឿលើព្រះអង្គ។ ហើយព្រះអង្គក៏បានធានាចំពោះទូលបង្គំទៀតថារាល់អំពើបាបទាំងអស់របស់ទូលបង្គំដែលមានជាប់តាំងពីកំណើតមកនោះគឺត្រូវបានអត់ទោសរួចហើយ! ដូច្នេះ ទូលបង្គំនឹងបានរស់នៅក្រោមព្រះគុណ និងសេចក្តីស្រលាញ់របស់ទ្រង់ដោយមានសេរីភាពដ៏ពិតប្រាកដ! ដ្បិតព្រះអង្គបានជ្រាបហើយថា អំពើបាបរបស់ទូលបង្គំទាំងប៉ុន្មានបានស្លាប់ហើយកប់រួមជាមួយនឹងព្រះគ្រីស្ទ តែក៏បានរស់ឡើងវិញរួមជាមួយនឹងទ្រង់ដោយមានជីវិតមួយថ្មី ដែលមិនមានជាប់ចំណងអំពើបាបទៀតទេ។ ហេតុដូច្នេះ ទូលបង្គំមានតែពាក្យអរព្រះគុណ និងការសរសើរដម្កើងដល់ទ្រង់តែប៉ុណ្ណោះ។ ________________________________________

________________________________________

________________________________________

________________________________________

# មេរៀនទី ២ - ផ្នែកទី ៤

## សេចក្តីណែនាំ:

ក្នុងខណៈពេលដែលការសិក្សារបស់យើងចេះតែបន្តទៅមុខ មានបុគ្គលសំខាន់ៗពីរដែលត្រូវបានលើកយកមកនិយាយនៅក្នុងខបន្ទាប់នៃព្រះគម្ពីរ លូកា ជំពូក ២។ បុគ្គលទាំងពីរនេះគឺមានវ័យចំណាស់បន្តិចណាស់ទៅហើយ ប៉ុន្តែ ពួកគេសុទ្ធតែជាអ្នកធ្វើ បន្ទាល់ថាព្រះយេស៊ូវគឺជាព្រះមេស្ស៊ីដែលត្រូវបានប្រទានមកតាមព្រះបន្ទូលសន្យា។ ហើយបុគ្គលទាំងពីរដដែលនេះគឺជាស្ពានភ្ជាប់ទំនាក់ទំនងនៃសេចក្តីសន្យានៅក្នុងព្រះគម្ពីរសញ្ញាចាស់ទៅនឹងការសម្រេចតាមសេចក្តីសន្យានៅក្នុងព្រះគម្ពីរសញ្ញាថ្មី។

## កិច្ចការ:

ចូរអានព្រះគម្ពីរ លូកា ២:២៥-៣៥

- តើនរណាដែលជាតួអង្គថ្មីនៅក្នុងបទគម្ពីរបន្ទាប់ទៅទៀតនេះ?
- តើពួកគេបាននិយាយដូចម្តេចអំពីព្រះរាជកុមារយេស៊ូវ?
- តើទ្រង់បានប្រើពាក្យសម្តីដូចម្តេចទៅកាន់នាងម៉ារី?

## លំហាត់:

1. តើយើងបានរៀនអ្វីខ្លះអំពីលោក ស៊ីម្មាន (ខ២៥)?

   ក. ________________________________ និង ______________________

   ខ. __________________________________________________________

   គ. __________________________________________________________

2. តើព្រះវិញ្ញាណនៃព្រះជាម្ចាស់បានបើកសម្តែងឲ្យគាត់បានឃើញដូចម្តេច (ខ២៦)? __________

   ____________________________________________________________

   ____________________________________________________________

3. គាត់បានចូលទៅក្នុងព្រះវិហារដោយ ____________________________________

   ________________________________________ លើគាត់ (ខ២៧)?

4. តើរឿងដូចគ្នានេះបានកើតឡើងចំពោះនរណាទៀត? ___________________________

   ____________________________________________________________

5. ហេតុអ្វីបានជាពួកគេប្រាប់យើងថាពួកគេនៅទីនោះ? ___________________________

   ____________________________________________________________

6. លោក ស៊ីម្មាន បានស្គាល់ព្រះរាជកុមារយេស៊ូវរួចស្រេចទៅហើយ! យើងបានដឹងថា គាត់បានព្រះរាជកុមារមកបីនៅក្នុងដៃ ហើយសរសើរដម្កើងដល់ព្រះជាម្ចាស់ (ខ២៨)។ តើលោក ស៊ីម្មាន បានដឹងថានោះគឺជាព្រះយេស៊ូវ ដែលជាសេចក្តីសង្គ្រោះរបស់អ៊ីស្រាអែលដែរឬទេ? យើងពិតជាមិនអាចដឹងបានទេ លុះត្រាមានព្រះវិញ្ញាណនៃព្រះជាម្ចាស់បានបើកសម្តែងអំពីព្រះយេស៊ូវដល់គាត់។ តើលោក ស៊ីម្មាន បាននិយាយដូចម្តេច (ខ២៩)? ______________________________

______________________________________________________________

______________________________________________________________

7. ពិតមែនហើយ! ព្រះជាម្ចាស់បានធ្វើសេចក្តីសន្យារបស់ទ្រង់ហើយ ដូច្នេះ គាត់អាចស្លាប់ទៅដោយសេចក្តីសុខសាន្តហើយ។ ហេតុអ្វី (ខ៣០-៣២)? "ដ្បិត ______________ បានឃើញ ___ ______________ របស់ផងទ្រង់ ដែល ___________ នៅមុខ _____________ _ ជា ___________ សំរាប់ ___________________ ដល់ _______________ ហើយជា ___________________ របស់ _______________ ជា _______ ទ្រង់។"

8. តើយ៉ូសែប និង នាងម៉ារី មានប្រតិកម្មដូចម្តេចនៅពេលបានឮអ្វីដែលលោកស៊ីម្មានបាននិយាយ (ខ៣៣)? ______________________________________________

______________________________________________________________

______________________________________________________________

9. ក្រោយមកបន្តិត លោក ស៊ីម្មាន ក៏បានចាកចេញទៅ ដោយការប្រទានពរ។ តើគាត់បាននិយាយពាក្យសម្តីចុងក្រោយទៅកាន់នាងម៉ារីយ៉ាងដូចម្តេច (ខ៣៤-៣៥)? "បុត្រនេះ _____________

______________________________________________________________

______________________________________________________________

______________________________________________ សំដែងចេញមក។"

## សេចក្តីបង្រៀនៈ

តើនឹងមានអ្វីកើតឡើងនៅក្នុងគំនិតរបស់នាងម៉ារី និងយ៉ូសែបនៅពេលពួកគេបានជួបជាមួយនឹងមនុស្សដែលមិនធ្លាប់បានស្គាល់ពីមុនមកសោះដូច្នេះ? លោក ស៊ីម្មានបានស្គាល់ព្រះយេស៊ូវថាជាអ្នកសង្គ្រោះសម្រាប់គ្រប់មនុស្សទាំងអស់ ហើយបន្ទាប់មកគាត់ក៏បានថ្លែងចេញយ៉ាងអស់ពីចិត្ត។ គាត់បាននិយាយថាព្រះយេស៊ូចគឺពិតជាព្រះមេស្ស៊ី ដែលត្រូវយាងមក សម្រាប់សាសន៍យូដា និង សាសន៍ដទៃផងដែរ។

ប្រជារាស្ត្រអ៊ីស្រាអែលទាំងអស់បានជឿថាជាព្រះមេស្ស៊ីនឹងត្រូវយាងមកដើម្បីធ្វើជាព្រះសង្គ្រោះរបស់ពួកគេ។ ចូរយើងចំណាយពេលវេលាខ្លះ ដើម្បីពិនិត្យមើលទៅលើខយោងខ្លះៗ ទុកជាការយល់ដឹងបន្ថែម។

- ដូចជាពាក្យមួយនៅក្នុងខយោងគឺពាក្យថា អ៊ីស្រាអែល ក្នុងខ ៣២ តើហោរាអេសាយបាននិយាយដូចម្តេចអំពីសាសន៍ដទៃ តាមរយៈព្រះគម្ពីរ អេសាយ ៤២:៦-៧? "ហើយ ______________ ________________________________ ទុកជា ___________________________ ____________________________________________________________"។
    - o នាំទៅ ________________________________________________________ ________________________________________________________________
    - o នាំទៅ ________________________________________________________ ________________________________________________________________
    - o នាំទៅ ________________________________________________________ ________________________________________________________________
- ជាថ្មីម្តងទៀត នៅក្នុងព្រះគម្ពីរ អេសាយ ៤៩:៦ ហោរា អេសាយប្រើពាក្យបញ្ចូលគ្នា គឺពាក្យថា សាសន៍ យូដា និង សាសន៍ដទៃ។ តើក្នុងបទទំនាយបានទាយទុកមកយ៉ាងដូចម្តេច? ".... ហើយនឹងនាំពួកបំរុងទុក ______________________________________________ មកវិញ នោះជាការតិចតួចពេកដល់ឯង អញនឹង ___________________________ ទាំងប៉ុន្មានទៀត ដើម្បី _____________________________________ រហូតដល់ចុងផែនដីបំផុត"។
- នៅក្នុងព្រះគម្ពីរសញ្ញាថ្មី តាមអំណះអំណាងនៅក្នុងព្រះគម្ពីរ កិច្ចការ ១៣:៤៧-៤៨ យើងឃើញថា បទទំនាយត្រូវបានសម្រេចតាមរយៈពាក្យរបស់លោក ស៊ីម្មាន ដែលបានការថ្លែងទៅកាន់នាង ម៉ារី និង យ៉ូសែបកាលពួកគេនៅក្នុងព្រះវិហារ។ តាមរយៈពាក្យទាំងនេះ តើពួកសាសន៍ដទៃនឹងមានការឆ្លើយតបវិញយ៉ាងដូចម្តេច? ________________________________________ ________________________________________________________________ ________________________________________________________________
- លោក ស៊ីម្មាន ក៏បាននិយាយនូវពាក្យសម្តីមួយចំនួនទៀត ដែលពាក្យទាំងនោះវាមិនងាយស្រួលសម្រាប់ ម៉ារី និង យ៉ូសែបស្តាប់ឡើយ។ គាត់បាននិយាយថា គ្រប់គ្នានឹងមករកទ្រង់ ដើម្បីទាស់នឹងទ្រង់។ ព្រះយេស៊ូវមានព្រះបន្ទូលថា:
    - o ទ្រង់ និង ព្រះវរបិតា ____________________________(យ៉ូហាន ១០:៣០)

- ទ្រង់នឹងនាំឲ្យ ____________________________________________
  ________________________________________(ម៉ាថាយ ១០:៣៤-៣៩)
- ទ្រង់នឹងត្រូវបានគេ ____________________________(ម៉ាថាយ ២៦:៥៩)
- ទ្រង់គឺជា ________________________________________________
  ____________________________________(ម៉ាថាយ ២៦:៦៣-៦៤)
- ទ្រង់នឹង ____________________________________(យ៉ូហាន ១០:៣៣)

- នៅទីបំផុត តើលោក ស៊ីម្មានបាននិយាយដូចម្តេចទៅកាន់នាងម៉ារី (លូក ២:៣៥)? _________

  ____________________________________________________________

  ____________________________________________________________

  ____________________________________________________________

មានចម្ងល់មួយបានផុសចេញនៅក្នុងគំនិត ថាតើនឹងមានអ្វីត្រូវកើតឡើងចំពោះនាង និង កូនប្រុសរបស់នាង។ ខណៈពេលដែលធ្វើការឆ្លុះបញ្ចាំងត្រឡប់ទៅកាន់ ព្រះគម្ពីរ លូកា ២:១៩ យើងអាចសួរបាន បើសិនជាការនេះ គឺជារឿងមួយដែលនាងម៉ារីត្រូវគិតពិចារណានៅក្នុងចិត្ត។

## ការអនុវត្តន៍:

1. អ្វីដែលលោក ស៊ីម្មាន បាននិយាយគឺសុទ្ធតែការពិតទាំងអស់។ តើខ្ញុំគួរជឿថាកុមារម្នាក់គឺជានរណាឲ្យពិតប្រាកដទៅ? តើខ្ញុំយល់ស្របតាមពាក្យសម្តីរបស់លោក ស៊ីម្មាន និង ការទាយទុករបស់ពួកហោរាថា ទ្រង់គឺជាព្រះសង្គ្រោះសម្រាប់មនុស្សទាំងអស់នៅផែនដីនេះឬមួយយ៉ាងណា? តើខ្ញុំជឿថាទ្រង់គឺជាអ្នកសង្គ្រោះសម្រាប់សាសន៍យូដា និង សាសន៍ដទៃដែរឬទេ? ការមួយដែលសំខាន់បំផុតនោះគឺថាតើ ខ្ញុំជឿទ្រង់គឺជាព្រះសង្គ្រោះ <u>របស់ខ្ញុំ</u> ដែរឬទេ? បើសិនជាមាននរណាម្នាក់សួរខ្ញុំថាតើព្រះរាជកុមារយេស៊ូវមានន័យដូចម្តេចសម្រាប់ខ្ញុំ តើត្រូវឲ្យខ្ញុំឆ្លើយប្រាប់គេវិញយ៉ាងដូចម្តេច?

   ____________________________________________________________

   ____________________________________________________________

   ____________________________________________________________

2. ពេលលោក ស៊ីម្មាន បានឃើញ គាត់ក៏បានស្គាល់ថាទ្រង់គឺជានរណាភ្លាម គឺដោយសារតែមានការបើកសម្តែងពីព្រះវិញ្ញាណបរិសុទ្ធ។ តើព្រះវិញ្ញាណនឹងបើកសម្តែងបែបណាសម្រាប់លោកអ្នក ទ្រង់នឹងនាំលោកអ្នកចូលឲ្យជិតព្រះរាជកុមារឬយ៉ាងណា? ______________________________

   ____________________________________________________________

   ____________________________________________________________

# មេរៀនទី ២ - ផ្នែកទី ៥

## កិច្ចការៈ

ចូរអានព្រះគម្ពីរ លូកា ២:៣៦-៤០

- តើតួអង្គថ្មីគឺជានរណា?
- តើយើងសិក្សាអ្វីខ្លះអំពីគាត់?
- តើគាត់មានប្រតិកម្មដូចម្ដេចនៅពេលដែលគាត់បានជួបនឹងព្រះយេស៊ូវ?

## លំហាត់ៈ

1. លោក លូកា បានកំណត់អត្តសញ្ញាណយ៉ាងច្បាស់អំពីស្ត្រីម្នាក់នេះ។ "ហើយមានហោរាស្រីម្នាក់ ឈ្មោះ ____________ ជាកូន ____________ ក្នុងពូជអំបូរ ____________ ____________ (ខ៣៦)។
2. លោក លូកា ក៏បានប្រាប់យើងអំពីគាត់នូវផ្សេងរឿងរ៉ាវមួយចំនួនទៀតដែរ។
   ក. តើគាត់ធ្វើអ្វី (ខ៣៦)? ____________
   ខ. គាត់ជាស្ត្រីមានវ័យចំណាស់ទៅហើយ គាតបានមានប្តី ____________ ឆ្នាំ
   គ. គាត់គឺជាស្ត្រីមេម៉ាយ ហើយឥឡូវនេះគាត់អាយុប្រហែលជា ____________ ឆ្នាំ
   ឃ. ជាក់ស្តែងគាត់មិនដែលចាកចេញពីព្រះវិហារឡើយ (ខ៣៧)
      ១. ____________ ទាំងយប់ទាំងថ្ងៃ
      ២. ដោយ ____________ ហើយ ____________
3. អាណាព្យាការីនីម្នាក់ ដែលបានចំណាយពេលវេលារស់នៅតែក្នុងព្រះវិហារពេញមួយជីវិតរបស់គាត់ សម្រាប់ការថ្វាយបង្គំ ដោយធ្វើ ការតមអាហារ និងការអធិស្ឋានផងដែរ ហើយគាត់ក៏បានមកជួប នឹងនាង ម៉ារី យ៉ូសែប និងព្រះឱរស (ខ៣៨)។ "គាត់បានឡើងមកនៅវេលានោះឯង .....″ ស្ដាប់ ទៅគាត់ក៏ត្រូវបានទទួលការបើកសម្ដែងពីព្រះវិញ្ញាណបរិសុទ្ធដូចជាលោក ស៊ីម្មានដែរ ដ្បិតគាត់បាន ស្គាល់ព្រះរាជកុមារយេស៊ូវ នៅពេលដែលគាត់បានឃើញទ្រង់ភ្លាម។ តើគាត់បានធ្វើអ្វីពេលដែល គាត់បានឃើញទ្រង់?
   ក. ____________
   ខ. ____________

## សេចក្តីបង្រៀនៈ

អាណាបានចំណាយពេលវេលារង់ចាំជាយូរយាណាស់មកហើយ ដោយការប្រមើលមើល ទាំងក្តីរំពឹងថានឹងមានការប្រោសលោះមួយដល់ទីក្រុងយេរូសាឡឹម។ ក្នុងអំឡុងឆ្នាំនៃការវិលត្រឡប់របស់រាស្ត្រអ៊ីស្រាអែលពីការនិរទេសខ្លួនជាមួយនឹងនេហេមា រហូតមកទល់នឹងព្រះយេស៊ូវប្រសូត នោះគឺជាពេលវេលាមួយដែលប្រជារាស្ត្រអ៊ីស្រាអែលគ្រប់គ្នាមានសេចក្តីទុក្ខព្រួយយ៉ាងខ្លាំង ព្រោះពួកគេត្រូវបានរស់នៅក្រោមការគ្រប់គ្រង ត្រួតត្រាជិះជាន់ពីសំណាក់ចក្រភពរ៉ូម៉ាំង។ នៅក្នុងគ្រានោះពួកគេទាំងអស់គ្នាត្រូវទទួលបន្ទុកយ៉ាងធ្ងន់ធ្ងរក្នុងការបង់ពន្ធ ហើយត្រូវទទួលការជិះជាន់សង្កត់សង្កិនយ៉ាងខ្លាំងទៀតផង។ ស្ថានភាពក្នុងគ្រានោះវាមិនខុសគ្នាជំនាន់ដូនតារបស់ពួកគេដែលត្រូវបានជាប់ជាទាសករនៅក្នុងប្រទេស អេស៊ីបនោះទេគឺគ្រាន់តែត្រូវស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋអំណាចផ្សេងគ្នាប៉ុណ្ណោះ ដូច្នេះហើយទើបពួកគេបានអធិស្ឋានដល់ព្រះជាម្ចាស់សម្រាប់ការរំដោះឲ្យមានសេរីភាពឡើងវិញ។ អាណាបានដឹង ហើយ ទទួលស្គាល់ភ្លាមៗថាក្រុងយេរូសាឡឹមត្រូវការនូវការប្រោសលោះជាបន្ទាន់។ តើមានអ្វីដែលគួរឱ្យចាប់អារម្មណ៍ពីការទទួលស្គាល់ថាជាអ្នករំដោះប្រជារាស្ត្រអ៊ីស្រាអែលគឺជាព្រះឱរស់ម្នាក់នេះ។

ស្របពេលជាមួយគ្នានឹងក្រុងយេរូសាឡឹមត្រូវការសេចក្តីប្រោសលោះនោះ ប្រជារាស្ត្រអ៊ីស្រាអែលកំពុងទន្ទឹងរង់ចាំការយាងមករបស់ព្រះមេស៊ី ដែលជាអ្នករើសតាំងឡើងគ្រងរាជ្យធ្វើជាស្តេចហើយនឹងបានរំដោះពួកគេពីឲ្យរួចពីការជិះជាន់សង្កត់សង្កិននេះ។ គឺជាការពិតណាស់ អាណា ក៏កំពុងតែរង់ចាំព្រះមេស៊ីដូចជារាស្ត្រអ៊ីស្រាអែលឯទៀតៗដែរ ប៉ុន្តែគាត់បានឃើញ ហើយស្គាល់ព្រះមេស៊ីដែលជាជ្រើសតាំងដើម្បីធ្វើជាព្រះសង្គ្រោះរួចហើយ។ ម៉ារី និងយ៉ូសែបបាននាំព្រះរាជកុមារព្រះយេស៊ូវទៅព្រះវិហារ នៅពេលនោះទ្រង់ត្រូវបានគេថ្វាយព្រះនាមថា យេស៊ូវ (លូកា ២:២១) ដោយសារតែ យ៉ូសែបត្រូវបានទទួលការណែនាំពីទេវតា (ម៉ាថាយ ១:២១) ថាទ្រង់នឹងសង្គ្រោះប្រជារាស្ត្រព្រះអង្គឲ្យបានរួចពីអំពលបាបរបស់ពួកគេ។ នៅខណៈពេលដែលព្យាការិនីម្នាក់នេះបានស្គាល់ថាគឺជាព្រះយេស៊ូវ នោះគាត់ក៏បានសរសើរដម្កើង និង អរព្រះគុណព្រះជាម្ចាស់ដែរ (ខ៣៨)។ អ្វីដែលគាត់ធ្វើបន្ទាប់ទៀតនេះគឺពិតជាការអស្ចារ្យខ្លាំងណាស់! គឺគាត់បានប្រាប់ឲ្យយើងបានដឹងអំពីព្រះរាជកុមារ... អាណា បានមើលឃើញថា ព្រះរាជកុមារគឺជាព្រះអំណោយទានមកពីព្រះជាម្ចាស់សម្រាប់ផែនដីនេះ គឺព្រះរាជកុមារនឹងរំដោះគ្រប់មនុស្សជាតិទាំងអស់ឲ្យរួចពីទាសភាពខាងព្រលឹងវិញ្ញាណ ភាពអស់សង្ឃឹម និងភាពតែលតោល ហើយទ្រង់នឹងប្រទានឱ្យមនុស្សគ្រប់ៗគ្នាមានសេចក្តីសុខសាន្ត និង សេចក្តីសង្ឃឹមដូចចិត្តពួកគេប្រាថ្នាចង់បានជាយូរយាមកហើយនោះ។

## ការឆ្លុះបញ្ចាំង:

សូមនឹកស្រមៃទៅដល់នាងម៉ារី និង យ៉ូសែបបន្តិចមើល! តើពួកគេត្រូវបានគិតអំពីអ្វីក្នុងពេលឥឡូវនេះ? មនុស្សគ្រប់គ្នាមិនដែលធ្លាប់បានជួប ឬស្គាល់ព្រះឱរសឡើយ លើកលែងតែ លោក ស៊ីម្មាន និងអាណា ដែលបានដឹងថាទ្រង់គឺជានរណា ដោយការបញ្ជាក់របស់ពួកគាត់គឺដូចគ្នាទៅនឹងអ្វីដែលទេវតាបានប្រាប់ដល់នាងម៉ារី និង យ៉ូសែបដែរ។ ពួកគេប្រាកដជាមានការងឿងឆ្ងល់ខ្លាំងណាស់ ថាតើមានមនុស្សបានដឹងអំពីរឿងរបស់ព្រះឱរសនេះបានដោយរបៀបណា ប៉ុន្តែ ព្រះវរបិតាសព្វព្រះហឫទ័យចង់ឱ្យមនុស្សគ្រប់ៗគ្នាបានស្គាល់ទ្រង់ ដូច្នេះហើយ ទើបបានជា អាណាបាននិយាយអំពីកុមារឲ្យយើងបានដឹងទាំងអស់។ ព្រះវរបិតាសព្វព្រះហឫទ័យចង់ឱ្យមនុស្សគ្រប់ៗគ្នាបានស្គាល់ទ្រង់ ចំណែកឯ អាណាវិញគាត់ក៏ចង់ជួយនាំព្រះបន្ទូលទ្រង់ចេញទៅមនុស្សគ្រប់ៗគ្នាដែរ! ខណៈពេលដែលយើងធ្វើការឆ្លុះបញ្ចាំងអំពីប្រតិកម្មរបស់គាត់នៅពេលគាត់បានឃើញព្រះយេស៊ូវ វាក៏ជាបុព្វហេតុមួយធ្វើឱ្យយើងឆ្លុះបញ្ចាំងអំពីប្រតិកម្មរបស់ខ្លួនឯងនៅពេលដែលបានស្គាល់ទ្រង់ដែរ។

## សំនួរអនុវត្តន៍:

តើខ្ញុំនឹងមានប្រតិកម្មដូចម្ដេចចំពោះការពិត ដែលបានឃើញព្រះឱរសយេស៊ូវត្រូវបានរុំនឹងក្រណាត់សំពត់ ហើយបានដឹងផ្ដេកនៅក្នុងស្នូកសត្វដូច្នេះ? ______________________

______________________

______________________

______________________

តើខ្ញុំនឹងមានប្រតិកម្មដូចម្ដេចចំពោះការពិត ដែលព្រះវរបិតាបានប្រទានព្រះយេស៊ូវឲ្យមកផែនដីដើម្បីឲ្យធ្វើព្រះសង្គ្រោះសម្រាប់គ្រប់មនុស្សជាតិទាំងអស់បូករួមទាំងខ្ញុំផងដែរនោះ? ______________________

______________________

______________________

______________________

ប្រសិនបើខ្ញុំមានប្រតិកម្មដូចជា អាណា តើខ្ញុំគួតែនិយាយពីការទាំងអស់នេះប្រាប់ទៅអ្នកណា? តើខ្ញុំនឹងទៅប្រាប់ដល់មនុស្សគ្រប់ៗគ្នាអំពីទ្រង់យ៉ាងដូចម្ដេច? ______________________

______________________

______________________

______________________

## លំហាត់:

1. កាលនាងម៉ារី និង យ៉ូសែប បានធ្វើសំរេចគ្រប់ទាំងអស់ តាមក្រឹត្យវិន័យព្រះអម្ចាស់ហើយ (ខ៣៩) នោះក៏នាំគ្នាត្រឡប់ទៅ ___________ វិញ គឺទៅឯ ____________________________ ____________________________________________________________។
2. តើយើងបានដឹងអ្វីខ្លះអំពីព្រះយេស៊ូវតាមរយៈខ ៤០?
   ក. ឯព្រះឱរស ____________________________________________
   មាន ______________________________________________________
   ខ. ប្រកបដោយ ______________________________________________
   គ. ហើយ______________________________________________លើទ្រង់ផង។

## ការឆ្លុះបញ្ចាំង:

- យើងបានសិក្សាអំពីការចម្រើនវ័យរបស់ព្រះយេស៊ូវក្លាយទៅជាមនុស្សពេញវ័យម្នាក់ ដែលប្រកបដោយសុខភាពយ៉ាងមាំមួន។
- យើងបានសិក្សាឃើញថាទ្រង់ប្រកបដោយកម្លាំងខាងវិញ្ញាណកាន់តែច្រើនឡើង ហើយជាទីគាប់ព្រះហឫទ័យដល់ព្រះវរបិតាដែល គង់នៅនរគស្ថានសួគ៌ និង ឪពុកម្តាយនៅលើផែនដីនេះផងដែរ។ ទ្រង់ក៏មានការច្រើនខាងឯចំណេះដឹងគ្រប់យ៉ាង ដូចមានចែងទុកក្នុងព្រះគម្ពីរ សុភាសិត ១:៧ ថា "សេចក្តីកោតខ្លាចដល់ព្រះយេហូវ៉ា នោះជាដើមចមនៃដំរិះ តែមនុស្សឥតបើគិតគេមើលងាយប្រាជ្ញា និងសេចក្តីប្រៀនប្រដៅវិញ។"
- ហើយយើងក៏បានដឹងទៀតថា ព្រះគុណនៃព្រះជាម្ចាស់គឺស្ថិតនៅលើទ្រង់ ដោយព្រះអង្គកាន់តែមានទំនាក់ទំនងជាមួយនឹងព្រះវរបិតាកាន់ប្រសើរឡើងជានិច្ច។
- ព្រះយេស៊ូវបានចម្រើនវ័យកាន់ធំឡើង តាមបទគម្ពីរបានប្រើពាក្យថា រឹងមាំ ហើយ ពេញលក្ខណៈ។ ព្រះគុណ និង សេចក្តីគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់បានស្ថិតនៅលើព្រះអង្គ គឺថាទ្រង់បានក្លាយទីជាមនុស្សពេញវ័យទាំងផ្នែកខាងរូបរាង្គកាយ គំនិត ប្រាជ្ញា និង ព្រះវិញ្ញាណ។

## ការអនុវត្តន៍:

ទន្ទឹមនឹងខ្ញុំមានការរីកលូតលាស់ចម្រើនវ័យក្លាយទៅជាមនុស្សធំពេញវ័យផ្នែកខាង រូបរាង្គកាយ គំនិតប្រាជ្ញា និង ផ្នែកខាងព្រលឹងវិញ្ញាណដែរនោះ តើខ្ញុំនឹងអាចនឹងទទួលបានការរីកចម្រើនផ្នែកខាង ចរិតលក្ខណៈ និង អកប្បកិរិយា ហើយប្រកបដោយព្រះគុណ និង ការគាប់ដល់ព្រះហឫទ័យនៃព្រះវរបិតាយ៉ាងដូចម្តេច?

- រូបរាង្គកាយ: ________________________________________________

- គំនិតប្រាជ្ញា: ____________________
- ព្រលឹងវិញ្ញាណ: ____________________

ការនេះគឺឪពុកម្ដាក់គ្រប់រូបចង់បានបំផុតសម្រាប់កូនៗរបស់ពួកគេ ក៏ដូចជាជីដូនជីតាគ្រប់រូបចង់ឲ្យចៅៗរបស់បានរីកលូតលាស់ចម្រើនវ័យក្នុងផ្នែកទាំងអស់នេះដែរ។ តើត្រូវធ្វើដូចម្ដេចដើម្បីឲ្យកូនចៅរបស់យើងបានរីកលូតលាស់ចម្រើនវ័យបានប្រសើរ ហើយមានឥទ្ធិពលលើជីវិតរបស់ពួកគេក្នុងផ្នែកទាំងបីនេះ?

- រូបរាងកាយ: ____________________
- គំនិតប្រាជ្ញា: ____________________
- ព្រលឹងវិញ្ញាណ: ____________________

ពូ មីង និង មិត្តភ័ក្រទាំងអស់ក៏ចង់មានឥទ្ធិពលលើជីវិតកូនក្មួយរបស់ពួកគេដូចគ្នានេះដែរ។ តើយើងគួរតែមានមធ្យោបាយបែបណាដើម្បីឲ្យមានឥទ្ធិពលលើជីវិតរបស់ពួកគេ និង លើកទឹកចិត្តពួកគេឲ្យមានការរីកលូតលាស់ចម្រើនវ័យក្នុងនាមជាកូនរបស់ព្រះជាម្ចាស់?

- រូបរាងកាយ: ____________________
- គំនិតប្រាជ្ញា: ____________________
- ព្រលឹងវិញ្ញាណ: ____________________

## សេចក្ដីអធិស្ឋាន:

ចូរលើកទូលថ្វាយដល់ព្រះជាម្ចាស់ចំពោះផ្នែកណាមួយក្នុងជីវិតដែលលោកអ្នកមានការខ្វល់ខ្វាយ ហើយមានបំណងចង់ឲ្យព្រះជាម្ចាស់បានបំពេញ និង ចម្រើនឲ្យបានរឹងមាំពេញលក្ខណៈ ប្រយោជន៍ឲ្យលោកអ្នកអាចធ្វើការឆ្លុះបញ្ចាំងដល់មនុស្សដែលរស់នៅជុំវិញបានឃើញពីព្រះគុណរបស់ព្រះជាម្ចាស់។ ____________________

____________________

____________________

ចូរលើកទូលថ្វាយកូនៗរបស់លោកអ្នកទៅព្រះជាម្ចាស់ ដើម្បីឲ្យបានដឹងថាពួកគេអាចសម្ដែងចេញនូវព្រះគុណរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់ពួកគេ ខណៈពេលដែលពួកគេមានការចម្រើនវ័យលើផ្នែករូបរាងកាយ គំនិតប្រាជ្ញា និង ផ្នែកព្រលឹងវិញ្ញាណ។ ____________________

____________________

____________________

# មេរៀនទី ៣

## មេរៀនទី ៣ - ផ្នែកទី ១

### សេចក្តីណែនាំ:

ដំណើរចុងក្រោយរបស់ព្រះយេស៊ូវ ដែលបានរៀបរាប់អំពីកុមារភាពរបស់ទ្រង់គឺត្រូវបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរលូកា ជំពូក ២។ យើងអាចនឹងសួរថា តើហេតុអ្វីបានជាមិនមានដំណើររឿងបន្ថែមទៀតដែលរៀបរាប់ក្នុងឆ្នាំនិមួយៗដែលព្រះអង្គចម្រើនវ័យឡើងរហូតដល់ក្លាយទៅជាមនុស្សធំពេញវ័យ។ តើនរណាដែលជាអ្នកមានឥទ្ធិពលទៅលើជីវិតរបស់ទ្រង់? តើទ្រង់តែងតែស្តាប់បង្គាប់តាមឪពុកម្តាយទ្រង់ ឬ ក៏មានការប្រឆាំងខ្លះៗនៅពេលណាដែលពួកគាត់ប្រើអំណាចមកលើព្រះអង្គ? អ្វីៗទាំងអស់យើងនឹងបានដឹងតាមរយៈខ ៤០ ឯព្រះឱរស ______________________________ មាន ________________ ______ ប្រកបដោយ ________________________ ហើយ ____________________ __________________________________________________ ក៏សណ្ឋិតលើទ្រង់ផង។

### កិច្ចការ:

ចូរអានព្រះគម្ពីរ លូកា ២:៤១-៥២

- ហេតុអ្វីបានជាគ្រួសាររបស់ទ្រង់ទៅកាន់ក្រុងយេរូសាឡិម?
- តើមានអ្វីកើតឡើងនៅពេលដែលពួកគេនៅទីនោះ?
- តើដំណើររឿងនេះបានប៉ះពាល់ចិត្តលោកអ្នកដូចម្តេចខ្លះ?

### លំហាត់:

1. ដោយយោងទៅលើខ ៤១ ជារៀងរាល់ឆ្នាំឪពុកម្តាយរបស់ព្រះយេស៊ូវបានទៅឯណា? ________

   ____________________________________________________________

   តើនៅក្នុងឱកាសអ្វី? ____________________________________________

   សំគាល់: តាមក្រឹត្យវិន័យមនុស្សដែលពេញវ័យត្រូវចូលរួមក្នុងកម្មវិធីបុណ្យចំនួនបីជារៀងរាល់ឆ្នាំគឺមានពិធីបុណ្យ ថ្ងៃទី ៥០ ពិធីបុណ្យរំលង និង ពិធីបុណ្យ ព្រះឧបោសថ។ ពេលវេលាដើរទៅមុខយ៉ាងឆាប់រហ័ស ឆ្នាំដំបូងដែលព្រះយេស៊ូវបានរួមដំណើរជាមួយឪពុកម្តាយទ្រង់ក៏បានមកដល់។
2. តើព្រះយេស៊ូវមានព្រះជន្មប៉ុន្មានឆ្នាំនៅក្នុងដំណើររឿងនេះ (ខ៤២)? __________________

   ____________________________________________________________

3. តើមានអ្វីកើតឡើងនៅពេលពិធីបុណ្យបានចប់ (១៩៣)? ______________________________

______________________________________________________________

4. ពេលនោះម៉ារី និង យ៉ូសែបបានធ្វើដំណើរត្រឡប់ទៅឯស្រុកណាសារ៉ែតវិញ។ តើពួកគេគិតព្រះយេស៊ូវ គង់នៅឯណា (១៩៤)? ______________________________

______________________________________________________________

5. តើពួកគេត្រូវធ្វើដំណើរចម្ងាយប៉ុន្មានដើម្បីតាមរកទ្រង់ទាំងមិនដឹងថាទ្រង់គង់នៅកន្លែងណា? ___

______________________________________________________________

6. តើពួកគេបានទៅតាមរកព្រះអង្គនៅឯណា (១៩៤)? ______________________________

______________________________________________________________

7. នៅពេលដែលពួកគេរកព្រះអង្គមិនឃើញ តើពួកគេបានធ្វើដូចម្ដេច (១៩៥)? ______________

______________________________________________________________

8. តើពួកគេបានចំណាយពេលប៉ុន្មានថ្ងៃដើម្បីតាមស្វែងរកព្រះយេស៊ូវ (១៩៦)? ______________

______________________________________________________________

9. តើពួកគេបានរកឃើញទ្រង់នៅកន្លែងណា? ______________________________

______________________________________________________________

10. តើទ្រង់កំពុងគង់នៅជាមួយអ្នកណា? ______________________________

______________________________________________________________

11. តើពេលនោះទ្រង់កំពុងតែធ្វើអ្វី? ______________________________

______________________________________________________________

12. តើអស់អ្នកដែលបានឮទ្រង់មានព្រះបន្ទូលមានប្រតិកម្មយ៉ាងដូចម្ដេច (១៩៧)? ______________

______________________________________________________________

13. តើម៉ារី និង យ៉ូសែបមានប្រតិកម្មដូចម្ដេចនៅពេលដែលពួកគេបានរកឃើញទ្រង់ (១៩៨)? _____

______________________________________________________________

14. តើមាតាទ្រង់បាននិយាយដូចម្ដេច (១៩៨)?

ក. សំនួរ: ______________________________

ខ. ការពិត: ______________________________

15. តើព្រះយេស៊ូវបានឆ្លើយតបវិញយ៉ាងដូចម្ដេច (ខ៤៩)?

ក. សំនួរ: ____________________

ខ. សំនួរ: ____________________

16. តើលោក លូកាមានប្រសាសន៍ដូចម្ដេចនៅក្នុងខ ៥០? ____________________

____________________

____________________

____________________

17. ព្រះយេស៊ូវ ក៏បានធ្វើដំណើរត្រឡប់ទៅឯស្រុកណាសារ៉ែតជាមួយនឹងនាង ម៉ារី និង យ៉ូសែបវិញ។ តើមានអ្វីជាពិសេសបាននិយាយអំពីទ្រង់ដែលស្ថិតក្នុងវ័យជំទង់បែបនេះ (ខ៥១)? ____________________

____________________

____________________

____________________

18. ជាថ្មីម្ដងទៀតលោក លូកាបានបង្ហើបប្រាប់យើងអំពីចិត្ត និង គំនិតរបស់នាង ម៉ារី។ តើគាត់បានប្រាប់អ្វីខ្លះដល់យើង? ____________________

____________________

____________________

19. ហើយ តើនៅមានអ្វីទៀតដែលបានដឹងអំពីព្រះយេស៊ូវ (ខ៥២)?

ក. ព្រះយេស៊ូវ ____________ ប្រកបដោយ ____________________

ខ. ហើយ ____________________ និង ____________________។

# មេរៀនទី ៣ - ផ្នែកទី ២

## ការឆ្លុះបញ្ចាំង:

- ចូរកត់ត្រាទុកនូវគំនិតមួយចំនួនរបស់លោកអ្នកអំពីដំណើររឿងនេះ។ ____________________

  ____________________
  ____________________
  ____________________
  ____________________

- តើលោកអ្នកមានប្រតិកម្មដូចម្ដេចចំពោះការបាត់ព្រះកាយរបស់ព្រះយេស៊ូវ? ____________________

  ____________________
  ____________________
  ____________________

- តើលោកអ្នកត្រូវទទួលខុសត្រូវដូចម្ដេចចំពោះរឿងនេះ? ____________________

  ____________________
  ____________________
  ____________________

- តើលោកអ្នកនឹងឆ្លើយតបដូចម្ដេចចំពោះចម្លើយរបស់ព្រះយេស៊ូវ?
  - ហេតុអ្វីបានជាស្វែងរកខ្ញុំដូច្នេះ?
    ចម្លើយរបស់លោកអ្នក: ____________________

    ____________________
    ____________________
    ____________________
  - តើអ្នកមិនដឹងថាខ្ញុំត្រូវនៅក្នុងព្រះដំណាក់នៃព្រះវរបិតារបស់ខ្ញុំទេឬអី?
    ចម្លើយរបស់លោកអ្នក: ____________________

    ____________________
    ____________________
    ____________________

- ព្រះយេស៊ូវបានសួរថា: ហេតុអ្វីបានជាស្វែងរកខ្ញុំដូច្នេះ? តើទ្រង់គ្មានការភ្ញាក់ផ្អើលចំពោះការតាមស្វែងរករបស់នាងម៉ារី និង យ៉ូសែប ដែលមិនបានដឹងថាទ្រង់គង់នៅកន្លែងណាទេឬយ៉ាងណា? តើព្រះអង្គបានយល់ឃើញដូចម្ដេចស្ថិតក្នុងភាពជាក្មេងជំទង់ដូច្នេះ? ______________________

______________________________________________

______________________________________________

- គ្រប់ៗគ្នាមានសេចក្ដីស្ញើចចំពោះការយល់ដឹង និង ចម្លើយរបស់ទ្រង់ (ខ៤៧) ជាខ្លាំង។ ព្រះយេស៊ូវត្រូវបានរកឃើញ នៅក្នុងចំណោមពួកគ្រូៗជាច្រើននាក់ ទ្រង់កំពុងស្ដាប់ ហើយ សួរសំនួរមួយចំនួនដល់ពួកគេ។ តើលោកអ្នកមិនចង់នៅក្នុងចំណោមពួកគេទាំងអស់នោះទេឬ? តើលោកអ្នកមាននឹកឆ្ងល់ថាតើពួកគេបានជជែកគ្នាអំពីប្រធានបទអ្វី?
- យើងបានដឹងថាព្រះយេស៊ូវបានប្រកបដោយការយល់ដឹងខ្ពស់។ ចូរស្រមៃមើលអំពីក្មេងជំទង់ម្នាក់ដែលមានអាយុត្រឹមតែ ១២ ឆ្នាំប៉ុណ្ណោះ តែបែរជានៅអង្គុយក្នុងចំណោមពួកគ្រូៗខាងវិន័យ ពួកបណ្ឌិតខាងទេវសាស្ត្រ និង សាស្ត្រាចារ្យជាច្រើននាក់ ដោយការស្ដាប់ និង សួរសំនួរជាច្រើនដល់ពួកគេ។ នៅទីបំផុតនាង ម៉ារី និង យ៉ូសែបបានទទួលការបង្រៀននូវបទគម្ពីរមួយចំនួនផងដែរ ដ្បិតទ្រង់បានដឹង និង ស្គាល់គ្រប់ទាំងច្បាប់នៃក្រឹត្យវិន័យទាំងអស់ ទ្រង់ក៏មានការយល់ដឹងអំពីប្រពៃណីទំនៀមទំលាប់របស់ពួកសាសន៍យូដាផងដែរ។ ព្រះយេស៊ូវបានគង់នៅក្នុងព្រះដំណាក់នៃព្រះវរបិតារបស់ទ្រង់!
- នៅក្នុងខ ៥០ បានប្រាប់យើងថា ឪពុកម្ដាយរបស់ទ្រង់ (ម៉ារី និង យ៉ូសែប) មិនបានយល់នូវអ្វីដែលព្រះយេស៊ូវមានព្រះបន្ទូលនោះឡើយ គឺពាក្យដែលទ្រង់មានព្រះបន្ទូលថា "តើអ្នកមិនដឹងថាខ្ញុំត្រូវនៅក្នុងព្រះដំណាក់នៃព្រះវរបិតារបស់ខ្ញុំទេឬអី"។ ជាការពិតណាស់ ឪពុកម្ដាយមានការធូរស្បើយក្នុងចិត្តនៅពេលដែលបានរកឃើញកូនដែលបាត់នោះវិញ ប៉ុន្តែ ចុះត្រង់ឯអត្ថន័យដែលទ្រង់មានព្រះបន្ទូលថា ទ្រង់ត្រូវគង់នៅក្នុងព្រះវរបិតាទ្រង់នោះ? ព្រះយេស៊ូវបានធំឡើង ហើយបានក្លាយទៅជាមនុស្សពេញវ័យម្នាក់ វាដោយគ្មានអ្វីត្រូវចោទសួរឡើយ ដ្បិតព្រះអង្គបានឈានទៅដល់កម្រិតមួយថ្មីទៀតដោយអង្គឯង តែលោកអ្នកគិតថា នាងម៉ារី និង យ៉ូសែបបានយល់អំពីអត្ថន័យនោះដែរឬមួយយ៉ាងណា។ ព្រះយេស៊ូវស្ថិតក្នុងវ័យ ១២ ឆ្នាំប៉ុណ្ណោះ តែព្រះអង្គមានការរីកចម្រើនឡើងយ៉ាងអស្ចារ្យ គឺទ្រង់អាចមានម្ចាស់ការលើរីកលូតលាស់ផ្នែកខាងព្រលឹងវិញ្ញាណដោយអង្គឯង គឺព្រះអង្គបានជ្រើសរើសយកការចម្អែតព្រលឹងវិញ្ញាណរបស់ទ្រង់ដោយការគង់នៅក្នុងព្រះវិហារ ទ្រង់បានបំពេញការយល់ដឹងផ្នែកខាងបទគម្ពីររបស់ទ្រង់ដោយការសួរសំនួរ និង ការពិភាក្សាត្រង់កន្លែងដែលព្រះអង្គបានគង់នៅនោះ។

## សំនួរអនុវត្តន៍:

តើការទទួលខុសត្រូវរបស់ខ្ញុំមានកម្រិតណា ក្នុងការធ្វើព្រលឹងវិញ្ញាណរបស់របស់ខ្ញុំមានការរីកលូតលាស់បានល្អប្រសើរនោះ?

1. តើខ្ញុំត្រូវខិតខំប្រឹងប្រែងប៉ុណ្ណា ដើម្បីធ្វើឲ្យខ្លួនឯងសិក្សាព្រះគម្ពីរបានទៀតទាត់ ប្រយោជន៍ឲ្យខ្ញុំអាចមានការយល់ដឹងអំពីព្រះវរបិតាដែលគង់នៅឯនរគស្ថានសួគ៌ និងបានពេញវ័យក្នុងទំនាក់ទំនងផ្ទាល់ជាមួយនឹងទ្រង់ និង ព្រះរាជបុត្រារបស់ទ្រង់បាននោះ? ______________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

2. តើខ្ញុំត្រូវខិតខំប្រឹងប្រែងប៉ុណ្ណា ដើម្បីធ្វើឲ្យខ្លួនឯងមានការចូលរួមជាមួយអ្នកដទៃ ថ្វាយបង្គំ និងអរព្រះគុណដល់ព្រះជាម្ចាស់ឲ្យបានទៀតទាត់នោះ? ______________________________

______________________________________________________________________

______________________________________________________________________

3. តើអ្នកណាអាចជួយឲ្យខ្ញុំមានការរីកចម្រើនក្នុងទំនាក់ទំនងជាមួយព្រះវរបិតា និង ព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទបាន? ______________________________________

______________________________________________________________________

______________________________________________________________________

## ការទន្ទេញចងចាំ:

យើងបានដឹងថា ព្រះយេស៊ូវបានចម្រើនឡើង ជាគាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់ និង ចិត្តមនុស្សផងដែរ។ នៅក្នុងព្រះគម្ពីរ សុភាសិត ៣:១-៤ គឺជាការបង្ហាញមួយសម្រាប់យើងដើម្បីឲ្យបានជាទីគាប់ព្រហឫទ័យដល់ព្រះជាម្ចាស់ និង ចិត្តផងដែរ។ ព្រះបាទសាឡូម៉ូនបានបង្រៀនកូនចៅរបស់ទ្រង់ដោយមានព្រះបន្ទូលថា:

- កុំឲ្យ ______________________ ឡើយ តួរឲ្យ ____________________
  កាន់តាម __________________ របស់អញ ___________________________
- ដ្បិត ______________________________ ទាំងនោះនឹង ________________

- និង ______________________________ ព្រមទាំង __________________________
  កុំឲ្យ ________________________ និង ____________________________________
  ចូរ ____________________________________ នៅ ________________________
  ហើយ ______________________________________________________________
- យ៉ាងនោះ ___________________________ និង _______________________ ហើយ
  _______________________________________________________________។

  ចូររីករាយក្នុងការកាន់តាមពាក្យទាំងនេះទុកនៅក្នុងចិត្តគំនិតរបស់លោកអ្នក ហើយអនុវត្តតាមចុះ នោះលោកអ្នកនឹងបានឈ្នះ ដោយបានជាទីគាប់ចិត្តដល់មនុស្សផងទាំងពួង និង មានកេរ្តិ៍ឈ្មោះល្អទៀតផង! ចូរសរសេរទុកនៅក្នុងសៀវភៅកត់ត្រារបស់លោកអ្នក ចូរកត់ត្រាទុកនូវព្រះពរមួយចំនួននៃកេរ្តិ៍ឈ្មោះល្អផងដែរ។

## សេចក្តីអធិស្ឋាន:

ឱព្រះយេស៊ូវអើយ! ព្រះអង្គទ្រង់ជ្រាបនូវរាល់អ្វីៗអំពីព្រះវរបិតារបស់ទ្រង់! ព្រះអង្គបានជាន់លើផែនដីនេះដោយប្រាជ្ញា និង ភាពពេញវ័យរបស់ទ្រង់។ សូមទ្រង់ប្រទានឲ្យទូលបង្គំបានរៀន ហើយនឹងកុំឲ្យទូលបង្គំភ្លេចអំពីការបង្រៀនរបស់ទ្រង់នេះសោះឡើយ។ សូមជួយអភិវឌ្ឍន៍ទូលបង្គំឲ្យមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលប្រកបដោយសេចក្តីស្រលាញ់ និង ភាពស្មោះត្រង់ ដើម្បីឲ្យអ្នកដទៃបានទទួលស្គាល់ថាព្រះអង្គកំពុងតែមានព្រះជន្មរស់នៅក្នុងជីវិតទូលបង្គំផង និង ដើម្បីឲ្យមនុស្សគ្រប់គ្នាបានសរសើរដម្កើងដល់ទ្រង់។

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

______________________________________________________________________

# មេរៀនទី ៣ - ផ្នែកទី ៣

## សេចក្ដីបង្រៀន:

នៅក្នុងព្រះគម្ពីរបានផ្ទុករឿងរ៉ាវអំពីព្រះយេស៊ូវជាច្រើន! យើងបានសិក្សាអំពីទីកន្លែងដែលទ្រង់បានយាងទៅដល់ អស់មនុស្សណាដែលទ្រង់បានជួបរឿងរ៉ាវ ឬ ពាក្យប្រៀបប្រដូចដែលទ្រង់មានព្រះបន្ទូលប្រាប់ និង ការអស្ចារ្យដែលព្រះអង្គបានសម្ដែងចេញ។ តាមការសិក្សាបានឲ្យយើងដឹងថាទ្រង់បានបង្រៀនព្រះបន្ទូលដល់ហ្វូងមនុស្ស ហើយក៏បានបង្រៀនអំពីអត្ថន័យនៃការដើរតាមទ្រង់ផងដែរ (ម៉ាថាយ ៥-៧) ។ ទ្រង់បានប្រោសអ្នកឈឺឲ្យបានជាសះស្បើយ (ម៉ាថាយ ៨:១-៨) ហើយទ្រង់បានប្រទានពរក្មេងតូចៗដែលបានមកកងទ្រង់ដែរ (លូកា ១៨:១៥-១៧) ។ លោកបានថ្កោលទោសចំពោះអ្នកដែលបានចាត់ទុកខ្លួនជាបានល្អប្រសើរជាងអ្នកឯទៀតៗ (ម៉ាថាយ ២៣) ទ្រង់បានបណ្ដេញវិញ្ញាណអារក្សឲ្យចេញពីមនុស្ស (ម៉ាថាយ ៨:២៨-៣៤) មិនតែប៉ុណ្ណោះ ទ្រង់ថែមទាំងបានប្រោសមនុស្សស្លាប់ឲ្យមានជីវិតរស់ឡើងវិញទៀតផង (យ៉ូហាន ១១:៣៨-៤៤)។ យើងបានសិក្សាឃើញថាទ្រង់បានចំណាយពេលនៅតែមួយអង្គឯងដើម្បីអធិស្ឋាន (ម៉ាកុស ១:៣៥) ទ្រង់បានគេចចេញពីហ្វូងមនុស្សដើម្បីបានចំណាយពេលវេលានៅជាមួយនឹងពួកសិស្ស (ម៉ាកុស ៩:៩-១១) ហើយក៏បានបើកសម្ដែងអង្គទ្រង់យ៉ាងពិសេសដល់អ្នកដែលជិតស្និទ្ធនឹងទ្រង់ផងដែរ (ម៉ាថាយ ១៧:១-៨) ។

យើងមិនដឹងថា ទ្រង់បានទៅក្លឹបហាត់ប្រាណប៉ុន្មាន ឬទ្រង់បានចុះឈ្មោះជាសមាជិកជាមួយក្លឹបប្រទេសណាខ្លះនោះទេ។ យើងបានមិនដឹងថាតើទ្រង់សព្វព្រះហឫទ័យមុខម្ហូបណា ឬ ក៏ស្លៀកសំលៀកបំពាក់ដូចម្ដេចពេលទ្រង់នៅផ្ទះនោះដែរ។ យើងមិនបានដឹងថាទ្រង់ត្រូវទទួលខុសត្រូវចំពោះកិច្ចការក្នុងផ្ទះអ្វីខ្លះនោះទេ ឬថាប្រសិនបើទ្រង់ត្រូវរៀននៅសាលាផងនោះ។ សំនួរទាំងនេះវាមិនមានសារៈសំខាន់ចាំបាច់អ្វីតម្រូវឲ្យអ្នកសរសេរព្រះគម្ពីរដំណឹងល្អត្រូវកត់ត្រាទុកនោះទេ។ ព្រះយេស៊ូវគ្មានអ្នកតាមប្រមាញ់ដែលតែងតែតាមឃ្លាំមើលដើម្បីរូបថត ទ្រង់ក៏គ្មានម៉ៃក្រូហ្វូន និង ម៉ាស៊ីនថតដែរ ប៉ុន្តែទ្រង់បានធ្វើឱ្យជនក្រីក្រ និងអ្នកដែលកំពុងជួបនឹងសេចក្ដីត្រូវការបានគ្រប់គ្រាន់។ ព្រះអង្គមិនបានចូលទៅបរិភោគក្នុងភោជនីយដ្ឋានទំនើបៗជាមួយនឹងពួកអភិជនឡើយ ប៉ុន្តែទ្រង់សព្វព្រះហឫទ័យសោយអាហារនៅក្នុងផ្ទះរបស់អ្នកទារពន្ធ និងមនុស្សមានបាបវិញ។ ទ្រង់បានរិះគន់ដល់ពួកផារិស៊ីដែលជាអ្នកមានទ្រព្យសម្បត្តិ ហើយបានដាក់ដង្វាយច្រើន តែទ្រង់បានកោតសរសើរយ៉ាងខ្លាំងស្ត្រីក្រីក្រម្នាក់ដែលគាត់ថ្វាយត្រឹមតែពីរកាក់ប៉ុណ្ណោះ។ ទ្រង់បានរស់នៅក្នុងសម័យកាលមួយដែលមានតែការរើសអើងក្នុងសង្គម វប្បធម៌គ្រអើតគ្រទម អំណួត និង អ្វីៗគឺជាការក្រឡាប់ចាក់ទាំងអស់ តែព្រះអង្គតែងតែមានព្រះហឫទ័យសប្បុរស ហើយអាស្រ័យ បានលើកឡើងអ្នកទន់ខ្សោយ និងអ្នកត្រូវគេជិះជាន់សង្កត់សង្កិនឲ្យបានងើបឡើងវិញ។

វាគឺជាការសំខាន់ណាស់ក្នុងការគត់សំគាល់អំពីព័ន្ធកិច្ចសាធារណៈរបស់ព្រះយេស៊ូវ ដ្បិតទ្រង់មិនបានចាប់ផ្តើមឡើងដោយការត្រាស់ហៅឲ្យមានពួកសិស្សនោះទេ។ នៅមុនពេលដែលព្រះយេស៊ូវត្រាស់ហៅពួកសិស្សរបស់ទ្រង់ (ម៉ាថាយ ៤:១៨-២២) យើងបានសិក្សានៅក្នុងព្រះគម្ពីរ ម៉ាថាយជំពូក ៣ និង ៤ វាគឺជាដំណើររឿងនៃការទទួលបុណ្យជ្រមុជទឹករបស់ទ្រង់ពីលោក យ៉ូហាន បាទីស្ត (ម៉ាថាយ ៣:១៣-១៧) រួចបន្ទាប់ពីនោះមក ទ្រង់បានចំណាយអស់ចំនួន ៤០ យប់ ៤០ ថ្ងៃ នៅក្នុងវាលរហោស្ថាននៅគ្រានោះទ្រង់ក៏ត្រូវវិញ្ញាណអារក្សល្បួង (ម៉ាថាយ ៤:១-១១)។ លើសពីនេះទៀតនោះ លោក លូកាបានប្រាប់យើងអំពីដំណើររឿងដែលទ្រង់បានជួបប្រយឈមជាមួយនឹងសាតាំងនៅក្នុងវាលរហោស្ថាន លុះក្រោយមកទៀត ទ្រង់ក៏បានវិលត្រឡប់ទៅស្រុកកាលីឡេដែលជាកន្លែងព្រះអង្គបង្រៀននៅតាមសាលាប្រជុំនោះវិញ។ នៅតាមសាលាប្រជុំនានាក្នុងស្រុកណាសារ៉ែត ព្រះអង្គបានប្រកាសថា ទ្រង់ត្រូវបានព្រះជាម្ចាស់ចាក់ព្រេងតាំងលើទ្រង់ ដើម្បីឲ្យប្រកាសដំណឹងល្អចេញទៅដល់ពួកអ្នកដែលត្រូវគេជិះជាន់ សង្កត់សង្កិន និងដើម្បីប្រកាសអំពីឆ្នាំព្រះអម្ចាស់បានសព្វព្រះហឫទ័យ (លូកា ៤:១៤-១៩; អេសាយ ៦១:១-២) ។ បន្ទាប់តទៅនេះ យើងនឹងបានសិក្សាអំពីដំណើរមួយ គឺព្រះយេស៊ូវបានត្រាស់ហៅពួកសិស្សរបស់ទ្រង់ ដែលជាការបង្កើតភាពជាអ្នកដឹកនាំសម្រាប់ពួកជំនុំគ្រីស្ទបរិស័ទ។

## សេចក្តីណែនាំ:

គ្រូកនរបស់ព្រះអង្គគឺមានលក្ខណៈជាចង្កោម ដែលគួរឱ្យចាប់អារម្មណ៍ចំពោះតួអង្គទាំងអស់នោះខ្លាំងណាស់! ពួកគេមកពីគ្រប់ស្រទាប់វណ្ណៈ ហើយមានជីវភាពរស់នៅប្រចាំថ្ងៃផ្សេងៗគ្នា ព័ន្ធកិច្ចបម្រើដើមដំបូងរបស់ព្រះយេស៊ូវ គឺទ្រង់បានជ្រើសរើសយកបុរស ១២ នាក់ ហើយទ្រង់បានហៅពួកគេថាជាសាវ័ករបស់ទ្រង់។ យើងនឹងពិនិត្យសង្កេតមើលទៅលើខយោងពីរកន្លែងនៅក្នុងព្រះគម្ពីរម៉ាថាយ ហើយចូរតាមដានមើលខណៈពេលដែលព្រះយេស៊ូវបានត្រាស់ហៅពួកគេឲ្យដើរតាមទ្រង់នោះ។

## កិច្ចការ:

ចូរអានព្រះគម្ពីរ ម៉ាថាយ ៤:១៨-២២

- តើបុរសទាំងបីនាក់នោះគឺជានរណាខ្លះ?
- តើទ្រង់បានទតឃើញពួកគេនៅឯណា?
- ហេតុអ្វីបានជាទ្រង់សព្វព្រះហឫទ័យចង់ឲ្យពួកគេបាននៅដើរជាប់ជាមួយនឹងទ្រង់?

## លំហាត់:

1. តើព្រះយេស៊ូវបានគង់នៅឯណា (ខ១៨)? ______________________________

______________________________

2. តើទ្រង់បានទតឃើញនរណា? ______________________________ និង _

______________________________

3. តើពួកគេទាំងពីរនាក់ត្រូវជាអ្វីនឹងគ្នា? ______________________________

______________________________

4. តើពួកគេកំពុងធ្វើអ្វី? ______________________________

______________________________

តើពួកគេមានមុខរបរជាអ្វី? ______________________________

______________________________

5. តើព្រះយេស៊ូវមានព្រះបន្ទូលដូចម្ដេច (ខ១៩)? ______________________________

______________________________

______________________________

6. តើពួកគេបានឆ្លើយតបវិញយ៉ាងដូចម្ដេច (ខ២០)? ______________________________

______________________________

7. ព្រះយេស៊ូវបានបន្តយាងកាត់តាមឆ្នេរសមុទ្រ កាលីឡេនោះតទៅទៀត។ បន្ទាប់ពីនោះមកតើទ្រង់បានទតឃើញនរណា (ខ២១)? ______________________________ និង _

______________________________

8. តើបុរសទាំងពីរនាក់នោះត្រូវជាអ្វីនឹងគ្នាដែរ? ______________________________

______________________________

9. តើឪពុករបស់ពួកគេមានឈ្មោះអ្វីដែរ? ______________________________
10. តើបុរសទាំងពីរនាក់នៅកំពុងធ្វើអ្វីជាមួយនឹងឪពុករបស់ពួកគេ? ______________________________

______________________________

11. តាមដំណើររឿង តើប្រាប់យើងថាព្រះយេស៊ូវបានធ្វើអ្វី? ______________________________

______________________________

12. តើពួកគេឆ្លើយតបទៅទ្រង់វិញយ៉ាងដូចម្ដេច (ខ២២)? ______________________________

______________________________

## ការឆ្លុះបញ្ចាំង:

ព្រះយេស៊ូវត្រូវបានចាប់ផ្ដើមព័ន្ធកិច្ចរបស់ទ្រង់ហើយ! តើលោកអ្នកមានគំនិតដូចម្ដេចខ្លះ ក្នុងខណៈពេលដែលកំពុងធ្វើការឆ្លុះបញ្ចាំងទៅលើដំណើររឿងនេះ?

- តើកិច្ចការដំបូងគេដែលទ្រង់បានធ្វើគឺជាអ្វី? ________________________________________________
- បើសិនជាលោកអ្នកបានចាប់ផ្ដើមដូចជាព្រះយេស៊ូវដែរ តើលោកអ្នកចង់បាននរណាមកចូលរួមជាមួយនឹងលោកអ្នក? តើតម្រូវឲ្យពួកគេនោះមានលក្ខណៈសម្បត្តិដូចម្ដេចខ្លះ? ________________________________________________
- តើព្រះយេស៊ូវបានជ្រើសរើសយកនរណាខ្លះ? ________________________________________________
- តើការអញ្ជើញរបស់ទ្រង់មានលក្ខណៈដូចម្ដេច? ________________________________________________
- តើទ្រង់បានសន្យាយ៉ាងដូចម្ដេច? ________________________________________________
- នៅពេលដែលអ្នកជំនាញខាងនេសាទនិយាយ នោះគ្រប់ៗគ្នាស្ដាប់! នៅពេលដែលអ្នកជំនាញផ្នែកខាងបច្ចេកទេសធ្វើការបង្ហាញដោយបានផ្ដល់គំនិតឲ្យចេះប្រើប្រាស់នុយ ហើយក៏ណែនាំដល់អ្នកនេសាទផ្សេងទៀតឲ្យចេះមើលទីតាំងដើម្បីនេសាទបានត្រីដែរ។ ចំពោះអស់អ្នកណាដែលធ្វើតាមគាត់ នោះគេប្រាកដជាដឹងអំពីវិធីនេសាទបានប្រសើរជាងមុនជាមិនខានឡើយ ហើយនៅទីបំផុត ពួកគេក៏នេសាទបានត្រីជាច្រើនដាក់ចូលទៅក្នុងទូករបស់ពួកគេប្រាកដមែន!
- ព្រះយេស៊ូវបានជ្រាបអំពីភាសារបស់បុរសទាំងបួននាក់នេះយ៉ាងច្បាស់។ ពេត្រុស និងអនទ្រេកំពុងបោះអួនរបស់គេ ចំណែកឯ យ៉ាកុប និង យ៉ូហានវិញកំពុងតែរៀបចំអួនរបស់គេ នេះហើយមុខរបរជាអ្នកនេសាទត្រូវធ្វើនោះ!
- ការនេសាទត្រីគឺជាមុខរបរប្រចាំថ្ងៃរបស់ពួកគេ! ព្រះយេស៊ូវបានត្រាស់ហៅពួកគេឲ្យទៅធ្វើកិច្ចការខ្លះៗប្លែកពីអ្វីដែលពួកគេធ្លាប់ធ្វើពីមុន គឺជារឿងថ្មីសម្រាប់ពួកគេ។ ទ្រង់បានត្រាស់ហៅពួកគេឱ្យចូលរួមជាមួយទ្រង់ក្នុងវិជ្ជាជីវៈវា ឬជាព័ន្ធកិច្ចរបស់ទ្រង់គឺជាការនេសាទមនុស្ស។ មិនត្រឹមតែជាការអញ្ជើញរបស់ព្រះយេស៊ូវឱ្យចូលរួមក្នុងកិច្ចការរបស់ទ្រង់ប៉ុណ្ណោះទេ ប៉ុន្តែបើសិនជាពួកគេបានដើរតាមទ្រង់ នោះទ្រង់បានសន្យាថាពួកគេនឹងក្លាយទៅជាអ្នកនេសាទមនុស្សជាទៀតផង។ បុរសទាំង

ប្អូននាក់នោះក៏បានឆ្លើយតបចំពោះការអញ្ជើញរបស់ព្រះយេស៊ូវវិញភ្លាមៗក្នុងពេលនោះមួយរំពេច។ ត្រូវចងចាំថា ក្នុងនាមជាអ្នកនេសាទម្នាក់ គេនឹងមិនដែលរៀបចំដើម្បីនេសាទឡើយ លុះត្រាតែគេមានការជឿជាក់ថានឹងចាប់បានអ្វីមួយ។

- បុរសទាំងនេះបានដឹងអំពីរបៀបដែលត្រូវរៀបចំ សំណាញ់ (អួន) និង របៀបប្រើប្រាស់វាដើម្បីចាប់ត្រីបានយ៉ាងច្បាស់ តែព្រះយេស៊ូវនឹងបង្រៀនពួកគេអំពីរបៀបរៀបចំសំណាញ់ (អួន) និង របៀបប្រើប្រាស់វាយ៉ាងណាដើម្បីអាចឈោងចាប់មនុស្សបាន។ តើព្រះអង្គនឹងធ្វើការនេះបានដោយរបៀបណា? ចូរយើងធ្វើការឆ្លុះបញ្ចាំងអំពីការអញ្ជើញរបស់ទ្រង់បន្តិចសិនៈ "ចូរមកតាមខ្ញុំ" ការអញ្ជើញរបស់ទ្រង់នេះគឺពិតជាការអញ្ជើញដែលមានបង្កប់អត្ថន័យ និង គោលបំណងដើម្បីឱ្យបានចូលមកក្នុងទំនាក់ទំនងជាមួយទ្រង់។ ពេត្រុស អនទ្រេ យ៉ាកុប និង យ៉ូហាន! ចូរអ្នកមកតាមខ្ញុំ! ចូរឲ្យមានការទទួលស្គាល់គ្នា ដើម្បីធ្វើជាមិត្តជាមួយគ្នា។ ជម្រះការអាក្រក់ជាមួយគ្នា ចំណាយពេលវេលាជាមួយគ្នា ចូរយើងប្រកបអាហារជាមួយគ្នា! នៅខណៈណាដែលយើងបានធ្វើដូច្នេះ នោះខ្ញុំនឹងធ្វើឱ្យអ្នកបានទៅជាអ្នកនេសាទមនុស្សវិញម្តង។ ក្នុងខណៈពេលដែលអ្នកទទួលខ្ញុំ បានចំណាយពេលជាមួយខ្ញុំ យកដម្រាប់តាមខ្ញុំ បានមើលឃើញនូវអ្វីដែលខ្ញុំបានធ្វើ ហើយបានឮនូវអ្វីដែលខ្ញុំបាននិយាយ នោះអ្នកនឹងបានក្លាយទៅជាអ្នកនេសាទមនុស្សជាមួយនឹងខ្ញុំមិនខាន។ ខ្ញុំនឹងបង្រៀនដល់អ្នក ហើយអ្នកនឹងរៀនអំពីរបៀបដែលត្រូវធ្វើយ៉ាងណាដើម្បីឲ្យបានសម្រេចជោគជ័យ។ នៅពេលនោះអ្នកនឹងបានក្លាយទៅជាអ្នកជំនាញក្នុងការនេសាទមនុស្ស ហើយអ្នកដទៃប្រាកដជាចង់មករៀនសូត្រអំពីជំនាញនេះពីអ្នកជាក់ជាមិនខានឡើយ។
- ព្រះយេស៊ូវនៅមិនទាន់មានប្រជាប្រិយភាពគ្រប់ផ្នែកទាំងអស់នោះនៅឡើយទេ។ ទ្រង់ទើបតែនឹងបានធ្វើការប្រកាសដំណឹងអំពីនរគស្ថានសួគ៌បានបន្តិចបន្តួចនៅក្នុងតំបន់មួយចំនួន ជុំវិញ ទឹកដីស្រុកកាពើណិម ប៉ុណ្ណោះ (៦១៣) ប៉ុន្តែ អ្វីដែលជាការពិតនោះ គឺថាទ្រង់មិនបានធ្វើអ្វីដើម្បីលើកដម្កើងព្រះនាមសម្រាប់អង្គឯងនោះទេ។ អ្វីៗដែលយើងបានដឹងក្នុងដំណឹងល្អតាមរយៈលោក ម៉ាថាយគឺថាព្រះយេស៊ូវបានចាប់ផ្តើមប្រកាសដំណឹងល្អ។ ចូរនឹកចាំនៅក្នុងគំនិតចុះថា នៅជំនាន់នោះគឺដំណឹងបានធ្វើដំណើរតាមរយៈពាក្យសម្តីដែលបាននិយាយចេញពីមាត់មក។ ក្នុងសម័យកាលនោះ រាល់ទម្រង់នៃប្រព័ន្ធផ្សព្វផ្សាយបែបទំនើបគឺនៅមានទាន់មាននៅឡើយទេ។ ប៉ុន្តែមានមានចម្ងល់មួយបានកើតឡើងថា តើមានអ្វីដែលអាចធ្វើឲ្យព្រះយេស៊ូវមានភាពទាក់ទាញពីសំណាក់បណ្តារជនខ្លាំងដល់ម្ល៉េះ។ ហេតុអ្វីបានជាអ្នកនេសាទទាំងនេះបានសុខចិត្តលះបង់អ្វីៗទាំងអស់ចោល រួចព្រមទៅតាមព្រះយេស៊ូវដូច្នេះ?

## ការអនុវត្តន៍:

1. បើសិនជាព្រះយេស៊ូវបានយាងឆ្លងកាត់ផ្លូវរបស់ខ្ញុំ ហើយទ្រង់បានត្រាស់ហៅខ្ញុំឲ្យដើរតាមទ្រង់ដែរ តើខ្ញុំគួរត្រូវឆ្លើយតបទៅទ្រង់វិញយ៉ាងដូចម្តេច? ____________________

2. បើសិនជាព្រះយេស៊ូវបានសន្យានឹងខ្ញុំថា បើរអ្នកព្រមដើរតាមខ្ញុំ នោះខ្ញុំនឹងធ្វើឲ្យបានក្លាយទៅជាអ្នកនេសាទមនុស្សវិញម្តង តើខ្ញុំគួរត្រូវឆ្លើយតបចំពោះទ្រង់វិញយ៉ាងដូចម្តេច? ____________________

3. ព្រះយេស៊ូវបានសុំខ្ញុំធ្វើជាមិត្តភ័ក្រជាមួយនឹងទ្រង់ ហើយទ្រង់នឹងប្រទាននូវការណែនាំដល់ខ្ញុំដើម្បីឲ្យខ្ញុំបានដើរតាមទ្រង់។ តើខ្ញុំត្រូវឆ្លើយតបទ្រង់វិញយ៉ាងដូចម្តេច? ____________________

# មេរៀនទី ៣- ផ្នែកទី ៤

## សេចក្តីណែនាំ:

ដំណើររឿងបន្ទាប់ទៅតទៀតនេះដែលយើងត្រូវសិក្សា គឺជាដំណើររឿងដែលបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរដំណឹងល្អតាមរយៈលោក ម៉ាថាយ។ គាត់បានប្រាប់យើងអំពីរឿងរ៉ាវផ្ទាល់ខ្លួនរបស់គាត់នៅពេលដែលព្រះយេស៊ូវបានត្រាស់ហៅគាត់ឱ្យដើរតាមទ្រង់។ សាច់រឿងនេះមិនបានរៀបរាប់វែងឆ្ងាយនោះទេ ប៉ុន្តែតាមរយៈរឿងនេះ ត្រូវបានណែនាំឲ្យស្គាល់អំពីតួអង្គថ្មីម្នាក់ទៀត ដែលគាត់បានដើរតាមព្រះយេស៊ូវបម្រើគ្រប់ពំនូកិច្ចទាំងអស់ ប៉ុន្តែគាត់បានប្រឈមនឹងបញ្ហាខ្លះៗដូចជាទាក់ទងទៅនឹងអ្វីដែលទ្រង់បានធ្វើ និង ការបដិសេធន៍មិនទទួលស្គាល់ទ្រង់ថាជាព្រះសង្គ្រោះដែលត្រូវយាងមកទៀតផង។ ចំណែកឯពួកគណៈផារិស៊ីដែលជាគ្រូបង្រៀនខាងច្បាប់នេះ ពួកគេចង់ឲ្យព្រះយេស៊ូវធ្វើការសម្រេចថាតើទ្រង់នឹងត្រូវគោរពប្រតិបត្តិតាមក្រឹត្យវិន័យដែរឬយ៉ាងណា។ មានសំណួរមួយដ៏ក្រអឺតក្រទមរបស់ពួកគណៈផារិស៊ីនោះគឺ: តើអ្នកនឹងកាន់តាមក្រឹត្យវិន័យទាំងប៉ុន្មានដូចដែលពួកយើងបានប្រតិបត្តិតាមនោះឬយ៉ាងណា?

## កិច្ចការ:

ចូរអានព្រះគម្ពីរ ម៉ាថាយ ៩:៩-១៣

- តើអ្នកទារពន្ធម្នាក់នេះគឺជានរណា?
- តើមានការត្រាស់ហៅយ៉ាងដូចម្តេចក្នុងការដើរតាមព្រះយេស៊ូវ?
- តើស្ថានភាពនាពេលនោះមានការអភិវឌ្ឍន៍យ៉ាងដូចម្តេច?

## លំហាត់:

1. ក្នុងកាលដែលព្រះយេស៊ូវកំពុងធ្វើដំណើរនៅតាមផ្លូវ តើទ្រង់បានទតឃើញនរណា (ខ៩)? _____

_____________________________________________

**សំគាល់:** សាច់រឿងមួយនេះក៏មានកត់ត្រាទុកនៅក្នុងព្រះគម្ពីរ ម៉ាកុសជំពូក ២ និងព្រះគម្ពីរ លូកាជំពូក ៥ ផងដែរ។ ប្រហែលជាមានភាពច្របូកច្របល់ខ្លះៗ ចំពោះឈ្មោះរបស់បុរសម្នាក់នេះ ព្រោះថាគាត់ត្រូវបានគេហៅថា លេវី ជាការពិតឈ្មោះ លេវី នេះគឺជាឈ្មោះដែលក្នុងចំណោម សាសន៍យូដាមានការនិយមប្រើខ្លាំងណាស់ យ៉ាងណាមិញដូចជាលោក ពេត្រុសដែលត្រូវបានគេហៅគាត់ថា ស៊ីម៉ូន ដូច្នេះដែរ។ នៅមានសាវ័កផ្សេងៗទៀតដែរ ដូចជា ថូម៉ាស់ ហៅថា ឌីឌីម ហើយលោក ប៉ូល ពីដំបូងគឺ សូល។ ការទទួលយកឈ្មោះថ្មី គឺអ្នក នោះបានមកនៅក្រោមអំណាចរបស់អ្នកដែលបានដាក់ឈ្មោះថ្មីឲ្យហើយ យ៉ាងណាមិញ លេវី គឺបានប្តូរទៅជា ម៉ាថាយ គឺសាវ័កម្នាក់ដែរ។

2. តើព្រះយេស៊ូវបានឃើញគាត់នៅឯណា (៩៩)? ____________________

____________________

3. លោក ម៉ាថាយគឺជាអ្នកទារពន្ធម្នាក់! នៅសម័យកាលនោះ អ្នកទារពន្ធត្រូវបានគេចាត់ទុកថាជាជនក្បត់ជាតិខ្លួនឯង ដោយសារពួកគេគឺជាសាសន៍យូដាតែបែរជាប្រមូលពន្ធសម្រាប់រដ្ឋាភិបាលរ៉ូម៉ាំងទៅវិញ។ ពួកគេត្រូវបានជាប់ឈ្មោះថាជាអ្នកគេងបន្លំ ដ្បិតពួកគេតែងតែទារពន្ធលើសពីចំនួនកំណត់ដែលត្រូវបង់។ តើព្រះយេស៊ូវមានព្រះបន្ទូលគាត់ថាដូចម្ដេច? ____________________

____________________

4. តើលោក ម៉ាថាយ ឆ្លើយតបទៅទ្រង់វិញយ៉ាងដូចម្ដេច? ____________________

____________________

5. ព្រះយេស៊ូវបានត្រាស់ហៅលោក ម៉ាថាយ ឲ្យដើរតាមទ្រង់។ តាមការជាក់ស្ដែង តើការត្រាស់ហៅលោក ម៉ាថាយឲ្យដើរតាមទ្រង់នោះយ៉ាងដូចម្ដេច (៩១០)? ____________________

____________________

6. តើមាននរណាខ្លះបានទៅចូលរួមបរិភោគអាហារល្ងាចនៅផ្ទះរបស់លោក ម៉ាថាយ?

   ក. ____________________

   ខ. ____________________

   គ. ____________________

   ឃ. ____________________

7. ពួកខាងគណៈផារិស៊ីបានតាមដានសង្កេតមើលថា តើមាននរណាខ្លះបានចូលរួមបរិភោគអាហារជាមួយនឹងព្រះយេស៊ូវខ្លះ (៩១១)។ តើគេបានសួរទៅសាវ័ករបស់ព្រះយេស៊ូវយ៉ាងដូចម្ដេច? ____________________

____________________

____________________

8. តើនរណាជាអ្នកដែលបានឮពួកគេសួរនៅពេលនោះ (៩១២)? ____________________

   តើទ្រង់មានព្រះបន្ទូលតបទៅគេវិញយ៉ាងដូចម្ដេច? ពួកអ្នក ____________________

   មិនត្រូវការ ____________________ គឺជា ____________________

   វិញទេតើ។ ____________________

____________________

____________________

## ការឆ្លុះបញ្ចាំង:

នៅក្នុងសាច់រឿងនេះ មានចំណុចប្រទាក់ក្រឡាគ្នាជាច្រើនដែលគួឲ្យចាប់អារម្មណ៍ណាស់:

- រវាងព្រះយេស៊ូវ និង លោក ម៉ាថាយ
- រវាងលោក ម៉ាថាយ និង មិត្តភ័ក្ររបស់គាត់
- រវាងពួកផារិស៊ី និង ពួកសាវ័ក
- រវាងពួកផារិស៊ី និង ព្រះយេស៊ូវ

1. ជាដំបូងចូរយើងក្រឡេកមើលអំពីទំនាក់ទំនងរវាងព្រះយេស៊ូវនិងលោក ម៉ាថាយសិន! ព្រះយេស៊ូវគឺជាព្រះបុត្រារបស់ព្រះជាម្ចាស់ ហើយទ្រង់បរិសុទ្ធ សុចរិត គ្រប់លក្ខណ៍ ទ្រង់បានយាងកាត់តាមផ្លូវនោះរួចបានឃើញលោក ម៉ាថាយដែលជាអ្នកទារពន្ធ ជាមនុស្សទុច្ចរិត ជាបញ្ហាក្នុងសង្គមនៃប្រទេសអ៊ីស្រាអែលដែលត្រូវបានគេមើលងាយ ហើយគ្មានអ្នករាប់រកឡើយ។ បន្ទាប់មកព្រះយេស៊ូវ បានទៅឯលោក ម៉ាថាយ គឺម្នាក់ដែលប្រកបដោយភាពបរិសុទ្ធ បានទៅរកមនុស្សដែលមានអំពើបាប។ ទ្រង់មិនត្រឹមតែបានចូលទៅឯគាត់ប៉ុណ្ណោះទេ ប៉ុន្តែព្រះយេស៊ូថែមទាំងបានត្រាស់ហៅគាត់ឲ្យចូលមកក្នុងទំនាក់ទំនងជាមួយទ្រង់ទៀតផង។ ការដែលទ្រង់ធ្វើដូច្នេះមិនមែនគ្រាន់តែជាទំនាក់ទំនងក្នុងលក្ខណៈមិត្តភាពធម្មតាដែលព្រះយេស៊ូវមាននៅក្នុងព្រះហឫទ័យនោះទេ ប៉ុន្តែព្រះអង្គបានត្រាស់ហៅគាត់ឱ្យដើរតាមទ្រង់ ធ្វើជាសិស្សម្នាក់ក្នុងចំណោមពួកអ្នកដែលទ្រង់បានជ្រើសរើស គឺជាអ្នកដែលបានប្ដេជ្ញាចិត្តចំពោះទ្រង់។ មានមនុស្សជាច្រើន ប៉ុន្តែហេតុអ្វីបានជាព្រះយេស៊ូវជ្រើសរើសយកគាត់ដូច្នេះ? តើអ្នកមិនគិតថាលោកម៉ាថាយ នឹងសួរខ្លួនឯងជារឿយៗថា: ហេតុអ្វីបានជារូបខ្ញុំទៅវិញ? ខ្ញុំបានរស់នៅក្នុងជីវិតមួយជាអ្នក គេងបន្លំមនុស្សគ្រប់គ្នា ខ្ញុំមិនដែលធ្លាប់បានធ្វើល្អចំពោះនរណាម្នាក់ទេ គឺមានតែខ្លួនខ្ញុំផ្ទាល់តែប៉ុណ្ណោះ ខ្ញុំតែងតែបានទាញយកប្រយោជន៍ពីអ្នកដទៃមកជារបស់ខ្លួនឯងដោយភាពអត្មានិយម ហើយឥឡូវនេះព្រះយេស៊ូវបានត្រាស់ហៅខ្ញុំឱ្យដើរតាមទ្រង់ទៅវិញ។

   **សំនួរ:** តើយើងបានសិក្សាអ្វីខ្លះអំពីព្រះយេស៊ូវ? ____________________

   ______________________________________________

   ______________________________________________

   ______________________________________________

   ______________________________________________

2. ឥឡូវនេះលោក ម៉ាថាយត្រូវបានគេត្រាស់ហៅឱ្យដើរតាមព្រះយេស៊ូវ ហើយតើយើងនឹងឃើញថា គាត់នឹងធ្វើអ្វីនៅពេលបន្ទាប់ទៅទៀតនេះ? គាត់បានយាងព្រះយេស៊ូវឲ្យទៅសោយអាហារល្ងាច នៅផ្ទះរបស់គាត់ គាត់មិនមែនយាងតែព្រះយេស៊ូវតែមួយអង្គប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏បានអញ្ជើញ មិត្តភក្តិរបស់គាត់មួយចំនួនទៀតឲ្យមកចូលរួមបរិភោគអាហារល្ងាចជាមួយគាត់ និង ព្រះយេស៊ូវ ផងដែរ។ ហើយចុះតើមិត្តភ័ក្ររបស់គាត់គឺជានរណា? តើនេះវាហាក់ដូចជាចម្លែកដែរឬទេដែល មិត្តភក្តិរបស់គាត់គឺសុទ្ធតែជាអ្នកទារពន្ធ និង "មនុស្សមានបាប"? តើលោកអ្នកមិនគិតថាអ្នកដែល បានជួបប្រាស្រ័យជាមួយនឹងព្រះយេស៊ូវនឹងអាចផ្លាស់ប្តូរជីវិតមិត្តភ័ក្រ និងមនុស្សឯទៀតៗឲ្យមក ជាមនុស្សត្រឹមត្រូវឡើងវិញទេឬយ៉ាងណា? មិនមែនជាលោក ម៉ាថាយនោះទេ! ព្រោះពាក្យសម្តី របស់គាត់លែងពាក់ព័ន្ធជាមួយគាត់ទៀតហើយ ប៉ុន្តែគាត់បានផ្តង់ទៅរកគោលដៅថ្មីមួយទៀត គឺ ផ្តង់ទៅរកព្រះយេស៊ូវនោះឯង។ លោក ម៉ាថាយចង់ឱ្យមិត្តភក្តិរបស់គាត់ដែលជាពួកអ្នកទារពន្ធ និង "មនុស្សមានបាប" បានជួបជាមួយនឹងមិត្តភ័ក្រថ្មីរបស់គាត់ម្នាក់ (ព្រះយេស៊ូវ) គឺគាត់ចង់ឱ្យពួកគេ បានស្គាល់ព្រះយេស៊ូវដែលជាអ្នករើសអើងចំពោះគាត់ ហើយថែមទាំងបានត្រាស់ហៅគាត់ចូលទៅ ក្នុងទំនាក់ទំនងមួយទ្រង់ទៀតផង។ មិនចាំបាច់ឆ្ងល់អ្វីនោះទេ ឲ្យតែជាពួកអ្នកទារពន្ធ គឺសុទ្ធបានរស់ ក្នុងជីវិតមួយត្រូវបានគេរើសអើង ហើយជាមនុស្សឯកោណាស់ បើនិយាយឲ្យចំទៅ គឺថាពួកគេគឺ សុទ្ធតែជា "មនុស្សមានបាប" ទាំងអស់ ជីវិតពួកគេរស់នៅត្រូវបានគេបោះបង់ចោល ស្អប់ខ្ពើម ចាត់ ទុកថាជាមនុស្សយ៉ាងអាក្រក់នៅក្នុងសង្គម។ ភ្លាមៗនោះ លោក ម៉ាថាយបានទទួលស្គាល់នូវ ព្រះគុណរបស់ព្រះជាម្ចាស់មកលើជីវិតរបស់គាត់ ក្នុងពេលជាមួយគ្នានោះ គាត់ក៏ចង់ឲ្យព្រះគុណនៃ ព្រះជាម្ចាស់បានប្រទានសម្រាប់មិត្តភ័ក្រ និងអ្នកដែលនៅក្នុងរង្វង់របស់គាត់ផងដែរ។

សំនួរ: តើយើងបានសិក្សាអំពីការរង់ប៉ះពាល់របស់ព្រះយេស៊ូវទៅលើជីវិតរបស់លោ ម៉ាថាយ បាន យ៉ាងដូចម្តេចខ្លះ? ________________________________________

________________________________________

________________________________________

តើពួកផារិស៊ីគិតថាខ្លួនគេ គឺជាមនុស្សសុចរិតត្រឹមត្រូវនោះសម្រេចចិត្តក្នុងការចាប់ថ្នាក់លើព្រះ យេស៊ូវត្រង់ចំណុចណាខ្លះទៅ? ពួកគេមានការហួសចិត្ត ដោយមិននឹកស្មានដល់ថាទ្រង់បានចូលរួម សោយអាហារជាមួយនឹងពួកអ្នកទាពន្ធ និង ពួកអ្នកមានអំពើបាបដូច្នេះទាល់តែសោះ។ ហេតុដូចនេះ តើពួគេបានសួរដល់ពួកសាវ័កដូចម្តេច? ________________________________________

________________________________________

________________________________________

ការដែលសួរថា "ហេតុអ្វី?" វាគឺជាឃ្លាមួយដែលមានគ្រោះថ្នាក់ខ្លាំងណាស់ ព្រោះវាអាចបណ្ដាលឱ្យនរណាម្នាក់ត្រូវបានបាក់ទឹកចិត្ត ឬ អន់ចិត្តបាន ទោះបីជាឃ្លាសម្រាប់សួរដោយពាក្យសម្ដី ឬ ការប្រព្រឹត្តរបស់យើងក៏ដោយ។ ហេតុអ្វីបានជាបណ្ដាលឱ្យយើងបង្ហាញអំពីភាពត្រឹមត្រូវខ្លួនឯង។ កាលណាប្រើឃ្លាថា "ហេតុអ្វី" យើងអាចនឹងឆ្លើយនឹងសំនួរបានយ៉ាងត្រឹមត្រូវ ឬ អាចត្រូវបង់ខាតក៏អ្វីម្យ៉ាងមានដែរ។ ឃ្លាថា "ហេតុអ្វី" គឺជាឃ្លាមួយសម្រាប់ប្រើក្នុងការវាយប្រហារគ្នាដោយពាក្យសម្ដី។ "ហេតុអ្វីបានជាគ្រូរបស់អ្នក ..." ពួកផារិស៊ីគឺជាគ្រូផ្នែកខាងក្រឹត្យវិន័យ ហើយតែងតែបានចាត់ទុកខ្លួនឯងថា ល្អប្រសើរជាងមនុស្សឯទៀតៗ។ បើសិនជាពួកសិស្សគឺជាពួកផារិស៊ីវិញ ម៉្លេះសមពួកគេនឹងមិនបរិភោគដោយក្រុមមនុស្សប្រភេទនេះទេ។ ការចោទប្រកាន់ និងការថ្កោលទោសរបស់ពួកផារិស៊ី គឺជាការប្រឆាំងទាស់នឹងព្រះយេស៊ូវ ដោយទ្រង់បានពាក់ព័ន្ធជាមួយនឹងពួកអ្នកមានបាប ដែលជាការខុសពីក្រឹត្យវិន័យនៃបុព្វបុរសរបស់ពួកគេ។ តើពួកសិស្សបានឆ្លើយតបទៅនឹងការរអ៊ូរទាំរបស់ពួកគេវិញយ៉ាងដូចម្ដេច? តើពួកគេបានឆ្លើយតបវិញដែរទេ?

**សំនួរ**: តើយើងបានសិក្សាអំពីការរង់ប៉ះពាល់របស់ព្រះយេស៊ូវទៅលើពួកផារិស៊ីបានដូចម្ដេចខ្លះ? __

________________________________________

________________________________________

________________________________________

________________________________________

________________________________________

________________________________________

ពិតជាគួរឱ្យចាប់អារម្មណ៍ណាស់! ក្នុងការកត់សម្គាល់ក្នុងកាលដែលពួកសិស្សមិនបាននិយាយអ្វីសោះដូច្នេះ។ សូម្បីតែឱកាសក្នុងការឆ្លើយតបសម្រាប់ពួកគេក៏គ្មានផង ពេលនោះព្រះយេស៊ូវបានឮអំពីអ្វីដែលពួកគេបានសួររួចទ្រង់ក៏មានព្រះបន្ទូលថា: "អស់អ្នកណាដែលជាហើយនោះមិនត្រូវការគ្រូពេទ្យទេ ប៉ុន្តែអ្នកដែលឈឺទេ ដែលត្រូវការគ្រូពេទ្យ"។ តើព្រះយេស៊ូវមានព្រះបន្ទូលថាដូចម្ដេច? តើនរណាគឺជាគ្រូពេទ្យ? ហើយនរណាគឺជាអ្នកឈឺ? តើនរណាខ្លះបានដឹងថាព្រះយេស៊ូវគឺជាគ្រូពេទ្យដែលជួយព្យាបាលជម្ងឺបាបរបស់មនុស្សលោកបាន? ពួកផារិស៊ីប្រាដកជាទទួលស្គាល់ថាពួកអ្នកទារពន្ធ និងពួកអ្នកមានបាបគឺជាអ្នកកំពុងតែត្រូវការជំនួយ និងការព្យាបាលមិនខាន។ ប៉ុន្តែទោះបីជាពួកគេមានការយល់ស្របបែបនេះក៏ដោយក្ដី ក៏ពួកគេនៅតែគិតថាការជៀសវាងឲ្យឆ្ងាយក្រុមមនុស្សប្រភេទនេះ ទើបពួកគេបានល្អប្រសើរ។

ព្រះយេស៊ូបានជូនដំណើរពួកផារិស៊ីចេញទៅដោយមានព្រះបន្ទូលប្រាប់ដល់ពួកគេថា ចូរឲ្យសង្វាតខាងឯសេចក្តីមេត្តាករុណាចុះ ដែលព្រះជាម្ចាស់ទ្រង់មានព្រះហឫទ័យសប្បុរសក្នុងថ្វាយ មិនដូចជាពួកផារិស៊ីថ្វាយដោយគ្រាន់តែបង្គ្រប់តាមក្រឹត្យវិន័យនោះឡើយ។ ព្រះបន្ទូលចុងក្រោយរបស់ទ្រង់គឺជាការប្រកាសប្រាប់ដល់ពួកផារិស៊ីបានដឹងអំពីហេតុផល ដែលទ្រង់ត្រូវយាងចុះមកលើផែនដីនេះដោយទ្រង់មានព្រះបន្ទូលថា: ខ្ញុំមកមិនមែនមករកមនុស្សសុចរិតនោះទេ តែខ្ញុំមករកមនុស្សមានបាបវិញ។ ហើយថាតើនរណាដែលបានគិតថាខ្លួនគឺជាមនុស្សសុចរិតនោះ? តើព្រះយេស៊ូវបានពិចារណានរណាដែលជាអ្នកមានបាបនោះ?

**សំនួរ:** ព្រះយេស៊ូវបានតស៊ូមតិជំនួសឲ្យលោក ម៉ាថាយ ដែលជាអ្នកទារពន្ធ និងជាសាវ័កម្នាក់ផងដែរ។ តើទ្រង់បានតស៊ូមតិដើម្បីការពារអ្វី? ________________________________

________________________________________________

________________________________________________

________________________________________________

________________________________________________

________________________________________________

# មេរៀនទី ៣ - ផ្នែកទី ៥

## សេចក្តីណែនាំ:

ការងាររបស់យើងនៅក្នុងសាច់រឿងរ៉ាវរបស់លោក ម៉ាថាយមិនត្រូវបានបញ្ចប់នៅឡើយទេ! យើងបានដឹងអំពីអង្គហេតុនៃសាច់រឿងរួចហើយ យើងបានធ្វើការឆ្លុះបញ្ចាំងពីការបង្រៀននៃដំណើររឿងនេះរួចរាល់ហើយដែរ តែយើងមិនទាន់បានយករឿងនេះទៅអនុវត្តន៍នៅក្នុងដំណើរជីវិតរបស់យើងផ្ទាល់នៅឡើយទេ។ តើយើងរៀនអ្វីខ្លះអំពីលោក ម៉ាថាយ និងព្រះយេស៊ូវ ដែលធ្វើឱ្យកើតមានទំនាក់ទំនងអស់រយៈពេលជាច្រើនឆ្នាំកន្លងទៅនេះ ហើយថែមទាំងមានសារៈសំខាន់មកលើជីវិតរបស់យើងរហូតមកដល់សព្វថ្ងៃនេះ?

## រំលឹកការទន្ទេញចងចាំ:

ជាជាងការដែលយើងលើកយកបទគម្ពីរថ្មីមកដើម្បីទន្ទេញចងចាំសម្រាប់មេរៀននេះ យើងគួរតែចំណាយពេលវេលាខ្លះដើម្បីដកយកក្រដាស ឬ សៀវភៅកត់ត្រារបស់លោកអ្នកដែលបានកត់ខគម្ពីរចងចាំជាច្រើនពេលកន្លង ដែលមានលក្ខណៈជាសេរីដើម្បីធ្វើការរំលឹងសារឡើងវិញ។ ចូររកមើលបទគម្ពីរចងចាំថ្មីៗណាមួយដែលទើបនឹងបានសិក្សាហើយអាចជួយដល់យើងបានយល់ច្បាស់ ថាហេតុអ្វីបានជាព្រះយេស៊ូវគឺជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់បានមកកំណើតជាមនុស្សលោក រស់នៅក្នុងចំណោមពួកយើងយ៉ាងដូច្នេះ។ នៅក្នុងសាច់រឿងរបស់លោក ម៉ាថាយ យើងបានដឹងថាគាត់បានចែករំលែករបស់អ្នកទារពន្ធដូចគ្នា និងពួកអ្នកបាបទៀតផង។ ចូរយើងរំលឹង អំពីព្រះគម្ពីរចងចាំត្រង់គម្ពីរ ម៉ាថាយ ១:២ និង ព្រះគម្ពីរ លូកា ១៩:១០ សារឡើងវិញ! ប្រសិនបើលោកអ្នកមិនទាន់បានកត់ត្រាបទគម្ពីរទាំងនេះទុកនៅលើក្រដាស ឬ សៀវភៅកត់ត្រានៅឡើយទេ ដូច្នេះចូរកត់ត្រាក្នុងពេលនេះដើម្បីទន្ទេញឲ្យបានចងចាំ។បន្ទាប់មកចូរធ្វើការពិចារណាចំពោះសំនួរៈ ដោយយោងតាមបទគម្ពីរទាំងនេះ តើហេតុអ្វីបានជាព្រះយេស៊ូវទ្រង់ត្រូវយាងមក? ______

______

______

______

______

## ការអនុវត្តន៍:

1. ហេតុអ្វីបានជាលោកអ្នកគិតថាលោក ម៉ាថាយចង់បញ្ចូលដំណើររឿងរបស់គាត់ (៩:៩-១៣) ចូលទៅក្នុងដំណឹងល្អ? ______

______

2. គ្រប់សាច់រឿងទាំងអស់គឺសុទ្ធតែសំខាន់ ព្រោះថាដំណើររឿងនិមួយៗបានផ្តល់ចំណុចអំណះអំណាងសម្រាប់យើង និងសម្រាប់អស់អ្នកដែលបានស្តាប់រឿងរបស់យើងដែរ។ លោកអ្នកមានរឿងជាច្រើនអាចយកទៅនិយាយប្រាប់ដល់អ្នកដទៃបាន! លោកអ្នកក៏មានអនុស្សាវរីយ៍នៃពេលវេលាដ៏ពិសេសក្នុងជីវិតរបស់អ្នកខ្លះៗដែលមានសារៈសំខាន់សម្រាប់អ្នកខ្លះៗដែរ ដូច្នេះ ចូរនឹកដល់ពេលវេលាណាមួយដែលលោកអ្នកនៅចងចាំច្បាស់: ______________________________

______________________________________________________________

______________________________________________________________

តើមានអនុស្សាវរីយ៍ ឬដំណើររឿងអ្វីដែលបានធ្វើឲ្យលោកអ្នកនៅចងចាំ? ______________

______________________________________________________________

______________________________________________________________

3. តើលោកអ្នកមានពេលវេលាណាមួយដែលមិនអាចបំភ្លេចបានជាជាមួយនឹងព្រះយេស៊ូវ? តើលោកអ្នកកំពុងស្ថិតនៅត្រង់ណាក្នុងការធ្វើដំណើរខាងព្រលឹងវិញ្ញាណរបស់លោកអ្នក? តើមាននរណាខ្លះ ឬមានអ្វីខ្លះ ឬមានកាលៈទេសៈដូចម្តេចដែលបានទាញយកលោកអ្នកបានមកដល់ត្រង់កន្លែងនេះក្នុងពេលនេះ? ______________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

4. ប្រហែលជាលោកអ្នកដូចគ្នានឹងលោក ម៉ាថាយ និងមិត្តភ័ក្ររបស់គាត់មួយចំនួនដែរហើយ ដែលទើបនឹងបានជួបជាមួយព្រះយេស៊ូវជាលើកទីមួយ។ តើលោកអ្នកមានគំនិតដូចម្តេច ចំពោះបុរសម្នាក់នេះដែលបានហៅខ្លួនឯងថាជាបុត្រារបស់ព្រះជាម្ចាស់ដូច្នេះ? តើលោកអ្នកព្រមទទួលស្គាល់ដែរឬទេ? ហេតុអ្វីបានជាលោកអ្នកគិតថាលោក ម៉ាថាយមានការរំភើបចិត្តយ៉ាងខ្លាំងអំពីការនិយាយរឿងរ៉ាវរបស់គាត់ប្រាប់ដល់យើង ហើយបានណែនាំឱ្យលោកអ្នកបានស្គាល់ព្រះយេស៊ូវ? តើគាត់បានដឹងថាគាត់ក៏ចង់ឱ្យលោកអ្នកបានស្គាល់ទ្រង់ដែរឬទេ? ________________

______________________________________________________________

______________________________________________________________

______________________________________________________________

## សេចក្តីបង្រៀន:

យើងបានអានអំពីមនុស្សចំនួនប្រាំនាក់ដែលព្រះយេស៊ូវបានត្រាស់ហៅឱ្យដើរតាមទ្រង់រួចមកហើយ គឺមានដូចជា អនទ្រេ ពេត្រុស យ៉ាកុប យ៉ូហាន ហើយនិង ម៉ាថាយ។ ក្នុងព្រះគម្ពីរ ម៉ាថាយ ១០:២-៤ គឺយើងសិក្សាអំពីឈ្មោះសាវ័កទាំងដប់ពីរនាក់ដែលព្រះយេស៊ូវបានត្រាស់ហៅពួកគេឲ្យធ្វើជាក្រុមសាវ័ក។ តើពួកគេទាំងអស់នោះមានឈ្មោះអ្វីខ្លះ?

១. ____________ ២. ____________

៣. ____________ ៤. ____________

៥. ____________ ៦. ____________

៧. ____________ ៨. ____________

៩. ____________ ១០. ____________

១១. ____________ ១២. ____________

ឥឡូវនេះយើងមានបញ្ជីឈ្មោះសាវ័កទាំងអស់គ្នាហើយ និងបានរៀងបានដឹងនូវចំណុចខ្លះៗរបស់ពួកគេទាំងនេះដែរ។ តើនៅមានអ្វីបន្ថែមផ្សេងទៀតដែលយើងមិនបានសិក្សានៅឡើយ? ____________

____________

____________

____________

គ្មាននៅសេសសល់កន្លែងមួយដែលយើងមិនបានដឹងអំពីបុរសទាំងអស់នេះឡើយ! ចូរយើងទៅសង្កេតមើលនៅក្នុងព្រះគម្ពីរ កិច្ចការ ៤:១៣ តើតាមការសង្កេតឃើញបីចំណុចអំពីបុរសទាំងនេះមានអ្វីខ្លះ?

1. ____________
2. ____________
3. ____________

## លំហាត់:

1. ជាបន្តទៅទៀតនេះ យើងនឹងបានដឹងថាការប្តេជ្ញាចិត្តរបស់ព្រះយេស៊ូវគឺកាន់តែអស្ចារ្យជាអ្វីដែលយើងបានមើលឃើញកាលពីដំបូងទៅទៀត។ នៅក្នុង ព្រះគម្ពីរ លូកា ៩:២៣ តើ ព្រះយេស៊ូវបានតម្រូវឲ្យធ្វើអ្វីខ្លះ? ចូរសរសេរចេញខ ២៣ ទុកនៅក្នុងសៀវភៅរបស់លោកអ្នក: ____________

____________

____________

2. ឥឡូវនេះព្រះយេស៊ូវបានបញ្ជាក់ខ្លះហើយ អំពីកិច្ចការមួយចំនួនក្នុងការដែលត្រូវលើឈើឆ្កាង តាមទ្រង់នោះ។ ឈើឆ្កាង? គ្មាននរណាម្នាក់បាននិយាយរៀបរាប់អំពីឈើឆ្កាងមុនទាល់តែសោះ! មកដល់ត្រង់ចំណុចនេះ ទ្រង់មានព្រះបន្ទូលអំពីការលីឈើឆ្កាងរបស់ខ្ញុំ។ បើយោងតាមបទគម្ពីរទាំងនេះ តើអ្វីទៅគឺជាឈើឆ្កាងរបស់ខ្ញុំដែលត្រូវតាមព្រះយេស៊ូវនោះ? ______________________

______________________________________________________

______________________________________________________

3. ព្រះយេស៊ូវមានព្រះបន្ទូលថានិយាយការលះកាត់ចិត្តខ្លួនឯង នោះគឺជាចំណែកមួយនៃឈើឆ្កាងរបស់មនុស្សម្នាក់ៗ គឺត្រូវតែលះកាត់ចិត្តខ្លួនចោល ដោយយកព្រះជាម្ចាស់ជាទីមួយនៅក្នុងជីវិតរបស់ខ្ញុំ។ មនុស្សយើងទាំងអស់គ្នាត្រូវជាប់មានទោសកំហុសដោយសារការទុលខ្លួនឯងជាទីមួយ "ខ្ញុំជាទីមួយ" ក្នុងជីវិតរស់នៅប្រចាំថ្ងៃ។ ដូច្នេះ តើជីវិតយើងនឹងទៅជាយ៉ាងណាវិញបើសិនជាយើងបានលះកាត់ចិត្តខ្លួនឯងចេញ ហើយលីឈើឆ្កាងរបស់របស់ខ្លួនដើរតាមទ្រង់នោះ? យើងបានដឹងតាមរយៈព្រះគម្ពីរ ភីលីពជំពូក ២ អំពីព្រះយេស៊ូវបានលះកាត់ចិត្តរបស់ទ្រង់ផ្ទាល់ចេញ គឺនៅត្រង់ខ ៧-៨: គឺ ទ្រង់បាន ______________________ មកយក ______________________

ព្រមទាំង ______________ ជា ____________ ផង ហើយ ________________

______________ ដូច្នោះ នោះក៏ ______________________________________

ទ្រង់ ទាំង ______________________ ______________ រហូតដល់ ________

____________________ គឺទ្រង់ ______________________________ ផង។

## ការអនុវត្តន៍:

ចូរលះកាត់ចិត្តខ្លួនឯង ហើយយាងព្រះអម្ចាស់ឲ្យទ្រង់គ្រប់គ្រង និងសោយរាជ្យនៅក្នុងជីវិតរបស់យើងជំនួសវិញ គឺមានតែទ្រង់មួយអង្គគាត់ដែលយើងត្រូវចុះចូលតាមគ្រប់កិច្ចការទាំងអស់។ យើងនឹងលែងធ្វើអ្វីទៅតាមចិត្តនឹកឃើញ ឬ ធ្វើអ្វីៗតាមវិធីរបស់ដូចពីមុនទៀតឡើយ ហើយយើងក៏លែងរស់នៅសម្រាប់ខ្លួនឯងតទៅទៀតហើយ ទោះបីជាពេលវេលា ទ្រព្យសម្បត្តិ និង គ្រប់របស់អ្វីផ្សេងៗទៀត គឺវាមិនមែនជារបស់យើងទៀតទេ។ ផ្ទុយទៅវិញ យើងត្រូវតែទទួលស្គាល់ថា ទាំងពេលវេលា លំនៅដ្ឋាន សេចក្តីអំណរសប្បាយ ផ្នែកហិរញ្ញវត្ថុ និងអ្វីៗទាំងអស់ដែលជារបស់យើងគឺសុទ្ធសឹងតែព្រះជាម្ចាស់បានប្រទានឲ្យទេ គឺដើម្បីឲ្យបានជាសុចរិតនៅចំពោះទ្រង់ ក្នុងខណៈពេលដែលយើងបម្រើដល់ក្រុមគ្រួសារ មិត្តភ័ក្រ ឬចំពោះអស់អ្នកដែលមានសេចក្តីត្រូវការនោះឯង។

ការលះកាត់ចិត្តខ្លួនឯង គឺត្រូវទទួលស្គាល់ថា យើងមិនអាចចុះចូលតាមឆន្ទៈរបស់យើងទៅព្រះអង្គបាននោះទេ ព្រោះថាគ្រប់អ្វីៗទាំងអស់ដែលមាននៅក្នុងយើង ពួកវាតែងតែចង់អូសទាញយើងឲ្យទុកខ្លួនឯងជាទីមួយ "ខ្ញុំជាទីមួយ"។ មានតែដោយអំណាចព្រះចេស្ដារបស់ព្រះយេស៊ូវ និង ដោយសារឈើឆ្កាងរបស់ទ្រង់ប៉ុណ្ណោះ ដែលយើងអាចលះកាត់ចិត្តខ្លួនឯងចេញបាន ហើយលីឈើឆ្កាងរបស់ខ្លួនរួចដើរតាមព្រះយេស៊ូវរាល់តែថ្ងៃបាន។

- នៅក្នុងជីវិតរបស់ខ្ញុំ តើនៅមានផ្នែកណាខ្លះទៀតដែលខ្ញុំបានបញ្ចេញ អត្តចរិត និង អកប្បកិរិយា "ខ្ញុំជាទីមួយ" ទៀត? ______________________________

______________________________

______________________________

______________________________

- តើមានកិច្ចការណាខ្លះដែលខ្ញុំធ្វើ ហើយខ្ញុំនិយាយដើម្បីបង្ហាញថាខ្ញុំមាន អត្តចរិត និង អកប្បកិរិយា "ខ្ញុំជាទីមួយ"? ______________________________

______________________________

______________________________

______________________________

## សេចក្ដីអធិស្ឋានៈ

ចូរសរសេរសេចក្ដីសំណូមអធិដ្ឋានរបស់លោកអ្នកដើម្បីទូលសូមដល់ព្រះជាម្ចាស់ ឲ្យទ្រង់ជួយចម្រើនកម្លាំងដល់លោកអ្នក ដើម្បីអាចធ្វើការលះកាត់ចិត្តខ្លួនឯងបាន ហើយលីឈើឆ្កាងរបស់ខ្លួនដើរតាមព្រះអង្គជារាល់ថ្ងៃបានៈ ______________________________

______________________________

______________________________

______________________________

______________________________

______________________________

# មេរៀនទី ៤

## មេរៀនទី ៤ - ផ្នែកទី ១

### សេចក្ដីណែនាំ:

នេះគឺជាការអស្ចារ្យលើកទីមួយរបស់ព្រះយេស៊ូវដែលទ្រង់បានសម្ដែងចេញនៅក្នុងភូមិ កាណា ភូមិនេះមានទីតាំងស្ថិតនៅក្នុងតំបន់កាលីឡេ វាគឺជាទីប្រជុំជនតូចមួយ វាស្ថិតនៅចំភាគខាងលិចនៃសមុទ្រនៃកាលីឡេផ្ទាល់តែម្ដង។ ដំណើររឿងនេះបានកើតឡើងនៅក្នុងកម្មពិធីរៀបមង្គលការមួយ គឺនៅពីរ ឬបីថ្ងៃមុនដែលព្រះយេស៊ូវបានត្រាស់ហៅពួកសិស្សរបស់ទ្រង់ឲ្យមកជួបជុំគ្នា។ នេះគឺជាលើកដំបូងហើយដែលទ្រង់បានសម្ដែងចេញនូវសិរីរុងរឿងរបស់ទ្រង់ក្នុងចំណោមសាធារណៈ។ ចូរនឹកគិតស្រមៃដល់ពួកសិស្សរបស់ទ្រង់ថាតើនឹងមានអ្វីខ្លះបានកើតឡើងនៅក្នុងគំនិតរបស់ពួកគេ ដែលទើបនឹងបានលះបង់អ្វីៗចោលហើយបានមកដើរតាមទ្រង់។

### កិច្ចការ:

ចូរអានព្រះគម្ពីរ យ៉ូហាន ២:១-១១

- តើមានបញ្ហាអ្វី?
- តើនរណាបានចែកចាយបញ្ហាជាមួយនឹងព្រះយេស៊ូវ?
- តើព្រះយេស៊ូវបានធ្វើដូចម្ដេច?
- តើព្រះយេស៊ូវបានបើកសម្ដែងអ្វី?

### លំហាត់:

1. ជាធម្មតាការអបអរសាទរសម្រាប់កម្មពិធីរៀបមង្គលការមួយនៅក្នុង ប៉ាឡេស្ទីន ស្ថិតនៅក្នុងសម័យកាលរបស់ព្រះយេស៊ូវ យ៉ាងហោចណាស់ក៏មានរយៈពេលប្រហែលមួយសប្ដាហ៍ដែរ! ក្រុមគ្រួសារនៃម្ចាស់ដើមការត្រូវមានភារៈទទួលខុសត្រូវក្នុងការរៀបចំម្ហូបអាហារដើម្បីទទួលដល់ភ្ញៀវដែលបានអញ្ជើញមកចូលរួមគ្រប់ៗគ្នា។ ហើយនេះគឺកម្មពិធីរៀបមង្គលការមួយយ៉ាងពិសេស ពីព្រោះគេមានទាំងបញ្ជីឈ្មោះភ្ញៀវដែលគេបានអញ្ជើញទាំងប៉ុន្មានទៀតផង។ ដោយយោងទៅតាមខ ១-២ តើមាននរណាខ្លះដែលជាភ្ញៀវក្នុងកម្មពិធីរៀបមង្គលការមួយនេះ? ______________________

   ______________________________________________

   ______________________________________________

2. កម្មពិធីកំពុងតែដំណើរការទៅ តើមានបញ្ហាអ្វីបានកើតឡើងនៅពេលនោះ (១៣)? ____________

______________________________________________________________________

3. នាង ម៉ារី មានចិត្តចង់ជួយសង្គ្រោះដល់គ្រួសារម្ចាស់ដើមការកុំឲ្យទទួលនូវភាពអាម៉ាស់ក្នុងចំណោមមនុស្សជាច្រើនបែបនេះទេ។ តើគាត់បានធ្វើដូចម្ដេច? ______________________________

______________________________________________________________________

______________________________________________________________________

4. តើគាត់បានអធិស្ឋានយ៉ាងដូចម្ដេចខ្លះ? ________________________________________

______________________________________________________________________

______________________________________________________________________

តើគាត់បានថ្វាយដំណោះស្រាយមួយដល់ព្រះយេស៊ូវដែរឬទេ? _________________________

______________________________________________________________________

តើគាត់ធ្លាប់បានឃើញព្រះយេស៊ូវសម្ដែងការអស្ចារ្យពីមុនមកដែរឬទេ? _____________

______________________________________________________________________

ហេតុអ្វីបានលោកអ្នកគិតថាគាត់បានទៅឯព្រះយេស៊ូវឲ្យទ្រង់ជួយ? __________________

______________________________________________________________________

5. ការឆ្លើយតមរបស់ព្រះយេស៊ូវហាក់ដូចជាគ្មានការគោរពទាល់តែសោះ ហើយក៏មិនសូវសមរម្យតាមបែបវប្បធម៌ ប្រពៃណីទំនៀមទំលាប់នៅជំនាន់នោះដែរ។ តើទ្រង់មានព្រះបន្ទូលទៅគាត់វិញយ៉ាងដូចម្ដេចខ្លះ (១៤)? ______________________________________________________

______________________________________________________________________

______________________________________________________________________

6. តើនាងម៉ារីបានធ្វើដូចម្ដេច (១៥)? ______________________________________

______________________________________________________________________

7. តើមានអ្វីដែលទំនេរនៅក្នុងដៃក្នុងពេលនោះ (១៦)? __________________________

______________________________________________________________________

សំគាល់: ពាងថ្មធំៗទាំងប៉ុន្មានត្រូវបានដាក់ទឹកសម្រាប់ទឹកលាងជើងដល់ភ្ញៀវដែលមកចូលរួមក្នុងកម្មពិធីនេះ ហើយម្យ៉ាងវិញទៀត កម្មពិធីអាពាហ៍ពិពាហ៍នេះនៅមានរយៈពេលជាច្រើនថ្ងៃទៀត គឺគេត្រូវការទឹកជាច្រើនសម្រាប់ទុកប្រើការ។

8. តើព្រះយេស៊ូវបានណែនាំឲ្យអ្នកបម្រើធ្វើដូចម្ដេច នៅក្នុងខ ៧? ____________________

______________________________________________________________

9. គេក៏ ________________________________________________ (ខ៧)
រួចទ្រង់មានព្រះបន្ទូលប្រាប់ឲ្យពួកគេធ្វើដូចម្ដេច (ខ៨) ________________________

______________________________________________________________

10. តើម្ចាស់នៃកម្មពិធីនោះមានប្រតិកម្មដូចម្ដេច នៅពេលដែលគាត់បានភ្លក់ស្រានោះរួចហើយ (ខ៨)?

______________________________________________________________

11. តើម្ចាស់នៃកម្មពិធីនោះបានប្រាប់ទៅកូនកម្លោះយ៉ាងដូចម្ដេច (ខ១០)? ________________

______________________________________________________________

______________________________________________________________

12. តើព្រះយេស៊ូវបានបើកសម្ដែងដូចម្ដេចតាមរយៈទីសំគាល់នៃការអស្ចារ្យដែលទ្រង់បានសធ្វើ (ខ១១)?

______________________________________________________________

______________________________________________________________

13. តើពួកសាវ័ករបស់ទ្រង់ពួកគេមានប្រតិកម្មដូចម្ដេចដែរ (ខ១១)? ____________________

______________________________________________________________

______________________________________________________________

## ការឆ្លុះបញ្ចាំង:

1. ប្រសិនបើការអធិស្ឋានគឺជាការនិយាយទៅកាន់ព្រះជាម្ចាស់ និងជាការចែករំលែកអំពីការព្រួយបារម្ភ និងភាពខ្វល់ខ្វាយ ហើយប្រសិនបើអ្នកសរសេរព្រះគម្ពីរ ទំនុកតម្កើងបានលើកទឹកចិត្តឱ្យយើងផ្ទេររាល់ក្ដីព្រួយកង្វល់របស់យើងទាំងអស់នៅលើទ្រង់ (ទំនុកដំកើង ៥៥:២២) ហើយបានប្រាប់យើងឲ្យអំពាវនាវរកទ្រង់នៅថ្ងៃណាដែលមានអាសន្ន (ទំនុកដំកើង ៥០:១៥) បើដូច្នេះ តើយើងបានរៀនអ្វីខ្លះអំពីសេចក្ដីអធិស្ឋានក្នុងខណៈពេលដែលយើងសង្កេតពីនាង ម៉ារី តាមរយៈគម្ពីរ យ៉ូហាន ជំពូក ២? ________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

2. បើសិនជាព្រះយេស៊ូវរបស់ព្រះយេស៊ូធ្វើការអស្ចារ្យដើម្បីបើកសម្តែងពីសិរីរុងរឿងរបស់ទ្រង់ ព្រមទាំងប្រទានការប្រមើលឲ្យដឹងជាក់ថាទ្រង់គឺជានរណា។ តើយើងរៀនអំពីអំណាចនិងព្រះហឫទ័យដ៏សប្បុរសរបស់ព្រះជាម្ចាស់ចេញមកពីការអស្ចារ្យដំបូងរបស់ព្រះយេស៊ូវ? តើយើងបានសិក្សា អំពីឫទ្ធានុភាព និង សេចក្តីសប្បុរសរបស់ព្រះជាម្ចាស់ យ៉ាងដូចម្តេចចេញពីទីសម្គាល់និងការអស្ចារ្យជាលើកដំបូងរបស់ព្រះយេស៊ូវ។ ________________________________________

____________________________________________________________

____________________________________________________________

## សេចក្តីអធិស្ឋានៈ

ឱ ព្រះយេស៊ូវអើយ! នាងម៉ារីបានមកឯងទ្រង់ ហើយបានចែកចាយនូវក្តីព្រួយបារម្ភរបស់គាត់ប្រាប់ដល់ព្រះអង្គយ៉ាងសមញ្ញធម្មតា បើទោះបីជានេះគឺជា ក្តីខ្វល់ខ្វាយបែបលោកីយ៍សម្រាប់ទ្រង់យ៉ាងណាក៏ដោយ ប៉ុន្តែព្រះអង្គនៅតែយកព្រះហឫទ័យទុកដាក់ចំពោះសេចក្តីអធិស្ឋានរបស់គាត់ដែរ។ គាត់បានទូលថ្វាយដល់ទ្រង់យ៉ាងសមញ្ញថាៈ "ពួកគេអស់ស្រាហើយ" យើងក៏បានឃើញថាគាត់មិនចាំបាច់ ត្រូវរៀបរាប់ទូលថ្វាយព្រះអង្គអំពីអ្វីដែលគាត់ត្រូវការនោះដែរ ឬ ចង់ឲ្យព្រះអង្គធ្វើយ៉ាងណាដែរ ប៉ុន្តែគ្រាន់តែ ទទួលយកនូវអ្វីៗដែលបានត្រៀមទុកជាស្រេចសម្រាប់ការអស្ចារ្យប្រកបដោយសេចក្តីស្រឡាញ់ និងសេចក្តីសប្បុរសរបស់ទ្រង់ប៉ុណ្ណោះ។ ព្រះអង្គមិនទាំងបានឆ្លើយតបចំពោះក្តីព្រួយបារម្ភរបស់គាត់វិញផង ប៉ុន្តែ ទ្រង់បានប្រទានពរដល់មនុស្សគ្រប់គ្នានៅក្នុងពិធីរៀបមង្គលការនោះដោយការរៀបចំបម្រើបានយ៉ាងល្អជាទីបំផុត។ សូមទ្រង់ជួយឱ្យទូលបង្គំចេះជឿទុកចិត្តលើព្រះអង្គជាមួយនឹងទុក្ខកង្វល់របស់ទូលបង្គំដែលមានទាំងប៉ុន្មានផង។ សូមទ្រង់បង្រៀនទូលបង្គំឲ្យចេះនឹកចាំអំពីអ្វីៗដែលទ្រង់មានព្រះបន្ទូលប្រាប់ដល់ទូលបង្គំផង ដើម្បីឲ្យទូលបង្គំបានធ្វើកិច្ចការសម្រាប់ទ្រង់ ដូចដែលទ្រង់បានជ្រាប់គ្រប់ការទាំងអស់ស្រាប់ហើយ។ ចំពោះអ្វីៗទាំងអស់ខាងលើនេះ ទូលបង្គំសូមអរគុណដល់ព្រះអង្គ! ក្នុងការដែលទូលបង្គំអាចចូលមកនៅចំពោះព្រះភ័ក្រទ្រង់ ជាមួយនឹងក្តីខ្វល់ខ្វាយផ្ទាល់ខ្លួន និង ការព្រួយបារម្ភផងដែរ ហើយក៏សម្រាប់អស់អ្នកដែលទូលបង្គំស្រឡាញ់ផងដែរ។ ______________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

## ចំណុចត្រូវចងចាំ:

បន្ទាប់ពីបានអានអំពីការអស្ចារ្យជាលើកទីមួយរបស់ព្រះយេស៊ូវហើយ យើងអាចយកទ្រង់មកធ្វើជាអ្នកធ្វើសម្តែងការអស្ចារ្យ ជាមួយគ្នានេះដែរ យើងចង់បន្តការសិក្សាសាច់រឿងផ្សេងៗទៀតដែលបាននិយាយអំពីទីសំគាល់ និង ការអស្ចារ្យរបស់ទ្រង់ទៀត។ ដោយហេតុផលនេះ វាគឺជាការសំខាន់ណាស់ដែលតម្រូវឲ្យយើងចងចាំទុកថាហេតុអ្វីបានជាព្រះយេស៊ូវត្រូវយាងមក។ ឆ្លងតាមការសិក្សារបស់យើងនៅក្នុងព្រះគម្ពីរ យ៉ូហាន ៣:១៦-១៨ បានធ្វើឲ្យយើងដឹងថា ព្រះបិតាបានប្រទានព្រះរាជបុត្រាទ្រង់ព្រះយេស៊ូវមកដល់យើង គឺដើម្បីឱ្យយើងទទួលបាននូវជីវិតដ៏នៅអស់កល្ប។ ហើយនៅក្នុងខ ១៧ បានប្រាប់ឲ្យយើងបានដឹងថា ព្រះយេស៊ូវបានយាងមកយកកំណើតជាមនុស្សនៅលើផែនដីនេះ គឺដើម្បីឲ្យមនុស្សគ្រប់ៗគ្នាអាចទទួលបានសេចក្តីសង្គ្រោះឲ្យរួចពីអំពើបាប។ រីឯការអស្ចារ្យដែលព្រះយេស៊ូវបានធ្វើនោះត្រូវបានគេហៅទីសំគាល់។ ពួកគេបានសម្រេចតាមបទទំនាយអំពីព្រះមេស៊ីដែលត្រូវយាងមកហើយ (ដូចជានៅក្នុងព្រះគម្ពីរ អេសាយ ៦១:១-២)។ ទីសំគាល់និមួយៗ ជាការពិតសុទ្ធបានបង្ហាញអំពីភាពអស្ចារ្យជាទីបំផុតនៃទីសំគាល់របស់គាត់ និង សិរីរុងរឿងយ៉ាងអស្ចារ្យបំផុតដែរ ជាពិសេសនោះគឺឈើឆ្កាងនោះតែម្តង។ អ្វីៗទាំងអស់នេះគឺជាហេតុផលចំបងបំផុតដែលតម្រូវឲ្យទ្រង់យាងមកលើផែនដីនេះ (យ៉ូហាន ១២:២៣-៣៧ ជាពិសេសខ ២៧)។

## លំហាត់:

1. ដោយយោងទៅលើបទគម្ពីរ ម៉ាថាយ ៤:២៣ តើព័ន្ធកិច្ចចំបងទាំងបីរបស់ព្រះយេស៊ូវមានអ្វីខ្លះ?
   ក. ______________________________
   ខ. ______________________________
   គ. ______________________________
2. ដំណឹងត្រូវបានផ្សព្វផ្សាយនៅទូទាំងផែនដី! ចូរលោកអ្នករៀបរាប់អំពីអ្នកជម្ងឺម្នាក់ដែលមានជម្ងឺជាច្រើនមុខដែលត្រូវបានគេយកទៅឯព្រះយេស៊ូវ:
   ក. ______________________________
   ខ. ______________________________
   គ. ______________________________
   ឃ. ______________________________

3. **បណ្តារជនបាននាំគ្នាមក ហើយព្រះយេស៊ូវ** ______________________________________

________________________________________________________

________________________________________________________ **ពួកគេ។**

4. **ចូរប្រើប្រាស់ផែនទីរបស់លោកអ្នក ដើម្បីកំណត់ទីតាំងនៃតំបន់ និង ទីក្រុងមួយចំនួនដែលបានលើកឡើងនៅក្នុងខ ២៥។ យើងបានដឹងថា មានហ្វូងមនុស្សយ៉ាងច្រើនបានមកតាមទ្រង់។ ហេតុអ្វីបានលោកអ្នកមានចិត្តមន្ទិលសង្ស័យចំពោះហ្វូងមនុស្សជាច្រើនបានមកតាមព្រះយេស៊ូវដូច្នេះ?** _____

________________________________________________________

________________________________________________________

________________________________________________________

តើការដើរតាមព្រះយេស៊ូវនៅទីនេះ មានភាពខុសគ្នាពីការដើរតាមទ្រង់នៅក្នុងព្រះគម្ពីរម៉ាកុស ៨:៣៤ យ៉ាងដូចម្តេចខ្លះ? ______________________________

________________________________________________________

________________________________________________________

________________________________________________________

## សំនួរអនុវត្តន៍:

បើសិនជាខ្ញុំគឺជាមនុស្សម្នាក់នៅក្នុងចំណោមហ្វូងមនុស្សដែលបានដើរតាមព្រះយេស៊ូវ តើហេតុអ្វីបានជាខ្ញុំត្រូវដើរតាមទ្រង់? តើទ្រង់មានអ្វីខ្លះដែលជាភាពទាក់ទាញដល់មនុស្សជាច្រើនដូច្នេះ? ____________

________________________________________________________

________________________________________________________

________________________________________________________

________________________________________________________

________________________________________________________

# មេរៀនទី ៤ - ផ្នែកទី ២

## សេចក្តីណែនាំ:

ឥឡូវចូរយើងនាំគ្នាសង្កេតមើលអំពីគំរូនៃព័ន្ធកិច្ចការប្រោសឱ្យរបស់ព្រះយេស៊ូវទាំងអស់គ្នា។ ប្រហែលជាជម្ងឺទាំងអស់នោះមានការភ័យខ្លាចចំពោះព្រះយេស៊ូវហើយ ដូចជាជម្ងឺឃ្លង់នេះជាដើម។ នៅក្នុងព្រះគម្ពីរ លេវីវិន័យជំពូក ១៣ បានកត់ត្រាទុកយ៉ាងច្បាស់លាស់ ចំពោះបុគ្គលណាដែលបានប៉ះពាល់នឹងអ្នកជម្ងឺឃ្លង់។ ចំពោះអស់អ្នកណាម្នាក់មានដែលមានជម្ងឺឆ្លងសើរស្បែកមួយឆ្លង នោះត្រូវឲ្យយកអ្នកជម្ងឺនោះទៅឯពួកអាចារ្យ។ ពួកបូជាចារ្យដើម្បីធ្វើការត្រួតពិនិត្យមើល បើសិនជាមាន ការបញ្ជាក់ថាអ្នកនោះពិតជាមានសើរស្បែកឆ្លងមែន នោះពួកអាចារ្យនឹងប្រកាសថា អ្នកនោះគឺជាមនុស្សមិនស្អាត ឬ ជាមនុស្សមិនបរិសុទ្ធ។

## កិច្ចការ:

ជាមួយនឹងការណែនាំនៅក្នុងគំនិតនេះ ចូរយើងអានព្រះគម្ពីរ លេវីវិន័យ ១៣:៤៥-៤៦

## លំហាត់:

បញ្ញត្តិរបស់ព្រះជាម្ចាស់នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មានច្បាប់ហាមប្រាមយ៉ាងច្បាស់លាស់អំពីអ្នកជម្ងឺឆ្លងសើរស្បែកនេះ។ តើនៅក្នុងព្រះគម្ពីរ លេវីវិន័យ ១៣:៤៥-៤៦ មានសេចក្តីណែនាំយ៉ាងដូចម្តេចខ្លះ?

ក. ______________________________

ខ. ______________________________

គ. ______________________________

ឃ. ______________________________

ង. ______________________________

## ការឆ្លុះបញ្ចាំង:

បើសិនជាស្ត្រី ឬ បុរសណាដែលត្រូវបានពួកអាចារ្យប្រកាសថាជាមនុស្សមិនស្អាតស្អំ ឬជាមនុស្សមិនបរិសុទ្ធហើយ នោះតើនឹងមានការអ្វីកើតឡើងចំពោះអ្នកជម្ងឺរូបនោះ? មនុស្សម្នាក់នេះមានជម្ងឺឆ្លង ហើយឥឡូវគឺតម្រូវឲ្យគាត់ធ្វើតាមច្បាប់ដែលបានចែងទុកនៅក្នុងព្រះគម្ពីរ លេវីវិន័យជំពូក ១៣: __________

______________________________

______________________________

______________________________

តើលោកអ្នកនឹងគិតដូចម្ដេច បើសិនជាអ្នកជម្ងឺឃ្លង់ម្នាក់នោះគឺជារូបលោកអ្នក? ________________

________________________________________________

តើលោកអ្នកនឹងមានប្រតិកម្មដូចម្ដេចចំពោះការកំណត់នៅក្នុងច្បាប់ បើសិនជាលោកអ្នកបានដឹងអំពីភាពចាំបាច់ក្នុងការថែរក្សាសុខភាព និងការប៉ះពាល់ដល់សហគមន៍អ៊ីស្រាអែលទាំងមូល? តើលោកអ្នកនឹងឆ្លើយតបតាមរបៀបផ្សេងដែរទេ? ________________

________________________________________________

## គំនិតអធិស្ឋានៈ

ចូរយើងបានចំណាយពេលស្ងប់ស្ងាត់ដើម្បីចូលទៅក្នុងព្រះវត្តមានរបស់ព្រះអម្ចាស់! ហើយចូរទូលសូមដល់ទ្រង់ដើម្បីបើកចិត្តគំនិតរបស់លោកអ្នកចំពោះការបង្រៀនរបស់ទ្រង់។ ចូរទូលសូមដល់ទ្រង់ សម្រាប់ការរីកចម្រើនលើការយល់ដឹងអំពើបាប និងផលប៉ះពាល់មកលើលោកអ្នកផ្ទាល់ ក៏ដូចជា សហគមន៍ដែលលោកអ្នកបានរស់នៅដែរ។ ចូរអរព្រះគុណដល់ទ្រង់ដែលដំណើរនេះមិនទាន់ត្រូវបានបញ្ចប់នៅឡើយ។ ________

________________________________________________

________________________________________________

## កិច្ចការៈ

1. ចូរអានបទគម្ពីរដែលអាចដឹងអំពីដំណើររឿងនេះជាមុន (ម៉ាកុស ១:៣៥-៣៩)
   - តើព្រះយេស៊ូវធ្វើដំណើរយាងទៅណា (ខ៣៩)? ________________

     ________________________________________
   - តើទ្រង់ធ្វើអ្វីខ្លះ (ខ៣៩)?

     . ________________________________________

     . ________________________________________
2. ចូរអានព្រះគម្ពីរ ម៉ាកុស ១:៤០-៤៥
   - តើតួអង្គក្នុងរឿងនេះគឺជានរណា? ________________

     ________________________________________
   - តើមានបញ្ហាអ្វីខ្លះ? ________________

     ________________________________________
   - តើមានដំណឹងអំពីអ្វី? ________________

     ________________________________________

## លំហាត់:

1. ព្រះយេស៊ូវបានកំណត់ថានឹងត្រូវធ្វើដំណើរពីភូមិមួយទៅភូមិ និង ពីសាលាប្រជុំមួយទៅសាលាប្រជុំមួយទៀតដើម្បីប្រកាសព្រះបន្ទូល និង បង្រៀនដល់បណ្តាជន ដោយទ្រង់មានចេតនាក្នុងការប្រកាសដំណឹងល្អដល់មនុស្សគ្រប់ៗគ្នា។ ព្រះរាជនៃព្រះជាម្ចាស់ (គឺការដឹកនាំ និងសោយរាជ្យនៅក្នុងចិត្តគំនិតរបស់មនុស្ស) ចំណែលឯនៅក្នុងរាជរបស់សាតាំងវិញគឺជាការបំផ្លាញចោលវិញ។ ទ្រង់បានប្រាប់យ៉ាងច្បាស់ណាស់ថាទ្រង់គឺជានរណា? ហើយមានគោលបំណងបែបណា។ នៅក្នុងខ ៣៨ តើទ្រង់មានព្រះបន្ទូលទៅកាន់ពួកសិស្សដែលកំពុងតែស្វែងរកទ្រង់ដូចម្តេចខ្លះ? ________

______________________________________________

______________________________________________

______________________________________________

នេះហើយគឺជាអ្វីដែលទ្រង់បានប្រាប់ពួកគេថាហេតុអ្វីបានជាទ្រង់ត្រូវយាងមក។ ចូរកត់សំគាល់លើសេចក្តីយោងត្រង់ខ ៣៨ មានអំណះអំណាងនៅក្នុងព្រះគម្ពីរ អេសាយ ៦១:១។

2. តើនរណាបានមកឯព្រះយេស៊ូវ (ខ៤០)? ______________________________

______________________________________________

3. ដំណើររឿងមួយនេះ គឺមានតួអង្គពីររូបគឺ ព្រះយេស៊ូវ និង អ្នកជម្ងឺឃ្លង់ម្នាក់។ នៅជុំវិញឈុតឆាកនៃសាច់រឿងនេះ តើលោកអ្នកនឹកស្រមៃឃើញថាតើបុរសដែលមានជម្ងឺឃ្លង់នោះមានលក្ខណៈ ដូចម្តេចទៅ? ______________________________________________

______________________________________________

4. តើអ្នកជម្ងឺឃ្លង់ម្នាក់នេះបានស្រែកឡើងថាដូចម្តេច (លេវីវិន័យ ១៣:៤៥)? ____________

______________________________________________

______________________________________________

5. បើសិនជាអ្នកជម្ងឺឃ្លង់ម្នាក់នេះបានរស់នៅឆ្ងាយពីមនុស្សម្នាឯទៀតៗ តើព្រះយេស៊ូវគួតែអាចជួបគាត់ឯណា? ______________________________________________

______________________________________________

6. តើបុរសម្នាក់នេះ មានអត្តចរិត និង អាកប្បកិរិយាយ៉ាងដូចម្តេច (ខ៤០)? ____________

______________________________________________

______________________________________________

7. គាត់បានស្រែកអង្វររកសេចក្ដីអាណិតមេត្តា ដោយទូលសូមឲ្យព្រះយេស៊ូវជួយដល់គាត់ ព្រោះវាគឺជារឿងដែលគាត់មិនអាចជួយខ្លួនឯងបាន។ តើគាត់បានទូលទៅព្រះយេស៊ូវដូចម្ដេច (៤៧)? ___

________________________________________

________________________________________

8. តើបុរសម្នាក់នេះបានសារភាពអំពីស្ថានភាពរបស់គាត់យ៉ាងដូចម្ដេចខ្លះ? ____________

________________________________________

________________________________________

9. តើមានអ្វីបណ្ដាលឲ្យគាត់បានមករកព្រះយេស៊ូវ? ____________________

________________________________________

________________________________________

10. តើគាត់បានដឹងថាព្រះយេស៊ូវអាចជួយគាត់បានដោយរបៀបណា? ______________

________________________________________

________________________________________

ចូរចងចាំទុកថា គាត់ក៏បានដឹងដែរថាព្រះយេស៊ូវអាចនឹងមិនប្រោសជម្ងឺគាត់ឡើយ!

# មេរៀនទី ៤ - ផ្នែកទី ៣

## ការអនុវត្តន៍:

បើតាមច្បាប់ផ្នែកខាងព្រលឹងវិញ្ញាណជម្ងឺឃ្លង់ គឺជារូបភាពមួយនៃការជាប់មានអំពើបាបរបស់យើង។ តាមការវាយតម្លៃដ៏ស្មោះត្រង់មួយមកលើជីវិតរបស់យើង គឺថាយើងត្រូវបានហ៊ុំព័ទ្ធទៅដោយអំពើបាបហើយបង្ខំឱ្យយើងប្រឈមមុខជាមួយនឹងការលំបាកជាក់ស្តែងជាច្រើន។ ក្រៅពីព្រះយេស៊ូវគឺគ្មានដំណឹងល្អនោះទេ! ក្នុងការចាប់ផ្តើមធ្វើការព្យាបាលជម្ងឺរបស់យើង នោះយើងត្រូវតែទទួលស្គាល់ អំពីស្ថានភាព និង អាការៈនៃជម្ងឺរបស់យើងតាំងពីយូរមកហើយក៏ដោយរហូតមកទល់នឹងការប្រោសឲ្យជា។

- តើលោកអ្នកនឹងត្រូវនិយាយប្រាប់អ្នកដទៃដូចម្តេច បើសិនជាលោកអ្នកមានជម្ងឺឆ្លង? ____________________________________________

  ____________________________________________

- តើលោកអ្នកនឹងត្រូវទទួលការរើសអើង ឬ មើលងាយពីសំណាក់មនុស្សនៅក្នុងសង្គម ហើយតម្រូវឲ្យលោកអ្នករស់នៅជាមួយនឹងសំលៀកបំពាក់កខ្វក់ ហើយសក់ក្បាលរញ៉េរញ៉ៃបានយ៉ាងដូចម្តេច? ____________________________________________

  ____________________________________________

- តើលោកអ្នកនឹងត្រូវរស់នៅដោយការខ្ទប់មាត់ជិត ដើម្បីឲ្យមានការខាកស្តោះ ដែលជាហេតុនាំឲ្យមានការចម្លងជម្ងឺទៅអ្នកដទៃទៀតបានយ៉ាងដូចម្តេច?____________________________________________

  ____________________________________________

- តើលោកអ្នកនឹងត្រូវធ្វើដូចម្តេចទៅ បើចំពោះវត្តមានរបស់លោកអ្នកវាហាក់បីដូចជាការព្រមានដល់អ្នកដទៃ បើទោះបីជាកាលពីពេលមុនលោកអ្នកធ្លាប់ជាមនុស្សម្នាក់ដែលមានភាពទាក់ទាញយ៉ាងណាក៏ដោយនោះ? ____________________________________________

  ____________________________________________

- ហើយតើលោកអ្នកគិតដូចម្តេច ឬត្រូវធ្វើយ៉ាងណា ក្នុងការរស់នៅឯកោតែម្នាក់ ដោយគ្មានទំនាក់ទំនងជាមួយអ្នកណាសោះ? គ្មានការអោប គ្មានការថើប ហើយក៏គ្មានភាពស្និទ្ធស្នាលអ្វីសោះដូច្នេះ? ____________________________________________

  ____________________________________________

## ការឆ្លុះបញ្ចាំង:

អំពើបាប គឺជាជម្ងឺឆ្លងម្យ៉ាងដែលត្រូវបានចម្លងបន្តយ៉ាងសាហាវនៅក្នុងប្រវត្តិសាស្ត្រ គឺវាបានចម្លងទៅដល់មនុស្សគ្រប់ៗរូបពីជំនាន់មួយទៅជំនាន់មួយទៀត ដោយគ្មានរំលងជនណាម្នាក់នោះឡើយ។ ហើយពួកយើងម្នាក់ៗសុទ្ធតែមានជម្ងឺនេះទាំងអស់គ្នា ជាលទ្ធផលនៅចុងបញ្ចប់នៃជម្ងឺនេះគឺសេចក្តីស្លាប់! ជម្ងឺឆ្លងរបស់ពួកយើងគឺជាការបែកចេញពីព្រះវរបិតារបស់យើង ដែលទ្រង់មានពេញទៅដោយភាពបរិសុទ្ធហើយសុចរិត។ នៅចំពោះព្រះភ័ក្រទ្រង់យើងអាចបានត្រឹមតែយំដោយស្រែកថា "មិនបរិសុទ្ធ! មិនបរិសុទ្ធ!" តែប៉ុណ្ណោះ។ ជម្ងឺឆ្លងរបស់យើងម្នាក់ៗ វាមិនត្រឹមតែបានបំបែកយើងឲ្យដាច់ទំនាក់ទំនងជាមួយនឹងព្រះវរបិតាប៉ុណ្ណោះទេ វាថែមទាំងធ្វើឲ្យយើងបែកចេញពីមនុស្សដូចគ្នាទៀតផង។ មេរោគនៃជម្ងឺនេះ វាបានបំផ្លាញរាល់ទំនាក់ទំនងរបស់ទាំងប៉ុន្មានឲ្យដាច់ចេញពីគ្នាអស់ ហើយទីបំផុតវាបានធ្វើឲ្យយើងរស់ក្នុងភាពឯកោ ហើយភ័យខ្លាចទាំងបង្ខំចិត្ត។

## គំនិតអធិស្ឋាន:

បុរសម្នាក់នេះបានចូលមករកព្រះយេស៊ូវក្នុងសភាពជាជនអនាថា ដែលត្រូវបានមនុស្សគ្រប់គ្នាបោះបង់គាត់ចោល ដោយបង្ខំឲ្យគាត់រស់នៅក្រៅសង្គមយ៉ាងតែលតោល ប៉ុន្តែនៅក្នុងពេលនេះគាត់បានមកអង្វរសូមឲ្យព្រះយេស៊ូវជួយដោយសេចក្តីអាណិតមេត្តាដល់គាត់ ទាំងគាត់បានដឹងថាគាត់មិនសក្តិសមឲ្យព្រះយេស៊ូវអាណិតអាសូរឡើយ តែគាត់នៅតែទទូចសូមឲ្យទ្រង់ជួយ។ គាត់បានចូលមកឯព្រះយេស៊ូវដោយការបន្ទាបខ្លួន និងការលន់តួយ៉ាងបើកចំហរ ហើយស្មោះត្រង់យ៉ាងអស់ពីចិត្ត ដើម្បីទូលសូមនូវសេចក្តីស្រលាញ់ និងការអត់ទោសបាបពីទ្រង់។ គាត់បានចូលមករកព្រះយេស៊ូវដោយចិត្តក្លាហាននៅចំពោះព្រះភ័ក្រទ្រង់ ដើម្បីទូលសូមអ្វីៗគ្រប់យ៉ាងពីទ្រង់។ ______________________________

______________________________

______________________________

______________________________

______________________________

## សេចក្តីបង្រៀន:

អ្នកជម្ងឺឃ្លង់ម្នាក់នេះ បានដឹងយ៉ាងច្បាស់ថាព្រះយេស៊ូវអាចប្រោសជម្ងឺគាត់ឲ្យជាសះស្បើយមិនខាន។ ចូរនឹកស្រមៃទៅដល់ទិដ្ឋភាពដែលបុរសម្នាក់លុតជង្គង់ ទូលសូមយ៉ាងទទូចនៅចំពោះព្រះយេស៊ូវរំដោះគាត់ចេញពីជីវិតដែលកខ្វក់ ឯកោ និងត្រូវបានគេបោះបង់ចោល។ គាត់មានបំណងចង់ឱ្យព្រះយេស៊ូវដោះរាល់បណ្តាសារទាំងអស់នោះចេញ។

ពីព្រោះវាបានធ្វើឲ្យជីវិតរបស់គាត់ព្រាត់ប្រាស់បែកចេញឆ្ងាយពីក្រុមគ្រួសារ បែកពីមិត្តភ័ក្រ ហើយវាថែមទាំងបានធ្វើដាច់ចេញពីទំនាក់ទំនងជាមួយព្រះជាម្ចាស់ទៀតផង គឺតាមរយៈការ ប្រកាសរបស់ពួកអាចារ្យថាជាមនុស្សមិនស្អាតស្អំ ជាមនុស្សមានអំពើបាប។ ______________________________

______________________________

______________________________

______________________________

## លំហាត់:

1. តើមានអ្វីបានចូលទៅខាងក្នុងព្រះយេស៊ូវ (ខ៤១)? ______________________________

   ______________________________

   ក. **សេចក្តីមេត្តាករុណា** គឺជាឃ្លាមួយដ៏គួរឱ្យចាប់អារម្មណ៍ជាទីបំផុត! ព្រោះថាឃ្លាមួយនេះវាមានអនុភាព និងមានអត្ថន័យជាងការដែលមានអារម្មណ៍ថាសោកស្តាយចំពោះនរណាម្នាក់។ ភាពអាណិតមេត្តាករុណា វាអាចបង្កឲ្យមនុស្សម្នាក់ទៅជាមានជម្ងឺបាន ដោយសារតែការឈឺចាប់ ឬ របួសរបស់នរណាម្នាក់។ បុរសម្នាក់នេះ ធ្វើប៉ះពាល់រហូតដល់ក្រពះរបស់ព្រះយេស៊ូវហើយ ដ្បិតទ្រង់មានសេចក្តីអាណិតអាសូរ និង សេចក្តីមេត្តាករុណាចំពោះបរុសម្នាក់យ៉ាងពោរពេញក្នុងព្រះហឫទ័យទៅហើយ។ នៅពេលណាដែលឪពុកម្តាយបានឃើញកូនរបស់ខ្លួនទទួលការឈឺចាប់ដោយមិនសមហេតុផល នោះពួកគេនឹងមានអារម្មណ៍ថាឈឺ ដល់ "ក្រពះ" ជាមិនខាន ដោយសារតែឪពុកម្តាយរាល់រូបមានសេចក្តីមេត្តាករុណាចំពោះកូនរបស់ខ្លួន។

   ខ. ព្រះយេស៊ូវបានស្គាល់ និង ដឹងអំពីច្បាប់ទាំងប៉ុន្មានយ៉ាងច្បាស់! ហើយទ្រង់ក៏ជ្រាបអំពីជីវិតរបស់បុរសម្នាក់យ៉ាងច្បាស់ណាស់ដែរ ថាគាត់ឯកោ ត្រូវបានគេមិនរាប់រាប់រក ហើយបោះបង់ចោល ត្រូវរស់នៅតែលតោល កណ្តោចកណ្តែងតែម្នាក់ឯងយ៉ាងអនាថា។ ទ្រង់បានជ្រាបថាដោយសារតែច្បាប់ទើបបានជាធ្វើឲ្យបុរសម្នាក់ក្លាយទៅជាមនុស្សដូច្នេះ។ ពាក្យថា "មិនស្អាតស្អំ ឬមិនបរិសុទ្ធ ឬជាមនុស្សមានបាប" វាបានព្រមានដល់អ្នកដទៃឲ្យនៅឆ្ងាយពីគាត់។

2. សេចក្តីមេត្តាករុណាត្រូវបានឆ្លើយតប! ទោះបីជាយ៉ាងណាក៏ដោយ ក៏ទ្រង់មិនចាកចោលគាត់ ឬដេញគាត់ឲ្យទៅឆ្ងាយពីទ្រង់នោះដែរ។ ចូរសំគាល់មើលថាតើដោយសារសេចក្តីមេត្តាករុណាបាននាំឲ្យព្រះយេស៊ូវធ្វើអ្វីខ្លះ (៤១)? ______________________________

   ______________________________

   ______________________________

សេចក្តីមេត្តាករុណាបណ្តាលឱ្យព្រះយេស៊ូវមានជាសកម្មភាពឡើង! ព្រះអង្គបានលូកព្រះហស្តទៅប៉ះពាល់បុរសម្នាក់នេះ វាគឺជារឿងដែលទ្រង់មិនធ្លាប់បានធ្វើដូច្នេះពីមុនមកទាល់តែសោះ គឺព្រះអង្គបានប៉ះពាល់អ្វីដែលមិនអាចប៉ះពាល់បាន។ វាគឺជារឿងមួយដែលមិនអាចគិតស្មានបានថាព្រះយេស៊ូវបានប៉ះពាល់ខ្លួនប្រាណបុរសឃ្លង់ម្នាក់នេះដោយមិនខ្ពើមរអើមបន្តិចណាសោះបែបនេះ។ តើលោកអ្នកគិតថាបុរសម្នាក់នេះត្រូវបានគេប៉ះពាល់គាត់លើកចុងក្រោយនៅពេលណាដែរ? តើការប៉ះពាល់របស់ព្រះយេស៊ូវបានផ្តល់ទំនាក់ទំនងដូចម្តេចចំពោះបុរស់ម្នាក់នេះ? ____________________

____________________________________________________________

____________________________________________________________

____________________________________________________________

3. ដោយមិនបានគិតឲ្យបានពីរដង ប្រហែលជាយើងមិនបានដឹលងថាទ្រង់បានប៉ះពាល់គាត់ហើយទ្រង់ក៏មានព្រះបន្ទូលទៅកាន់គាត់ដែរ។ តើទ្រង់មានព្រះបន្ទូលទៅកាន់គាត់យ៉ាងដូចម្តេច (ខ៤១)? ___

____________________________________________________________

____________________________________________________________

4. **បុរសម្នាក់នោះត្រូវបានជាប់ក្នុងបណ្តាសារ! ជម្ងឺឃ្លង់បានចេញបាត់ពីរូបកាយរបស់គាត់**! ដូច្នេះ ទ្រង់មាន__________________

____________________ ក៏លូកព្រះហស្ត______________________________

_ ដោយ______________________________________________________

__________________________ (ខ៤១) ។

តើលោកអ្នកអាចគិតស្មានបានដែរទេថា ព្រះហស្តរបស់ព្រះយេស៊ូវដកចេញមកវិញ តើទ្រង់យកមកដាក់នៅលើព្រះអង្គផ្ទាល់ ឬក៏ទ្រង់យកទៅត្រាំក្នុងទឹកសាប៊ូ ហើយដុសសម្អាត លាងជម្រះជាមួយអេប៉ុង ដើម្បីកុំឲ្យមេរោគនៃជម្ងឺនេះវាបំផ្លាញដល់សរីរាង្គកាយរបស់ទ្រង់បានឬយ៉ាងណា? តើការប្រោសឲ្យជានេះ វាអាចនឹងកើតឡើងម្តងទៀតសម្រាប់ជីវិតគាត់នៅពេលអនាគតដែរឬក៏យ៉ាងណា?

ក. សម្លៀកបំពាក់របស់គាត់? ________________________________________

ខ. សក់របស់គាត់? ______________________________________________

គ. ការចូលទៅជិតអ្នកដទៃរបស់គាត់? __________________________________

ក. ទំនាក់ទំនងរបស់គាត់? ________________________________________

# មេរៀនទី ៤- ផ្នែកទី ៤

## ការឆ្លុះបញ្ចាំង:

ជាមួយនឹងព្រះបន្ទូលរបស់ព្រះយេស៊ូវដែលថា: "ចូរឲ្យជាស្អាតចុះ!" បានធ្វើឲ្យបុរសម្នាក់លែងត្រូវការលាក់ខ្លួនពួនអាត្មា ហើយយំស្រែកឡើងថា "មិនស្អាតស្អំ!" តទៀតនោះទេ បន្ទាប់ពីនេះទៅគាត់មិនចាំបាច់ត្រូវខ្លាចអ្នកដទៃមើលងាយ ហើយប្រមាថដល់ជីវិតដូចកាលពីមុនទៀតដែរ។ ឥឡូវនេះគាត់អាចរស់នៅក្នុងសហគមន៍ អាចរស់នៅជួបជុំជាមួយក្រុមគ្រួសារ និងមិត្តភ័ក្របានឡើងវិញដោយអំណរ។ យើងឃើញថាគាត់ត្រូវបានគេទទួលស្វាគមន៍ ហើយប្រកបគ្នាជាមួយអ្នកដទៃបានជាធម្មតាវិញហើយ។ ចំពោះការភ័យខ្លាច ការចម្លងមេរោគ ការបដិសេធន៍មិនទទួលស្គាល់ ការបោះបង់ចោល ភាពឯកោ ការថ្កោលទោស និងការមើលងាយរិះគន់ គឺលែងមានសម្រាប់ជីវិតគាត់ទៀតហើយ។

ប៉ុន្តែ មានអ្វីផ្សេងទៀតដែលទាក់ទិននឹងទស្សនៈរបស់ព្រះយេស៊ូវច្រើនជាងការដែលទ្រង់បានប្រោសបុរសម្នាក់នេះឲ្យជាសះស្បើយពីជម្ងឺរបស់គាត់ទៅទៀតដោយទ្រង់បានប្រកាសថា ចូរឲ្យបានជាស្អាតចុះ! បុរសម្នាក់នេះមិនត្រឹមតែបានរួចពីបណ្តាសារ ដែលបានចងគាត់ដោយរោគឃ្លង់ ប៉ុណ្ណោះទេ ជម្ងឺឆ្លងនៃអំពើបាបដែលជាប់តាំងពីកំណើតមក ក៏ត្រូវបានអត់ទោសឲ្យរួចហើយដែរ គឺចាប់ពីពេលនេះតទៅអំពើបាបលែងមានអំណាចលើជីវិតរបស់គាត់តទៅទៀតហើយ។ បុរសម្នាក់នេះត្រូវបានជាប់ចំណងបណ្តាសារ ដោយមានជម្ងឺឃ្លង់ តែដោយសារការប្រកាសចេញរបស់ព្រះយេស៊ូវ ទើបគាត់បានរួចពីចំណងបណ្តាសារនេះ ហើយត្រូវបានអត់ទោសឲ្យរួចពីគ្រប់ទាំងអំពើបាបរបស់គាត់ទៀតផង គឺដោយសារតែសេចក្តីស្រលាញ់របស់ព្រះវរបិតាដែលបានបង្កើតរូបគាត់មក។

- បុរសម្នាក់នេះបានមកឯព្រះយេស៊ូវដើម្បីសូមឲ្យទ្រង់ជួយប្រោសជម្ងឺឃ្លងរបស់គាត់ឲ្យបានជាស្អាតឡើងវិញ (១៤០)។ បើតាមគំនិតរបស់លោកអ្នក តើគាត់នឹងមានទំនាក់ទំនងជាមួយព្រះយេស៊ូវយ៉ាងដូចម្តេច បន្ទាប់ពីគាត់បានជួបនឹងទ្រង់ ហើយបានទទួលការប្រោសឲ្យជាពីជម្ងឺឃ្លង់? _____

  ____________________________________________

  ____________________________________________

  ____________________________________________

  ព្រះយេស៊ូវគឺជាមិត្តសម្លាញ់ម្នាក់របស់គាត់! ជាអ្នកប្រោសឲ្យជា ជាអ្នកស្តារតម្លៃជីវិតរបស់គាត់ឡើងវិញ ហើយបានធ្វើឲ្យគាត់បានរស់នៅក្នុងជីវិតមួយដែលប្រកបដោយអត្ថន័យ និងគុណតម្លៃ។

- តើបុរសម្នាក់នេះមានប្រតិកម្មចំពោះការជាសះស្បើយពីជម្ងឺរបស់គាត់យ៉ាងដូចម្ដេច (៤៥)? ___

  ______________________________________________

  ______________________________________________

  គាត់មានសេរីភាពដោយបានរួចពីចំណងនៃអំពើបាប ហើយបានធ្វើឲ្យគាត់មានការអបអរសាទរជាថ្មីឡើងវិញម្ដងទៀត។ ឥឡូវនេះ គាត់អាចនិយាយថាគាត់ជាមនុស្សស្អាតស្អំម្នាក់បានដោយសេរី។ ព្រះយេស៊ូវ មិនត្រឹមតែបានដកយកអំពើបាបរបស់គាត់ចេញពីជីវិត ប៉ុណ្ណោះទេ គឺទ្រង់បានប្រទានគាត់នូវជីវិតមួយយ៉ាងពេញបរិបូរណ៍ ដោយសេចក្ដីប្រោសលោះ ហើយបានធ្វើឲ្យគាត់ថ្មីឡើងវិញម្ដងទៀត។ អ្វីដែលមនុស្សគ្រប់មនុស្សទាំងអស់អាចធ្វើបានដោយសេរីនោះគឺ ការជជែកគ្នា និងការចែកចាយបន្តអំពីដំណឹងនេះទៅមនុស្សផ្សេងៗទៀត។

## ការអនុវត្តន៍:

- តើលោកអ្នកមានអារម្មណ៍ថាខ្លួនឯងមិនអាចប៉ះពាល់បានដែរឬទេ? តើលោកអ្នកធ្លាប់មានពេលណាដែលមានអារម្មណ៍ថា ខ្លួនឯងជាមនុស្សអាក្រក់ខ្លាំងណាស់ រស់នៅដោយគ្មានជម្រើស ប្រព្រឹត្តចំពោះអ្នកដទៃយ៉ាងឃោរឃៅ ដែលធ្វើឲ្យខ្លួនឯងទៅជាមនុស្សម្នាក់មិនសក្ដិសមនឹងទទួលយកក្ដីស្រលាញ់ទាល់តែសោះ។ ______________________________

  ______________________________________________

  ______________________________________________

- តើធ្លាប់មាននរណាម្នាក់និយាយប្រាប់ថា លោកអ្នកគឺជាមនុស្សដែលអាចស្រលាញ់បានដែរឬទេ? _

  ______________________________________________

  ______________________________________________

- តើរបៀបជីវិតរបស់លោកអ្នកអាចធ្វើការបំផ្លាញខ្លួន ហើយលោកអ្នកទទួលស្គាល់ថា ខ្លួនកំពុងតែត្រូវការព្រះយេស៊ូវដែរឬទេ? "ឱព្រះអម្ចាស់អើយ! បើទ្រង់សព្វព្រះហឫទ័យ សូមធ្វើទូលបង្គំបានស្អាតសារជាថ្មីឡើងវិញផង"។ ______________________________

  ______________________________________________

  ______________________________________________

  - ចូរសំឡឹងឲ្យចំព្រះនេត្ររបស់ព្រះយេស៊ូវចុះ នោះលោកអ្នកប្រាកដជានឹងបានឃើញថាទ្រង់មានពេញដោយសេចក្ដីមេត្តាករុណា។

- ចូរពិនិត្យមើលការលាតព្រះហស្ដចេញរបស់ទ្រង់ មិនមែនជាការចង្អុលថ្កោលទោស ឬ ទះកម្ទេចលោកអ្នកនោះទេ តែជាព្រះហស្ដដែលលាតមកអោយលោកអ្នកដោយសេចក្ដីស្រលាញ់វិញ។
- ចូរផ្ដោតអារម្មណ៍ទៅលើការប៉ះពាល់របស់ទ្រង់មើល៎! ការប៉ះពាល់របស់ទ្រង់ពោរពេញទៅដោយសេចក្ដីស្រលាញ់ និង ការប្រោសឲ្យជា។

- តើការប៉ះពាល់របស់ព្រះយេស៊ូវមកលើជីវិតលោកអ្នកអាចនឹងមានការកែប្រែដូចម្ដេចខ្លះ? _____

_______________________________________________

_______________________________________________

_______________________________________________

## គំនិតអធិស្ឋាន:

ឱព្រះអម្ចាស់ព្រះយេស៊ូវអើយ! ជីវិតទូលបង្គំមានពេញដោយមេរោគឃ្លង់នៃអំពើបាប ទូលបង្គំដឹងថាទូលបង្គំកំពុងអំពាវនាវរកទ្រង់ថា "ឱព្រះអម្ចាស់អើយ! បើទ្រង់សព្វព្រះហឫទ័យសូមជួយប្រោសទូលបង្គំឲ្យបានជាស្អាតឡើងវិញផង"។ ទូលបង្គំបានចូលមករកទ្រង់ដោយមានសេចក្ដីជំនឿថា ព្រះអង្គនឹងអត់ទោសបាបដល់ទូលបង្គំ ហើយនឹងប្រោសឲ្យជាស្អាតជាថ្មីឡើងវិញមិនខាន។ ទូលបង្គំសូមអរព្រះគុណព្រះយេស៊ូវ.... _

_______________________________________________

_______________________________________________

_______________________________________________

_______________________________________________

## ដំណឹងល្អរបស់ព្រះជាម្ចាស់:

ព្រះយេស៊ូវបានហៅលោកអ្នកចំឈ្មោះហើយទ្រង់មានព្រះបន្ទូលថា "ខ្ញុំចង់ឲ្យ _______________
(ដាក់ឈ្មោះរបស់លោកអ្នក) _______________________ ចូរបានជាស្អាតចុះ!"
ចូរអនុញ្ញាតឱ្យព្រះយេស៊ូវបានដកយកបន្ទុកនៃអំពើបាបដ៏ធ្ងន់របស់លោកអ្នកចេញ ហើយចូរចាប់ផ្ដើមជីវិតមួយថ្មីដោយរីករាយចុះ នោះលោកអ្នកត្រូវដើរឈ្លោះតម្រង់ទៅមុខ ដោយប្រកាសប្រាប់ដល់មនុស្សគ្រប់គ្នាថា ទ្រង់បានប្រោសខ្ញុំឲ្យជាស្អាតហើយ! ដោយពន្លឺនៃក្រឹត្យវិន័យ (ច្បាប់) ដែលមានចែងទុកនៅក្នុងព្រះគម្ពីរ លេវីវិន័យជំពូល ១៣ យើងអាចសន្និដ្ឋានបានថាបុរសកើតឃ្លង់ម្នាក់នោះបានទទួលការផ្លាស់ប្ដូររបៀបជីវិតរបស់គាត់ទាំងស្រុង។

ក្នុងខណៈពេលដែលលោកអ្នកបានទទួលនូវបទពិសោធន៍អំពីការប៉ះពាល់ប្រោសឲ្យជារបស់ព្រះយេស៊ូវ និងព្រះបន្ទូលរបស់ទ្រង់ថា "ចូរឲ្យបានជាស្អាតចុះ!" ទាំងលោកអ្នកផ្ទាល់ និងមនុស្សគ្រប់ៗគ្នានៅជុំវិញលោកអ្នកនឹងចាប់ផ្ដើមកត់សម្គាល់ពីការផ្លាស់ប្ដូរដែលបានកើតឡើងនៅក្នុងជីវិតនៅក្នុងជីវិតជាមិនខាន។ តើមាននរណាខ្លះដែលបានដើរជាមួយលោកអ្នកដោយបានផ្ដល់នូវការគាំទ្រ និងការលើកទឹកចិត្តដូចជាព្រះអម្ចាស់បានចាប់ផ្ដើមធ្វើឱ្យមានការផ្លាស់ប្ដូរទាំងនេះ?

## គំនិតអធិស្ឋាន:

ឱព្រះអម្ចាស់អើយ! ព្រះអង្គបានប្រទានឲ្យទូលបង្គំមានជីវិតមួយថ្មី! ព្រះអង្គបានស្អាង ហើយធ្វើឲ្យជីវិតរបស់ទូលបង្គំមានពេញដោយគុណតម្លៃជាថ្មីឡើងវិញ។ ព្រលឹងវិញ្ញាណរបស់ទូលបង្គំបានឆេះឡើងដើម្បីឲ្យទូលបង្គំរស់នៅដោយ "ការនិយាយយ៉ាងបើកចំហរ ផ្សព្វផ្សាយអំពីដំណឹងមួយនេះ" ដែលព្រះអង្គសព្វព្រះហឫទ័យចង់មនុស្សគ្រប់ៗគ្នាបានព្រះអង្គផងដែរ ប្រយោជន៍ឲ្យពួកគេបានស្អាងឡើង ឲ្យជីវិតរបស់ពួកគេមានពេញដោយគុណតម្លៃតាមរយៈព្រះយេស៊ូវ។ ______________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

______________________________________________

# មេរៀនទី ៤ - ផ្នែកទី ៥

## ការអនុវត្តន៍:

មានមនុស្សមួយចំនួន បានចាត់ទុកខ្លួនឯងថាជាមនុស្សដែលមិនអាចប៉ះពាល់បានពីសំណាក់អ្នកនៅជុំវិញពួកគេបានឡើយ។ ពួកគេបានយល់ឃើញថាមនុស្សមនុស្សគ្រប់គ្នាដែលរស់នៅជុំវិញគេ មិនអាចចូលមកជិតដោយការប្រកបគ្នាយ៉ាងស្និទ្ធស្នាលបានទេ។ ជានិច្ចកាលពួកគេតែងតែត្រូវចាំឃ្លាំមើល ដោយបង្ខំឲ្យអ្នកដទៃរស់នៅឃ្លាតឆ្ងាយពីជីវិតរបស់ពួកគេ ប៉ុន្តែតាមការពិតក្នុងចិត្តរបស់ពួកគេវិញកំពុងតែស្រែកឡើងថា: "សូមចូលមកជិត ហើយប៉ះពាល់ខ្ញុំផង!" ពួកគេមានអារម្មណ៍ថាបាត់បង់តម្លៃជាមនុស្សអស់រលីងហើយ ព្រោះតែជីវិតពួកគេបានរស់នៅក្នុងភក់ជ្រាំ ដែលគ្មានមធ្យោបាយណាមួយអាចជួយសង្គ្រោះស្រោចស្រង់ជីវិតពួកគេបានឡើយ។ តែតាមការពិតក្នុងចិត្តរបស់ពួកគេ ពិតជាចង់ឮនរណាម្នាក់និយាយទៅកាន់ពួកគេថាព្រះស្រឡាញ់ពួកគេ ហើយទ្រង់បានអត់ទោសអំពើបាបរបស់ពួករួចហើយ ព្រមទាំងបានស្តារទំនាក់ទំនងដែលបាក់បែបជាមួយនឹងព្រះជាម្ចាស់នោះឲ្យល្អឡើងវិញផង។ ពួកគេចង់ដឹងថាជីវិតរបស់ពួកគេមានគុណតម្លៃ មានភាពសំខាន់ និងមានជីវិតយ៉ាងពេញបរិបូរណ៍តាមរយៈអង្គព្រះយេស៊ូវ។

1. ចូរចំណាយពេលវេលាខ្លះដើម្បីពិចារណាអំពីការមិនអាចប៉ះពាល់នៅក្នុងជីវិតរបស់លោកអ្នក។ តើមាននរណាខ្លះដែលជាមនុស្សគួឲ្យលោកអ្នកជៀសវាង ឬ គេចេញឲ្យឆ្ងាយនោះ? នៅក្នុងសហគមន៍របស់អ្នក តើមាននរណាខ្លះកំពុងត្រូវបានរស់នៅក្នុងភាពដែលមិនអាចប៉ះពាល់បាន? ___

   ___

   ___

2. ចូរនឹកគិតពីនរណាម្នាក់ដែលលោកអ្នកគិតថាចង់ចែកចាយអំពីអ្វីៗដែលព្រះយេស៊ូវបានធ្វើសម្រាប់លោកអ្នកពីរបៀបដែលទ្រង់បានស្រឡាញ់ និងបានអត់ទោសបាបសម្រាប់លោកអ្នកតាមរយៈការសុគត នៅលើឈើឆ្កាងរបស់ទ្រង់ ហើយឥឡូវទ្រង់មានព្រះជន្មរស់ឡើងវិញ ដោយបានប្រទានដល់មនុស្សគ្រប់ៗគ្នានូវជីវិតដល់នៅអស់កល្បជានិច្ច។ ___

   ___

3. ចូរនិយាយ ហើយផ្សព្វផ្សារដំណឹងនេះដោយបើកចំហរដល់មនុស្សគ្រប់ៗគ្នាឲ្យពួកគេបានដឹងអំពីគុណតម្លៃ និង សារៈសំខាន់របស់លោកអ្នកចំពោះព្រះយេស៊ូវចុះ! តើលោកអ្នកមាន "ដំណឹង" អ្វីដែលត្រូវចែកចាយដល់អ្នកដទៃដែរ? ___

   ___

   ___

## គំនិតអធិស្ឋាន:

ឱព្រះអម្ចាស់អើយ! សូមជួយដល់ទូលបង្គំឲ្យមានពេញដោយសេចក្ដីមេត្តាករុណាចំពោះអ្នកដទៃផង ហើយ សូមទ្រង់បើកចិត្ត និងមាត់របស់ទូលបង្គំនិយាយយ៉ាងបើកចំហរ ដើម្បីផ្សព្វផ្សាយដំណឹងពីក្ដីស្រឡាញ់ និង សេចក្ដីមេត្តាករុណាព្រះអង្គដល់អ្នកដទៃផង! សូមព្រះអង្គប្រទានន្ធវការលើកទឹកចិត្តដល់ទូលបង្គំដើម្បីឲ្យ ទូលបង្គំបានប្រកាសដោយសេចក្ដីក្លាហានថា ព្រះយេស៊ូវអាចធ្វើឲ្យយើងម្នាក់ៗក្លាយទៅជាមនុស្សប្រកប ដោយគុណតម្លៃ និង សារៈសំខាន់នៅចំពោះព្រះជាម្ចាស់ជាព្រះវរបិតា។ ____________________

____________________________________________

____________________________________________

____________________________________________

## សេចក្ដីបង្រៀន:

ចំពោះដំណឹងល្អដែលពាក់ព័ន្ធជាមួយពួកយើង អំពីព័ន្ធកិច្ចរបស់ព្រះយេស៊ូវ លើការប្រោសជម្ងឺនេះ គឺនៅ មានជាច្រើនទៀត។ កាលពីមេរៀនមុននេះយើងបានសិក្សាអំពីអ្នកជម្ងឺឃ្លង់ម្នាក់ត្រូវបានព្រះយេស៊ូវប្រោស ឲ្យបានជាស្អាតឡើងវិញ។ នៅក្នុងព្រះគម្ពីរ លូកា ៤:៣៨-៤៤ ព្រះយេស៊ូវបានយាងទៅ ____________

______________ រីឯម្ដាយក្មេកស៊ីម៉ូន ______________________________

______________________ (ខ៣៨) ទ្រង់ ______________________________ នោះ ______

____________________________________ (ខ៣៩) អស់អ្នកដែលមានបងប្អូនឈឺជំងឺផ្សេងៗ

គេនាំអ្នកទាំងនោះមកឯទ្រង់ ហើយ ________________________________________

____________________________________________

______________________ (ខ៤០-៤១) លុះព្រឹកឡើង ______________________________

____________________________________________

______________________________________________________________ (ខ៤២)

ហើយតើទ្រង់មានព្រះបន្ទូលប្រាប់ពួកគេថាដូចម្ដេច (ខ៤៣)? ______________________________

____________________________________________

____________________________________________

____________________________________________

យើងបានសិក្សាអំពីរឿងរ៉ាវខ្លះៗអំពីកិច្ចបំរើរបស់ព្រះយេស៊ូវរួចមកហើយ។ ជាញឹកញាប់យើងយល់ឃើញ ថាព្រះជាម្ចាស់ពិតអាចប្រោសយើងម្នាក់ៗឲ្យបានជាសះស្បើយពីជំងឺគ្រប់ប្រទេភទបាន។

ចូរយើងអធិស្ឋានសម្រាប់ខ្លួនឯង និងសម្រាប់អ្នកដទៃទៀត ទូលសូមទ្រង់ប្រោសឲ្យបានជាសះស្បើយពីជម្ងឺគ្រប់ប្រភេទដែលមាននៅក្នុងរូបកាយ និង ចិត្តគំនិតរបស់យើង។ តែទោះបីជាយ៉ាងណាក៏ដោយ មិនមែនអ្នកជម្ងឺគ្រប់ៗគ្នាដែលបានរកព្រះយេស៊ូវសុទ្ធតែត្រូវបានទទួលការប្រោសឲ្យជាទាំងអស់គ្នានោះទេ។ យ៉ាងនោះ មិនមែនមានន័យថា ព្រះយេស៊ូវគ្មានអំណាចចេស្តាដើម្បីប្រោសឲ្យបានជាសះស្បើយនោះឡើយ ប៉ុន្តែព័ន្ធកិច្ចរបស់ទ្រង់គឺមានអទិភាពជាជាង ការប្រោសឲ្យពីជម្ងឺនៅក្នុងរូបកាយ និង ចិត្តគំនិតរបស់មនុស្សនោះទៅទៀត។ ទ្រង់បានយាងមកគឺដើម្បីផ្សះផ្សាទំនាក់ទំនង ផ្នែកខាងព្រលឹងវិញ្ញាណរបស់មនុស្សលោកដែលបានបែកបាក់ដោយសារអំពើបាបនោះឲ្យបានជានានឹងព្រះជាម្ចាស់ឡើងវិញ។ តាមរយៈបទគម្ពីរទាំងនេះ ព្រះយេស៊ូវ សព្វព្រះហឫទ័យចង់ឲ្យមនុស្សគ្រប់គ្នាបានដឹងថា ជម្ងឺគឺវាមានវត្តមាននៅលើផែនដីនេះ ជាការពិតណាស់ ប៉ុន្តែ ដំណឹងល្អអំពីនរគស្ថានសួគ៌ និង ជីវិតអស់កល្បជានិច្ចនោះទើបវាសំខាន់ជាង។ ហេតុដូច្នេះហើយ ទើបបានជាទ្រង់ប្រាប់ដល់អស់អ្នកដែលបានរឹងទទឹងចំពោះការយាងមករបស់ព្រះអង្គថា នៅមានមនុស្សជាច្រើននៅកន្លែងផ្សេងទៀតត្រូវការស្តាប់អំពីដំណឹងល្អនេះ ដ្បិតជាដំណឹងល្អអំពីនរគស្ថានសួគ៌ និង ជីវិតអស់កល្បជានិច្ច ដែលថាព្រះជាម្ចាស់នឹងគ្រប់គ្រង ហើយសោយរាជ្យលើជីវិតរបស់ពួកគេ។ អំពើបាបបានចូលមកក្នុងលោកីយ៍នេះ ហើយមានជម្ងឺគ្រប់ប្រភេទក៏បានមកជាមួយដែរ។ ទោះបីជាយ៉ាងណាក៏ដោយ ចំពោះការប្រកាសដំណឹងអំពីនរគព្រះ វាគឺជាហេតុផលតែមួយដែលទ្រង់បានយាងមកលើផែនដីនេះ។ ដោយហេតុផលនេះទើបបានជាទ្រង់ _______________ ក្នុងអស់ទាំង _______ _______________ នៅ _______________________ _______________________________________ (៤៤)។

## ការអនុវត្តន៍:

- ចូររំលឹកដល់ពេលវេលាណាមួយដែលលោកអ្នក ឬ នរណាម្នាក់ដែលលោកអ្នកស្គាល់ ហើយ បានដឹងទូលសូមឲ្យមានការប្រោសឲ្យជា តែគ្មានការឆ្លើយតប: _______________________ _______________________________________ _______________________________________
- តើមានការប្រតិកម្មនៅក្នុងចិត្តដូចម្តេច នៅពេលដែលសេចក្តីអធិស្ឋានរបស់លោកអ្នក មិនមានការឆ្លើយតប ចំពោះអ្វីដែលបានទូលសូមនោះ? _______________________ _______________________________________ _______________________________________

- តើលោកអ្នកមានប្រត្តិកម្មនៅក្នុងចិត្តដូចម្តេចចំពោះព្រះជាម្ចាស់ ដែលទ្រង់មានគ្រប់ទាំងឫទ្ធានុភាពក្នុងការប្រោសឲ្យជា តែបែរជានៅស្ងាត់មិនមានការប៉ះពាល់ពីទ្រង់នោះ? ________________

________________________________________

________________________________________

- ជាពន្លឺនៅក្នុងព្រះគម្ពីរ លូកា ៤:៤៣ តើលោកអ្នកមានការយល់ដឹងអំពីពន្ធកិច្ចនៃការប្រោសឲ្យជារបស់ព្រះយេស៊ូវដូចម្តេចខ្លះ? ________________

________________________________________

________________________________________

________________________________________

## ការឆ្លុះបញ្ចាំង:

ព្រះយេស៊ូវបានធ្វើកិច្ចការណាដែលទ្រង់ត្រូវធ្វើតែប៉ុណ្ណោះ! យើងប្រហែលជាអាចនិយាយបានថា ព្រះអង្គមាន "កិច្ចការធំៗគឺជាអទិភាពចំបង"។ នៅក្នុងសម័យកាលដែលទ្រង់បានយាងមកលើផែនដីនោះ ពេលវេលារបស់ទ្រង់ គឺមានដែនកំណត់! ប្រសិនបើខ្ញុំបានទៅដល់ផ្ទះរបស់លោក ពេត្រុស ដើម្បីមើលពីការប្រោសឲ្យជា ឬថាខ្ញុំបាននាំយកនរណាម្នាក់ដើម្បីឲ្យព្រះយេស៊ូវប្រោសឲ្យជានោះ តើខ្ញុំនឹងមានប្រត្តិកម្មដូចម្តេចចំពោះពាក្យដែលទ្រង់មានព្រះបន្ទូលថា "ខ្ញុំត្រូវប្រាប់ដំណឹងល្អពីនគរព្រះ ដល់អស់ទាំងស្រុកឯទៀតដែរ គឺហេតុនោះបានជាព្រះវរបិតាចាត់ឲ្យខ្ញុំមក" (៤៤៣)? ________________

________________________________________

________________________________________

________________________________________

________________________________________

ឥឡូវនេះព្រះអម្ចាស់មានព្រះជន្មរស់ឡើងវិញ ហើយគង់នៅលើបល្ល័ង្ករបស់ព្រះអង្គប្រកបដោយសិរីរុងរឿងដែលមនុស្សលោកមិនអាចថ្លាថ្លែងបាន។ តើខ្ញុំនឹងមានប្រត្តិកម្មដូចម្តេច ចំពោះភាពក្លៀវក្លារបស់ខ្ញុំក្នុងការអធិស្ឋាន ប៉ុន្តែនៅតែគ្មានចម្លើយពីការប្រោសឲ្យជាដូច្នេះ? ________________

________________________________________

________________________________________

________________________________________

# មេរៀនទី ៥

## មេរៀនទី ៥ - ផ្នែកទី ១

### សេចក្តីបង្រៀនៈ

ទីសំគាល់ និង ការអស្ចារ្យមួយចំនួនត្រូវបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរដំណឹងល្អទាំងបួនតែម្តង។ សេចក្តីមេត្តាការុណារបស់ទ្រង់គឺពិតជាមានអនុភាពអស្ចារ្យខ្លាំងណាស់! សូមលោកអ្នកត្រឡប់ទៅអានព្រះគម្ពីរ ម៉ាថាយ ៩:៣៥-៣៧ សារវិញម្តងទៀត។

1. នៅក្នុងព្រះគម្ពីរ ម៉ាថាយ ៩:៣៥ បានរំលឹកយើងសារជាថ្មីម្តងទៀតអំពីព័ន្ធកិច្ចបម្រើធំៗទាំងបីរបស់ព្រះយេស៊ូវ (សូមអាននៅក្នុងព្រះគម្ពីរ ម៉ាថាយ ៤:២៣)។ តើព្រះយេស៊ូវទ្រង់បានយាងទៅគ្រប់ស្រុកគ្រប់ភូមិនៅសម័យនោះដើម្បីធ្វើអ្វី?

   ក. ____________________

   ខ. ____________________

   គ. ____________________

2. នៅក្នុងខ ៣៦ បានប្រាប់យើងថា កាលទ្រង់ឃើញហ្វូងមនុស្សហើយ នោះទ្រង់ ____________ ____________ ដ្បិត ____________ ហើយ ____________ ដូច ____________ ដែល ____________

   **សំគាល់:** លោកអ្នកនឹងនឹកចាំអំពីពាក្យថា សេចក្តីមេត្តាករុណា ដែលបានសិក្សារួចកន្លងមកហើយ វាគឺជាពាក្យមួយដែលមានអនុភាពជម្រុញដល់ចិត្ត រួចបញ្ចេញជាសកម្មភាពមួយ ហើយវាជាអារម្មណ៍ដែលចេញពីខាងក្នុងចិត្តមក របស់មនុស្សណាម្នាក់ ដែលអ្នកនោះធ្លាប់ដឹងអំពីបទពិសោធន៍របស់មនុស្សដទៃទៀត មិនតែប៉ុណ្ណោះ វាជាអារម្មណ៍ដែលអាចបង្ករឲ្យទៅជាឈឺនៅក្នុងក្រពះរបស់អ្នកណាម្នាក់។ "កាលទ្រង់ (ព្រះយេស៊ូវ) ឃើញហ្វូងមនុស្សហើយ នោះទ្រង់មានព្រះហឫទ័យក្តួលអាណិតដល់គេ..."។

3. នៅខណៈនោះព្រះយេស៊ូវមានព្រះបន្ទូលណែនាំដល់សិស្សរបស់ទ្រង់។ តើទ្រង់មានព្រះបន្ទូលថាដូចម្តេច (ខ៣៧)?

   ក. តើមានអ្វីធំណាស់? ____________________

   ខ. តើត្រូវការអ្វី? ____________________

   គ. តើមានដំណោះស្រាយដូចម្តេច (ខ៣៨)? ____________________

## ការឆ្លុះបញ្ចាំង:

- ព្រះយេស៊ូវបានរៀបរាប់រឿងរ៉ាវមួយចំនួនអំពីអស់អ្នកដែលបានតាមទ្រង់ថា "ចៀមដែលគ្មានអ្នកគង្វាល"។ សេចក្ដីបង្រៀនរបស់ព្រះយេស៊ូវបានធ្វើឲ្យអ្នកស្ដាប់បានយល់យ៉ាងច្បាស់លាស់ និង ចំណេះដឹងនៃព្រះបន្ទូលរបស់ព្រះជាម្ចាស់មានព្រះបន្ទូលចេញមក គឺប្រកបដោយឫទ្ធានុភាព។ ការបង្រៀនរបស់ទ្រង់បានប្រទានដល់ពួកគេនូវដំណឹងល្អ និងសេចក្ដីសង្ឃឹមសម្រាប់ការរស់នៅរបស់ពួកគេ គឺវាខុសគ្នាពីការគ្រប់គ្រង ជិះជាន់សង្កត់សង្កិនរបស់ពួកសាសន៍រ៉ូម៉ាំង ក្នុងនោះមានដូចជា ព្រះយេស៊ូវ បានប្រោសជំងឺគ្រប់ប្រភេទទាំងអស់ឲ្យបានជាសះស្បើយ ជាហេតុធ្វើឲ្យពួកបណ្ដារជនចាត់ទ្រង់ថាជា អ្នកសម្ដែងទីសំគាល់ និង ការអស្ចារ្យ ដ្បិតព្រះយេស៊ូវបានរំដោះពួកគេឲ្យបានរួចចេញពី ការរងទុក្ខវេទនា និង ការឈឺចាប់ផ្នែកខាងសាច់ឈាមរបស់ពួកគេទាំងនោះ។ តើលោកអ្នកយល់ឃើញដូចម្ដេចចំពោះប្រជាប្រិយ៍ភាពរបស់ទ្រង់នេះ? ____________________

  ______________________________

  ______________________________

  ______________________________

- យើងប្រហែលជាអាចនឹងគិតថា ប្រជាប្រិយ៍ភាព វាគ្រាន់តែជាក្ដីសុបិន្តរបស់មនុស្សគ្រប់ៗរូបតែប៉ុណ្ណោះទេ។ ចុះតើព្រះយេស៊ូវទទួលប្រជាប្រិយ៍ភាពនេះបានយ៉ាងដូចម្ដេច? នៅពេលដែលព្រះយេស៊ូវបានទតឃើញហ្វូងមនុស្សដ៏ច្រើននោះ តើទ្រង់មានព្រះបន្ទូលដូចម្ដេច? __________

  ______________________________

  ______________________________

  ______________________________

## ការអនុវត្តន៍:

- ព្រះយេស៊ូវបានទតឃើញថាមនុស្សបានរស់នៅដោយបាត់បង់គោលដៅជីវិត និងគ្មានផែនការច្បាស់លាស់សម្រាប់ជីវិតរបស់ពួកគេ។ តើលោកអ្នកមានរកឃើញថាខ្លួនឯងនៅក្នុងចំណោមហ្វូងមនុស្សនោះ ចាប់អារម្មណ៍នឹងអ្វីដែលទ្រង់មានព្រះបន្ទូល ចាប់ចិត្តនឹងអ្វីដែលទ្រង់បានធ្វើ រំភើបចិត្តចំពោះអ្វីដែលទ្រង់បានប្រទានឲ្យដែរឬទេ? ____________________

  ______________________________

  ______________________________

  ______________________________

- តើលោកអ្នកមានទាក់ទាញចំណាប់អារម្មណ៍របស់ទ្រង់ដែរឬទេ? ______________________

______________________________________________

______________________________________________

- បើសិនជាព្រះអង្គសួរលោកអ្នកថា "តើហេតុអ្វីបានជាអ្នកមកតាមខ្ញុំ?" តើលោកអ្នកនឹងទូលទ្រង់វិញយ៉ាងដូចម្ដេច? ______________________

______________________________________________

______________________________________________

- ប្រហែលជាលោកអ្នកមិនមែនជាមនុស្សដែលស្ថិតនៅក្នុងចំណោមហ្វូងមនុស្ស ដែលព្រះយេស៊ូវមានបន្ទូលថា "ចៀមដែលគ្មានអ្នកគង្វាល" នោះទេ ប៉ុន្តែប្រហែលលោកអ្នកគឺជាមនុស្សម្នាក់នៅក្នុងចំណោមពួលសិស្សរបស់ទ្រង់ ដែលទ្រង់មានបន្ទូលប្រាប់ថា "វាលចម្រូតធំណាស់ តែមានអ្នកច្រូតតិចទេ ដូច្នេះ ចូលសូមអង្វរដល់ម្ចាស់ចម្រូតឲ្យទ្រង់ចាត់បញ្ជូល អ្នកចម្រូតមកបន្ថែមទៀត"។ តើលោកអ្នកមានសេចក្ដីសាទរក្នុងការលើកដៃហើយស្រែកឡើងថា "ខ្ញុំ! ខ្ញុំ! សូមចាត់បញ្ជូនឲ្យខ្ញុំទៅ!" តើលោកអ្នកត្រូវឆ្លើយតមដូចម្ដេចចំពោះសេចក្ដីត្រូវការអ្នកច្រូតបន្ថែមរបស់ទ្រង់? ______

______________________________________________

______________________________________________

______________________________________________

- អ្នកច្រូតត្រូវបានចាត់បញ្ជូលឲ្យទៅហើយ! តាមធម្មតាអ្នកច្រូតគេមិនដែលបញ្ជូនទៅឯ ឃ្លាំងទុកស្រូវ ឬចាត់ទៅឯជង្រុកស្រូវនោះទេ។ ជាទូទៅគឺអ្នកច្រូតត្រូវទៅកាន់វាលចម្រូចដើម្បីច្រូត។ តើលោកត្រូវបានចាត់បញ្ជូនឲ្យទៅកន្លែងណាដែរ? ______________________

______________________________________________

______________________________________________

______________________________________________

# មេរៀនទី ៥ - ផ្នែកទី ២

## សេចក្តីណែនាំៈ

ទីសំគាល់ និងការអស្ចារ្យរបស់ព្រះយេស៊ូវដែលយើងនឹងត្រូវសិក្សាជាបន្ទាប់ទៅទៀតនេះ គឺជាដំណើររឿងក្នុងព្រឹត្តិការណ៍មួយដែលបានកើតចេញពីសេចក្តីមេត្តាករុណារបស់ព្រះអង្គ។ សេចក្តីមេត្តាករុណា គឺជាផ្នែកមួយដ៏សារៈសំខាន់ដែលបញ្ជាក់ពីអត្តសញ្ញាណរបស់ទ្រង់ថាជានរណា ហើយក៏ជាអ្វីដែលព្រះអង្គត្រូវការផ្តត់ផ្គង់បំពាក់បំប៉នសេចក្តីមេត្តាករុណានេះទៅដល់ពួកសិស្សរបស់ទ្រង់ទាំងអស់គ្នា។ មានដំណើររឿងមួយស្តីអំពីព្រះយេស៊ូវបានចម្អែតមនុស្សចំនួនប្រាំពាន់នាក់ រឿងនេះត្រូវបានកត់ត្រាទុកនៅក្នុងកំណត់គម្ពីរដំណឹងល្អទាំងបួននៃព្រះគម្ពីរសញ្ញាថ្មី។ ការកត់ត្រាទុកនិមួយៗសុទ្ធតែបានផ្តល់ឱ្យបន្ថែមនូវការរៀបរាប់អំពីទីសំគាល់ និង ការអស្ចារ្យដែលព្រះយេស៊ូវបានធ្វើនាសម័យកាលនោះ។

## កិច្ចការៈ

ចូរអានព្រះគម្ពីរ ម៉ាថាយ ១៤:១៣-២១ ម៉ាកុស ៦:៣០-៤៤ និង យ៉ូហាន ៦:១-១៥

- បើតាមការលើកឡើងរបស់ពួកសាវ័ក តើនៅក្នុងសាច់រឿងនាពេលនោះមានស្ថានភាពដូចម្តេច? _

  ______________________________

  ______________________________

- ចុះបើតាមការលើកឡើងរបស់ព្រះយេស៊ូវវិញ នៅពេលនោះមានស្ថានភាពដូចម្តេចដែរ? ______

  ______________________________

  ______________________________

- នៅក្នុងដំណើររឿងនេះ តើមានទីសំគាល់ និង ការអស្ចារ្យបែបណាបានកើតឡើង? __________

  ______________________________

## ប្រវត្តិដើមៈ

តាមរយៈបទគម្ពីរទាំងនេះ បាននាំយើងទៅដល់ដំណើររឿងមួយដែលព្រះយេស៊ូវបានមានព្រះបន្ទូលប្រាប់ពីដំណឹងដ៏គួរឲ្យសោកសង្រេងមួយទាក់ទងនឹងបងប្រុសជីដូនរបស់ទ្រង់ គឺលោក យ៉ូហាន បាទីស្ទ។ លោកអ្នកគួរតែអាននូវដំណើររឿងនេះ ដើម្បីឲ្យបានដឹងថាតើលោក យ៉ូហានត្រូវបានគេសម្លាប់ដោយរបៀបណា រឿងនេះត្រូវបានកត់ត្រាទុកនៅក្នុងព្រះគម្ពីរ ម៉ាថាយ ១៤:១-១២ ម៉ាកុស ៦:១៤-២៩ និង លូកា ៩:៧-៩។

## លំហាត់៖

1. នៅក្រោយពេលបានទទួលដំណឹងអំពីលោក យ៉ូហាន រួចហើយ តើព្រះយេស៊ូវបានធ្វើអ្វី? (ម៉ាថាយ ១៤:១៣)? ____________________

    ____________________

    ____________________

    ម៉ាកុស ៦:៣១ បានប្រាប់យើងថា ព្រះយេស៊ូវ និង ពួកសិស្សបានរបស់ពេញអស់ពេញមួយថ្ងៃ! នៅពេលនោះ តើព្រះអង្គមានព្រះបន្ទូលទៅកាន់ពួកសិស្សយ៉ាងដូចម្តេច? ____________________

    ____________________

    ____________________

2. តើហ្វូងមនុស្សបានធ្វើដូចម្តេច នៅពេលដែលពួកគេបានដឹងព្រះយេស៊ូវបានចេញទៅបាត់ហើយនោះ (ម៉ាថាយ ១៤:១៣ និង ម៉ាកុស ៦:៣៣)? ____________________

    ____________________

3. ហេតុអ្វីបានហ្វូងមនុស្សនាំគ្នាដើរតាមទ្រង់ (យ៉ូហាន ៦:២)? ____________________

    ____________________

4. តើព្រះយេស៊ូវមានប្រតិកម្មដូចម្តេច នៅពេលដែលទ្រង់បានទតឃើញហ្វូងមនុស្សយ៉ាងច្រើនដូច្នោះ (ម៉ាថាយ ១៤:១៤ និង ម៉ាកុស ៦:៣៤)? ____________________

    ____________________

    ____________________

    តើដោយសារសេចក្តីមេត្តាករុណាបាននាំទ្រង់ធ្វើអ្វីនៅពេលនោះ? ____________________

    ____________________

    រួចទ្រង់ ____________________

5. ថ្ងៃកាន់តែល្ងាចណាស់ទៅហើយ ក៏ដល់ពេលត្រូវបរិភោគអាហារពេលល្ងាចហើយដែរ! តើព្រះយេស៊ូវបានប្រាប់ឲ្យ ភីលីពធ្វើអ្វី នៅក្នុងព្រះគម្ពីរ យ៉ូហាន ៦:៥-៦? ____________________

    ____________________

    បើយោងទៅលើព្រះគម្ពីរ ម៉ាថាយ ១៤:១៥ និង ព្រះគម្ពីរ ម៉ាកុស ៦:៣៥-៣៦ តើពួកសិស្សចង់ឲ្យព្រះយេស៊ូវធ្វើដូចម្តេច? ____________________

    ____________________

    ____________________

6. តើព្រះយេស៊ូវបានឆ្លើយតបទៅពួកគេវិញយ៉ាងដូចម្ដេច (ម៉ាថាយ ១៤:១៦ និង ម៉ាកុស ៦:៣៧?

______________________________________________

______________________________________________

## ការឆ្លុះបញ្ចាំង:

- មិនដឹងថាត្រូវធ្វើដូចម្ដេច គឺបានត្រឹមតែញញឹមប៉ុណ្ណោះ! យ៉ាងហោចណាស់មានមនុស្សប្រាំពាន់នាក់ រួចទ្រង់បែរជាមានព្រះបន្ទូលថា ចូរឲ្យមនុស្សទាំងនេះបានបរិភោគចុះ! ចិញ្ចឹមពួកគេ! ពួកយើងបាននៅឆ្ងាយពីប្រជុំជន ដោយគ្មានអាហារបរិភោគគ្រប់គ្រាន់ទេ! ព្រះយេស៊ូវ! តើទ្រង់ដូចម្ដេចទើបបានជាមានព្រះបន្ទូលយ៉ាងដូច្នេះទៅវិញ? បើសិនជាយើងពួកគេវិលត្រឡប់ទៅវិញក្នុងពេលឥឡូវនេះ ប្រហែលជាពួកគេអាចនឹងរកអាហារបរិភោគបានដោយខ្លួនឯង។ ម្យ៉ាងវិញទៀត ពួកយើងនឿយហត់អស់កម្លាំងហើយ ព្រះអង្គអស់ព្រះកាយពលដែរ ដ្បិតពួកយើងបានរវល់ជាមួយហ្វូងមនុស្សទាំងអស់នេះអស់ពេញមួយថ្ងៃហើយ ពួកយើងពិតជាអស់កម្លាំងខ្លាំងណាស់! ពីព្រោះថា កាលពីដំបូងឡើយពួកយើងបានគិតថាគេចចេញពីពួកគេមកទីកន្លែងនេះដើម្បីបានសម្រាកតែប៉ុណ្ណោះ (ម៉ាកុស ៦:៣១)។ មានអ្នកសរសេរព្រះម្ពីរដំណឹងល្អបីនាក់បានកត់ត្រាជាពាក្យដូចៗគ្នាថា "សូមឲ្យពួកគេត្រឡប់ទៅវិញ"។
- នៅក្នុងខណៈពេលនោះ ពួកសិស្សពិតជាត្រូវស្រឡាំងកាំង រកនិយាយអ្វីមិនចេញឡើយ នៅពេលដែលពួកគេបានឮព្រះយេស៊ូវមានព្រះបន្ទូលប្រាប់ថា "ចូរឲ្យមនុស្សទាំងអស់នេះបានបរិភោគចុះ"។ អញ្ចឹងមែនឬ! ច្បាស់ហើយមែនទេ! ដែលពួកយើងនឹងត្រូវផ្ដល់អាហារសម្រាប់មនុស្សចំនួនប្រាំពាន់នាក់បានបរិភោគនោះ! ព្រះយេស៊ូវគ្រាន់តែប្រាប់ប៉ុណ្ណោះ ប៉ុន្តែ ទ្រង់បានជ្រាបអំពីគំនិតរបស់ភីលីពរួចទៅហើយ "តើយើងត្រូវទៅទិញនំបុ័ងនៅឯណាដើម្បីឲ្យមនុស្សទាំងនេះបរិភោគបានគ្រប់គ្រាន់ទៅ?" ដ្បិតភីលីពបានគិតនៅក្នុងចិត្តរួចស្រេចទៅហើយថានឹងត្រូវចំណាយអស់ប៉ុន្មាននោះ "ទោះបើទិញនំបុ័ងអស់៤០រៀល ក៏មិនគ្រាន់ឲ្យគ្រប់គ្នា សូម្បីតែបន្តិចបន្តួចផង" (យ៉ូហាន ៦:៧)! ក្រៅពីនោះថា "តើឲ្យយើងរាល់គ្នាទៅទិញនំបុ័ងចំនួន៤០រៀល ឲ្យគេបរិភោគឬអី?" (ម៉ាកុស ៦:៣៧)។ ព្រះយេស៊ូវ! តើទ្រង់កំពុងគិតដូចម្ដេចហ្នឹង?

# មេរៀនទី ៥ - ផ្នែកទី ៣

## សេចក្តីបង្រៀនៈ

តើធ្វើដូចម្តេចបានជាអាចបានជាព្រះយេស៊ូមានពេញដោយព្រះហឫទ័យមេត្តាករុណា ចំពោះហ្វូងមនុស្ស ដែលបានដើរតាមទ្រង់ប្រៀបដូចជាចៀមដែលគ្មានអ្នកគង្វាលដូច្នេះ (ម៉ាកុស។ ៦:៣៤)? ត្រូវឲ្យពួកគេត្រឡប់ទៅវិញឬ? តើធ្វើដូចម្តេចបានដោយសារតែមនុស្ស (ព្រះ) តែម្នាក់អាចទាក់ទាញមនុស្សដ៏ច្រើនដូច្នេះបាន (យ៉ូហាន។ ១២:៣២)? ត្រូវរុញច្រានពួកគេឲ្យត្រឡប់ទៅវិញឬ? តើឲ្យអ្នកគង្វាលដ៏ម្នាក់ដេញចៀមរបស់ខ្លួនឲ្យទៅឆ្ងាយដោយគ្មានការផ្គត់ផ្គង់ម្តេចនឹងបានទៅ? តើឲ្យនំបុ័ងនៃជីវិត (យ៉ូហាន។ ៦:៣៥) មិនចម្អែតអស់អ្នកដែលកំពុងតែឃ្លានម្តេចនឹងបានទៅ?

ចូរយើងពិចារណាអំពីពួកសិស្សបន្តិចសិន ការដែលពួកគេបានជួបប្រទះនឹងបទពិសោធន៍ទទួលខុសត្រូវក្នុងការផ្តល់អាហារដល់មនុស្សទាំងអស់នេះ។ ចំពោះដំណោះស្រាយដែលចេញពីទស្សនៈរបស់ពួកគេគឺមានតែបញ្ជូនហ្វូងមនុស្សទាំងនោះត្រឡប់ទៅវិញប៉ុណ្ណោះ រីឯមនុស្សទាំងអស់នេះវិញពួកគេបានមើលទៅខ្លួនឯងហើយឃើញថាខ្លួនគេកំពុងតែជួបនឹងភាពក្រីខ្សត់ លុះបន្ទាប់ពីនោះមក តើពួកគេបានបរិភោគឆ្អែតដោយរបៀបណា? មានអ្នកខ្លះអាចនឹងធ្វើដំណើរទៅ បេតសៃដា ដើម្បីរកទិញចំណីអាហាររួចត្រឡប់មកវិញ តែចំពោះព្រះយេស៊ូវវិញ ទ្រង់មានបំណងព្រះហឫទ័យចង់ឱ្យពួកគេប្រយុទ្ធប្រឆាំងដើម្បីរកដំណោះស្រាយ។ ប្រសិនបើត្រូវបញ្ជូនពួកគេឲ្យត្រឡប់ទៅវិញ តើពួកគេនឹងធ្វើអ្វី? ម្យ៉ាងទៀតពួកគេទាំងអស់គ្នាសុទ្ធតែជួបនឹងបញ្ហាហិរញ្ញវត្ថុ។ ការដែលពួកគេជួបប្រទះនឹងការស្រេកឃ្លាននេះ វាគឺជារឿងដ៏សែនលំបាកសម្រាប់ពួកគេណាស់ទៅហើយ។

តើមានអ្វីទាស់ខុសចំពោះរូបភាពមួយនេះ? តើពួកសិស្សបានមើលរំលងអ្វី? តើពួកគេបានបរាជ័យការដែលមើលមិនឃើញអ្វីដែលត្រឹមត្រូវនៅនឹងមុខពួកគេយ៉ាងដូចម្តេច? តើមានអ្វីដែលអាចកើតឡើងរួមគ្នាដោយមិនអាចធ្វើបានតែម្នាក់ឯងនោះ? ព្រះយេស៊ូវគួរតែចំអែតមនុស្សទាំងអស់នេះ ទ្រង់មិនគួរបញ្ជូនពួកគេឲ្យត្រឡប់ទៅវិញឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏ព្រះយេស៊ូវមិនបានធ្វើកិច្ចការនោះតែមួយអង្គឯងដែរ។ ចូរត្រឡប់ទៅកាន់ ដំណើររបស់យើងវិញ!

## លំហាត់:

1. តើព្រះយេស៊ូវបានសួរបានសួរដូចម្ដេច នៅក្នុងព្រះគម្ពីរ ម៉ាកុស ៦:៣៨? ________________

________________________________________________

2. តើពួកសិស្សបានរកឃើញអ្វី (ខ៣៨)? ________________________________

________________________________________________

3. អនទ្រេបានរកឃើញថាមានក្មេងប្រុសម្នាក់ ដែលមាននំបុ័ងប្រាំដុំ និង ត្រីពីរកន្ទុយ រួចបានយកមកថ្វាយព្រះយេស៊ូវទត។ តើការវាយតម្លៃរបស់អនទ្រេយ៉ាងដូចម្ដេចចំពោះចំនួន នំបុ័ង និង ត្រីនោះ (យ៉ូហាន ៦:៩)? ________________________________

________________________________________________

________________________________________________

4. ព្រះយេស៊ូវមានព្រះបន្ទូលឆ្លើយតបចំពោះសំនួររបស់អនទ្រេដោយការបង្គាប់។ តើព្រះយេស៊ូវបានបង្គាប់ដូចម្ដេច (ម៉ាថាយ ១៤:១៨)? ________________________________

________________________________________________

________________________________________________

5. តើទ្រង់បានណែនាំដល់ពួកសិស្សដូចម្ដេចទាក់ទងនឹងហ្វូងមនុស្ស (ម៉ាកុស ៦:៣៩-៤០)? ______

________________________________________________

________________________________________________

________________________________________________

6. ហ្វូងមនុស្សបានអង្គុយនៅលើស្មៅ។ តើបន្ទាប់មកទៀតព្រះយេស៊ូវបានធ្វើអ្វី (ម៉ាថាយ ១៤:១៩) គឺនៅមុនពេលការចែកអាហារ? ________________________________

________________________________________________

7. រួចកាច់ ________________________ ហើយ ________________

________________ ពួកសិស្ស________________________________

8. នៅក្នុងព្រះគម្ពីរម៉ាថាយ ១៤:២០ បានប្រាប់យើងថា គ្រប់គ្នាបានបរិភោគឆ្អែត ហើយ ________

________________________________________________

________________________________________________

9. តើព្រះយេស៊ូវបានបង្គាប់ទៅពួកសិស្សយ៉ាងដូចម្ដេច បន្ទាប់ពីមនុស្សគ្រប់គ្នាបានបរិភោគឆ្អែតរួចហើយ (យ៉ូហាន ៦:១២)? ______________________________

______________________________

10. តើពួកសិស្សបានប្រាប់ថានៅសល់ប៉ុន្មាន (យ៉ូហាន ៦:១២)? ______________________________

______________________________

11. ម៉ាថាយ និង ម៉ាកុស បានបញ្ជាប់សាច់រឿងដោយប្រាប់អំពីចំនួនមនុស្សដែលបានបរិភោគឆ្អែត។ ម៉ាថាយ បានប្រាប់យើងថាមានមនុស្សប្រហែល ៥០០០ នាក់ គឺរាប់តែមនុស្សប្រុស ដោយមិនរាប់បញ្ចូលស្ត្រី និង កូនក្មេង។ នៅក្នុងព្រះគម្ពីរយ៉ូហាន ៦:១៤-១៥ បានចែកចាយប្រាប់យើងអំពីការប្រតិកម្មរបស់បណ្ដាជន នៅពេលដែលពួកគេបានឃើញពីទីសំគាល់ និង ការអស្ចារ្យនោះ។ តើពួកបណ្ដាជនបាននិយាយគ្នាដូចម្ដេចខ្លះ? ______________________________

______________________________

______________________________

12. តើហ្វូងមនុស្សមានបំណងចង់ធ្វើអ្វី (យ៉ូហាន ៦:១៥)? ______________________________

______________________________

______________________________

13. តើព្រះយេស៊ូវបានធ្វើដូចម្ដេច? ______________________________

______________________________

______________________________

# មេរៀនទី ៥- ផ្នែកទី ៤

## ការឆ្លុះបញ្ចាំង:

នៅខណៈដែលលោកអ្នកកំពុងធ្វើការឆ្លុះបញ្ចាំងទៅលើរឿងរ៉ាវដែលទើបតែនឹងបានកើតឡើង ចូរធ្វើការពិចារណាអំពីចំណុចខ្លះៗដែលនឹងផុសចេញនៅក្នុងគំនិតរបស់លោកអ្នក បើសិនជាលោកអ្នកគឺជា**មនុស្សម្នាក់ដែលបាននៅក្នុងចំណោមហ្វូង**មនុស្សដែលបានដើរតាមព្រះយេស៊ូវនៅម៉្តុំសមុទ្រដែរ នោះលោកអ្នកពិតជាមិនដឹងយ៉ាងច្បាស់ថាហេតុអ្វីបានជាមានភាពទាក់ទាញដល់ទ្រង់នោះទេ ប៉ុន្តែលោកអ្នកដឹងត្រឹមថាព្រះអង្គគឺជាអ្នកប្រោសជម្ងឺម្នាក់ប៉ុណ្ណោះ ពីព្រោះតែលោកអ្នកបានឃើញអ្នកជំងឺជាច្រើនបានជាសះស្បើយ គឺជាទាំងជម្ងឺក្នុងផ្លូវកាយ និងជម្ងឺក្នុងផ្លូវចិត្តផងដែរ ហើយលោកអ្នកប្រហែលជាបានដឹងថាទ្រង់គឺជាគ្រូបង្រៀនម្នាក់ដ៏ចំណាន ដ្បិតគ្រប់ពាក្យដែលទ្រង់មានព្រះបន្ទូលចេញទៅ គឺមានពេញដោយឫទ្ធានុភាព។ វានឹងធ្វើឲ្យលោកអ្នកត្រឡប់ទៅផ្ទះវិញយឺតពេល ឬ ប្រហែលឃ្លានបាយហើយមើល៎ទៅ! ប៉ុន្តែយ៉ាងណាក៏មិនចង់ចាកចេញទៅនោះដែរ...

- ______________________________

  ______________________________

- ______________________________

  ______________________________

ចូរពិចារណាពីអ្វីដែលអាចនឹងកើតមានឡើងនៅក្នុងគំនិតរបស់លោកអ្នក បើសិនលោកអ្នកគឺជាមនុស្សម្នាក់នៅក្នុងចំណោមពួកសិស្សរបស់ព្រះយេស៊ូវ ដែលមានការខ្វល់ខ្វាយអំពីការអនុវត្តជាក់ស្តែងចំពោះសេចក្តីត្រូវការរបស់ព្រះយេស៊ូវ សម្រាប់ហ្វូងមនុស្ស យ៉ាងហោចណាស់ក៏មានការខ្វល់ខ្វាយសម្រាប់ខ្លួនឯងផ្ទាល់ដែរ។ វាគឺជាថ្ងៃមួយដ៏សែនរវល់ខ្លាំងណាស់ ហើយនៅក្នុងថ្ងៃជាមួយគ្នានោះដែរ ព្រះយេស៊ូវក៏ទើបតែនឹងបានទទួលដំណឹងអំពីការស្លាប់លោក យ៉ូហាន បាទីស្ទ ទៀតផង។ វាបានយឺតពេលទៅហើយ ម្យ៉ាងហ្វូងមនុស្សជាច្រើននាក់កំពុងត្រូវការចំណីអាហារដើម្បីបរិភោគ។ គ្មានមធ្យោបាយណាដើម្បីចម្អែតដល់មនុស្សយ៉ាងច្រើនដូច្នេះបាននោះទេ! លោកអ្នកប្រហែលកំពុងចាប់ផ្តើមមានការភ័យស្លន់ស្លោ ដោយសារតែខ្លួនឯងអសមត្ថភាព ទើបមិនអាចបញ្ចៀសបញ្ហាចំពោះមុខនេះបាន។ ប៉ុន្តែ ដំណោះស្រាយប្រាកដជាមាន...

- ______________________________

  ______________________________

- ______________________________

  ______________________________

## ការសង្កេតៈ

1. ព្រះយេស៊ូវនិងពួកសិស្សបានឃើញហ្វូងមនុស្សយ៉ាងច្រើនបានដើរសំដៅមករកព្រះអង្គ។ ព្រះយេស៊ូ និងពួកសិស្សបានឃើញក្នុងអត្ថន័យផ្សេងពីគ្នា គឺ ព្រះយេស៊ូវបានទតឃើញហ្វូងមនុស្សហើយ ទ្រង់ក៏មានព្រះហឫទ័យអាណិតអាសូរយ៉ាងក្រៃលែង ពីព្រោះពួកគេប្រៀបដូចជាចៀមដែលគ្មានគង្វាល (ម៉ាកុស ៦:៣៤) ចំណែកឯពួកសិស្សវិញបានឃើញហ្វូងមនុស្សហើយក៏ចាប់ផ្ដើមមានការព្រួយបារម្ភថាតើត្រូវរកចំណីអាហារឯណាដើម្បីយកមកឲ្យពួកគេបរិភោគ។ ព្រះយេស៊ូវទតឃើញអំពីការស្រេកឃ្លានខាងព្រលឹងវិញ្ញាណ ដូច្នេះហើយបានជាទ្រង់ចម្អែតពួកគេដោយការបង្រៀនអំពីសេចក្ដីជាច្រើន។ ប៉ុន្តែពួកសិស្សបានមើលឃើញអំពីការស្រេកឃ្លានផ្នែកខាងសាច់ឈាមទៅវិញ ហើយគេមិនដឹងថាត្រូវធ្វើដូចម្ដេច ដើម្បីឲ្យអាហារសម្រាប់ពួកគេបានបរិភោគគ្រប់គ្រាន់នោះទេ។ គំនិតរបស់លោកអ្នកៈ ________________________________________________

   ____________________________________________________________

   ____________________________________________________________

   ____________________________________________________________

   ____________________________________________________________

2. ពួកសិស្សមានបំណងចង់មនុស្សទាំងអស់នោះវិលត្រឡប់ទៅវិញ ប៉ុន្តែព្រះយេស៊ូវបានណែនាំ ថាឲ្យពួកគេអង្គុយជាក្រុមតូចៗនៅស្មៅនៅក្បែរនោះ។ ការរៀបចំរបស់ពួកសិស្សគឺនឹងធ្វើឲ្យហ្វូងមនុស្សត្រូវជួបនឹងភាពមហន្តរាយ តែការរៀបចំរបស់ព្រះយេស៊ូវវិញ នឹងធ្វើឲ្យមនុស្សទាំងនោះបានទទួលព្រះពរតាមរយៈទីសំគាល់ និងការអស្ចារ្យវិញ។ គំនិតរបស់លោកអ្នកៈ __________________

   ____________________________________________________________

   ____________________________________________________________

   ____________________________________________________________

3. ព្រះយេស៊ូវសួររកចំពោះអ្វីដែលមាន (នំបុ័ងប្រាំដុំ និងត្រីពីរកន្ទុយ) ពេលដែលទ្រង់បានទទួល ទ្រង់បានយកមកកាន់រួចអរព្រះគុណដល់ព្រះជាម្ចាស់ បន្ទាប់មកក៏បានប្រទានឲ្យទៅពួកសិស្សដើម្បីចែកដល់មនុស្សទាំងអស់ដែលកំពុងឃ្លាន។ គំនិតរបស់លោកអ្នកៈ ________________________

   ____________________________________________________________

   ____________________________________________________________

   ____________________________________________________________

4. យើងគឺជាសក្សីអំពីសេចក្ដីសប្បុរសរបស់ព្រះយេស៊ូវ! ពួកគេបានបរិភោគឆ្អែតគ្រប់គ្នា! ក្រោយពីពួកគេបានបរិភោគរួចហើយ ពួកគេក៏ប្រមូលចំណែកដែលនៅសល់បានចំនួន ១២ កន្ត្រកទៀតផង។ យើងបានឃើញថាពួកសិស្សបានប្រមូលចំណែលដែលនៅសល់នោះដាក់ក្នុងកន្ត្រកបានយ៉ាងត្រឹមត្រូវ ដោយគ្មានការខ្ជះខ្ជាយនោះឡើយ។ គំនិតរបស់លោកអ្នក: ____________________

____________________________________________________________

____________________________________________________________

____________________________________________________________

____________________________________________________________

# មេរៀនទី ៥ - ផ្នែកទី ៥

## សំនួរអនុវត្តន៍:

1. នៅពេលដែលខ្ញុំបានពិចារណាដល់ជីវិតរបស់ខ្ញុំអំពីការស្រេកឃ្លានផ្នែកខាងសាច់ឈាម គឺវាមិនមែនជាការលំបាកក្នុងការកំណត់អត្តសញ្ញាណរបស់វា និង ការធ្វើឲ្យបានស្កប់ចិត្តនោះទេ។ តើខ្ញុំមានបំណងចង់ដឹងអំពីការស្រេកឃ្លានផ្នែកខាងព្រលឹងវិញ្ញាណរបស់ឬទេ? តើខ្ញុំដឹងថាត្រូវធ្វើដូចម្តេចទើបបំពេញឲ្យបានស្កប់ចិត្តដែរឬទេ? ខ្ញុំគ្រាន់តែដឹងថាកាលណាមានសេចក្តីស្រេកឃ្លាន នោះវានាំឲ្យមានការឈឺចាប់ ហើយការឈឺចាប់វាបានធ្វើឲ្យខ្ញុំមានការស្រេកឃ្លានផ្នែកខាងសាច់ឈាម ជាមួយគ្នានោះព្រលឹងវិញ្ញាណរបស់ខ្ញុំបានទទួលរងនូវការឈឺចាប់នេះផងដែរ មិនអាចធ្វេសប្រហែសបានទេ? ការឈឺចាប់នៃការស្រេកឃ្លានផ្នែកខាងព្រលឹងវិញ្ញាណទាំងនេះអាចនឹងមិនត្រូវបានយកចិត្តទុកដាក់ ឬ អាចនឹងមើលច្រឡំអស់រយៈពេលដ៏យូរ ដូច្នេះទើបបានជាពួកគេមានការលំបាកក្នុងការទទួលស្គាល់។ អំពីជីវិតរបស់ខ្ញុំកំពុងតែអំពាវនាវប្រាថ្នាចង់បាននំបុ័ងជីវិត ចង់បានព្រះបន្ទូលនៃព្រះ ចង់ឲ្យព្រះយេស៊ូវយាងមករកខ្ញុំ និង ចង់បានជីវិតមួយដែលរស់ដោយការស្កប់ចិត្ត តើត្រូវធ្វើដូចម្តេចទៅ? ________________________________________

2. ខណៈពេលដែលខ្ញុំបានសម្លឹងមើលជុំវិញខ្លួនឯងគឺឃើញមានតែត្រីពីរកន្ទុយ ហើយនិងនំបុ័ងប្រាំដុំតែប៉ុណ្ណោះរួចក៏សួរឡើងថា "ប៉ុន្តែដែលមានប៉ុណ្ណោះ តើមានប្រយោជន៍អ្វី ដល់មនុស្សច្រើនដូច្នេះ?" (យ៉ូហាន ៦:៩)? ឬមួយតើខ្ញុំបានឃើញអ្វីដែលអាចនឹងថ្វាយដល់ព្រះជាម្ចាស់ក្នុងពេលកំពុងសួររកដើម្បីប្រទានពរ ហើយប្រើប្រាស់វានៅគ្រប់ទីកន្លែងដែលទ្រង់ជ្រើសរើសសម្រាប់បង្ហើយបំណងព្រះហឫទ័យរបស់ទ្រង់? ចូរពិចារណាបអំពីទេពកោសល្យ និង សមត្ថភាពរបស់លោកអ្នកបន្តិចសិន និង អំពី បុគ្គលិកលក្ខណៈផ្ទាល់ខ្លួន ចរិតលក្ខណៈ ចំណេះដឹង និង សតិសម្បជញ្ញៈរបស់លោកអ្នកផ្សេងៗទៀត។

## ការទន្ទេញចងចាំ:

ក្រោយពីព្រះយេស៊ូវបានចម្អែតមនុស្សចំនួន ៥០០០ នាក់រួចហើយទ្រង់ក៏យាងចេញពីពួកគេបាត់ទៅ ពីព្រោះពួកគេចង់តាំងឲ្យទ្រង់ឡើងសោយរាជ្យធ្វើជាស្តេចដោយបង្ខំ។ (យ៉ូហាន ៦:១៥)។ ហើយនៅក្នុងវេលាយប់នោះពួកសិស្សឆ្លងទៅត្រើយម្ខាងដោយជិះទូកទៅ ហើយព្រះយេស៊ូវយាងមកតាមក្រោយពួកគេដោយយាងលើទឹកទៅ (យ៉ូហាន ៦:១៦-២១)។ លុះដល់បន្ទាប់ នៅពេលដែលបណ្តាជនបានដឹងថាព្រះយេស៊ូវ និងពួកសិស្សបានចេញទៅត្រើយម្ខាងបាត់ហើយ នោះពួកគេក៏បានឡើងទូកឆ្លងទៅត្រើយម្ខាងដើម្បីទៅតាមទ្រង់នៅទីនោះ (យ៉ូហាន ៦: ២២-២៤)។ នៅពេលដែលហ្វូងមនុស្សទាំងនោះបានជួបជាមួយព្រះយេស៊ូវហើយ ទ្រង់ក៏មានព្រះបន្ទូលទៅគេអំពី មូលហេតុដែលពួកគេបានមកតាមព្រះអង្គ គឺមិនមែនដោយសារទ្រង់ជានរណានោះទេ តែដោយសារពួកគេចង់បានឲ្យតែបានឆ្អែតក្រពះប៉ុណ្ណោះ។ ទោះជាយ៉ាងណាក្តីនៅក្នុងព្រះគម្ពីរយ៉ូហានជំពូក ៦ ព្រះយេស៊ូវបានមានព្រះបន្ទូលថា ទ្រង់គឺជានំបុ័ងជីវិតដែលមនុស្សគ្រប់គ្នាគួរតែស្វែងរកទ្រង់ សម្រាប់ឆ្អែតខាងផ្នែកព្រលឹងវិញ្ញាណ ប្រសើរជាងការស្វែងរកដើម្បីតែបានអាហារដែលត្រូវរលួយខូចនោះវិញ។ តាមការពិតទ្រង់គឺជានំបុ័ងខាងផ្នែកព្រលឹងវិញ្ញាណ សម្រាប់ផ្គត់ផ្គង់អាហារខាងព្រលឹងវិញ្ញាណដែលនៅជាយូរអង្វែង គឺជានំបុ័ងដែលត្រូវទ្រាំទ្រដើម្បីឲ្យគ្រប់គ្នាបានទទួលនូវជីវិតដ៏នៅអស់កល្បជានិច្ច (យ៉ូហាន ៦:២៧)។

ចូរសរសេរបទគម្ពីរនេះទុកនៅក្នុងសៀវភៅ ឬ ក្រដាសកត់ត្រារបស់លោក! យ៉ូហាន ៦:២៧, ៣៥ "កុំឲ្យខំប្រឹងឲ្យបានតែអាហារ ដែលតែងតែពុករលួយនោះឡើយ ចូរខំឲ្យបានអាហារ ដែលនៅស្ថិតស្ថេរ ដរាបដល់ជីវិតអស់កល្បជានិច្ចវិញ .... ខ្ញុំជានំបុ័ងជីវិត អ្នកណាដែលមកឯខ្ញុំ នោះនឹងមិនឃ្លានទៀតឡើយ ហើយអ្នកណាដែលជឿដល់ខ្ញុំ ក៏មិនត្រូវស្រេកដែរ។"

បើសិនជាលោកអ្នកបានទទួលប្រាក់ចំណូលក្នុងម៉ោងធ្វើការនាសប្តាហ៍កន្លង ចូរសន្សំឲ្យបានគ្រប់ដើម្បីទិញ "នំបុ័ងដែលផ្តល់នូវជីវិតអស់កល្ប"។ តើលោកអ្នកគិតថា អាចនឹងសន្សំប្រាក់ចំណូលគ្រប់គ្រាន់ដើម្បីទិញនំបុ័ងនេះ ឬ ដើម្បីធ្វើឲ្យជីវិតលោករស់នៅស្កប់ស្កល់ដែរទេ? ឬ លោកអ្នកគិតនៅតែមានការខ្វះខាត មិនគ្រប់គ្រាន់ដោយសារការសន្សំរបស់លោកអ្នកវាតិចតួចពេក ឬក៏គ្មានប្រាក់សម្រាប់សន្សំដើម្បីទិញនំបុ័ងដែលផ្តល់ជីវិតអស់កល្បជានិច្ច? ________________________________________

________________________________________

________________________________________

________________________________________

តើមានចំណុចផ្លាស់ប្រែណាខ្លះដែលអាចធ្វើឲ្យលោកអ្នក នឹកគិតទៅដល់ពេលវេលាមួយដែលត្រូវ "ធ្វើការដើម្បីឲ្យបាននំបុ័ងដែលផ្តល់ជីវិតអស់កល្បជានិច្ច? ____________________

____________________

____________________

____________________

## សេចក្តីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! សូមធ្វើទូលបង្គំមានចិត្តដូចជាក្មេងប្រុសម្នាក់នោះផង ដែលគេបានថ្វាយដល់ទ្រង់ពីរបស់អ្វីដែលគេមាន ទោះបីជាមើលទៅហាក់ដូចជាតិចតួចសម្រាប់មនុស្សជាច្រើននាក់យ៉ាងណាក៏ដោយ។ គេបានថ្វាយនូវអ្វីដែលគេមាន! ព្រះអង្គបានអរព្រះគុណដល់ព្រះអម្ចាស់ សម្រាប់អ្វីដែលមាន រួចទ្រង់បានប្រទានដល់ពួកសិស្សដើម្បីឲ្យពួកគេបានចែកដល់ហ្វូងមនុស្ស ហើយគ្រប់ៗគ្នាក៏បានឆ្អែតស្កប់ស្កល់ ព្រមទាំងនៅសល់ជាច្រើនកន្ត្រកទៀតផង។ សូមទ្រង់ធ្វើទូលបង្គំមានចិត្តសប្បុរសជាមួយនឹងអំណោយ និងព្រះពររបស់ខ្ញុំផង ហើយសូមទ្រង់ប្រទានសេចក្តីជំនឿដល់ទូលបង្គំ ប្រយោជន៏ឲ្យទូលបង្គំបានជឿថា អ្វីៗដែលទូលបង្គំបានថ្វាយទៅដល់ព្រះអង្គ នឹងបានប្រើប្រាសបានជាប្រយោជន៏ និងជាព្រះពរដល់អ្នកដទៃផងដែរ។ សូមបើកភ្នែករបស់ទូលបង្គំឲ្យបានមើលឃើញក្នុងនិមិត្តក្នុងគ្រប់អ្វីៗដែលអាចធ្វើទៅបាន មិនមែនជាការមើលឃើញអ្វីតិចតួចដែលតិចតួចនោះទេ។ ____________________

____________________

____________________

____________________

____________________

____________________

____________________

# មេរៀនទី ៦

## មេរៀនទី ៦ - ផ្នែកទី ១

### សេចក្តីណែនាំ:

តាមរយៈការសិក្សាមេរៀន **"ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ អ្នកសង្គ្រោះរបស់យើង"** ឃើញថាព្រះយេស៊ូវបានធ្វើទីសំគាល់ និង ការអស្ចារ្យគឺសម្រាប់ជាសម្ភារៈ និងសេចក្តីត្រូវការផ្នែកខាងសាច់ឈាមរបស់មនុស្ស។ លោកបានផ្តល់ស្រាសម្រាប់ពិធីអាពាហ៍ពិពាហ៍នេះនិងម្ហូបអាហារសម្រាប់ហ្វូងមនុស្ស។ ព្រះអង្គប្រទានឲ្យមានស្រានៅក្នុងពិធីមង្គលកា ប្រទានអាហារដល់ហ្វូងមនុស្ស ហើយយើងក៏បានដឹងមានអ្នកជម្ងឺឃ្លង់ម្នាក់ត្រូវបានព្រះយេស៊ូវធ្វើការអស្ចារ្យប្រោសគាត់ឲ្យបានជាសះស្បើយ ប្រោសគាត់ឲ្យមានសុខភាពល្អឡើងវិញ ទ្រង់ក៏បានផ្សះផ្សាទំនាក់ទំនងរបស់គាត់ជាមួយមនុស្សជុំវិញគាត់ និង សហគមន៍ ទ្រង់បានដកភាពឯកោការរស់នៅតែលតោន គ្មានអ្នករាប់រក ចេញពីជីវិតរបស់គាត់ផងដែរ។ ដំណើររឿងដែលយើងត្រូវសិក្សាបន្ទាប់ទៅទៀតនេះ គឺជាដំណើររឿងមួយស្តីអំពីព្រះយេស៊ូវ បង្ហាញឫទ្ធានុភាព និង ព្រះចេស្តារបស់ទ្រង់ទៅបង្ក្រាប់លើអំណាចធម្មជាតិ។

### កិច្ចការ:

ចូរអានព្រះគម្ពីរម៉ាថាយ ៨:២៣-២៧ ម៉ាកុស ៤:៣៥-៤១ និង លូកា ៨:២២-២៥

- តើមានស្ថានភាពដូចម្តេច?
- តើពួកសិស្សមានសេចក្តីសន្និដ្ឋានយ៉ាងដូចម្តេច?
- តើព្រះយេស៊ូវបានធ្វើអ្វី?
- តើព្រះយេស៊ូវបានសួរទៅពួកសិស្សដូចម្តេច?

### លំហាត់:

1. តើព្រះយេស៊ូវបានផ្តល់គំនិតឲ្យពួកសិស្សធ្វើអ្វី (លូកា ៨:២២)? ____________________

______________________________________________________________

______________________________________________________________

______________________________________________________________

2. ពួកគេបានចេញទូកទៅ!
ខណៈពេលដែលពួកសិស្សកំពុងធ្វើដំណើរតាមទូកទៅឯត្រើយម្ខាងបាត់ហើយ តើព្រះយេស៊ូវធ្វើអ្វី (ខ២៣)? ________________________________________

________________________________________

3. កាលពួកសិស្សកំពុងធ្វើដំណើរតាមទូកទៅ ព្រះយេស៊ូទ្រង់បានផ្ទុំលក់នៅក្នុងទូក នៅពេលនោះស្រាប់តែមានខ្យល់ព្យុះមួយយ៉ាងធំបានបក់បោកប៉ះនឹងទូករបស់ពួក។ ចូររៀងរាបើអំពីអ្វីដែលបានកើតឡើយ ខ២៣)

4. តើព្រះយេស៊ូវនៅទេកំពុងតែនៅធ្វើអ្វី? ________________________________________

________________________________________

5. ពួកសិស្សបានទៅដាសទ្រង់ឲ្យភ្ញាក់ឡើង! តើពួកគេបានទូលទៅទ្រង់ដូចម្តេច (ខ២៤)? ________

________________________________________

________________________________________

6. តើពួកគេមានការភ័យខ្លាចចំពោះអ្វី? ________________________________________

________________________________________

7. តើពួព្រះយេស៊ូវបានធ្វើអ្វី (ខ២៤)? ________________________________________

________________________________________

________________________________________

8. ព្យុះ ________________________________________ និង __

________________________________________

9. តើព្រះយេស៊ូវបានសួរទៅពួកសិស្សរបស់ទ្រង់ដូចម្តេចខ្លះ (ខ២៥)? ____________________

________________________________________

________________________________________

ចូរអាននៅក្នុងព្រះម៉ាថាយ ៨:២៦ ________________________________________

________________________________________

10.តើពួកគេបានសួរគ្នាទៅវិញទៅមកថាយ៉ាងដូចម្ដេច (ខ២៥)? ______________________

______________________________________________

______________________________________________

ចូរអាននៅក្នុងព្រះម៉ាថាយ ៨:២៧ ______________________________

ចូរអាននៅក្នុងព្រះម៉ាកុស ៤:៤០

11.តើពួកគេបាននិយាអំពីទ្រង់ដូចម្ដេច (ខ២៥)? ______________________________

______________________________________________

______________________________________________

## ការឆ្លុះបញ្ចាំងៈ

ដូច្នេះ ចូរខ្លួនឯងនៅក្នុងទូកនោះ! វានឹងក្លាយជារឿងមួយផ្សេងមួយទៀត នៅពេលដែលយើងធ្វើការប្រមើស្រមៃអំពីខ្យល់ដែលបក់មកយ៉ាងខ្លាំងៗ ហើយបានបុកខ្ទប់នឹងទូកស្ទើលិចម្ដងទៅហើយ។ ទូករបស់អ្នកត្រូវបានលិចក្នុងពេលឆាប់ៗនេះមិនខាន! ហើយធុងសង្គ្រោះក៏ប្រើការមិនកើតទៀត! តាមការពិតទៅធុងសង្គ្រោះរបស់អ្នក និង របស់មិត្តភ័ក្ររួមដំណើរមិនបានយក់ឡើងមកតាមទូលឡើយ។ អ្នកប្រាកដជាត្រូវជួប និងគ្រោះថ្នាក់ធំហើយពេលនេះ!

- តើលោកអ្នកនឹងត្រូវធ្វើដូចម្ដេចចំពោះរឿងដែលព្រះយេស៊ូវកំពុងផ្ទុំនៅក្នុងទូកនោះ? ________

  ______________________________________________

  ______________________________________________

- លោកអ្នកជឿថានឹងត្រូវលង់ទឹកជាមិនខាន ហើយលោកអ្នកក៏បានទូលសូមឲ្យទ្រង់ជួយសង្គ្រោះ។ តើនៅពេលនោះទ្រង់មានព្រះបន្ទូលថាដូចម្ដេច? ______________________________

  ______________________________________________

  ______________________________________________

វាគឺជាការលំបាកឆ្លើយតបទៅនឹងសំណួររបស់ព្រះយេស៊ូវខ្លាំងណាស់ នៅពេលដែលលោកអ្នកកំពុងតែមានការភ័យខ្លាចដូច្នេះ។ នៅពេលដែលលោកអ្នកកំពុងស្ថិតក្នុងការភ័យខ្លាចលង់ទឹក លោកអ្នកដឹងថាទន់ខ្សោយដោយសារបញ្ហាចំពោះមុខនោះវាមានកម្លាំងខ្លាំងជាងលោកអ្នក ហើយក៏ត្រូវបានសួរថាៈ "ហេតុអ្វីបានជាអ្នកភ័យខ្លាចដូច្នេះ?" ដូចជាមិនសមហេតុផលសោះ! មែនទេ? សំនួរនេះត្រូវបានសំដៅទៅលើអ្នកដែលមានជំនឿតិច ឬអ្នគ្មានជំនឿសោះ។ គំនិតរបស់លោកអ្នកៈ

______________________________________________

- ចូរពិនិត្យឡើងវិញៈ ព្រះយេស៊ូវកំពុងតែផ្ទំលក់នៅក្នុងទូក! ពួកសិស្សកំពុងធ្វើដំណើរតាមទូក រំពេចនោះស្រាប់តែមានខ្យល់បក់បោកយ៉ាងខ្លាំង ហើយបានធ្វើឲ្យមានរលកធំមកប៉ះនឹងទូករបស់ពួកគេ! ព្រះយេស៊ូវនៅតែផ្ទំលក់ដដែល! ពួកគេមានការភ័យខ្លាចថាត្រូវលង់ទឹកជាមិនខាន! ពួកគេបានទៅដាស់ព្រះយេស៊ូវឲ្យតើនឡើង ដោយស្រែកសូមឲ្យទ្រង់ជួយសង្គ្រោះពួកគេ មិនពេលដែលពួកគេលិចលង់ចូលទៅក្នុងទឹក ហើយព្រះយេស៊ូវក៏សួរទៅពួកគេថា "តើសេចក្ដីជំនឿរបស់អ្នករាល់គ្នានៅឯណា?" ទ្រង់ក៏បានកំហែងទៅខ្យល់ និង ទឹករលក! រំពេចនោះអ្វីៗគ្រប់យ៉ាងបានស្ងប់ស្ងាត់ធម្មតាវិញ ដោយគ្មាននរណាម្នាក់មានគ្រោះថ្នាក់អ្វីឡើយ។ ពេលនោះពួកសិស្សបានសម្លឹងមើលមុខគ្នាទៅ វិញទៅមកដោយការងឿយឆ្ងល់ថា "តើអ្នកគឺជានណា?" "តើអ្នកនេះគឺជាមនុស្សបែបណា?" សូម្បីតែខ្យល់ និង ទឹកក៏ស្ដាប់បង្គាប់ដែរ។ គំនិតរបស់លោកអ្នកៈ ________________

____________________________________________

____________________________________________

____________________________________________

# មេរៀនទី ៦ - ផ្នែកទី ២

## ការអនុវត្តន៍ផ្ទាល់ខ្លួនៈ

1. ចូរយើងធ្វើការពិចារណាអំពីទូកបន្តិចសិន! តើទូករបស់លោកអ្នកដូចម្ដេចដែរ ការដែលលោកអ្នកបានសង្កេតឃើញថាខ្លួនឯងគឺជាអ្នកបញ្ជា ហើយគឺជាក្ដោងផង? ផ្ទះសំបែង និងជីវិតក្រុមគ្រួសាររបស់លោកអ្នកដូចម្ដេចដែរ? ចុះចំណែកការងារ ឬ មុខជំនួញរបស់លោកអ្នកវិញ? ហើយចុះចំពោះកាលវិភាគ និង ទំនាក់ទំនងរបស់លោកអ្នកវិញដូចម្ដេចដែរ? តើទូលរបស់លោកអ្នកអាចនឹងទៅជាយ៉ាងណា នៅពេលដែលវាត្រូវបានប្រឈមមុខនឹងការវាយប្រហារពីសំណាក់រលក និង ព្យុះនៃជីវិត? ________________________________________

2. យើងទាំងអស់គ្នាអាចមានចេតនាដើម្បីបំភ្លេចអស់អ្នកដែលស្ថិតនៅក្នុងទូករបស់យើងបាន។ យើងមានចេតនាភ្លេចគិតថាព្រះយេស៊ូវកំពុងគង់នៅក្នុងផ្ទះរបស់យើង ឬគង់នៅកន្លែងធ្វើការងាររបស់យើង ដែលទ្រង់បានជ្រាបអំពីកាលវិភាគ និងរឿងរ៉ាវនានាដែលអាចវាយប្រហារមកលើទំនាក់ទំនងរបស់យើង។ ជារឿយៗយើងតែងតែត្រូវបានស្រែកដង្ហោយហៅរកជំនួយននៅពេលយើងបានដាច់ទំនាក់ទំនងដោយស្រែកឡើងថាៈ "ព្រះអម្ចាស់អើយជួយសង្គ្រោះទូលបង្គំផង! ទឹកដល់ច្រមុះទូលបង្គំហើយ!" យើងបានក្លាយមនុស្សដែលងាយទទួលរងគ្រោះនៅពេលដែលជីវិតរបស់យើងស្ថិតក្នុងស្ថានភាពមួយមិនអាចគ្រប់គ្រងបាន ហើយពេលនោះយើងក៏កើតមានការភ័យខ្លាច។ ព្រះយេស៊ូវបានឆ្លើយតបចំពោះការអធិស្ឋានរបស់ពួកគេ! ហើយពេលនោះទ្រង់បានកំហែងដល់ព្យុះ និង ទឹករលកឲ្យមានភាពស្ងប់ស្ងាត់ជាធម្មតាវិញ។ តើខ្ញុំនឹងមានប្រតិកម្មចំពោះជីវិតដូចម្ដេច នៅពេលដែលខ្ញុំមានអារម្មណ៍ថា ខ្លួនឯងកំពុងជួបប្រទះនឹងព្យុះ និងរលកហើយនឹងត្រូវលិចលង់នោះ?__________

3. ព្រះយេស៊ូវត្រូវបានត្រាស់ហៅពួកសិស្សមកដើម្បីឲ្យការទទួលខុសត្រូវផ្សេងៗពីគ្នា មិនមែនឲ្យពួកគេទទួលខុសត្រូវលើការភ័យខ្លាចនៅពេលដែលជីវិតជួបការលំបាកនោះទេ។ មានវិធីតែមួយគត់ដើម្បីទទួលខុសត្រូវចំពោះបញ្ហាលំបាកនានានៅក្នុងជីវិត គឺការដែលបានស្គាល់ថាព្រះយេស៊ូវថាគឺជានរណា។ ពួកគេវាបានសួរថា "តើមនុស្សម្នាក់នេះគឺជានរណា?" "តើម្នាក់នេះជាមនុស្សប្រភេទណា?" នៅពេលដែលជីវិតរបស់ខ្ញុំកំពុងស្ថិតនៅក្នុងស្ថានភាពលំបាក តើខ្ញុំអាចធ្វើជាបន្ទាល់ដល់អ្នកដទៃថា ខ្ញុំស្គាល់អ្នកដែលដែលបានបង្កើត និង គ្រប់គ្រងលើព្យុះ និង ទឹករលកបានដូចម្តេចទៅ? ឬបានស្គាល់អ្នកដែលអាចបញ្ជាឲ្យព្យុះ និង ទឹករលកស្ងប់ទាំងស្រុង និង ជាអ្នកដែលដល់គ្រប់ទីកន្លែងណាដែលខ្ញុំត្រូវប្រឈមនឹងគ្រោះថ្នាក់បានដោយរបៀបណាទៅ? ______________________

________________________________________________

________________________________________________

________________________________________________

4. នៅក្នុងព្រះគម្ពីរទំនុកដម្កើង ៥៥:២២ បានធានាអះអាងដល់យើងថាព្រះជាម្ចាស់ ទ្រង់នឹងរក្សា ការពារដល់យើងម្នាក់ៗ។ ចូរយើងរំលឹងខគម្ពីរនេះឡើងវិញ " ______________________

________________________________________________

________________________________________________"

## ការអានបន្ថែម:

ចូរអានព្រះគម្ពីរទំនុកដម្កើង ១០៧:២៣-៣២ ក្នុងពេលជាមួយគ្នានោះ យើងប្រហែលជាអាចនឹងមានអារម្មណ៍ថាចូលចិត្ត អ្នកធ្វើដំណើរនៅក្នុងកប៉ាល់មួយស្ថិតនៅលើផ្ទៃទឹកសមុទ្រដ៏សែនធំល្វឹងល្វើយនោះជាមិនខាន។

1. បទគម្ពីរទាំងនេះស្តាប់ទៅវាស្រដៀងគ្នានឹងដំណើររបស់ព្រះយេស៊ូវ និង ពួកសិស្សរបស់ទ្រង់នៅលើផ្ទៃទឹកសមុទ្រដែរ។ វាមិនតម្រូវឲ្យធ្វើការស្រមើស្រមៃនៅក្នុងអារម្មណ៍ និង គំនិតនោះទេ គ្រាន់តែចាត់ទុកថា លោកអ្នកកំពុងស្ថិតនៅក្នុងកប៉ាល់មួយដែលកំពុងជួបជាមួយនឹងទឹករលកយ៉ាងធំ ហើយកប៉ាល់បានចាប់ផ្តើមលិចចុះបន្តិចម្តងៗ កាន់តែជ្រៅទៅៗក្នុងទឹកសមុទ្រ។ តើលោកអ្នកអាចធ្វើការស្រមើស្រមៃបានទេថាលោកអ្នកកំពុងតែស្រវេស្រវាចាប់របស់របរនៅកប៉ាល់បោះចេញទៅក្រៅ ហើយដោយ សារទឹករលកបានធ្វើកប៉ាល់ឃ្លីងឃ្លោង ចំណែលលោកអ្នកប្រៀបបីដូចជាមនុស្សស្រវឹងស្រាម្នាក់?

2. នៅក្នុងខ ២៨ មនុស្សម្នាគេបានស្រែកអង្វររកព្រះជាម្ចាស់ ដើម្បីសូមឲ្យទ្រង់បានយាងមករំដោះពួកគេ! តើនៅក្នុងខ ៣៩ បានប្រាប់យើងដូចម្ដេចខ្លះ? ______________________________

______________________________________________________________

______________________________________________________________

តើពួកគេមានប្រតិកម្មយ៉ាងដូចម្ដេចនៅក្នុងខ ៣០? ______________________________

______________________________________________________________

______________________________________________________________

3. ចំពោះពាក្យមួយចំនួនដែលជា ខ្សឹបខ្សៀវ ស្ងាត់ឈឹង ស្ងាត់ស្ងៀម វាបានបង្ហាញដល់លោកអ្នកដូចម្ដេច? តើមានរូបភាពបែបណាខ្លះដែលផុសចេញនៅក្នុងគំនិតរបស់លោកអ្នក? __________

______________________________________________________________

______________________________________________________________

______________________________________________________________

4. ពួកអ្នកធ្វើដំណើរបានដឹងថា មានតែព្រះជាម្ចាស់តែមួយប៉ុណ្ណោះដែលពួកគេត្រូវអំពាវនាវរក នៅពេលណាពួកគេជួបនឹងភាពអាសន្ន នោះទ្រង់នឹងសង្គ្រោះពួកគេចេញពីភាពឈឺចាប់ជាមិនខាន។ គឺព្រះអង្គបានធ្វើព្យុះ និង រលកសមុទ្របានស្ងប់ជាធម្មតាវិញ។ ចុះតើពួកគេបានធ្វើអ្វីដែរ?
   ក. ឱសូមឲ្យមនុស្សទាំងឡាយ ______________________________
   ដោយព្រោះ ______________________________ ហើយដោយ
   ព្រោះ ______________________________
   ដែលទ្រង់ ______________________________ (ខ៣១)។
   ខ. គួរឲ្យគេ ____________________ នៅក្នុង ____________ ហើយ
   ____________________ នៅទី ____________________
   ____________________ (ខ៣២)។
5. តាមរយៈបទគម្ពីរខាងលើនេះ ពួកគេបានរំលឹកឲ្យយើងបានដឹងអំពីកិច្ចការដែលត្រូវធ្វើ
   ក. ត្រូវចេះអរព្រះគុណដល់ព្រះជាម្ចាស់
   ខ. លើកដម្កើងទ្រង់ ហើយសរសើរដល់ទ្រង់តាមរយៈការនិយាយប្រាប់អ្នកដទៃអំពីកិច្ចការទ្រង់បានធ្វើសម្រាប់យើង។

- តើខ្ញុំអាននឹងពាក្យសម្ដីដូចម្ដេច ដើម្បីអរព្រះគុណដល់ព្រះជាម្ចាស់ដែលទ្រង់បាន កំហែងដល់រលកសមុទ្រ និង ព្យុះស្ងប់វិញ តែវាបានធ្វើឲ្យទូលរបស់ខ្ញុំធ្លុះធ្លាយទៅហើយនោះ? _

______________________________

______________________________

______________________________

- តើខ្ញុំស្វែងរកឱកាសបែបណាដើម្បីសរសើរ និង លើកដម្កើងដល់ព្រះជាម្ចាស់តាមរយៈ "ការនិយាយប្រាប់អ្នកដទៃអំពីអ្វីដែលទ្រង់បានធ្វើសម្រាប់ខ្ញុំ" នោះ? ______________

______________________________

______________________________

- តើខ្ញុំគួរតែលើកទឹកចិត្តដល់អ្នកដទៃឲ្យពួកគេចេះ សរសើរ និង លើកដម្កើងដល់ព្រះជាម្ចាស់អំពីអ្វីដែលទ្រង់បានធ្វើសម្រាប់ពួកគេតាមរយៈ ការនិយាយប្រាប់អ្នកដទៃទៀត? _

______________________________

______________________________

## សេចក្ដីអធិស្ឋានៈ

ឱព្រះអម្ចាស់អើយ! ទូលបង្គំបានអំពាវនាវរកព្រះអង្គ នោះព្រះអង្គតែងស្ដាប់ពាក្យរបស់ទូលបង្គំ! ព្រះអង្គបានឆ្លើយតប ក្នុងពេលណាដែលទូលបង្គំជួបនឹងភាពគ្រោះថ្នាក់ និង ភាពអាសន្នក្នុងជីវិត គឺព្រះអង្គបានធ្វើឲ្យអ្វីៗគ្រប់យ៉ាងដែលមានបំណងចង់យីយារដល់ទូលបង្គំបានស្ងាត់ស្ងៀមទៅវិញ។ នៅពេលដែលទូករបស់ទូលបង្គំជួបនឹងភាពចលាចល ភាពស្រពេចស្រពិល ការវាយប្រហារ ហើយបាក់ទឹកចិត្ត ទូលបង្គំបានស្រែករកព្រះអង្គ នោះព្រះអង្គក៏បានលូកព្រះហស្តមកជួយសង្គ្រោះទូលបង្គំ។ ដោយទ្រង់បានធ្វើកិច្ចការទាំងអស់នេះ ដូច្នេះទូលបង្គំសូមថ្វាយការអរព្រះគុណ និង ការសរសើរដម្កើងដល់ព្រះអង្គ! សូមព្រះអង្គជួយឲ្យទូលបង្គំអាចនិយាយប្រាប់ដល់មនុស្សគ្រប់គ្នាបានដឹងអំពីអ្វីៗដែលព្រះអង្គបានធ្វើសម្រាប់ទូលបង្គំផង! សូមទ្រង់កុំបញ្ឈប់ការច្រៀងសរសើរដម្កើងដល់ទ្រង់ឡើយ! សូមព្រះអង្គបើកមាត់ ភ្នែក និង ត្រចៀកទូលបង្គំដើម្បីទូលបង្គំមើលឃើញឱកាសក្នុងការនិយាយប្រាប់អ្នកដទៃអំពីស្នាព្រះហស្តរបស់ទ្រង់ផង ហើយដែលអាចឲ្យទូលបង្គំលើកទឹកចិត្តមនុស្សផ្សេងទៀតឲ្យគេធ្វើដូច្នេះផងដែរ។ សូមអរព្រះគុណ ព្រះអង្គសម្រាប់សេចក្ដីស្រលាញ់ដែលមិនចេះប្រែប្រួល ហើយទូលបង្គំសូមលើកដម្កើងព្រះអង្គដរាបអស់កល្បជានិច្ច។ __

______________________________

______________________________

# មេរៀនទី ៦ - ផ្នែកទី ៣

## សេចក្តីណែនាំ:

សត្រូវចុងក្រោយដែលបំផ្លាញយើងនោះគឺជាសេចក្តីស្លាប់! (១ កូរិនថូស ១៥:២៦) សូមព្រះអរគុណដល់ព្រះជាម្ចាស់! ដែលទ្រង់បានប្រទានឲ្យយើងមានជ័យជំនះលើវាដោយសារព្រះអម្ចាស់យេស៊ូគ្រីស្ទនៃយើង (១ កូរិនថូស ១៥:៥៧) ពាក្យទាំងនេះត្រូវបានសរសេរដោយលោកសាវ័ក ប៉ូល សម្រាប់យើងទាំងអស់គ្នាឲ្យមានសេចកក្តីសង្ឃឹមក្នុងជីវិតអស់កល្បជានិច្ចតាមរយៈអង្គព្រះយេស៊ូគ្រីស្ទ។ ដំណើររឿងជាបន្ទាប់ទៅទៀតនេះ យើងនឹងបានឃើញតាមរយៈកិច្ចការព្រះយេស៊ូវដែលបានប្រទានជ័យជំនះឱ្យទៅបុរសម្នាក់ឈ្មោះឡាសារគឺទ្រង់បានគាត់ហៅងើបពីសេចក្តីស្លាប់ឲ្យមានជីវិតរស់ឡើងវិញ។

**កិច្ចការ:** ចូរអានព្រះគម្ពីរ យ៉ូហាន ១១:១-១៤

- តើនរណាគឺជាតួឯកនៅក្នុងសាច់រឿងនេះ?
- តើព្រះយេស៊ូវមានព្រះបន្ទូលប្រាប់ម៉ាថា ថាទ្រង់គឺជានរណា?
- តើព្រះយេស៊ូវបានសន្យាជាមួយម៉ាថាដូចម្តេច?
- តើព្រះយេស៊ូវសព្វព្រះហឫទ័យចង់ឲ្យម៉ាថាឃើញអ្វី?

## លំហាត់:

1. តើមានបញ្ហាអ្វីកើតឡើង (ខ១)? ______________________________

   ______________________________

2. តើមានដំណោះស្រាយយ៉ាងដូចម្តេច (ខ៣)? ______________________________

   ______________________________

3. តើព្រះយេស៊ូវមានព្រះបន្ទូលអំពីជម្ងឺរបស់ឡាសារយ៉ាងដូចម្តេច នៅក្នុងខ ៤? ______________

   ______________________________

   ______________________________

4. តើព្រះយេស៊ូវមានទំនាក់ទំនងដូចម្តេចជាមួយនឹង ឡាសារ និង បងប្អូនស្រីរបស់គាត់ (ខ៥)? ____

   ______________________________

   ______________________________

5. តើព្រះយេស៊ូវបានធ្វើដូចម្តេច នៅពេលដែលទ្រង់បានទទួលដំណឹងអំពីឡាសារ (ខ៦)? ________

   ______________________________

6. ព្រះយេស៊ូវត្រូវយាងត្រឡប់ទៅកាន់ស្រុកយូដាវិញ តើក្នុងពេលនោះទ្រង់គង់នៅឯណា (យ៉ូហាន ១០:៤០)? ______________________________________________

______________________________________________

7. តើព្រះយេស៊ូវមានព្រះបន្ទូលទៅកាន់ពួកសិស្សដូចម្តេច នៅក្នុងខ ១១? ______________

______________________________________________

______________________________________________

8. តើមានការភាន់ច្រឡំដូចម្តេច នៅក្នុងខ ១២ និង ខ១៣? ______________________

______________________________________________

______________________________________________

9. ព្រះយេស៊ូវបានមានព្រះបន្ទូលប្រាប់ពួកគេថា ឡាសារបានស្លាប់ហើយ (ខ១៤)។ ហេតុអ្វីបានទ្រង់មានបំណងព្រះហឫទ័យចង់ទៅរកគាត់ (ខ១៥)? ______________________________

______________________________________________

តើលោកអ្នកគិតថាព្រះយេស៊ូវចង់មានអត្ថន័យដូចម្តេច ដែលទ្រង់មានព្រះបន្ទូលថា "ដើម្បីឲ្យអ្នករាល់គ្នាបានជឿ" នៅក្នុងខ ១៥? ______________________________________

______________________________________________

______________________________________________

## សេចក្តីបង្រៀនៈ

ដើម្បីសិក្សាដំណើររឿងនេះឲ្យបានច្បាស់លាស់ត្រឹមត្រូវនៅក្នុងផ្នត់គំនិត នោះយើងត្រូវដឹងនូវរឿងរ៉ាវខ្លះៗដែលលោក យ៉ូហានបានរៀបរាប់នៅក្នុងជំពូកមុនៗសិន។ នៅក្នុងព្រះគម្ពីរ យ៉ូហាន ១១:៧ ព្រះយេស៊ូវមានព្រះបន្ទូលថា "ចូរយើងត្រឡប់ទៅស្រុកយូដាវិញ"។ប្រសិនបើលោកអ្នកកំណត់ទីតាំងនៃស្រុកយូដានៅលើផែនទីក្នុងអំឡុងពេលនៃជំនាន់ព្រះយេស៊ូវ និងព័ន្ធកិច្ចរបស់ទ្រង់ នោះលោកអ្នកនឹងរកឃើញតំបន់នៃស្រុកយូដា គឺមានទីតាំងស្ថិតនៅភាគខាងត្បូង។ ស្រុកយូដាស្ថិននៅតាមបណ្តោយឈៀងខាងជើងបន្តិចជាប់នឹងស្រុក សាម៉ារី និងស្រុកកាលីឡេ ដែលត្រូវបានគេបញ្ចូលទៅជាទឹកដីនៃពួកប៉ាឡេស្ទីន។

តាមការសិក្សាបានឲ្យយើងដឹងថានៅពេលដែលព្រះយេស៊ូវបានប្រកាសប្រាប់ដល់ពួកសាសន៍យូដាថា ទ្រង់ជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ នោះពួកគេបម្រុងនឹងរើសដុំថ្មដើម្បីគប់សម្លាប់ទ្រង់ (យ៉ូហាន ៨:៥៩)។

មានម្តងទៀតនោះ នៅខណៈពេលដែលទ្រង់គង់នៅក្នុងទីក្រុងយេរូសាឡិម ពួកអ្នកជឿជាសាសន៍យូដា បានចោទប្រកាន់ទ្រង់ថា បានប្រមាថដល់ព្រះជាម្ចាស់ (យ៉ូហាន ១០:៣៣) ហើយពួកគេបានរកគប់សម្លាប់ទ្រង់នឹងដុំថ្មផងដែរ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ក៏ទ្រង់នៅតែអាចគេចចេញរួចពីកណ្តាប់ដៃពួកគេបានដែរ (យ៉ូហាន ១០:៣៩) ។

នៅក្នុងព្រះគម្ពីរ យ៉ូហាន ១០:៤០ ប្រាប់យើងថាព្រះយេស៊ូវបាន យាងទៅខាងនាយទន្លេយ័រដាន់វិញទៀត គឺជាកន្លែងដែលលោកយ៉ូហានធ្វើបុណ្យជ្រមុជជាមុនដំបូង ហើយទ្រង់គង់នៅទីនោះ។ តាមការកំណត់ទីតាំងឃើញថា ទីក្រុងយេរូសាឡិមស្ថិតនៅក្នុងស្រុកយូដា ហើយទន្លេ យ័រដាន់បានហូរចេញពីភាគខាងជើងនៃសមុទ្រ កាលីឡេឈ្លោះទៅភាគខាងត្បូងនៃសមុទ្រស្លាប់ ។ ឥឡូវនេះព្រះយេស៊ូវបានគង់នៅក្នុងមួយភាគខាងកើតនៃទន្លេ គឺជាកន្លែងដែលមានហ្វូងមនុស្សជាច្រើនបានមកតាមទ្រង់ (យ៉ូហាន ១០:៤០-៤១)។ នៅមានទីក្រុងតូចមួយផ្សេងទៀតដែលត្រូវកំណត់ទីតាំងភូមិសាស្ត្រផងដែរ គឺភូមិ បេថានី ដែលត្រូវជាស្រុកកំណើតរបស់ ម៉ារី ម៉ាថា និងឡាសារ។ ភូមិបេថានីមានចម្ងាយប្រហែលត្រឹមតែ បី ឬ បួនគីឡូម៉ែតពីទីក្រុងយេរូសាឡឹមនៅស្រុកយូដាប៉ុណ្ណោះ។

ហេតុការណ៍និយាយអំពីការគប់សម្លាប់នឹងដុំថ្ម និងការរកទីតាំងដែលជាកំណត់ពីកន្លែងដែលព្រះយេស៊ូវបានធ្វើដំណើរទៅដល់នឹងត្រូវបានផ្តល់ឱ្យមានការយល់ដឹងនៅក្នុងព្រះគម្ពីរ យ៉ូហាន ១១:៧-៨។ ពួកសិស្សមានចិត្តចង់ការពារសុវត្ថិភាពថ្វាយម្ចាស់របស់ពួកគេ! ដូច្នេះហើយទើបបានជាពួកគេសួរទ្រង់អំពីការសម្រេចព្រះហឫទ័យក្នុងការយាងទៅស្រុកយូដាម្តងទៀតរបស់ទ្រង់។ កាលពីពេលដែលពួកបណ្តាជនប្រុងគប់សម្លាប់ព្រះយេស៊ូវនឹងដុំថ្មនោះ ពួកសិស្សក៏បាននៅក្នុងហេតុការណ៍នោះជាមួយទ្រង់ដែរ អញ្ចឹងហើយប្រហែលជាពួកគេ មិនដែលនឹកគិតថានឹងត្រូវត្រឡប់ទៅកាន់ទឹកដីនោះម្តងទៀតទេ។ ម្យ៉ាងវិញទៀត ព្រះយេស៊ូវបានរៀបចំជាស្រេចដើម្បីយាងទៅកាន់ទឹកដីនោះ ព្រោះភូមិ បេថានីគឺមានទីតាំងនៅក្នុងតំបន់នោះ ហើយវាគឺជាទីកន្លែងដែលមិត្តភ័ក្ររបស់ទ្រង់ត្រូវការទ្រង់ដែរ។ ហើយនៅក្នុងព្រះគម្ពីរ យ៉ូហាន ១១:១៦ យើងបានអានឃើញថាសិស្សរបស់ទ្រង់ម្នាក់ឈ្មោះ ថូម៉ាស ហៅថា ឌីឌីម គឺជាមនុស្សដែលមានទឹកចិត្តអង់អាចក្លាហានក្នុងចំណោមពួកសិស្ស បានសុខចិត្តរួមដំណើរទៅជាមួយនឹងព្រះយេស៊ូវ ទោះបីជាមានគ្រោះថ្នាក់រហូតដល់ស្លាប់បាត់បង់ជីវិតយ៉ាងណាក៏ដោយ។

## សំនួរឆ្លុះបញ្ចាំង:

1. តើយើងបានសិក្សាអំពីព័ន្ធកិច្ចរបស់ព្រះយេស៊ូវបានដូចម្ដេចខ្លះ ចាប់ពី យ៉ូហាន ១១:៧-៨ មក? __

____________________________________________

____________________________________________

____________________________________________

____________________________________________

2. បើសិនជាខ្ញុំគឺជាអ្នកដើរតាមព្រះយេស៊ូវគ្រីស្ទម្នាក់ តើបទគម្ពីរទាំងនេះបានបង្រៀនខ្ញុំដូចម្ដេចខ្លះអំពីការវិលត្រឡប់ទៅរកមនុស្ស ឬ ទីកន្លែងអសុវត្ថិភាពដែលជាគោលដៅព័ន្ធកិច្ចបម្រើ? ________

____________________________________________

____________________________________________

____________________________________________

3. តើខ្ញុំបានត្រៀមខ្លួនស្ម័គ្រដើម្បីធ្វើពលីកម្មជីវិតដើម្បីព្រះរាជបុត្រារបស់ព្រះជាម្ចាស់ត្រូវបានគេលើកដម្កើង និង ថ្វាយសិរីរុងរឿងដែរឬទេ (យ៉ូហាន ១១:៤)? គំនិតរបស់លោកអ្នក: ___________

____________________________________________

____________________________________________

____________________________________________

____________________________________________

# មេរៀនទី ៦- ផ្នែកទី ៤

**លំហាត់:** (បន្តជាមួយនឹងព្រះគម្ពីរ យ៉ូហាន ១១:១៧)

1. លុះដល់ពេលដែលព្រះយេស៊ូវបានយាងទៅដល់ភូមិ បេថានី តើមានការបញ្ជាក់ប្រាប់ថាដូចម្ដេច (ខ១៧)? ______________________________________________
______________________________________________

2. ព្រះយេស៊ូវ និង ពួកសិស្សបានធ្វើដំណើរតាំងពី ទីក្រុង យេរូសាឡិមមានចម្ងាយបី ឬ បួនគីឡូម៉ែត ហើយត្រូវឆ្លងកាត់ទន្លេ យ័រដាន់ទៀត គឺដើម្បីត្រឹមតែចូលរួមរំលែកទុក្ខ ម៉ារី និង ម៉ាថាមែនទេ (ខ១៩)? ______________________________________________
______________________________________________
______________________________________________

3. នៅពេលដែល ម៉ាថា បានទទួលដំណឹងថាព្រះយេស៊ូវបានយាងមកដល់ តើនាងបានធ្វើដូចម្ដេច (ខ២០)? ______________________________________________
______________________________________________

   តើ ម៉ារី វិញនាងបានធ្វើដូចម្ដេចដែរ? ______________________________________________
______________________________________________

4. ម៉ាថា បានចេញទៅជួបព្រះយេស៊ូវនៅខាងក្រៅ ហើយនាងបានទូលព្រះយេស៊ូវយ៉ាងដូចម្ដេចខ្លះ (ខ២១)? ______________________________________________
______________________________________________
______________________________________________

5. ដំបូងទឹកចិត្តរបស់ម៉ាថាបាននិយាយ (ខ២១) ហើយបន្ទាប់មកទើបសេចក្ដីជំនឿរបស់នាងនិយាយម្ដង (ខ២២)។ តើសេចក្ដីជំនឿរបស់នាងបាននិយាយចេញយ៉ាងដូចម្ដេចខ្លះ? ______________
______________________________________________
______________________________________________

6. តើព្រះយេស៊ូវមានព្រះបន្ទូលទៅកាន់នាងវិញថាដូចម្ដេច (ខ២៣)? ______________
______________________________________________
______________________________________________

7. តើម៉ាថា យល់ឃើញដូចម្ដេចថាជាសេចក្ដីពិត (ខ២៤)? ______________________________

______________________________________________________________________

______________________________________________________________________

តើម៉ាថាបានជឿដោយសេចក្ដីជំនឿយ៉ាងដូចម្ដេច? ______________________________

______________________________________________________________________

8. ព្រះយេស៊ូវមានព្រះបន្ទូលជាសេចក្ដីប្រកាសមួយយ៉ាងច្បាស់នៅក្នុងខ ២៥។ តើទ្រង់មានព្រះបន្ទូលដូចម្ដេចអំពីព្រះអង្គទ្រង់ផ្ទាល់? ______________________________

______________________________________________________________________

ក្រោយពីព្រះអង្គមានព្រះបន្ទូលថា អស់អ្នកណាដែលបានជឿដល់ទ្រង់... តើទ្រង់បានបន្តដូចម្ដេចទៀត? ______________________________

______________________________________________________________________

9. នៅខណៈនោះព្រះយេស៊ូវបានសួរដល់ម៉ាថា នូវសំណួរមួយយ៉ាងជ្រាលជ្រៅ នៅក្នុងខ ២៦ តើទ្រង់បានសួរដល់នាងថាដូចម្ដេច? ______________________________

______________________________________________________________________

______________________________________________________________________

10. ម៉ាថាបានទូលដល់ព្រះយេស៊ូវវិញជាសេចក្ដីប្រកាសមួយយ៉ាងច្បាស់លាស់អំពីអ្វីដែលនាងបានជឿថាជាសេចក្ដីពិត។ តើអ្វីទៅដែលនាងបានជឿថាគឺជាសេចក្ដីពិតនោះ (ខ២៧)? ____________

______________________________________________________________________

______________________________________________________________________

## ការឆ្លុះបញ្ចាំង:

តើមានអ្វីដែលទើបនឹងបានកើតឡើង? នៅពីរ ឬបីថ្ងៃមុនព្រះយេស៊ូវបានទទួលដំណឹងថា សម្លាញ់របស់ទ្រង់មានជម្ងឺយ៉ាងធ្ងន់ធ្ងរ។ ទ្រង់មិនបានប្រញាប់ប្រញាល់ធ្វើដំណើរមកភូមិ បេថានី ភ្លាមៗនោះទេ តែទ្រង់បានគង់នៅឯត្រើយខាងកើតនៃទន្លេ យ៉រដាន់អស់ពី ឬ បីថ្ងៃ។ ឥឡូវនេះបានទទួលដំណឹងថា ឡាសារបានស្លាប់បាត់ទៅហើយ ប៉ុន្ដែព្រះយេស៊ូវមានព្រះបន្ទូលប្រាប់ពួកសិស្សថា ឡាសារបានដេកលក់ តម្រូវឲ្យទ្រង់យាងទៅកាន់ភូមិ បេថានី ដើម្បីដាស់គាត់ឲ្យក្រោកពីដេកឡើងវិញ។ តាមការពិតពួកសិស្ស នឹកស្មានថា ឡាសារគាត់កំពុងសម្រាក ហើយនឹងត្រូវបានធូរស្រាលពីជម្ងឺវិញក្នុងឆាប់មិនខាន ប៉ុន្ដែព្រះយេស៊ូវ បានបញ្ជាក់ យ៉ាងច្បាស់ដោយមានព្រះបន្ទូលថា “ឡាសារ បានស្លាប់ហើយ!”

នៅពេលពួកគេធ្វើដំណើរទៅដល់ភូមិ បេថានី ហើយទើបពួកគេបានដឹងថា ឡាសារបានស្លាប់បញ្ចុះនៅក្នុងផ្នូរអស់បួនថ្ងៃទៅហើយ។ មានមិត្តភ័ក្រ ជាសាសន៍យូដា និង អ្នកជិតខាងជាច្រើនបានមកឯផ្ទះរបស់ ម៉ារី និង ម៉ាថា ដើម្បីជួយរំលែកទុក្ខ ប៉ុន្តែ នៅពេលដែលម៉ាថាបានទទួលដំណឹងថា ព្រះយេស៊ូវបានយាងមកដល់ នាងស្ទុះចេញទៅខាងក្រៅដើម្បីជួបនឹងទ្រង់។

- តើលោកអ្នកនឹងគិតថាត្រូវនិយាយដូចម្ដេចទៅនរណាម្នាក់ដែលលោកអ្នកគិតថា គឺជាមិត្តដ៏ល្អនឹងគ្នា ដែលមិត្តភ័ក្ររបស់ខ្លួនបានស្លាប់អស់បួនថ្ងៃហើយទើបបានមកបង្ហាញមុខដូច្នេះ?
- តើលោកអ្នកនឹងត្រូវនិយាយដូចម្ដេចចំពោះនរណាម្នាក់ដែលការពិតលោកអ្នកបានដឹងថា គឺជាអ្នកអាចប្រោសមនុស្សស្លាប់ហើយឲ្យរស់ឡើងវិញបាន (យ៉ូហាន ៧:១១-១៧)?
- តើលោកអ្នកចង់និយាយដូចម្ដេចចំពោះ ដំណើររឿងនៃការអស្ចារ្យមួយដែលបានកើតឡើងនៅឯកាពើណិម អំពីការជាសះស្បើយពីជម្ងឺកូនប្រុសរបស់លោកមេទ័ពម្នាក់នោះ (យ៉ូហាន ៤:៤៣-៥៤) ដែលថាកូនប្រុសរបស់គាត់បានជាសះស្បើយមុនពេលដែលគាត់បានវិលត្រឡប់ទៅវិញនោះ?
- ម៉ាថាមានសេចក្ដីទុក្ខព្រួយពេញនៅក្នុងចិត្តរបស់នាង ហើយអារម្មណ៍ និង ផ្លូវចិត្តរបស់នាងក៏បានទទួលរងការឈឺចាប់យ៉ាងខ្លាំងដែរ។ តើពួកយើងមិនបាននៅទីនោះទេឬ? មាននរណាម្នាក់ ដែលបានរស់នៅជាមួយយើងរាល់ថ្ងៃ ត្រូវបានឃ្លាតឆ្ងាយពីយើងទៅដោយគ្មានថ្ងៃត្រឡប់មកវិញ ហើយគិតថា "ព្រះអង្គម្ចាស់អើយ! បើសិនជាទ្រង់គង់នៅទីនេះ..." បើសិនជា... ប្រសិនបើ.... ! នេះគឺជាទឹកចិត្តដែលបានដឹងថាខ្លួនឯងមិនអាចជួយអ្វីចំពោះស្ថានភាពនៃសេចក្ដីស្លាប់ដូច្នេះ។
- ម៉ាថាមានពេញដោយសេចក្ដីទុក្ខព្រួយនៅក្នុងចិត្តរបស់នាង ប៉ុន្តែព្រះយេស៊ូវសព្វព្រះហឫទ័យចង់លើកនាងឡើងឲ្យខ្ពស់ទៅដល់ការទទួលស្គាល់មួយ គឺជាការទទួលស្គាល់សេចក្ដីពិតដោយជំនឿ។ ទ្រង់បានរំលឹកបាននាងថា ប្អូនប្រុសរបស់នាងអាចនឹងរស់ឡើងវិញ ហើយសេចក្ដីជំនឿរបស់នាងបានដឹងថា:
    - ទ្រង់ចង់ឲ្យនាងដឹងថា ទ្រង់គឺជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត
    - ទ្រង់ចង់ឲ្យនាងដឹងថា អស់អ្នកណាដែលបានជឿដល់ទ្រង់ ទោះបើបានស្លាប់ហើយ គង់តែនឹងបានរស់ឡើងវិញ។
    - ទ្រង់ចង់ឲ្យនាងដឹងថា អស់អ្នកណាដែលរស់នៅ ហើយបានជឿលើទ្រង់ នោះមិនត្រូវស្លាប់ឡើងយ (មានជីវិតអស់កល្បជានិច្ច)។

- នៅខណៈនោះ ដោយសេចក្ដីជំនឿ ម៉ាថា អាចនិយាយបានថា "ព្រះពរព្រះអម្ចាស់ ខ្ញុំម្ចាស់ជឿហើយ ថាទ្រង់ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះ ដែលត្រូវយាងមកក្នុងលោកីយ៍មែន។" ទោះបីជាកំពុងនៅក្នុងពេលវេលានៃសេចក្ដីទុក្ខសោកដែលបានកើតឡើងដោយសោកនាដកម្ម និង សេចក្ដីស្លាប់ក៏ដោយ យើងនៅតែអាចប្រកាសចេញដោយសេចក្ដីជឿជាក់ថា "ខ្ញុំជឿហើយ ថាទ្រង់ជាព្រះគ្រីស្ទ គឺជាព្រះរាជបុត្រានៃព្រះដែលត្រូវយាងមកក្នុងលោកីយ៍មែន!"។

## ការអនុវត្តន៍:

1. តើនៅពេលណាដែលការរំពឹងទុករបស់អ្នកត្រូវបានខកបំណង? តើមាននរណាម្នាក់ធ្លាប់បានធ្វើឲ្យលោកអ្នកធ្លាក់ចុះដែរឬទេ? តើលោកអ្នកធ្លាប់គិតថា ព្រះជាម្ចាស់ហាក់ដូចជានៅស្ងៀម អវត្តមានក្នុងពេលវេលាដែលលោកជួយប្រទះនឹងការលំបាកខ្លាំងក្នុងជីវិត ហើយការអំពាវនាវចេញពីដួងចិត្តរបស់លោកអ្នកហាក់ដូចជាទទេស្អាតដែរឬទេ? ______________________________

______________________________________________________________

______________________________________________________________

______________________________________________________________

2. បើសិនជាព្រះយេស៊ូវទើបមានព្រះបន្ទូលទៅកាន់លោកអ្នកថា: "ខ្ញុំជាសេចក្ដីរស់ឡើងវិញ ហើយជាជីវិត អ្នកណាដែលជឿដល់ខ្ញុំ ទោះបើបានស្លាប់ហើយ គង់តែនឹងរស់ឡើងវិញដែរ ឯអ្នកណាដែលរស់នៅ ហើយជឿដល់ខ្ញុំ នោះមិនត្រូវស្លាប់ឡើយ"។ តើលោកអ្នកនឹងឆ្លើយតបនឹងសំណួររបស់ទ្រង់ថា "តើអ្នកជឿសេចក្ដីនេះទេ?" យ៉ាងដូចម្ដេច? ______________________________

______________________________________________________________

______________________________________________________________

______________________________________________________________

3. ចូរបញ្ចប់ប្រយោគនេះ: ព្រះយេស៊ូវអើយ! ទូលបង្គំជឿថា ព្រះអង្គគឺជា.... ________________

______________________________________________________________

______________________________________________________________

______________________________________________________________

______________________________________________________________

# មេរៀនទី ៦ - ផ្នែកទី ៥

**លំហាត់:** (បន្តជាមួយនឹងព្រះគម្ពីរ យ៉ូហាន ១១:២៨)

1. ម៉ាថា វិលត្រឡប់ទៅផ្ទះរបស់នាងវិញ នាងក៏ប្រាប់ ម៉ារីជាប្អូនថា ព្រះយេស៊ូវបានសួររកនាង។ កាលនាងម៉ារាបានឮពាក្យនោះ នាងបានធ្វើដូចម្ដេច (ខ២៩)? ______________________________
______________________________________________________________
______________________________________________________________

2. តើពួកសាសន៍យូដាដែលបាននៅអង្គុយជាមួយម៉ារី បានគិតថានាងទៅឯណា (ខ៣១)? ________
______________________________________________________________
______________________________________________________________

3. តើម៉ារីបាននិយាយដូចម្ដេចនៅពេលដែលនាងបានឃើញព្រះយេស៊ូវ (ខ៣២)? _____________
______________________________________________________________
______________________________________________________________

4. កាលព្រះយេស៊ូវឃើញនាងយំ នោះទ្រង់ ________________________________________
ទាំង _________________________ ក្នុង _________________________ (ខ៣៣)។
តើព្រះអង្គបានសួរទៅនាងយ៉ាងដូចម្ដេច (ខ៣៤)? ________________________________
______________________________________________________________

5. នៅក្នុងខ ៣៥ បានប្រាប់យើងថា ព្រះយេស៊ូវបាន ____________________________ ។ ភាពសោកសៅ និង ទឹកភ្នែករបស់ទ្រង់បានធ្វើប៉ះពាល់ចិត្តពួកសាសន៍យូដាដែលនៅទីនោះ។ តើពួកគេបាននិយាយដូចម្ដេច (ខ៣៦)? ______________________________________________
______________________________________________________________
______________________________________________________________

6. ចុះចំណែកមនុស្សផ្សេងទៀតមានប្រតិកម្មដូចម្ដេច (ខ៣៧)? ___________________________
______________________________________________________________
______________________________________________________________
______________________________________________________________

## ការឆ្លុះបញ្ចាំង:

- ឥឡូវនេះព្រះយេស៊ូវបានមកឯក្រៅភូមិ បេថានីហើយ។ ម៉ាថាបានរត់ទៅហៅ ម៉ារីដែលដែលនៅកំពុងកាន់ទុក្ខខាងក្នុងផ្ទះជាមួយនឹងមនុស្សឯទៀតៗ ពេលដែលម៉ារីបានដឹងថាព្រះយេស៊ូវសួររកនាង ពេលនោះនាងបានចេញទៅយ៉ាងលឿនដើម្បីជួបទ្រង់ ធ្វើពួកសាសន៍យូដាដែលបាននៅជាមួយនឹងនោះ នឹកស្មានតែទៅឯផ្នូររបស់ឡាសារដើម្បីកាន់ទុក្ខនៅទីនោះ (ខ៣១) តែតាមការពិត ម៉ារីមិនបានទៅឯផ្នូររបស់ឡាសារទេ គឺនាងបានរត់សំដៅទៅព្រះយេស៊ូវវិញ។ មួយសន្ទុះក្រោយមក ម៉ារីបាននិយាយទៅកាន់ព្រះយេស៊ូវ អ្វីដែលនាងបាននិយាយនោះគឺវាដូចគ្នាទៅនឹងអ្វីដែលម៉ាថាបាននិយាយកាលពីពេលដែលនាងបានជួបជាមួយនឹងព្រះយេស៊ូវដែរ។ បានឮពាក្យសម្ដីដែលផុសចេញពីការអំពាវនាវក្នុងចិត្តម្ដទៀតហើយ "បើសិនជាព្រះអង្គបានគង់នៅទីនេះ!"។
- ដួងចិត្តរបស់យើងត្រូវបានជាប់ជាមួយនឹងភាពសោកសង្រេង និងទុក្ខព្រួយ។ វាគឺជារឿងធម្មតាទេ ដែលមនុស្សគ្រប់គ្នាមិនបានគេចចេញពីព្រះយេស៊ូវនោះ ពីព្រោះព្រះអង្គក៏ជាមនុស្សម្នាក់ដែរ គឺទ្រង់ចេះព្រះកន្សែង (យំ) ដូចតែមនុស្សឯទៀតៗដែរ (ខ៣៥)។ ហើយទ្រង់កាន់តែក្តុកក្តួលនៅក្នុងព្រះហប្ញទ័យខ្លាំងជាងពីមុនទៅទៀត គឺនៅពេលដែលព្រះអង្គបានយាងមកដល់ផ្នូររបស់ឡាសារ (ខ៣៦)។ នៅខាងមុខផ្នូររបស់ឡាសារត្រូវបានគេដាក់ផ្ទាំងថ្មមួយដុំចំពីមុខផ្នូរ។ នៅខាងចុង ខ ៣៨ ប្រហែលជាមានខយោងសម្រាប់ជាពត៏មានបន្ថែមដល់លោកអ្នក។ ខយោងទាំងនោះមានរួមបញ្ចូលទាំងព្រះគម្ពីរ ម៉ាថាយ ២៧:៦០ ម៉ាកុស ១៦:៣ លូកា ២៤:២ និង យ៉ូហាន ២១:១ ផងដែរ។ ខយោងទាំងអស់នេះគឺបាននិយាយរៀបរាប់អំពីផ្ទាំងថ្មដែលបានដាក់នៅចំពីមុខផ្នូរ ដែលសពព្រះយេស៊ូវក៏ត្រូវបានគេដាក់នៅក្នុងផ្នូរដូច្នេះដែរ គឺក្រោយពីគេបានយកសពព្រះអង្គចុះពីលើឈើឆ្កាង។ តើព្រះយេស៊ូវមានសេចក្តីទុក្ខព្រួយជាងមិត្តភ័ក្ររបស់ឡាសារទៅទៀតមែនទេ? តើរូបកាយដែលបានស្លាប់ដោយមិនអាចជួយបាន ផ្នូរ ផ្ទាំងថ្ម គឺដំណាងឲ្យអ្វី? ______________________

  ____________________________________________

  ____________________________________________
- ប្រហែលជាលោកអ្នកនឹកឃើញដល់បំរាមមួយ ដែលព្រះជាម្ចាស់បានហាមនៅក្នុងសួនច្បារអេដែនហើយមើលទៅ! (លោកុប្បត្តិ ២:១៧)។ តើព្រះជាម្ចាស់ទ្រង់មានព្រះបន្ទូលដូចម្តេចខ្លះ? ______

  ____________________________________________

  ____________________________________________

  ____________________________________________

  ____________________________________________

- ព្រះគម្ពីរ រ៉ូម ៥:១២ បានរំលឹកយើងឲ្យដឹងថា: ________________ បានចូល _________ ____________________________________________________ ហើយក៏មានសេចក្តីស្លាប់ចូលមកដែរ ដោយសារអំពើបាបនោះជាយ៉ាងណា នោះសេចក្តីស្លាប់បានឆ្លងរាលដាលដល់មនុស្សគ្រប់គ្នាយ៉ាងនោះដែរ។ ព្រះគម្ពីរ រ៉ូម ៥:១៥ បានរំលឹកដល់យើងថា: ប៉ុន្តែ _____ _____________________ មិនមែនដូចជា_____________________________ ដ្បិតបើសិន __________________________________________________ ដោយព្រោះអំពើរំលងរបស់មនុស្សតែម្នាក់ នោះប្រាកដជាព្រះគុណនៃព្រះ ហើយនិង ________ ________________________________________ ដែលមកដោយសារមនុស្សតែម្នាក់ គឺ _________________________________________________________ ____________________________________________________ ជាច្រើនដែរ។
- តើទឹកភ្នែកនៃសេចក្តីទុក្ខព្រួយរបស់ព្រះយេស៊ូវ ក៏បានហូរស្រក់ចុះមកសម្រាប់លោកអ្នក ហើយនឹងខ្ញុំដែរទេ? សេចក្តីស្លាប់មិនមែនជាផែនការណ៍របស់ព្រះជាម្ចាស់សម្រាប់យើងម្នាក់ៗនោះទេ ប៉ុន្តែដោយសារអំពើបាបបាននាំសេចក្តីស្លាប់ចូលមក ទើបធ្វើឲ្យមនុស្សរស់នៅក្នុងភាពអស់សង្ឃឹមក្នុងការជួយសង្គ្រោះខ្លួន។ គំនិតរបស់លោកអ្នក: __________________________________ ______________________________________________________________ ______________________________________________________________ ______________________________________________________________

**លំហាត់:** (បន្តជាមួយនឹងព្រះគម្ពីរ យ៉ូហាន ១១:៣៩)

1. ព្រះយេស៊ូវបានប្រុងប្រៀបរួចជាស្រេចក្នុងការធ្វើសកម្មភាព! តើសេចក្តីបង្គាប់របស់ទ្រង់នៅក្នុងខ ៣៩ បាននិយាយដូចម្តេចខ្លះ? __________________________________________ ______________________________________________________________
2. តែម៉ាថាបានបន្ថែមពាក្យមួយថា "ប៉ុន្តែ" តើនាងបានខ្វល់ខ្វាយអំពីអ្វី? __________________ ______________________________________________________________ ______________________________________________________________ ______________________________________________________________

**សំគាល់:** នៅពេលដែលព្រះយេស៊ូវបានយាងមកដល់ក្នុងភូមិ មានគេទូលព្រះអង្គថា ឡាសារត្រូវបានបញ្ចុះនៅផ្នូរអស់បួនថ្ងៃមកហើយ។ ពួកសាសន៍យូដាមានជំនឿថា រយៈពេលបីថ្ងៃក្រោយពីមនុស្សស្លាប់ហើយ នោះព្រលឹងវិញ្ញាណរបស់អ្នកនោះ នឹងចាកចេញពីរូបកាយហើយ។ ព្រះយេស៊ូវបានពន្យាពេលក្នុងការយាងមកភូមិបេថានី ដើម្បីឲ្យបានដឹងច្បាស់ថាឡាសារពិតជាបានស្លាប់មែន!

3. តើព្រះយេស៊ូវបានរំលឹងដល់ម៉ាថាដូចម្តេច (៥៤០)? ________________________________
________________________________________________________________________
________________________________________________________________________

4. ពួកគេបានរំកិលថ្មធំដែលបាំងនៅខាងមុខផ្នូរនោះចេញរួចហើយ នៅខណៈនោះដែរ ព្រះយេស៊ូវ ក៏អធិស្ឋានទៅព្រះវរបិតា អរព្រះគុណដល់ទ្រង់ដែលតែងតែស្តាប់ព្រះអង្គគ្រប់ពេលវេលា។ ចុះតើហេតុអ្វីបានព្រះយេស៊ូវមានព្រះបន្ទូលដូច្នេះ (៥៤២)? ________________________________
________________________________________________________________________
________________________________________________________________________

5. ក្រោយពីអធិស្ឋានរួចហើយ ព្រះយេស៊ូវបានស្រែកហៅ: "________________________________
________________________________________________________________ "។

6. មនុស្សដែលបានស្លាប់ហើយនោះបានស្តាប់បង្គាប់ទ្រង់ ហើយក៏បានដើរចេញមកខាងក្រៅ! ចូររៀបរាប់អំពីសភាពខាងក្រៅរបស់បុរសនោះ គឺឡាសារ (៥៤៤)។ ________________________________
________________________________________________________________________
________________________________________________________________________

7. តើព្រះយេស៊ូវបានបង្គាប់ដូចម្តេច (៥៤៤)? ________________________________
________________________________________________________________________
________________________________________________________________________

## ការឆ្លុះបញ្ចាំង:

ជាច្រើនឆ្នាំកន្លងទៅមានខ្សែភាពយន្តមួយដែលមានចំណងជើងថា (Dead Man Walking) "ការដើរបុរសម្នាក់ស្លាប់" ហើយចំពោះរឿងរបស់ឡាសារប្រៀបបីដូចជាឈុតឆាកមួយក្នុងខ្សែភាពយន្តនោះដែរ។ វាជាការគួរឱ្យចាប់អារម្មណ៍មួយក្នុងការកត់សម្គាល់អំពីបទគម្ពីរនេះ ដែលមិនបានរៀបរាប់ថាឡាសារបានដើរចេញមកក្រៅទេ ប៉ុន្តែបាននិយាយថា បុរសដែលស្លាប់នោះបានដើរចេញមកក្រៅទៅវិញ។ គឺបានចេញមកខាងក្រៅទាំងនៅជាប់ក្រណាត់រុំសាកសព កាលពីគេបានដាក់គាត់ចូលទៅក្នុងម្ឈូស គឺដើម្បីបញ្ជាក់ថា

មនុស្សនេះបានស្លាប់ហើយ គឺរុំខ្លួនប្រាណទាំងមូល រហូតរុំទាំងមុខមាត់ផងដែរ។ មិនតែប៉ុណ្ណោះមានធុំក្លិនចាប់ផ្តើមរលួយទៅហើយទៀតផង។

តើគួរនឹងស្រាយក្រណាត់ដែលរុំសាកសពនោះចេញពីខ្លួនគាត់យ៉ាងដូចម្តេចទៅ? តើលោកអ្នកប្រាកដក្នុងចិត្តឬទេថា នឹងគ្មានអ្វីនៅក្នុងផ្នូរនោះ? ឬថាប្រហែលជាលោកអ្នកដូចជា ម៉ារី និង ម៉ាថា គឺជាអ្នកចូលទៅស្រាយក្រណាត់នោះចេញពីប្អូនប្រុសរបស់ខ្លួនដែលបានស្លាប់ទៅហើយនោះឲ្យមានជីវិតរស់ឡើងវិញ។ ឬប្រហែលជាលោកអ្នកដូចជាបណ្តាជនដែលកំពុងឈរមើលហេតុការណ៍ ដែលបានព្យាយាមតាមដានថា តើនឹងមានអ្វីកើតឡើងជាបន្តទៀត។ យើងកំពុងតែងឿយឆ្ងល់ក្នុងចិត្តថា តើមនុស្សម្នាក់នេះគឺជានរណាដែលនិយាយទៅកាន់សាកសពមនុស្សដែលស្លាប់ សាច់រលួយ ហើម ធុំក្លិនទៅហើយ មានជីវិតរស់ឡើងវិញបានដូច្នេះ? តើនៅក្នុងហេតុការណ៍មួយនេះ លោកអ្នកនៅកន្លែងណាដែរ? តើលោកអ្នកកំពុងគិតអ្វី? ហើយកំពុងតែធ្វើអ្វីដែរ? ______________________________

______________________________

______________________________

## ភាពអនុវត្តន៍:

1. ព្រះយេស៊ូវបានអធិស្ឋានទៅកាន់ព្រះបិតារបស់ទ្រង់ គឺដើម្បីឲ្យបណ្តាជនដែលកំពុងឈរនៅទីនោះទាំងអស់បានជឿថាគឺព្រះវរបិតារបស់ទ្រង់គឺជាអ្នកចាត់បញ្ជូនទ្រង់ឲ្យយាងមកផែនដីនេះ។ តើអ្នកគិតយ៉ាងដូចម្តេចដែរ? តាមរយៈទីសំគាល់ និង ការអស្ចារ្យដែលព្រះយេស៊ូវបានប្រោសឡាសារឲ្យរស់ពីស្លាប់ឡើងវិញនេះ នឹងធ្វើឲ្យលោកអ្នកជឿថាព្រះយេស៊ូជាអ្នកដែលអាចផ្តល់ជីវិតដល់ព្រលឹងវិញ្ញាណរបស់យើងដែរឬទេ? ព្រះជាម្ចាស់បានចាត់បញ្ជូនព្រះយេស៊ូវឲ្យយាងមក គឺជាអ្នកដែលបានមានព្រះបន្ទូលថា "តែខ្ញុំគឺជាសេចក្តីរស់ឡើងវិញ និងជាជីវិតមែនទេ?" ទ្រង់បានសួរលោកអ្នកម្តងទៀតថា: តើអ្នកជឿសេចក្តីនេះឬទេ? គំនិតរបស់លោកអ្នក: ______________________________

   ______________________________

   ______________________________

   ______________________________

2. ក្នុងចំណោមពួកយើងរាល់គ្នា ភាគច្រើនបានរស់នៅកំពុងតែរុំព័ទ្ធជិតទៅដោយក្រណាត់បីដូចជាសាកសពអញ្ចឹងដែរ។ ព្រះយេស៊ូវចង់ឲ្យគេបានស្រាយក្រណាត់រុំសាកសព (សម្លៀកបំពាក់សាកសព) នោះចេញពីឡាសារគឺ ដើម្បីឲ្យគាត់មានសេរីភាពឡើងវិញ។

"សម្លៀកបំពាក់សាកសព" ដែលលោកអ្នក កំពុងស្លៀកពាក់នេះ គឺវាបញ្ជាក់ប្រាប់លោកអ្នក និងអ្នក ដទៃទៀតបានដឹងថា ការរស់នៅមិនទាន់បានស្រាយចេញ ឬ រំដោះឲ្យមានសេរីភាពនៅឡើយទេ។ វាអាចជាការចងចាំនៃនូវរឿងរ៉ាវនានាកាលពីអតីតកាល ដែលអ្នកបានធ្វើ ឬជារឿងរ៉ាវទាំងឡាយណាដែលនរណាម្នាក់បានធ្វើមកលើលោកអ្នក។ ឬប្រហែលជាការរស់នៅក្នុងភាពភ័យខ្លាច គឺជាភ័យខ្លាចក្នុងការបោះជំហានដើរចេញទៅរស់នៅក្នុងសេរីភាព ព្រោះថាអាចនឹងមាននរណាម្នាក់ ឬមានអ្វីម្យ៉ាងបានធ្វើឲ្យលោកអ្នកភ័យខ្លាចដោយពាក្យសម្ដី ដោយរំលឹកដល់លោកអ្នក ថាលោកអ្នកកំពុងស្លៀកសម្លៀកបំពាក់ក្នុងផ្នូរ វាគ្មានសេចក្ដីសុខសាន្ត អន់ជាងនរណាម្នាក់ទៀត ឬភាពឯកោ។ តើមាននរណាខ្លះ ឬ មានអ្វីខ្លះដែលជាសម្លៀកបំពាក់សាកសពដែលលោកអ្នកចង់យកឲ្យនរណាម្នាក់ស្រាយចេញពីជីវិតរបស់អ្នក? ____________________________

__________________________________________

__________________________________________

__________________________________________

__________________________________________

3. ហើយចុះថា តើលោកអ្នកគិតថានរណាដែលជាអ្នកអាចជួយដោះសម្លៀកបំពាក់សាកសពរបស់អ្នកបាន? តួយ៉ាងដូចជាឡាសារដែរ ដៃ ជើងរបស់គាត់ត្រូវបានរុំព័ទជិតដោយក្រណាត់ ហើយរុំទាំងមុខទៀតផង ដូច្នេះហើយ គាត់ត្រូវការឲ្យមាននរណាម្នាក់ជួយស្រាយក្រណាត់នោះចេញពីគាត់ទើបគាត់អាចមានសេរីភាពក្នុងការរស់នៅវិញបាន។ តើនរណាដែលជាអ្នកអាចជួយឲ្យលោកអ្នកមានជីវិតរស់វិញបាន? ____________________________

__________________________________________

__________________________________________

4. វាគឺជារឿងសាមញ្ញ ធម្មតាទៅហើយដែលមាន មនុស្សមួយចំនួននៅជុំវិញលោកអ្នក ហើយលោកអ្នកបានដឹងថាពួកគេកំពុងរស់នៅដោយកំពុងស្លៀកសម្លៀកបំពាក់សាកសព គឺពួកគេទាំងអស់នោះ "បានស្លាប់ទៅទាំងមានជីវិតរស់"។ បើដូច្នេះ តើមាននរណាខ្លះដែលលោកអ្នកបានស្គាល់ជាពិសេស ហើយចង់ឲ្យព្រះយេស៊ូវស្រែកហៅឲ្យចេញពី "ផ្នូរ" ដើរចេញមកខាងក្រៅ ដើម្បីឲ្យពួកគេអាចមានជីវិតរស់នៅដោយសេរីភាពដ៏ពិតប្រាកដ? ____________________________

__________________________________________

__________________________________________

5. តើមានវិធីណាខ្លះដែលព្រះជាម្ចាស់អាចប្រើលោកអ្នកឲ្យធ្វើជាអ្នកជួយស្រាយក្រណាត់ ឬ ដោះសម្លៀមបំពាក់សាកសពចេញពីពួកគេ ហើយជួយឲ្យពួកគេមានសេរីភាពវិញបាន? __________

______________________________________________

______________________________________________

______________________________________________

## ការទន្ទេញចងចាំ:

ព្រះគម្ពីរ យ៉ូហាន ១១:២៥-២៦ គឺជាបទគម្ពីរមួយប្រហែលជាលោកអ្នកធ្លាប់បានអាចអានច្រើនដងហើយ ប៉ុន្តែប្រសិនបើជាមិនទាន់បានអាននៅឡើយទេ ដូច្នេះ ចូរលោកអ្នកសរសេរវាទុកនៅក្នុងសៀវភៅកត់ត្រា ឬក្រដាសរបស់អ្នកទុកខគម្ពីរចងចាំ ត្រូវចងចាំថា ហេតុអ្វីបានជាលោកយ៉ូហានបានសរសេរអំពីដំណឹងល្អនេះទុកដូច្នេះ។ ចំណែកព្រះគម្ពីរ យ៉ូហាន ២០:៣១ បានរំឮកឲ្យយើងដឹងថារឿងរ៉ាវទាំងប៉ុន្មានដែលត្រូវបានសរសេរទុកមកនេះ គឺក្នុងគោលបំណងចង់លោកអ្នកបានជឿថាព្រះយេស៊ូវគឺជាព្រះគ្រីស្ទពិតប្រាកដមែន និងពិតជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ ហើយការជឿជាក់ថាលោកអ្នកអាចនឹងមានជីវិតដោយនូវព្រះនាមរបស់ទ្រង់ផងដែរ។ ហើយនៅក្នុងព្រះគម្ពីរ ក្នុងយ៉ូហានជំពូក ១១ នេះទៀតសោត ព្រះយេស៊ូវបានបញ្ជាក់ប្រាប់យើងយ៉ាងច្បាស់ថាទ្រង់គឺជាសេចក្តីរស់ឡើងវិញ និងជាជីវិត! ទ្រង់បានស៊ូលះបង់ព្រះជន្មរបស់ទ្រង់គឺដើម្បីឱ្យយើងរាល់គ្នាអាចមានជីវិតអស់កល្បជានិច្ចវិញ។ ព្រះបន្ទូលទាំងអស់នេះមិនមែនទុកសម្រាប់តែពួកយើងប៉ុណ្ណោះទេ! យើងរាល់គ្នាបានរស់នៅក្នុងពិភពលោកនោះគឺរស់នៅដោយសារព្រះបន្ទូលនៃសេចក្តីសង្ឃឹម និងសេចក្តីសន្យា ដូច្នេះ នៅពេលណាដែលលោកអ្នកបានចាំស្ទាត់នៅព្រះបន្ទូលទាំងអស់នេះហើយត ចូរចែករំលែកទៅដល់អ្នកដទៃទៀត ដើម្បីឲ្យពួកគេបានស្គាល់អំពីសេចក្តីពិតទាំងនេះផងដែរ។ ចូរចែករំលែកជាមួយអស់អ្នកបានបាត់បង់ដេលមនុស្សជាទីស្រឡាញ់របស់ពួកគេទៅក្នុងសេចក្តីស្លាប់ និងអស់អ្នកដែលត្រូវមិត្តភ័ក្របោះបង់ចោល អ្នកដែលបាត់បង់ការងារ ឬ មុខរបរ បាត់បង់ក្តីសុបិន្ត និងអស់អ្នកដែលបែកបាក់ទំនាក់ទំនាក់ដោយព្រោះតែសេចក្តីស្លាប់។

## សេចក្តីអធិស្ឋាន:

ឱព្រះអម្ចាស់យេស៊ូវអើយ! ប្រសិនបើព្រះអង្គគឺពិតជាអ្នកដែលព្រះអង្គមានព្រះបន្ទូល ហើយបានសួរដល់ទូលបង្គំនោះមែន សូមទ្រង់ប្រទានសេចក្តីជំនឿដល់ទូលបង្គំ ដើម្បីឲ្យទូលបង្គបានជឿលើសេចក្តីនោះផង ដ្បិតទូលបង្គំមានបំណងចិត្តចងបានឲ្យមានជីវិត។

ទូលបង្គំចង់រស់នៅក្នុងជីវិតមួយប្រកបដោយការដឹងគុណចំពោះព្រះអំណោយទានដល់ព្រះអង្គ សម្រាប់ព្រះគុណដែលមកពីព្រះជាម្ចាស់ (រ៉ូម ៥:១៥) តាមរយៈព្រះអង្គ។ ទូលបង្គំអាចស្រមៃមើលឃើញថាព្រះអង្គកំពុងឈរនៅខាងមុខផ្នូររបស់ខ្ញុំ! ទូលបង្គំក៏បានមើលឃើញទៀតថាព្រះអង្គកំពុងព្រះកន្សែងព្រោះទូលបង្គំត្រូវបានគេរុំដោយក្រណាត់យ៉ាងជិតខ្លួនប្រាណ និង មុខមាត់របស់ទូលបង្គំដែរ។ ទូលបង្គំបានឮសម្លេងរបស់ព្រះអង្គស្រែកហៅទូលបង្គំដោយព្រះសូរសៀងខ្លាំងពីខាងក្រៅមក ហៅឱ្យទូលបង្គំចេញទៅខាងក្រៅហើយឲ្យជីវិតរស់ជាថ្មីប្រកបដោយសេរីភាពដ៏ពិតប្រាកដ។ ឱព្រះយេស៊ូវអើយ! ទូលបង្គំត្រូវការព្រះអង្គហើយត្រូវការមនុស្សរបស់ព្រះអង្គឲ្យពួកគេបានជួយស្រាយក្រណាត់សាកសពដែលបានរុំជិតជុំទូលបង្គំនេះចេញផងដែរ ដ្បិតទូលបង្គំមិនអាចរំដោះដោយខ្លួនឯងបានទេ! ទូលបង្គំសូមអរគុណដល់ព្រះអង្គដែលបានស្តាប់សេចក្តីអធិស្ឋានរបស់ទូលបង្គំ! អាម៉ែន ________________________________________

________________________________________

________________________________________

________________________________________

________________________________________

## ការសន្និដ្ឋានបញ្ចប់:

លោកសាវ័ក យ៉ូហានបានសរសេរថា: "ព្រះយេស៊ូវបានធ្វើទីសំគាល់ និង ការអស្ចារ្យជាច្រើនផ្សេងទៀតនៅក្នុងវត្តមានពួកសិស្សរបស់ទ្រង់.... ប៉ុន្តែសេចក្តីទាំងនេះត្រូវបានសរសេរថា ដើម្បីឲ្យអ្នករាល់គ្នាបានជឿថាព្រះយេស៊ូវគឺពិតជាព្រះគ្រីស្ទ និងពិតជាព្រះរាចបុត្រារបស់ព្រះជាម្ចាស់មែន ហើយឲ្យអ្នករាល់គ្នាដែលបានជឿមានជីវិតដោយនៅក្នុងព្រះនាមរបស់ទ្រង់។" តាមការសិក្សារបស់យើងបានណែនាំថា ព្រះយេស៊ូវគឺជាព្រះអង្គសង្គ្រោះ ជាព្រះមេស៊ី និងជាព្រះគ្រីស្ទ។ ព្រះនាមរបស់ទ្រង់បានប្រាប់ពីអត្ថន័យឲ្យយើងដឹងថាទ្រង់គឺជានរណា ហើយហេតុអ្វីបានជាទ្រង់យាងមកយកកំណើតធ្វើជាមនុស្សលោក ធ្វើជាគ្រូបង្រៀន គ្រូអធិប្បាយព្រះបន្ទូល និង ជាអ្នកប្រោសឲ្យជា ហើយចុងក្រោយបង្អស់បានបញ្ជាប់ប្រាប់ថា ហេតុអ្វីបានជាព្រះអង្គស៊ូរងទុក្ខវេទនារហូតដក់សុគតបាត់បង់ព្រះជន្ម គឺដើម្បីធ្វើជាព្រះអង្គសង្គ្រោះ និងជាព្រះដ៏ប្រោសលោះដល់យើងរាល់គ្នា។ ព្រះនាមរបស់ទ្រង់ថា អេម៉ាញូអែ គឺជាសេចក្តីប្រកាសប្រាប់ថាទ្រង់គឺជាព្រះមួយអង្គដែលតែងតែងគង់នៅក្នុងចំណោម និងគង់នៅក្នុងយើង ព្រមទាំងប្រជារាស្ត្ររបស់ទ្រង់ផងដែរ។ យ៉ាងណាមិញមានដូចជាពួកហោរាទាំងបីដែលមកពីទិសខាងកើត លោក ស៊ីម្មាន និង អាណា គឺសុទ្ធតែជាអ្នកដែលបានទទួលស្គាល់ថាគឺជានរណា ហើយហេតុអ្វីបានជាទ្រង់យាងមក។

ពួកគេបានប្រកាសថាទ្រង់ជាអ្នកដែលបានស្ដាប់បង្គាប់តាមព្រះវរបិតារបស់ទ្រង់ នឹងរំដោះរាស្ត្រអ៊ីស្រាអែល និងជួយសង្គ្រោះរាស្ត្ររបស់ព្រះជាម្ចាស់ឲ្យរួចផុតពីជិះជាន់សង្កត់សង្កិននៃអំណាចអំពើបាប។

នៅពេលបានក្លាយទៅជាមនុស្សធំពេញវ័យហើយ ព្រះយេស៊ូវបានចាប់ផ្ដើមបម្រើព័ន្ធកិច្ចរបស់ទ្រង់ដោយត្រាស់ហៅមនុស្សចំនួន ១២ នាក់ឱ្យធ្វើជាសិស្ស ហើយដើរតាមទ្រង់ក្នុងគោលបំណងបង្ហាត់បង្រៀនដល់ពួកគេឲ្យក្លាយទៅជាអ្នកនេសាទមនុស្ស។ ពួកគេទាំងនោះបានរួមដំណើរជាមួយទ្រង់គ្រប់ទីកន្លែងណាដែលទ្រង់យាងទៅដល់ ដូចជាពេលទ្រង់បង្រៀននៅក្នុងសាលាប្រជុំ និង តំបន់ផ្សេងជាច្រើនទៀត ហើយទ្រង់បានប្រោសមនុស្សជរាពិការឲ្យបានជាសះស្បើយពីជម្ងឺគ្រប់ប្រភេទដែលមិនឹកស្មានដល់។ ពួកគេបានរៀនអំពីព្រះហឫទ័យដ៏សប្បុរសរបស់ទ្រង់នៅពេលទ្រង់បានធ្វើទឹកឲ្យទៅជាស្រា រៀនអំពីសេចក្ដីមេត្តាការុណារបស់ទ្រង់គឺនៅពេលទ្រង់បានប្រោសអ្នកជម្ងឺឃ្លង់ម្នាក់ឲ្យបានជាស្អាតឡើងវិញ និង ការប្រទានអាហារដល់មនុស្សចំនួន ៥០០០ នាក់។ តាមរយៈព្រះចេស្ដាលើអស់ទាំងធម្មជាតិនានា គឺនៅពេលដែលទ្រង់បានកំហែងទៅខ្យល់ព្យុះ ណិង រលកសមុទ្រឲ្យស្ងប់ជាធម្មតាវិញ ហើយដោយសារ ឫទ្ធានុភាព និង អំណាចឈ្នះលើសេចក្ដីស្លាប់ ទ្រង់បានហៅឡាសារដែលបានស្លាប់បួនថ្ងៃហើយឲ្យចេញ ពីផ្នូរមកវិញ។ ទាំងអស់នេះសុទ្ធសឹងតែជាទីសំគាល់ និង ការអស្ចារ្យរបស់ទ្រង់បានធ្វើ ហើយនៅមានជាច្រើនផ្សេងៗទៀតដែលទ្រង់បានធ្វើផងដែរ ប៉ុន្តែការកត់ត្រាទុលទាំងអស់នេះដើម្បីឲ្យលោកអ្នកអាចទទួលជឿបានថាព្រះយេស៊ូវគឺជា ________________________________________

____________________________________________

____________________ ដែលលោកអ្នកអាចមាន ____________________

____________________________________________

ទ្រង់ក៏បានសួរសំនួរដដែលនេះដោយផ្ទាល់ទៅកាន់ពួកសិស្សរបស់ទ្រង់ផងដែរៈ “ចុះឯអ្នករាល់គ្នាវិញ តើថាខ្ញុំជាអ្នកណា (ម៉ាថាយ ១៦:១៥)?” ហើយនៅក្នុងថ្ងៃនេះទ្រង់បានសួរសំណួរដដែរនេះទៅលោកអ្នកហើយ តើលោកអ្នកនឹងត្រូវឆ្លើយដូចម្ដេចទូលដល់ទ្រង់វិញ? ________________________

____________________________________________

____________________________________________

ព្រះអង្គគឺជាពិតជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ និង ជាព្រះអង្គសង្គ្រោះ!

# ការរំលឹកសារឡើងវិញ

សូមចូលរួមអបអរសាទរ! លោកអ្នកបានបញ្ចប់ការសិក្សាមេរៀន "ព្រះរាជបុត្រារបស់ព្រះជាម្ចាស់ អ្នកសង្គ្រោះរបស់យើង" ដោយបរិបូរណ៌។ ដូច្នេះ លោកអ្នកបានស្គាល់ព្រះនាមជាច្រើនរបស់ព្រះយេស៊ូវ និង អត្ថន័យនៃព្រះនាមទាំងនោះហើយ បានដឹងអំពីទីសំគាល់ និង ការអស្ចារ្យជាច្រើនដែលព្រះយេស៊ូវបានធ្វើ និង បានដឹងថាទ្រង់បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំងនៅក្នុងចំណោមមនុស្សជាច្រើនដូចពួកសាសន៍យូដា ដែលអ្នករកទាស់ប្រឆាំងនឹងទ្រង់ផងដែរ។ យើងបានរៀនអំពីព្រះហឫទ័យមេត្តាករុណារបស់ព្រះយេស៊ូវ និង បំណងព្រះហឫទ័យធ្វើតាមព្រះហឫទ័យរបស់ព្រះវរបិតារបស់ទ្រង់។ ឥឡូវនេះគឺដល់ពេលវេលាដែលយើងត្រូវរំលឹកមេរៀនសារឡើងវិញហើយ! សូមចងចាំថានេះមិនមែនជាការធ្វើសាកល្បង ឬជាការប្រលងនោះទេ វាគ្រាន់តែជាឱកាសមួយដើម្បីធ្វើការបញ្ជាក់ឲ្យបានដឹងថាលោកអ្នកមានការរីកចំរើនបានកម្រិតណាក្នុងការបន្តការធ្វើដំណើរដ៏គួរឱ្យរំភើបចិត្តដើម្បីធ្វើឲ្យជីវិតរបស់កាន់តែមានភាពមុតស្រួចថែមទៀត។ នៅក្នុងខណៈពេលដែលលោកអ្នកសិក្សាលើមេរៀននិមួយៗ គឺបានសិក្សាទៅលើអង្គហេតុនៃសាច់រឿង និងអំពីសេចក្តីពិតរបស់ព្រះជាម្ចាស់ និងសេចក្តីរបស់មនុស្សលោក ហើយលោកអ្នកក៏បានគេរកឃើញពីរបៀបដែលត្រូវយកអង្គហេតុនៃដំណើររឿងនិមួយ និង សេចក្តីពិតដែលបានសិក្សាកន្លងទៅអនុវត្តន៍ក្នុងជីវិតរស់នៅប្រចាំរបស់លោកអ្នកនាសតវត្សទី ២១ នេះផងដែរ។

1. ចូររំលឹកអំពីព្រះនាមរបស់ព្រះយេស៊ូវទាំងប៉ុន្មានដែលបានសិក្សាកន្លង។ តើព្រះនាមរបស់ទ្រង់មួយណាដែលមានអត្ថន័យជាពិសេសជាងគេសម្រាប់លោកអ្នកផ្ទាល់? ហេតុអ្វី? ______________

______________________________

______________________________

______________________________

2. តើលោកអ្នកទទួលការយល់ឃើញបែបណាខ្លះទុកក្នុងជីវិត ការដែលនរណាម្នាក់បានហៅលោកអ្នកទទួលការបម្រើនៅក្នុងពន្ធកិច្ចមួយដ៏ពិតប្រាកដ? តើមានពាក្យពិសេសដូចម្តេចដែលព្រះយេស៊ូវបានប្រើនៅពេលដែលដែលទ្រង់មានព្រះបន្ទូលអំពីពន្ធកិច្ច (ម៉ាថាយ ១០:៣៨)? ______________

______________________________

______________________________

______________________________

3. តើទីសំគាល់ និង ការអស្ចារ្យទាំងប៉ុន្មានដែលបានសិក្សាកន្លងមកកើតឡើងនៅកន្លែងណាខ្លះ?
   ក. ______________________________
   ខ. ______________________________
   គ. ______________________________
   ឃ. ______________________________
   ង. ______________________________
   ______________________________

4. ចូរកំណត់អត្តសញ្ញាណចំពោះអ្វីដែលលោកអ្នកបានសិក្សាអំពីព្រះយេស៊ូវ ឬ អ្វីដែលលោកអ្នកបានចង់ចាំអំពីទ្រង់នៅក្នុងដំណើររឿងនិមួយៗ ហើយលោកអ្នកគិតថាយកវាដាក់បញ្ចូលទៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់លោកអ្នក?
   ក. ______________________________
   ខ. ______________________________
   គ. ______________________________
   ឃ. ______________________________
   ង. ______________________________
   ______________________________

5. ប្រសិនបើព្រះយេស៊ូវសួរលោកអ្នកថា "តើហេតុអ្វីបានជាអ្នកមកតាមខ្ញុំ?" តើលោកអ្នកនឹងត្រូវឆ្លើយទូលទ្រង់វិញយ៉ាងដូចម្តេច? ______________________________
   ______________________________
   ______________________________
   ______________________________
   ______________________________

6. នៅក្នុងកំណត់គម្ពីរដំណឹងល្អតាមរយៈលោក យ៉ូហាន បានកត់ត្រាទុលពាក្យថា "ខ្ញុំគឺជា" ចំនួន ៧ ដង គឺជាសេចក្តីប្រកាសរបស់ព្រះយេស៊ូវដែលទ្រង់ចង់សំដៅទៅលើព្រះអង្គទ្រង់ផ្ទាល់។ ទោះបីជាយ៉ាងណាក៏ដោយ តែយើងមិនបានលើកយកបទគម្ពីរទាំងនោះមកសិក្សាទាំងអស់ដែរ ឆ្លៀតឱកាសក្នុងពេលនេះ ចូរយើងរំលឹងអំពីបទគម្ពីរទាំងនោះសារឡើងវិញ ហើយយើងនឹងទន្ទេញចងចាំចំពោះខណាដែលយើងមិនទាន់បានលើកយកមកសិក្សានៅឡើយ។
   - ក. យ៉ូហាន ៦:៣៥ - ខ្ញុំគឺជា________________________________________
   - ខ. យ៉ូហាន ៨:១២ - ខ្ញុំគឺជា________________________________________
   - គ. យ៉ូហាន ១០:៧ - ខ្ញុំគឺជា________________________________________
   - ឃ. យ៉ូហាន ១១:២៥ - ខ្ញុំគឺជា______________________________________
   - ង. យ៉ូហាន ១៤:៦ - ខ្ញុំគឺជា________________________________________
   - ច. យ៉ូហាន ១៥:៥ - ខ្ញុំគឺជា________________________________________
   - ឆ. យ៉ូហាន ៦:៣៥ - ខ្ញុំគឺជា________________________________________

## អវសានកថា:

ដោយបានឃើញថា លោកអ្នកមានការរីចម្រើនក្នុងការសិក្សាស្រាវជ្រាវអំពីទ្រង់គឺជានរណាពិតប្រាកដនោះ ឥឡូវនេះ ចូរយើងប្រុងប្រៀបរៀបចំខ្លួន ចិត្តគំនិតដើម្បីនឹងសិក្សាអំពីព្រះយេស៊ូវដែលជាព្រះរាជបុត្រារបស់ព្រះជាម្ចាស់ និង ជាព្រះសង្គ្រោះរបស់យើងបន្ថែមទៀត ថាតើនរណាដែលជាអ្នកចាត់បញ្ជូនឲ្យមកទុកជាសេចក្តីសង្គ្រោះសម្រាប់យើងរាល់គ្នានេះ។ ព្រះយេស៊ូវគឺជាសេចក្តីសង្ឃឹមរបស់យើងគ្រប់ៗគ្នា ហេតុដូច្នេះហើយ ចូរយើងអរព្រះគុណ សរសើរ និង លើកដម្កើងដល់ព្រះនាមទ្រង់ចុះ!